ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍បូកសរុប
# ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំឆ្នាំ២០២០ និងទិសដៅអនុវត្តឆ្នាំ២០២១



ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ខែមេសា ឆ្នាំ២០២១

# មាតិកា


**I- សេចក្តីផ្តើម** ........ 1
**II- គោលនយោបាយនិងយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម** ........ 5
**III- លទ្ធផលជារួម** ........ 9
**IV- លទ្ធផលតាមអនុវិស័យ** ........ 12
១. បង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិធុរកិច្ច ........ 12
២. ការលើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ ........ 34
៣. លទ្ធផលនៃការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម ........ 52
៤. លទ្ធផលនៃការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើនិងសត្វព្រៃ ........ 55
៥. លទ្ធផលនៃការពង្រឹងសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស ........ 60
**V- បញ្ហាប្រឈម** ........ 94
**VI- ទិសដៅអនុវត្ត** ........ 94
១. ផែនការផលិតកម្មដំណាំស្រូវ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្ម ........ 94
២. ផែនការផលិតកម្មដំណាំកៅស៊ូ ........ 96
៣. ផែនការលើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ ........ 97
៤. ផែនការផ្នែកជលផល ........ 98
៥. ផែនការផ្នែកព្រៃឈើ ........ 99
**VII- សេចក្តីសន្និដ្ឋាន** ........ 100
**តារាងឧបសម្ព័ន្ធ**

# របាយការណ៍បូកសរុប
# ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០២០
# និងទិសដៅអនុវត្តឆ្នាំ២០២១

## I- សេចក្តីផ្តើម

រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃបំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅតែចាត់ទុកវិស័យកសិកម្មជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ហើយវិស័យនេះបាននិងកំពុងចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ ធានាបាននូវសន្តិសុខស្បៀង ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ តាមរយៈការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច ការលើកកម្ពស់ផលិតកម្មសត្វនិងសុខភាពសត្វ ការគ្រប់គ្រងធនធានជលផល និងអភិវឌ្ឍន៍វារីវប្បកម្ម ការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានព្រៃឈើនិងសត្វព្រៃ រួមទាំងការបង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្សផងដែរ ជាពិសេស ក្នុងកាលៈទេសៈដែលប្រទេសជាតិយើងកំពុងទទួលរងនូវហានិភ័យពីវិបត្តិជាសាកលនៃជំងឺឆ្លងកូវីដ-១៩នេះ។

ជាកត្តាសត្យានុម័ត "សន្តិភាព" គឺជាបុរេលក្ខខណ្ឌដ៏ចម្បង និងសំខាន់បំផុតសម្រាប់កសាងខឿនសេដ្ឋកិច្ច និងអភិវឌ្ឍសង្គមជាតិ។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា បានប្តេជ្ញាចិត្តខ្ពស់ក្នុងការធានានូវសុខសន្តិភាព ស្ថិរភាពនយោបាយ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចដែលមានភាពអនុគ្រោះសម្រាប់សកម្មភាពផុសផុលនៃការវិនិយោគ និងធុរកិច្ចក្នុងគ្រប់វិស័យ។ ឈរលើមូលដ្ឋាននេះ កម្ពុជាបានឆ្លងកាត់ពីឋានៈជាប្រទេសមានចំណូលទាបមកជាប្រទេសមានចំណូលមធ្យមកម្រិតទាបនាឆ្នាំ២០១៥កន្លងទៅ ហើយប្រាក់ចំណូលប្រជាជនបានកើនឡើងដល់ ១ ៧០០ដុល្លារអាមេរិកក្នុងមួយឆ្នាំសម្រាប់មនុស្សម្នាក់ក្នុងឆ្នាំ២០១៩នេះ។ សេដ្ឋកិច្ចជាតិបានរីកធំធាត់យ៉ាងឆាប់រហ័ស ហើយរចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជាក៏កំពុងផ្លាស់ប្តូរពីប្រទេសដែលពឹងផ្អែកលើវិស័យកសិកម្ម ទៅជាប្រទេសដែលពឹងផ្អែកជាសំខាន់លើវិស័យឧស្សាហកម្ម និងសេវាកម្មវិញក្នុងបរិបទនៃបដិវត្តន៍ឧស្សាហកម្មទី៤។

ជាអកុសល រលកព្យុះនៃវិបត្តិជំងឺឆ្លងកូវីដ-១៩ បាននិងកំពុងបោកបក់មកលើសេដ្ឋកិច្ច និងសង្គមនៅក្នុងបណ្តាប្រទេសនៅទូទាំងពិភពលោក។ ការរីករាលដាលនៃជំងឺកូវីដ-១៩ បានប៉ះពាល់ និងបង្កការគំរាមកំហែងយ៉ាងខ្លាំងដល់ការអភិវឌ្ឍប្រទេស ក៏ដូចជាសេដ្ឋកិច្ចកម្ពុជា។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានព្យាករណ៍ថានៅឆ្នាំ ២០២០នេះ សេដ្ឋកិច្ចកម្ពុជាអាចធ្លាក់ចុះក្នុងរង្វង់ -៣,១% និងអាចងើបឡើងវិញនៅឆ្នាំ២០២១ ក្នុងអត្រាកំណើនប្រមាណ ៤% និងនៅឆ្នាំ២០២២ នឹងអាចមានកំណើនក្នុងរង្វង់ ៥,៧% ដោយសារកម្លាំងជំរុញនៃគោលនយោបាយគាំទ្ររបស់រាជរដ្ឋាភិបាលជួយដល់ជនងាយរងគ្រោះ ភាពល្អប្រសើរជាងមុននៃសេដ្ឋកិច្ច រួមទាំងផលិតកម្មគ្រប់វិស័យមានការកើនឡើង។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលកម្ពុជាបានខិតខំតស៊ូយ៉ាងប្តូរផ្តាច់ និងយកអស់កម្លាំងកាយចិត្ត បញ្ញាញាណ និងធនធាន ដើម្បីការពារសុខុមាលភាពប្រជាពលរដ្ឋប្រកបដោយភាពកក់ក្តៅ ព្រមទាំងបាននិងកំពុងជំរុញកំណើនសេដ្ឋកិច្ចដោយបន្តអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ស៊ីជម្រៅ និងការអភិវឌ្ឍលើគ្រប់វិស័យ ជាពិសេសវិស័យកសិកម្មដែលកំពុងតែដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ ការរក្សាបាននូវសន្តិសុខស្បៀងជូនប្រជាជនកម្ពុជាប្រមាណ១៦លាននាក់ និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនក្នុងសមរភូមិប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩នេះ។

ជាចក្ខុវិស័យនិងទិសដៅគោលនយោបាយវែងឆ្ងាយរបស់រាជរដ្ឋាភិបាលគឺ ប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ក្នុងកាលៈទេសៈដែលយើងកំពុងទទួលរងនូវបញ្ហាប្រឈមពីវិបត្តិនៃជំងឺកូវីដ-១៩នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានអង្គភាពជំនាញជាសេនាធិការបានខិតខំបំពេញកាតព្វកិច្ចចំពោះមុខនេះ សំដៅគាំទ្រនិងចូលរួមដោះស្រាយបញ្ហាជីវភាពប្រជាជនដែលបានជួបប្រទះក្នុងវិបត្តិនេះ និងប្រឹងប្រែងឱ្យបានសកម្មថែមទៀតដើម្បី "ប្រែក្លាយកសិកម្មកម្ពុជាជាកសិកម្មទំនើប មានលក្ខណៈប្រកួតប្រជែង បរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាពសំដៅបង្កើនប្រាក់ចំណូលគ្រួសារកសិករ" តាមអភិក្រម និងវិសាលភាពថ្មី ដោយត្រូវប្រែក្លាយវិស័យនេះ ពីដំណាក់កាលនៃការអភិវឌ្ឍតាមបែបយថាផល ឈានទៅរកដំណាក់កាលថ្មីដែលផ្ដោតលើប្រពលវប្បកម្ម ព្រមទាំងលើកកម្ពស់ពិពិធភាវូបនីយកម្មដំណាំដែលមានសក្ដានុពល មានផលចំណេញខ្ពស់ និងមានតម្រូវការទីផ្សារ រួមទាំងការចិញ្ចឹមសត្វនិងវារីវប្បកម្មជាលក្ខណៈពាណិជ្ជកម្មផងដែរ។

ក្នុងបរិការណ៍នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្ដោតការយកចិត្តទុកដាក់ខ្ពស់លើការបន្តធ្វើទំនើបកម្មវិស័យកសិកម្ម ដោយបានអនុវត្តវិធានការគោលនយោបាយនានា សំដៅបង្កើនផលិតភាពលើមុខដំណាំដែលមានតម្លៃទីផ្សារខ្ពស់ ធ្វើពិពិធភាវូបនីយកម្មកសិកម្ម និងកសិ-ពាណិជ្ជកម្ម។ ជាមួយគ្នានេះដែរ ក្រសួងបានជំរុញការអនុវត្តវិធានការចាំបាច់មួយចំនួនទៀតរួមមាន៖ ការកសាងនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធគាំទ្រដែលបម្រើដល់ផលិតកម្មកសិកម្ម បង្កើនគុណភាពនៃការផ្ដល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មដល់កសិករ ជំរុញការស្រាវជ្រាវបច្ចេកទេសកសិកម្ម សំដៅបង្កើនទិន្នផលដំណាំ និងធន់នឹងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងនិងបង្កើនប្រសិទ្ធភាពការប្រើប្រាស់ដីកសិកម្ម ការពង្រឹងសហគមន៍កសិកម្ម ការអនុវត្តកសិកម្មតាមកិច្ចសន្យា ព្រមទាំងការកសាង និងពង្រឹងសមត្ថភាពធនធានមនុស្សនិងស្ថាប័ន ដើម្បីជំរុញការអភិវឌ្ឍវិស័យកសិកម្មឱ្យមានប្រសិទ្ធភាព។ ទន្ទឹមនឹងនេះ ក្រសួងក៏បានយកចិត្តទុកដាក់ខ្ពស់អំពីការលើកកម្ពស់ការចិញ្ចឹមសត្វនិងវារីវប្បកម្ម ព្រមទាំងខិតខំយ៉ាងខ្លាំងក្លាលើការអនុវត្តវិធានការច្បាប់ និងវិធានការបច្ចេកទេសសមស្របក្នុងការគ្រប់គ្រងប្រើប្រាស់ធនធានព្រៃឈើ និងជលផលប្រកបដោយចីរភាព។ កិច្ចខិតខំប្រឹងប្រែងទាំងអស់នេះ គឺក្នុងគោលដៅរួមចំណែកបង្កើនតម្លៃបន្ថែមនៃផលិតផលកសិកម្ម ក៏ដូចជាការជួយបង្កើនប្រាក់ចំណូលជូនប្រជាកសិករ ការបន្តជំរុញការធ្វើកសិ-ពាណិជ្ជកម្ម និងការបង្កើនចំណូលថវិកាជាតិ។ គួរកត់សម្គាល់ថា ផលិតកម្មដំណាំស្រូវ និងដំណាំកសិឧស្សាហកម្មមានការរីកវឌ្ឍឈានឡើងជាលំដាប់ គឺអាស្រ័យដោយមានការគាំទ្រយ៉ាងខ្លាំងក្លាពីរាជរដ្ឋាភិបាលកម្ពុជា ក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន អង្គការជាតិនិងអន្តរជាតិនានា អាជ្ញាធរថ្នាក់ក្រោមជាតិ និងការចូលរួមយ៉ាងសកម្មពីប្រជាកសិករ ជាពិសេសការប្ដូរទម្លាប់ពីការផលិតសម្រាប់ហូបចុកមកជាការផលិតសម្រាប់ពាណិជ្ជកម្ម និងការនាំចេញ។

ជាមួយគ្នានេះ គ្រប់អង្គភាពជំនាញបានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តផែនការសកម្មភាព សំដៅលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាកសិករដែលប្រកបមុខរបរកសិកម្ម និងធ្វើឱ្យកសិករប្រែក្លាយខ្លួនទៅជា "កសិ-ពាណិជ្ជករ" ដើម្បីទទួលបានតម្លៃបន្ថែមក្នុងជីវភាពរស់នៅរបស់ខ្លួន។ ជាលទ្ធផល វិស័យកសិកម្មបានបំពេញតួនាទីក្នុងការធានាបាននូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភប្រកបដោយគុណភាពសម្រាប់ប្រជាជនកម្ពុជា និងមានអតិរេកសម្រាប់ការនាំចេញ តាមរយៈការបង្កើនផលិតភាព ពិពិធកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ព្រមទាំងការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើ និងជលផល ដើម្បីនិរន្តរភាពនៃភពផែនដី ឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍ដោយចីរភាពគឺ "លុបបំបាត់ភាពអត់ឃ្លាន សម្រេចបានសន្តិសុខស្បៀង ធ្វើឱ្យប្រសើរឡើងអាហារូបត្ថម្ភ និងជំរុញការអភិវឌ្ឍកសិកម្មដោយនិរន្តរភាព"។

ក្នុងស្ថានភាពជំងឺកូវីដ-១៩ ដែលបាននិងកំពុងរីករាលដាលក្នុងឆ្នាំ២០២០ ក៏ដូចជាគ្រោះរាំងស្ងួត និងទឹកជំនន់ផងនោះ បានបង្កជាផលប៉ះពាល់ដល់ជីវភាពរស់នៅ និងសុវត្ថិភាពស្បៀងអាហាររបស់ប្រជាពលរដ្ឋ។ ដើម្បី

ត្រៀមស្បៀងបម្រុងទុកសម្រាប់តម្រូវការនៅក្នុងស្រុកឱ្យបានគ្រប់គ្រាន់ សំដៅធានាសន្តិសុខស្បៀង និងស្ថិរភាពតម្លៃផលិតផលកសិកម្មក្នុងដំណាក់កាលដែលមានផលប៉ះពាល់ជាសកលអាចអូសបន្លាយរយៈពេលយូរនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានធ្វើការណែនាំដល់គ្រប់អង្គភាពក្រោមឱវាទដែលពាក់ព័ន្ធ និងមន្ទីរកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់នៅក្នុងរដូវវស្សាឆ្នាំ២០២០ ឱ្យអនុវត្តនូវវិធានការចាំបាច់មួយចំនួនរួមមាន៖

១-ជំរុញការអភិវឌ្ឍដំណាំស្រូវ ដំណាំសាកវប្បកម្មនិងដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម ដោយលើកកម្ពស់ផលិតភាព គុណភាព និងសុវត្ថិភាព ដើម្បីផ្គត់ផ្គង់តម្រូវការប្រើប្រាស់របស់កសិករ និងទីផ្សារក្នុងស្រុក តាមរយៈការប្រើប្រាស់ពូជដំណាំមានគុណភាព ការធ្វើពិពិធកម្មប្រភេទដំណាំ ការអនុវត្តបង្កំបច្ចេកទេសទំនើប ការលើកកម្ពស់ការអនុវត្តកសិកម្មល្អ និងការផ្តល់សេវាបច្ចេកទេសកសិកម្មថ្មី និងបច្ចេកវិទ្យាវៃឆ្លាតធន់នឹងអាកាសធាតុដល់កសិករ និងសហគមន៍កសិកម្ម។ ពង្រឹងវិធានការការពារដំណាំ អនាម័យ និងភូតគាមអនាម័យ ដើម្បីកាត់បន្ថយហានិភ័យពាក់ព័ន្ធនឹងការរាតត្បាតសមាសភាពចង្រៃក្នុងទិសដៅទប់ស្កាត់ការធ្លាក់ចុះបរិមាណ គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម ដែលធ្វើឱ្យប៉ះពាល់ដល់សន្តិសុខស្បៀង និងសុខុមាលភាពរបស់ប្រជាជន និងខូចទីផ្សារ។ ត្រៀមបម្រុងគ្រាប់ពូជដំណាំក្រោមក្របខ័ណ្ឌប្រព័ន្ធស្បៀងបម្រុងកម្ពុជាសម្រាប់ចែកជូនដល់កសិករ ដើម្បីស្តារផលិតកម្មដំណាំនៅតាមតំបន់ដែលរងគ្រោះដោយសារកត្តាធម្មជាតិនៅរដូវវស្សា។

២-ជំរុញការចិញ្ចឹមសត្វ ធានាការផ្គត់ផ្គង់សាច់ និងផលិតផលសត្វមានគុណភាព អនាម័យ និងសុវត្ថិភាពសម្រាប់បំពេញតម្រូវការហូបចុករបស់ប្រជាពលរដ្ឋ ដោយបានបំផុស និងលើកទឹកចិត្តដល់ប្រជាកសិករដែលចិញ្ចឹមសត្វជាលក្ខណៈគ្រួសារឱ្យបង្កើនការចិញ្ចឹមសត្វដែលមានវដ្តផលិតកម្មខ្លី ដូចជា មាន់ ទា ជាដើម។ ជំរុញក្រុមហ៊ុនចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មឱ្យបង្កើនទុនវិនិយោគបន្ថែមទៀតក្នុងការពង្រីកកសិដ្ឋានចិញ្ចឹមសត្វ និងបង្កើនផលិតកម្មសត្វ។ ជំរុញក្រុមហ៊ុនផលិតចំណីសត្វក្នុងការបង្កើនទុនសម្រាប់ការទិញវត្ថុធាតុដើមក្នុងស្រុក ដើម្បីបង្កើនការផលិតចំណីសត្វ ធានានូវគុណភាព សុវត្ថិភាព និងមានតម្លៃសមស្រប។ ជាមួយគ្នានេះ ក្រសួងបានជំរុញសមាគមចិញ្ចឹមសត្វឱ្យបន្តកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ជាមួយអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល រៀបចំផែនការផលិតកម្មសត្វស្របតាមវិធានជីវសុវត្ថិភាព ឬគោលការណ៍ណែនាំស្តីពីការអនុវត្តការចិញ្ចឹមសត្វល្អ (GAHP) ដើម្បីធានាបានការផ្គត់ផ្គង់សត្វ។

៣-ជំរុញការអភិវឌ្ឍវារីវប្បកម្មគ្រប់រូបភាពដល់ប្រជាកសិករ និងអ្នកវិនិយោគផ្នែកនេះ ដើម្បីធានាបាននូវការផ្គត់ផ្គង់ត្រី កាត់បន្ថយការនាំចូល រក្សាបានតុល្យភាពតម្លៃទីផ្សារ ព្រមទាំងធានាបាននូវគុណភាព និងសុវត្ថិភាពដល់អ្នកបរិភោគ បង្កើនការផលិតកូនត្រីពូជឱ្យបានគ្រប់គ្រាន់ ដើម្បីចែកចាយដល់កសិករនៅតំបន់ដែលមានសក្តានុពលក្នុងការធ្វើវារីវប្បកម្ម ផ្តល់ការគាំទ្រទាំងផ្នែកបច្ចេកទេស និងធនធានហិរញ្ញវត្ថុដល់សហគមន៍នេសាទ ដើម្បីបង្កើនប្រាក់ចំណូលបន្ថែមក្នុងការធ្វើវារីវប្បកម្ម។

៤-ជំរុញឱ្យមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ធ្វើការណែនាំដល់ប្រជាកសិករ និងអ្នកពាក់ព័ន្ធទាំងអស់ក្នុងខ្សែច្រវ៉ាក់ផលិតកម្មកសិកម្មឱ្យត្រៀមលក្ខណៈក្នុងការបង្កបង្កើនផលក្នុងរដូវវស្សា ដើម្បីបង្កើនផលិតកម្មស្បៀងគ្រប់ប្រភេទប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងត្រូវសម្របសម្រួលសហការជាមួយអាជ្ញាធរមូលដ្ឋាន ពិនិត្យនិងកំណត់តំបន់មានប្រភពទឹក ឬតំបន់ដែលមានស្ថានភាពអំណោយផលនៅក្នុងមូលដ្ឋានជាពិសេសសម្របសម្រួលស្វែងរកលទ្ធភាពផ្គត់ផ្គង់ទឹក សម្រាប់ជំរុញផលិតកម្មដំណាំរដូវវស្សាឱ្យបានលឿនតាមដែលអាចធ្វើទៅបាន។ ជាមួយគ្នានេះដែរ ក្រសួងបានជំរុញឱ្យមន្ទីរត្រូវធ្វើជាអន្តរការីដ៏សកម្ម និងមានប្រសិទ្ធភាពក្នុងការភ្ជាប់ទំនាក់ទំនងរវាងអ្នកផលិតជាមួយនឹងអ្នកប្រមូលទិញ តាមយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា ដើម្បីធានាការផ្គត់ផ្គង់ និងថ្លៃកសិផលសមរម្យ។

៥-អង្គភាពអនុវត្តគម្រោងអភិវឌ្ឍន៍កសិកម្ម និងអង្គភាពជំនាញពាក់ព័ន្ធក្រោមឱវាទក្រសួង ត្រូវបានស្នើឱ្យជំរុញការអនុវត្តផែនការសកម្មភាពដែលបានអនុម័តរួច ដើម្បីបង្កើនផលិតកម្មស្បៀងអាហារ (បន្លែ ផ្លែឈើ ត្រី សាច់) សម្រាប់ផ្គត់ផ្គង់សេចក្តីត្រូវការហូបចុកក្នុងប្រទេសឱ្យបានគ្រប់គ្រាន់ក្នុងបរិការណ៍នៃជំងឺកូវីដ-១៩នេះ។

ទាំងនេះគឺបានឆ្លុះបញ្ចាំងឱ្យឃើញថា ស្ថាប័នជាច្រើន ទាំងរដ្ឋ វិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាលបាននិងកំពុងផ្តល់សេវាកម្ម ដើម្បីបង្កើនចំណេះដឹងនិងចំណេះធ្វើដល់កសិករនៅមូលដ្ឋាន ហើយកសិករភាគច្រើនបានទទួលយកនូវបទពិសោធន៍ និងទេពកោសល្យទាំងអស់នេះយកទៅអនុវត្តប្រកបដោយភាពឧស្សាហ៍ព្យាយាម និងគំនិតច្នៃប្រឌិត ដោយទទួលបានលទ្ធផលជាផ្លែផ្កាយ៉ាងត្រចះត្រចង់នៅក្នុងតំបន់ជាច្រើន ទៅតាមអនុវិស័យនីមួយៗ។ ដោយឡែក វិស័យឯកជនបានតម្រង់ទិសការផលិតឆ្ពោះទៅរកទីផ្សារនាំចេញ តាមរយៈការអនុវត្តគោលការណ៍ផលិតកម្មកសិកម្មតាមកិច្ចសន្យា ការបង្កើនសមត្ថភាពកែច្នៃ ធានាបានទាំងគុណភាព និងបរិមាណឆ្លើយតបទៅនឹងតម្រូវការទីផ្សារអន្តរជាតិ ពិសេសការនាំចេញចេកអំបូងលឿង ស្វាយកែវរមៀត ម្រេច ដំឡូងមី និងផលិតផលកសិកម្មសំខាន់ៗដ៏ទៃទៀត មានសន្ទុះកើនឡើងគួរឲ្យកត់សម្គាល់។

ផ្ទៃដីដាំដុះស្រូវសរុបទូទាំងប្រទេសនៅឆ្នាំ២០២០នេះ សម្រេចបានចំនួន ១១២% នៃផែនការ ដែលផ្ទៃដីដាំដុះសរុបនេះកើនឡើងចំនួន ២,២៦% ធៀបនឹងឆ្នាំ២០១៩។ បរិមាណផលស្រូវទទួលបានចំនួន ១០,៩៤លានតោន កើនឡើងចំនួន ៥០ម៉ឺនតោនលើសឆ្នាំ២០១៩ ដោយមានអតិរេកស្រូវប្រមាណ ៥,៩២លានតោន គិតជាអង្ករស្មើនឹង ៣,៧៩លានតោន សម្រាប់បម្រើការកែច្នៃនិងនាំចេញ។ លើសពីនេះទៀត ក្រសួងបានបញ្ចេញគ្រាប់ពូជស្រូវចំនួន ៦ ៥៧៦តោន ដើម្បីស្តារការខូចខាតដំណាំស្រូវចំនួន ៦៨ ២៨៥ហិកតា ស្មើនឹង ៥៤% នៃផ្ទៃដីស្រូវខូចខាតសរុបចំនួន ១២៦ ៣៨៨ហិកតា នៅក្នុងខេត្តចំនួន១៩ ដែលរងគ្រោះដោយទឹកជំនន់ ដោយមានអ្នកទទួលផលចំនួន ៦៩ ៨១៦គ្រួសារ។

ការដាំដុះកៅស៊ូនៅកម្ពុជាមានការកើនឡើងជាលំដាប់ អាស្រ័យដោយស្ថានភាពនយោបាយ សន្តិសុខល្អប្រសើរ សក្តានុពលនៃដីសមស្រប និងគោលនយោបាយទីផ្សារសេរី លើការលក់ដូរផលិតផលកៅស៊ូគ្រួសារក្នុងស្រុក។ ទន្ទឹមនឹងនេះ ការចូលរួមពីផ្នែកឯកជនក្នុងការធ្វើវិនិយោគលើដីសម្បទានសេដ្ឋកិច្ច និងកៅស៊ូគ្រួសារបានធ្វើឱ្យផ្ទៃដីដាំដុះកៅស៊ូកើនឡើង ទោះជាស្ថានភាពទីផ្សារនិងតម្លៃកៅស៊ូ ព្រមទាំងកម្លាំងពលកម្មមានការប្រឈមក៏ដោយ។

ផលិតកម្មសត្វទាំងលក្ខណៈគ្រួសារនិងពាណិជ្ជកម្មនៅកម្ពុជា ក៏មានការវិវឌ្ឍគួរឲ្យកត់សម្គាល់ ទាំងបរិមាណសត្វ និងបែបផែនផលិតកម្ម។ ការរីកចម្រើនទាំងអស់នេះ គឺជាលទ្ធផលនៃការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម គួបផ្សំនឹងការខិតខំប្រឹងប្រែងស្រាវជ្រាវ និងការយល់ដឹងអំពីបច្ចេកទេសចិញ្ចឹមសត្វ ការជ្រើសរើស និងការបង្កាត់ពូជសត្វ ការផលិតចំណីសត្វ និង ការផ្តល់សេវាថែទាំសុខភាពសត្វ។ ជាមួយគ្នានេះ ការអនុវត្តច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ បាននិងកំពុងប្រតិបត្តិយ៉ាងមានប្រសិទ្ធភាព។ ការអភិវឌ្ឍផ្នែកផលិតកម្មសត្វ ពិសេសផលិតកម្មគោពូជកូនកាត់ដែលផ្តល់តម្លៃខ្ពស់និងលើកកម្ពស់សុខភាពសត្វនៅកម្ពុជាបាននិងកំពុងជំរុញយ៉ាងផុលផុស។ ជាងនេះទៅទៀត ការទប់ស្កាត់ចលនាសត្វខុសច្បាប់ត្រូវបានអនុវត្តយ៉ាងយកចិត្តទុកដាក់ ហើយការទប់ស្កាត់ជំងឺឆ្លងសត្វក៏ត្រូវបានពង្រឹងប្រកបដោយប្រសិទ្ធភាពខ្ពស់។

ការកែទម្រង់ស៊ីជម្រៅអនុវិស័យជលផលត្រូវបន្តបានអនុវត្តយ៉ាងសកម្ម។ កំណែទម្រង់នេះ បានធ្វើឱ្យប្រជាជនទូទៅ ជាពិសេសអ្នកប្រកបរបរនេសាទជាលក្ខណៈគ្រួសារ អាចធ្វើអាជីវកម្មបានទូលំទូលាយជាងមុន។ រហូតមកដល់ពេលនេះ យើងបានបង្កើតសហគមន៍នេសាទចំនួន៥១៦ ដើម្បីគ្រប់គ្រងធនធានជលផលឱ្យមាននិរន្តរភាព តាមរយៈការអនុវត្តទិសស្លោក **“សហគមន៍នេសាទ គ្មានបទល្មើស”** ក្នុងគោលបំណងពង្រឹងសហគមន៍នេសាទឱ្យបានរឹងមាំ មានសមត្ថភាពគ្រប់គ្រាន់ក្នុងការចូលរួមគ្រប់គ្រង ថែរក្សាការពារធនធានជលផលឱ្យបានគង់វង្ស និងការទាក់ទាញពីភ្ញៀវទេសចរផងដែរ។ ការធ្វើវារីវប្បកម្ម ពិសេសការចិញ្ចឹមបង្កង ត្រីរ៉ស់ ត្រីឆ្ពោ និងពពួកត្រីដែលមានតម្លៃទីផ្សារខ្ពស់ ទាំងជាលក្ខណៈគ្រួសារ និងពាណិជ្ជកម្មត្រូវបានអនុវត្តយ៉ាងសកម្ម ហើយបានរួមចំណែកដល់ការបង្កើនប្រាក់ចំណូលក្នុងគ្រួសារ។

ដើម្បីឆ្លើយតបទៅនឹងអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងការជំរុញការងារកសិកម្ម ក៏ដូចជាវារីវប្បកម្ម និងសេចក្តីណែនាំលេខ១៣២ សណន.កសក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការអនុវត្តវិធានការឆ្លើយតបជាបន្ទាន់របស់កម្មវិធី និងគម្រោងអភិវឌ្ឍន៍នានាក្នុងបរិបទនៃការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានទទួលកញ្ចប់ថវិកាពិសេស តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចំនួន ២ ០០០ លានរៀល ដើម្បីអនុវត្តគម្រោងវារីវប្បកម្ម ការចិញ្ចឹមត្រីអណ្តែង និងកង្កែបក្នុងធុងប្លាស្ទីកដោយប្រើរយៈពេលខ្លី ចំណាយដើមទុនតិច និងទទួលបានប្រាក់ចំណូលខ្ពស់នៅតាមខេត្តគោលដៅចំនួន១១ និងខេត្តទទួលរងគ្រោះជំនន់ទឹកភ្លៀងចំនួន៤ នាពេលកន្លងមក។ ជាលទ្ធផលជាក់ស្តែង ផលិតកម្មវារីវប្បកម្មបានកើនឡើងរហូតដល់ជាង៣០% បើប្រៀបធៀបនឹងឆ្នាំមុន។

ចំពោះការកែទម្រង់វិស័យព្រៃឈើ ក្រសួងបានផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការបង្កើនសមត្ថភាពបច្ចេកទេស សំដៅជំរុញការងារគ្រប់គ្រងឱ្យមានប្រសិទ្ធភាពខ្ពស់ និងពិសេសពង្រឹងការត្រួតពិនិត្យតាមដានដ៏តឹងរ៉ឹង ព្រមទាំងសម្រេចបាននូវលទ្ធផលមួយចំនួនផងដែរ។ ជាការកត់សម្គាល់ ការចូលរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសនានា ឃើញថាទទួលបានប្រសិទ្ធភាពជាងមុន។ បន្ថែមលើសពីនេះ ក្រសួងក៏បានចូលរួមអនុវត្តយ៉ាងសកម្មជាមួយគណៈកម្មការជាតិដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា សំដៅទប់ស្កាត់ និងបង្ក្រាបសកម្មភាពអនាធិបតេយ្យកាប់ឈើ ការនាំចេញឈើខុសច្បាប់ និងបទល្មើសនានានៅទូទាំងប្រទេស។ ទន្ទឹមនឹងនេះ ក្រសួងក៏សូមវាយតម្លៃខ្ពស់ចំពោះកិច្ចសហការល្អ និងការជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងពីក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដែលបានរួមចំណែកយ៉ាងសកម្មក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានជលផល និងព្រៃឈើប្រកបដោយនិរន្តរភាពក្នុងក្របខ័ណ្ឌកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ជាពិសេសការបង្ក្រាបបទល្មើសតាមគ្រប់រូបភាពឱ្យទទួលបានលទ្ធផលល្អប្រសើរ ទោះបីនៅមានបញ្ហាខ្លះៗក៏ដោយ។

## II- គោលនយោបាយនិងយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម

### ១. គោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្ម

ផែនការមេវិស័យកសិកម្មឆ្នាំ២០៣០ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីសម្រេចបាន និងឆ្លើយតបទៅនឹងចក្ខុវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាល ព្រមទាំងមានសង្គតិភាពទៅនឹងឯកសារគោលនយោបាយ និងយុទ្ធសាស្ត្រផ្សេងៗដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម។ គោលដៅចម្បងដែលត្រូវសម្រេចបានក្នុងផែនការមេនេះគឺត្រូវ៖

(១) ជំរុញកំណើននៃតម្លៃបន្ថែមសរុបរបស់វិស័យកសិកម្មឱ្យកើនក្នុងរង្វង់ពី ៣% ទៅ ៤%ក្នុងមួយឆ្នាំ ពោលគឺកើនពី ២១ ៩១៣ ពាន់លានរៀលនៅឆ្នាំ ២០១៨ ដល់ ៣១ ៨៥២ ពាន់លានរៀលនៅឆ្នាំ២០៣០។

(២) ផលិតភាពពលកម្មកសិកម្មកើនពី ១ ៨៣៩ ដុល្លារ អាមេរិកនៅឆ្នាំ២០១៨ ដល់ ៤ ៦២៥ ដុល្លារ អាមេរិក/ម្នាក់/ឆ្នាំ នៅឆ្នាំ២០៣០។

ដើម្បីសម្រេចបាននូវទិសដៅអភិវឌ្ឍន៍វិស័យកសិកម្មក្នុងរយៈពេល១០ឆ្នាំខាងមុខ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកំណត់គោលដៅជាយុទ្ធសាស្ត្រចំនួន០៤ ដូចខាងក្រោម៖

**គោលដៅយុទ្ធសាស្ត្រ (ទី.១)៖ ការលើកកម្ពស់ខ្សែច្រវាក់ផលិតកម្មកសិកម្ម ប្រកបដោយភាពប្រកួតប្រជែង**

គោលដៅយុទ្ធសាស្ត្រនេះ មានគោលបំណងបង្កើនផលិតភាព និងផលចំណេញក្នុងខ្សែច្រវាក់តម្លៃផលិតកម្មដំណាំស្រូវ ដំណាំរដូវ កៅស៊ូ និងដំណាំកសិ-ឧស្សាហកម្មដទៃទៀត ក៏ដូចជាផលិតកម្មសត្វដែលមានសក្តានុពល

សេដ្ឋកិច្ច រួមទាំងការជំរុញឱ្យបានខ្លាំងក្លានូវការអភិវឌ្ឍផ្នែកកសិ-ឧស្សាហកម្ម ពិសេសការអនុវត្តយន្តការភាពជាដៃគូរវាងរដ្ឋ វិស័យឯកជន និងអ្នកផលិតក្នុងវិស័យកសិកម្មតាមគោលការណ៍ផលិតកម្មកសិកម្មតាមកិច្ចសន្យា។

ដើម្បីសម្រេចបាននូវគោលដៅយុទ្ធសាស្ត្រនេះ ក្រសួងបានកំណត់នូវសូចនាករមួយចំនួនដើម្បីវាស់វែងលទ្ធផល (១).កំណើនតម្លៃបន្ថែមសរុបនៃផលិតផលដំណាំកសិកម្មត្រូវសម្រេចឱ្យបានប្រមាណ ៣,១% ក្នុងមួយឆ្នាំ ដោយត្រូវកើនពី ១៣ ១៣០ពាន់លានរៀលនៅឆ្នាំ២០១៩ ដល់ ១៨ ៣៧២ពាន់លានរៀលនៅឆ្នាំ២០៣០ (២). តម្លៃបន្ថែមសរុបនៃផលិតផលសត្វត្រូវកើន២,៧%ក្នុងមួយឆ្នាំ ដោយត្រូវកើនពី ២ ៥០២ពាន់លានរៀលនៅឆ្នាំ ២០១៩ ដល់ ៣ ៣៥៥ពាន់លានរៀលនៅឆ្នាំ២០៣០ និង(៣). អត្រា (%) នៃការនាំចេញផលិតផលកសិកម្មកែច្នៃ ធៀបនឹងផលិតផលនាំចេញសរុបត្រូវកើនពី៧% នៅឆ្នាំ២០១៩ ដល់ ១៥%នៅឆ្នាំ២០៣០។

**គោលដៅយុទ្ធសាស្ត្រ (ទី.២)៖ បង្កើនការគាំទ្រហេដ្ឋារចនាសម្ព័ន្ធកសិកម្ម និងការសម្រួលពាណិជ្ជកម្មកសិកម្ម**

គោលដៅនេះមានគោលបំណងបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធស្រោចស្រពកសិកម្ម ការពង្រីកការតភ្ជាប់ផ្លូវទៅកាន់កសិដ្ឋានផលិត ការផ្គត់ផ្គង់អគ្គិសនីដែលមានតម្លៃអនុគ្រោះដល់សហគ្រាសនិងសហករណ៍កសិកម្ម និងការបង្កើនឥណទានកសិកម្ម ព្រមទាំងកិច្ចការសម្របសម្រួលកសិ-ពាណិជ្ជកម្ម។

ក្នុងការធ្វើឲ្យសម្រេចបាននូវគោលដៅយុទ្ធសាស្ត្រ ក្រសួងបានកំណត់នូវសូចនាករគន្លឹះមួយចំនួនសម្រាប់វាស់វែងគឺ (១.) ជំរុញកំណើននៃតម្លៃផលិតផលដំណាំក្រៅពីស្រូវឱ្យកើនពី ១៦ ០៨០ ពាន់លានរៀលនៅឆ្នាំ២០១៩ ដល់ប្រមាណ ២០ ៨០០ពាន់លានរៀលនៅឆ្នាំ២០៣០។ (២.) តម្លៃផលិតផលដំណាំស្រូវកើនពី ៧ ៤០០ពាន់លានរៀលនៅឆ្នាំ២០១៩ ដល់ប្រមាណ ៩ ៧៥៦ពាន់លានរៀលនៅឆ្នាំ២០៣០ និង(៣.) ជំរុញការនាំចេញផ្លូវការនៃផលិតផលដំណាំទាំងនេះឱ្យបានកើនក្នុងរង្វង់៧%ក្នុងមួយឆ្នាំ ពីឆ្នាំ២០២០ ដល់ឆ្នាំ ២០២៥ និង៦%ក្នុងមួយឆ្នាំ ពីឆ្នាំ២០២៦ ដល់ឆ្នាំ២០៣០។

**គោលដៅយុទ្ធសាស្ត្រ (ទី.៣)៖ បង្កើនការគ្រប់គ្រងធនធានដី ព្រៃឈើ និងជលផលប្រកបដោយនិរន្តរភាព**

គោលដៅនេះមានគោលបំណងលើកកម្ពស់ការគ្រប់គ្រងធនធានដី ព្រៃឈើនិងសត្វព្រៃ និងការលើកកម្ពស់ការគ្រប់គ្រងធនធានជលផលប្រកបដោយប្រសិទ្ធភាពខ្ពស់។

ដើម្បីសម្រេចបាននូវគោលដៅយុទ្ធសាស្ត្រនេះ ក្រសួងបានកំណត់នូវសូចនាករចំនួន២ ដែលត្រូវសម្រេចឱ្យបានគឺ៖ (១) តម្លៃបន្ថែមសរុបនៃផលិតផលព្រៃឈើកើន ១,២%ក្នុងមួយឆ្នាំ ដោយត្រូវបង្កើនពី ១ ៤៩០ពាន់លានរៀល នៅឆ្នាំ២០១៩ ដល់ ១ ៦៩៩ពាន់លានរៀល នៅឆ្នាំ២០៣០។ (២) តម្លៃបន្ថែមសរុបនៃផលិតផលជលផលកើនយ៉ាងតិច ៤,៣%ក្នុងមួយឆ្នាំ ដោយត្រូវបង្កើនពី ៥ ៤៩៣ពាន់លានរៀលនៅឆ្នាំ២០១៩ ដល់៨ ៧២៩ ពាន់លានរៀល នៅឆ្នាំ២០៣០។

**គោលដៅយុទ្ធសាស្ត្រ (ទី.៤)៖ គឺការពង្រឹងស្ថាប័ន បទដ្ឋានគតិយុត្ត និងអភិវឌ្ឍន៍ធនធានមនុស្ស**

គោលដៅនេះ មានគោលបំណងផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើការលើកកម្ពស់ការគ្រប់គ្រងស្ថាប័ន ការពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ការលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្ស ការស្រាវជ្រាវដើម្បីអភិវឌ្ឍន៍ និងការអប់រំកសិកម្មប្រកបដោយភាពវៃឆ្លាត ឆ្លើយតបទៅនឹងការប្រែប្រួលនៃបច្ចេកវិទ្យាឌីជីថល។

ដើម្បីសម្រេចបាននូវគោលដៅនេះ ក្រសួងបានកំណត់នូវយុទ្ធសាស្ត្រជាក់លាក់ចំនួន៤ ចូលរួមគាំទ្រគឺ៖

(១).លើកកម្ពស់ការគ្រប់គ្រងស្ថាប័នក្នុងវិស័យកសិកម្ម។

(២).កសាងនិងពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តបម្រើឱ្យវិស័យកសិកម្ម។

(៣).លើកកម្ពស់ការអភិវឌ្ឍធនធានមនុស្ស និងការអប់រំកសិកម្ម។

(៤).បង្កើនសមត្ថភាពស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កសិកម្ម។

(៥).បង្កើនសមត្ថភាពផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ២. យុទ្ធសាស្ត្រចម្បងៗសម្រាប់តម្រង់ទិសអភិវឌ្ឍន៍កសិកម្ម

ទី១- បន្តលើកកម្ពស់ការស្រាវជ្រាវដើម្បីអភិវឌ្ឍន៍បច្ចេកវិទ្យា និងបច្ចេកទេសកសិកម្មទំនើបក្នុងទិសដៅបង្កើនបរិមាណ គុណភាព អាហារូបត្ថម្ភ និងពិពិធកម្មផលិតផលកសិកម្មប្រកបដោយនិរន្តរភាព ក្នុងបរិបទបម្រែបម្រួលអាកាសធាតុ និងតម្រូវការទីផ្សារក្នុងប្រទេស តំបន់ និងអន្តរជាតិ។ យកចិត្តទុកដាក់បន្តពង្រឹងការអប់រំ បណ្តុះបណ្តាលបច្ចេកទេសកសិកម្ម និងអភិវឌ្ឍន៍ធនធានមនុស្សគ្រប់កម្រិតសញ្ញាបត្រ និងជំនាញវិជ្ជាជីវៈ និងជាពិសេសបង្កើនចំនួនអ្នកស្រាវជ្រាវនិងអ្នកវិទ្យាសាស្ត្រកសិកម្មឱ្យបានច្រើន ដោយផ្តល់ការលើកទឹកចិត្តដល់អ្នកស្រាវជ្រាវ និងអ្នកវិទ្យាសាស្ត្រជាចាំបាច់។ ទន្ទឹមនឹងនេះ ត្រូវយកចិត្តទុកដាក់ជំរុញការប្រើប្រាស់បច្ចេកវិទ្យាកសិកម្មថ្មីៗប្រកបដោយនវានុវត្តន៍ និងមានលក្ខណៈបច្ចេកវិទ្យាឌីជីថល ការអនុវត្តកសិកម្មល្អ ការរៀបចំកំណត់តំបន់ដាំដុះ ការរៀបចំផែនការដាំដុះទៅតាមតម្រូវការទីផ្សារ ការកែលម្អការគ្រប់គ្រង និងប្រើប្រាស់ធនធានដីប្រកបដោយចីរភាព ការកែលម្អប្រព័ន្ធស្រោចស្រព និងការគ្រប់គ្រងទឹកតាមរយៈប្រព័ន្ធសន្សំសំចៃទឹក ការប្រើប្រាស់យន្តូបនីយកម្មកសិកម្ម និងបច្ចេកវិទ្យាក្រោយប្រមូលផល ការបង្កើនភាពធន់នឹងអាកាសធាតុ និងគ្រោះធម្មជាតិ ការលើកកម្ពស់គុណភាពនៃការផ្តល់សេវាផ្សព្វផ្សាយកសិកម្មឱ្យបានទៅដល់កសិករ និងសហគមន៍កសិកម្ម ពង្រឹងការគ្រប់គ្រង និងត្រួតពិនិត្យពូជដំណាំកសិកម្ម និងធាតុចូលកសិកម្ម ពង្រីកសមត្ថភាពមន្ទីរពិសោធន៍ជាតិ កសិដ្ឋានផលិតពូជ និងស្ថានីយ មជ្ឈមណ្ឌលស្រាវជ្រាវនិងផ្សព្វផ្សាយកសិកម្មឱ្យបានល្អប្រសើរ។ ត្រូវជំរុញការកសាងច្បាប់ លិខិតបទដ្ឋានគតិយុត្តលើដំណាំកសិកម្ម ការគ្រប់គ្រងកសិដ្ឋាន ការពារដំណាំ និងភូតគាមអនាម័យ និងច្បាប់ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា។

ទី២- ពង្រឹងសមត្ថភាពសហគមន៍កសិកម្ម ដែលបានចុះបញ្ជីរួចហើយឲ្យមានលក្ខណៈជាពាណិជ្ជកម្ម ដោយជំរុញឱ្យអនុវត្តបច្ចេកវិទ្យាសមស្រប ការផ្គត់ផ្គង់សន្សំសំចៃទឹកនៅតាមសហគមន៍កសិកម្ម និងអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា ព្រមទាំងលើកកម្ពស់ការចូលរួមវិនិយោគពីវិស័យឯកជនក្នុងគ្រប់ខ្សែច្រវ៉ាក់តម្លៃកសិកម្ម តាមអភិក្រមភាពជាដៃគូរវាង “រដ្ឋ ឯកជន ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្ម/ផលិតករ” ឲ្យមានលក្ខណៈប្រទាក់ក្រឡាគ្នាក្នុងការរកទីផ្សារបន្ថែមសម្រាប់ផលិតផលកសិកម្មជាអាទិភាព។ លើសពីនេះទៀត ត្រូវពិនិត្យមើលលទ្ធភាពធ្វើយ៉ាងណាឱ្យសហគមន៍អាចទទួលបានផលប្រយោជន៍ និងមានចំណូលសម្រាប់ដំណើរការអភិវឌ្ឍរបស់ខ្លួនប្រកបដោយភាពម្ចាស់ការ។ ទន្ទឹមនឹងនេះ ក៏ត្រូវបន្តសហការជាមួយដៃគូអភិវឌ្ឍន៍នានា និងស្វែងរកដៃគូថ្មីៗទៀត ដើម្បីអនុវត្តគម្រោងការបណ្តុះបណ្តាលសមត្ថភាពដល់មន្ត្រីជំនាញ និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍សហគមន៍ ព្រមទាំងជំរុញ និងរួមគ្នាធ្វើការអប់រំ ផ្សព្វផ្សាយ បណ្តុះបណ្តាល បំពាក់បំប៉នដល់សហគមន៍មូលដ្ឋានឲ្យយល់ដឹងជាសាធារណៈអំពីការអភិវឌ្ឍវិស័យកសិកម្ម។

ទី៣- ពង្រឹងនិងពង្រីកសហគមន៍កៅស៊ូគ្រួសារ ដើម្បីបង្កើនកាលានុវត្តភាពក្នុងការការពារផលប្រយោជន៍របស់កសិករ ទាំងការដាំដុះ ការប្រមូលផល ការកែច្នៃ ព្រមទាំងពង្រឹងអំណាចនៃការចរចាថ្លៃនៅពេលលក់ផលិតផលទាំងនោះ។ ជំរុញការវិនិយោគលើការកែច្នៃផលិតផលកៅស៊ូ ដើម្បីបង្កើនតម្លៃបន្ថែម បង្កើតការងារ ចូលរួមកាត់បន្ថយភាពក្រីក្រនៅជនបទ។ ជាមួយគ្នានេះ ត្រូវពិនិត្យនិងរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូធម្មជាតិប្រកបដោយនិរន្តរភាព។

ទី៤- ជំរុញការធ្វើពិពិធកម្មកសិកម្មទៅរកផលិតផលដែលមានតម្លៃបន្ថែមខ្ពស់ និងមានសក្តានុពលលើដំណាំ បសុសត្វ វារីវប្បកម្ម ផលិតផលឈើដាំ និងការវិនិយោគលើការកែច្នៃកសិផលសំខាន់ៗ ដោយត្រូវបន្តលើកកម្ពស់គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម ការកែច្នៃវេចខ្ចប់ និងពង្រឹងសមត្ថភាពពិសោធន៍ ស្តង់ដារគុណភាពតាមរយៈគោលការណ៍ការអនុវត្តកសិកម្មល្អ (GAP) ការអនុវត្តការចិញ្ចឹមសត្វល្អ (GAHP) ការអនុវត្តវារីវប្បកម្មល្អ (GAqP) ក៏ដូចជាពង្រឹងវិធានការពារដំណាំ សុខភាពសត្វ និងគុណភាពផលិតផលសត្វ និងផលិតផល ជលផល អនាម័យនិង

ភូតគាមអនាម័យ (SPS) តាមរយៈការចរចាជាមួយបណ្តាប្រទេសដែលទិញផលិតផលកសិកម្មពីកម្ពុជា ការរៀបចំពិធីសារស្តីពីការនាំចេញផលិតផលកសិកម្មកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ។

ទី៥- ជំរុញការចិញ្ចឹមសត្វរបស់កសិករឲ្យទៅជាការចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្ម ជាពិសេសការចិញ្ចឹមគោពូជកូនកាត់ដែលមានផលិតភាពខ្ពស់ ដើម្បីបង្កើនប្រាក់ចំណូល ព្រមទាំងលើកទឹកចិត្តដល់ការចិញ្ចឹមសត្វខ្នាតតូច មធ្យម និងខ្នាតធំដែលមានផលិតភាពខ្ពស់ ប្រកបដោយគុណភាព សុវត្ថិភាព និងប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ ដើម្បីផ្គត់ផ្គង់តម្រូវការក្នុងស្រុក និងបង្កើនសមត្ថភាពប្រកួតប្រជែងសម្រាប់ការនាំចេញ។ គ្រប់គ្រងការធ្វើអាជីវកម្មសត្វរស់ ផលិតផលសត្វ ចំណីសត្វ បសុឱសថ និងធាតុចូលផ្សេងៗ ដោយមិនឲ្យមានការធ្វើអាជីវកម្មផ្តាច់មុខដែលប៉ះពាល់ដល់តម្លៃ និងបញ្ហាទីផ្សារ។ ត្រូវជំរុញការកែច្នៃផលិតផលសាច់ ដោយត្រូវគ្រប់គ្រងសត្តឃាតដ្ឋាន កន្លែងពិឃាតសត្វ និងកន្លែងកែច្នៃ ឲ្យអនុវត្តតាមបទដ្ឋានបច្ចេកទេសបសុព្យាបាល និងមានការត្រួតពិនិត្យអនាម័យសាច់ និងផលិតផលសត្វ ធានាបាននូវគុណភាព អនាម័យ និងសុវត្ថិភាពសាច់សម្រាប់ធានាតម្រូវការក្នុងស្រុក និងឆ្ពោះទៅរកការនាំចេញទៅបរទេស។ លើសពីនេះ ត្រូវពង្រឹងការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វ ដើម្បីបង្ការការពារជំងឺឆ្លងសត្វ ជំងឺស៊ូណូស ផលិតផលសត្វប្រកបដោយសុវត្ថិភាព និងគ្រប់គ្រងហានិភ័យជំងឺរាតត្បាតនានាជាយថាហេតុ។ បន្ថែមលើសពីនេះ ត្រូវពង្រឹងការអនុវត្តច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វឲ្យមានប្រសិទ្ធភាពខ្ពស់ និងត្រូវរៀបចំកសាងលិខិតបទដ្ឋានក្រោមច្បាប់ឲ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ។

ទី៦- បង្កើតស្ថានីយចត្តាឡីស័កសម្រាប់ដំណាំ សត្វ និងជលផល នៅតាមតំបន់សំខាន់ៗ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលសមាសធាតុចង្រៃ ជំងឺសត្វ និងជំងឺស៊ូណូស ជំងឺត្រី ព្រមទាំងទប់ស្កាត់ការនាំចូល នាំចេញ ឆ្លងកាត់នូវផលិតផលកសិកម្មខូចគុណភាព ដែលនាំឱ្យប៉ះពាល់ដល់សុខភាពសាធារណៈ និងខូចទីផ្សារក្នុងស្រុក និងនាំចេញ។ ជំរុញឱ្យក្រសួងស្ថាប័នពាក់ព័ន្ធ ពិសេសរដ្ឋបាលខេត្តនៅជាប់ព្រំដែន ត្រូវសហការឲ្យមានលក្ខណៈប្រទាក់ក្រឡាគ្នាក្នុងការគ្រប់គ្រងឲ្យមានប្រសិទ្ធភាព ព្រមទាំងក្តាប់ឲ្យបាននូវព័ត៌មាននិងទិន្នន័យនៃការនាំចូល និងនាំចេញផលិតផលកសិកម្មពីបណ្តាប្រទេសជិតខាង ដើម្បីធានានូវការគ្រប់គ្រងផលស្តុកក្នុងស្រុក និងផលប៉ះពាល់ទីផ្សារក្នុងតំបន់ក្នុងស្មារតីទទួលខុសត្រូវខ្ពស់។

ទី៧- ពង្រឹងសមត្ថភាពរបស់សហគមន៍នេសាទឱ្យក្លាយជាសហគមន៍នេសាទគ្មានបទល្មើសជលផល ទាំងទឹកសាបនិងសមុទ្រ។ ជាមួយគ្នានេះ ត្រូវជំរុញការអភិវឌ្ឍវារីវប្បកម្មគ្រប់ប្រភេទទៅតាមស្ថានភាពជាក់ស្តែង ព្រមទាំងត្រូវបន្តពង្រឹងការគ្រប់គ្រង និងការពារកន្លែងអភិរក្សជលផលឱ្យមានប្រសិទ្ធភាពខ្ពស់ ពិសេសត្រូវថែរក្សាការពារព្រៃលិចទឹក និងព្រៃកោងកាងឱ្យបានគង់វង្ស ដែលជាជម្រកដ៏សំខាន់របស់មច្ឆជាតិ ក៏ដូចជាការទាក់ទាញភ្ញៀវទេសចរផងដែរ។ លើសពីនេះទៀត បន្តចូលរួមធ្វើវិសោធនកម្មច្បាប់ស្តីពីជលផល និងត្រូវខិតខំរៀបចំលិខិតបទដ្ឋានគតិយុត្ត ជំរុញការអនុវត្តអនុសញ្ញាអន្តរជាតិពាក់ព័ន្ធ ដើម្បីប្រយុទ្ធប្រឆាំងការនេសាទល្មើសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍ (IUU Fishing) ដោយត្រូវបង្កើតយន្តការថ្នាក់ជាតិឱ្យមានលក្ខណៈប្រទាក់ក្រឡាគ្នាជាមួយអន្តរស្ថាប័នស្របតាមនីតិវិធីជាធរមាន។

ទី៨- រៀបចំនិងអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ព្រៃផ្តល់ផល ដើម្បីឆ្លើយតបទៅនឹងបរិបទកំណែទម្រង់បច្ចុប្បន្ន សំដៅធានាបានស្ថិរភាពរឹងមាំលើការអភិវឌ្ឍអនុវិស័យព្រៃឈើជាតិយូរអង្វែង។ បន្ថែមលើនេះ ត្រូវបន្តពង្រឹង និងពង្រីកសហគមន៍ព្រៃឈើ ដោយជួយប្រជាសហគមន៍ជនបទឱ្យបង្កើនចំណូល លើកកម្ពស់ជីវភាពរស់នៅតាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម។ ក្នុងគោលដៅពង្រីកគម្របព្រៃឈើ ត្រូវបន្តជំរុញការស្តារដាំដុះព្រៃឈើឡើងវិញនៅលើដីព្រៃរេចរឹល ដីព្រៃរងការធ្វើអាជីវកម្ម ដីទំនេររបស់រដ្ឋ និងដីព្រៃដែលបានដកហូតពីដីសម្បទានសេដ្ឋកិច្ច ដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយ សម្រាប់ចែកចាយជូនប្រជាពលរដ្ឋដាំដុះ។ ជាមួយគ្នានេះ ត្រូវរៀបចំបង្កើតសួនភូតគាមសាស្ត្រ (Botanical Garden) នៅតាមតំបន់

អេកូឡូស៊ីរុក្ខជាតិកម្ពុជា ក្នុងគោលបំណងអប់រំ បណ្តុះបណ្តាល និងផ្សព្វផ្សាយនូវប្រភេទរុក្ខជាតិមានដោយកម្រ និងជិតផុតពូជ ព្រមទាំងដាក់តាំងបង្ហាញនូវសំណាកប្រភេទរុក្ខជាតិសំខាន់ៗ ប្រភេទគ្រួសារ និងអំបូរដទៃទៀត ដោយប្រើប្រាស់ប្រភពថវិកាមូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិ និងពីប្រភពផ្សេងៗទៀត។ ជាមួយគ្នានេះ ក៏ត្រូវសហការជាមួយគណៈបញ្ជាការឯកភាពរាជធានី ខេត្ត ដើម្បីចូលរួមឱ្យបានល្អក្នុងការស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ និងការកាប់រានដីព្រៃឈើឱ្យមានប្រសិទ្ធភាព។ ម្យ៉ាងទៀត តំបន់សម្បទានដីសេដ្ឋកិច្ចដែលនៅសេសសល់ពីមុនមក នឹងត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យដ៏តឹងរ៉ឹង ដើម្បីធានាថា ដំណើរការសម្បទានដីសេដ្ឋកិច្ចទាំងនោះប្រព្រឹត្តទៅប្រកបដោយចីរភាព និងប្រសិទ្ធភាពខ្ពស់។ ព្រមជាមួយនោះ ត្រូវចូលរួមធ្វើវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ និងរៀបចំកសាងលិខិតបទដ្ឋានក្រោមច្បាប់ ព្រមទាំងពង្រឹងការអនុវត្តច្បាប់ឲ្យមានប្រសិទ្ធភាពខ្ពស់។

ទី៩- បន្តចុះស្រាវជ្រាវរុករក និងបង្ក្រាបបទល្មើសព្រៃឈើ ជលផល ការកាប់រាន ដុត ឈូសឆាយដីព្រៃឈើ និងព្រៃលិចទឹកយកដីធ្វើកម្មសិទ្ធិតាមគ្រប់រូបភាព ដោយប្រើប្រាស់កម្លាំងចម្រុះ អាជ្ញាធរដែនដី កងកម្លាំងប្រដាប់អាវុធ អង្គភាពពាក់ព័ន្ធ និងតុលាការ ព្រមទាំងបន្តយកចិត្តទុកដាក់ជំរុញការបោះបង្គោលព្រំព្រៃឈើ និងព្រៃលិចទឹកឱ្យបានឆាប់រហ័ស ដើម្បីទប់ស្កាត់ និងកាត់បន្ថយឱ្យបានជាអតិបរមានូវការរំលោភបំពានលើដីព្រៃឈើ និងព្រៃលិចទឹកជាដើម។

ទី១០- ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជិតខាង និងបណ្តាប្រទេសដៃគូអភិវឌ្ឍន៍នានាទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគី និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់និងអន្តរជាតិ ដើម្បីស្វែងរកជំនួយហិរញ្ញវត្ថុ និងជំនួយបច្ចេកទេសថ្មីៗ សម្រាប់ការធ្វើទំនើបភាវូបនីយកម្មកសិកម្ម ព្រមទាំងខិតខំបង្កើនកិច្ចសហប្រតិបត្តិការ និងធ្វើការចរចាដើម្បីស្វែងរកទីផ្សារសម្រាប់ការនាំចេញផលិតផលកសិកម្មឱ្យបានទូលំទូលាយជាមួយប្រទេសនានា ក្នុងបរិបទនៃសាកលភាវូបនីយកម្ម។ លើកទឹកចិត្តដល់អ្នកវិនិយោគទុនពីខាងក្នុងនិងក្រៅប្រទេស បង្កើនទុនវិនិយោគក្នុងវិស័យកសិកម្មលើគ្រប់ខ្សែច្រវាក់តម្លៃកសិកម្ម ពិសេសការកែច្នៃផលិតផលកសិកម្ម ដើម្បីផ្សារភ្ជាប់កសិករ ឬសហគមន៍កសិកម្ម ទៅនឹងទីផ្សារតាមអភិក្រមភាពជាដៃគូរវាង រដ្ឋ ឯកជន និងសហគមន៍កសិកម្ម/ផលិតករ។ ទន្ទឹមនឹងនេះ ត្រូវជំរុញដល់ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការជាតិអន្តរជាតិទាំងអស់ឱ្យបន្តគាំទ្រការលើកកម្ពស់ និងជំរុញការអភិវឌ្ឍវិស័យកសិកម្មតាមគ្រប់រូបភាព ជាពិសេសត្រូវរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនឹងអនុវិស័យនៃវិស័យកសិកម្ម ដើម្បីអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់។

## III- លទ្ធផលជារួម

នៅក្នុងឆ្នាំ២០២០នេះ ទឹកភ្លៀងបានចាប់ផ្តើមធ្លាក់យឺតជាងរដូវវស្សាឆ្នាំមុន និងមានកូនរដូវប្រាំងកើតឡើងនៅតាមបណ្តាខេត្តមួយចំនួន ពិសេសមានគ្រោះរាំងស្ងួតក្នុងអំឡុងខែសីហានិងដើមខែកញ្ញា និងជាចុងក្រោយគឺគ្រោះទឹកជំនន់បានកើតមានក្នុងអំឡុងខែតុលា ដែលបានបង្កការលំបាកដល់ដំណើរការបង្កបង្កើនផលដំណាំ។

មកទល់ពេលនេះ ជំងឺកូវីដ-១៩ បាននិងកំពុងរីករាលដាលនៅទូទាំងសកលលោក និងបានធ្វើឱ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់សេដ្ឋកិច្ច សង្គម និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ជាមួយនឹងការខិតខំស្តារឡើងវិញនូវវិស័យបម្រើឱ្យសេដ្ឋកិច្ច វិស័យកសិកម្មបានឈរនៅក្នុងអាទិភាពមួយខ្ពស់ដើម្បីឆ្លើយតបទៅនឹងបញ្ហានេះ ពិសេសពាក់ព័ន្ធនឹងការបង្កើនស្បៀងអាហារ អង្ករ ត្រីសាច់ឱ្យបានគ្រប់គ្រាន់ និងនាំចេញទៅកាន់ទីផ្សារអន្តរជាតិ។ ផ្អែកលើកត្តាសត្យានុម័តនិងអត្តនោម័ត និងអនុវត្តតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** លើវិធានការត្រៀមបម្រុងស្បៀងអាហារសម្រាប់ប្រជាពលរដ្ឋ ក្នុងស្ថានភាពដែលមានផលប៉ះពាល់ជាសកលបង្កដោយជំងឺកូវីដ-១៩ ការជំរុញអនុវត្តនូវគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្ម ត្រូវបានវាយតម្លៃថាបានអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់។ ក្នុងបរិកាណ៍នេះ យុទ្ធនាការជាទ្រង់ទ្រាយធំក្នុងការបំផុសប្រជាកសិករនៅតាមមូលដ្ឋាន ដែល

មានសក្តានុពលផលិតកម្មកសិកម្ម ឱ្យធ្វើការដាំដុះដំណាំស្បៀង ការចិញ្ចឹមសត្វ និងវារីវប្បកម្ម ស្របតាមវិធានការបច្ចេកទេសកសិកម្មទំនើបត្រូវបានរៀបចំធ្វើយ៉ាងផុលផុស។ ជាមួយគ្នានេះ សន្ទុះនៃការអនុវត្តផែនការសកម្មភាពចាំបាច់ក្នុងស្ថានភាពបន្ទាន់ជាការឆ្លើយតប ដើម្បីបង្កើនផលិតកម្មស្បៀងប្រកបដោយគុណភាព និងសុវត្ថិភាព សំដៅរួមចំណែកបង្កើននូវឱកាសការងារ និងប្រាក់ចំណូលដល់ប្រជាពលរដ្ឋនៅជនបទ ក៏ដូចជាពលករដែលបានត្រឡប់ពីបរទេសវិញ ក៏ត្រូវបានអនុវត្តយ៉ាងល្អប្រសើរ។ ម៉្យាងវិញទៀត សកម្មភាពឆ្លើយតបបន្ទាន់ក្នុងបណ្តាគម្រោងដែលកំពុងអនុវត្តក៏ត្រូវបានជំរុញយ៉ាងខ្លាំងក្លា ដើម្បីរួមចំណែកជួយដោះស្រាយបញ្ហាប្រឈមរបស់កសិករ ពិសេសបញ្ហាទឹកដោយការប្រើប្រព័ន្ធសន្សំសំចៃទឹក ការជួយជីកនិងស្តារស្រះ ត្រពាំង និងអណ្តូងជាដើម ការអប់រំបណ្តុះបណ្តាលកសិករណែនាំផ្សព្វផ្សាយអំពីបច្ចេកទេស ការអនុវត្តកសិកម្មល្អ និងការធ្វើហិរញ្ញប្បទានដល់ប្រជាកសិករតាមគ្រប់រូបភាពសំដៅដល់ការបង្កើតកសិដ្ឋានថ្មីៗ ព្រមទាំងគាំទ្រ និងពង្រីកទំហំផលិតកម្មស្បៀងដែលឆាប់ផ្តល់ផល។ល។

លើសពីនេះទៀត ការចិញ្ចឹមសត្វដើម្បីធានាការផ្គត់ផ្គង់សាច់ និងផលិតផលសត្វ សម្រាប់បំពេញតម្រូវការហូបចុករបស់ប្រជាពលរដ្ឋ ត្រូវបានវាយតម្លៃថាអនុវត្តបានល្អប្រសើរជាមួយនឹងការរៀបចំយុទ្ធនាការបំផុសដល់ប្រជាកសិករដែលចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ ឱ្យបង្កើនការចិញ្ចឹមសត្វដែលមានវដ្តផលិតកម្មខ្លី និងដោះស្រាយបានទាន់ពេលវេលាបញ្ហាសន្តិសុខស្បៀងត្រូវបានធ្វើយ៉ាងយកចិត្តទុកដាក់ខ្ពស់។ បន្ថែមពីនេះ ការបង្កើតកសិដ្ឋានចិញ្ចឹមសត្វថ្មីៗរបស់កសិករត្រូវបានពិនិត្យឃើញថាមានការកើនឡើងគួរឱ្យកត់សម្គាល់ និងក្រុមហ៊ុនឯកជនក៏ត្រូវបានជំរុញឱ្យមានការចិញ្ចឹមសត្វក្នុងទ្រង់ទ្រាយធំបន្ថែមទៀត ដើម្បីបម្រើសេចក្តីត្រូវការសាច់ក្នុងប្រទេស និងកាត់បន្ថយការនាំចូល។

ដើម្បីធានាបាននូវការផ្គត់ផ្គង់ត្រីសម្រាប់ប្រើប្រាស់ក្នុងស្រុក រក្សាបានតុល្យភាពតម្លៃទីផ្សារ ដែលរួមចំណែកធានាបាននូវសន្តិសុខស្បៀងគ្រប់គ្រាន់ដល់ប្រជាពលរដ្ឋកម្ពុជា រដ្ឋបាលជលផល និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត បានធ្វើយុទ្ធនាការទ្រង់ទ្រាយធំក្នុងការចុះជំរុញការអភិវឌ្ឍវារីវប្បកម្មតាមគ្រប់រូបភាពដល់ប្រជាកសិករ និងអ្នកវិនិយោគផ្នែកនេះ ដោយបានសហការជាមួយដៃគូអភិវឌ្ឍន៍ ព្រមទាំងបានលើកទឹកចិត្តដល់ការចិញ្ចឹមត្រីដែលមានវដ្តផលិតកម្មខ្លី ដូចជាការចិញ្ចឹមត្រីអណ្តែង កង្កែបនៅក្នុងតង់ផ្លាស្ទិក និងប្រភេទត្រីមួយចំនួនទៀតដែលមិនប្រើទុនវិនិយោគច្រើន ទីតាំងធំ និងទឹកច្រើន តែផ្តល់នូវផលល្អនិងឆាប់រហ័ស។

គ្រប់អង្គភាពជំនាញ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត បានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពខ្ពស់នូវធនធានដែលទទួលបានពីរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ក្នុងការបង្កើនយុទ្ធនាការជំរុញផលិតកម្មដំណាំ ការចិញ្ចឹមសត្វ និងវារីវប្បកម្មនេះ។

ជាមួយគ្នានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ក្នុងក្របខ័ណ្ឌនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម សំដៅជំរុញលើកកម្ពស់ផលិតភាពកសិកម្មទាំងបរិមាណនិងគុណភាព ដោយធានាបានសន្តិសុខស្បៀង និងបង្កើនការនាំចេញកសិផល ក៏ដូចជាការគ្រប់គ្រងធនធានព្រៃឈើ និងជលផលប្រកបដោយចីរភាព។

## ១. ការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិ

វិស័យកសិកម្មបានចូលរួមចំណែកប្រមាណ២២,៨% (គិតតាមថ្លៃបច្ចុប្បន្ន) នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០២០។ ដោយឡែក វិស័យឧស្សាហកម្មបានរួមចំណែកប្រមាណ៣៤,៧% និងវិស័យសេវាកម្មប្រមាណ៣៦,២%។ ការកើនឬថយចុះនូវចំណែកនៃការចូលរួមរបស់វិស័យកសិកម្ម គឺអាស្រ័យទៅនឹងការរីកលូតលាស់នៃផ្នែកពីរសំខាន់ផ្សេងទៀតក្នុងវិស័យសេដ្ឋកិច្ច (វិស័យឧស្សាហកម្ម សំណង់ និងវិស័យសេវាកម្ម) ដែលជាការកត់សម្គាល់នាពេលកន្លងមក ការចូលរួមចំណែករបស់វិស័យកសិកម្មមានការប្រែប្រួលថយចុះពី២៤,៧% ដល់២២,៨% ក្នុងចន្លោះឆ្នាំ២០១៦-២០២០។

### ក្រាហ្វិកទី១៖ ការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិ




**ប្រភព៖** ក្រសួងផែនការឆ្នាំ២០២០ (ការវាយតម្លៃជំហានដំបូង)

ទោះជាយ៉ាងនេះក្តី បើពិនិត្យទៅលើតម្លៃបន្ថែមសរុប (គិតតាមតម្លៃបច្ចុប្បន្ន) នៃវិស័យកសិកម្ម (Agricultural Gross Value Added-GVA) គឺមានការកើនឡើងជារៀងរាល់ឆ្នាំ។ តម្លៃបន្ថែមសរុបនៃវិស័យកសិកម្មបានកើនពី ១៧ ៩៩៤ ពាន់លានរៀលនៅឆ្នាំ២០១១ ដល់ ២០ ១០១ពាន់លានរៀលនៅឆ្នាំ២០១៦ និងបានបន្តកើនដល់ ២៣ ៦៣៩ពាន់លានរៀលនៅឆ្នាំ២០២០។

### ក្រាហ្វិកទី២៖ កំណើនតម្លៃបន្ថែមសរុបនៃវិស័យកសិកម្ម




ប្រភព៖ ក្រសួងផែនការឆ្នាំ២០២០ (ការវាយតម្លៃជំហានដំបូង)

## ២. សមាសភាគនៃអនុវិស័យក្នុងវិស័យកសិកម្ម

នៅឆ្នាំ២០២០នេះ ការចូលរួមចំណែកនៃអនុវិស័យក្នុងផលិតផលក្នុងស្រុកសរុបរបស់វិស័យកសិកម្ម រួមមាន៖ ផ្នែកដំណាំ៥៧% ផ្នែកផលិតកម្មសត្វ១១% ផ្នែកជលផល២៤% និងផ្នែកព្រៃឈើ៧,៤%។ ជាការកត់សម្គាល់ផ្នែកដំណាំ និងជលផល គឺជាកម្លាំងចលករនាំមុខក្នុងវិស័យកសិកម្ម (ការចូលរួមចំណែកច្រើនជាងគេក្នុងវិស័យទាំងមូល)។ ផលិតកម្មសត្វក៏ជាមុខព្រួញសំខាន់មួយទៀតក្នុងការផ្គត់ផ្គង់តម្រូវការសាច់ក្នុងស្រុក និងបម្រើឱ្យការនាំចេញ ដែលផ្នែកទាំងនេះត្រូវជំរុញអភិវឌ្ឍឱ្យបានខ្លាំងក្លាផងដែរ។

ក្រាហ្វិកទី៣៖ ការចូលរួមនៃអនុវិស័យកសិកម្ម (%)




ប្រភព៖ ក្រសួងផែនការឆ្នាំ២០២០ (ការវាយតម្លៃជំហានដំបូង)

## ៣. ស្ថានភាពកម្លាំងពលកម្មក្នុងវិស័យកសិកម្ម

អត្រាកម្លាំងពលកម្មកសិកម្មធៀបនឹងពលកម្មសរុបបានបន្តធ្លាក់ចុះពី ៤១,៥% នាឆ្នាំ២០១៥ មកត្រឹម ៣៥,៥% នៅឆ្នាំ២០២០។ យន្តូបនីយកម្មកសិកម្មបានចូលមកជំនួសការបាត់បង់កម្លាំងពលកម្មកសិកម្ម ដោយក្នុងឆ្នាំ២០២០ នេះ ការប្រើប្រាស់គ្រឿងយន្តកសិកម្មសម្រាប់ការងាររៀបចំដីស្រែមានជាង៩៩% និងការប្រមូលផលស្រូវដោយគ្រឿងយន្តមានប្រមាណ៨៥%។

**តារាងទី១៖ ប្រៀបធៀបកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ច**

| កម្លាំងពលកម្ម (ពាន់នាក់) | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ២០១៥ | | | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ២០១៩ | | |
|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | បុរស | សរុប | ស្ត្រី | បុរស |
| ចំនួនពលកម្មសរុប | ៨ ៣៥២ | ៤ ០២៩ | ៤ ៣២២ | **៨ ៨០៥** | **៤ ៣១៨** | **៤ ៤៨៧** |
| កសិកម្ម (%) | ៤១,៥ | ៤៣,៩ | ៣៩,៤ | ៣៥,៥ | ៣៨,០ | ៣៣,០ |
| ឧស្សាហកម្ម (%) | ២៥,៥ | ២៤,៨ | ២៦,១ | ២៦,១ | ២៤,២ | ២៧,៩ |
| សេវាកម្ម (%) | ៣៣,០ | ៣១,៣ | ៣៤,៥ | ៣៨,៤ | ៣៧,៨ | ៣៩,១ |
| សរុប (%) | ១០០ | ១០០ | **១០០** | ១០០ | ១០០ | **១០០** |

ប្រភព៖ ក្រសួងផែនការឆ្នាំ២០២០ (អង្កេតសេដ្ឋកិច្ចសង្គមកិច្ច)

# IV- លទ្ធផលតាមអនុវិស័យ

## ១. បង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិធុរកិច្ច

### ក. ផលិតកម្មដំណាំស្រូវ

ក្នុងឆ្នាំ២០២០នេះ ផ្ទៃដីដាំដុះស្រូវសរុបទូទាំងប្រទេសសម្រេចបានចំនួន ៣,៤០លានហិកតា ស្មើនឹង ១១២% នៃផែនការ ក្នុងនោះស្រូវរដូវប្រាំងមានចំនួន០,៦០លានហិកតា និងស្រូវរដូវវស្សាមានចំនួន ២,៨១លានហិកតា

ដែលផ្ទៃដីដាំដុះសរុបនេះកើនឡើងចំនួន ២,២៦% ធៀបនឹងផ្ទៃដីដាំដុះសរុបនៅឆ្នាំ២០១៩។ ផ្ទៃដីប្រមូលផលសរុបមានចំនួន ៣,២៧លានហិកតា ក្នុងនោះស្រូវរដូវប្រាំងមានចំនួន ០,៥៩លានហិកតា ស្រូវរដូវវស្សាចំនួន ២,៦៨លានហិកតា។ បរិមាណផលស្រូវសរុបទទួលបានចំនួន ១០,៩៤លានតោន ក្នុងនោះ បរិមាណផលស្រូវរដូវប្រាំងទទួលបាន ២,៦២លានតោន បរិមាណផលស្រូវរដូវវស្សាទទួលបានប្រមាណ ៨,៣២លានតោន និងបរិមាណផលសរុបកើនចំនួន ៥០ ០៣២តោន លើសឆ្នាំ២០១៩។ ទិន្នផលស្រូវជាមធ្យមប្រចាំឆ្នាំទទួលបាន ៣,៣៤៥តោន/ហិកតា ក្នុងនោះទិន្នផលស្រូវប្រាំងទទួលបាន ៤,៤១៨ហិកតា/តោន និងទិន្នផលស្រូវវស្សាទទួលបាន ៣,១០៨តោន/ហិកតា។

**ក្រាហ្វិកទី៤៖ បង្ហាញពីកំណើនបរិមាណផល និងទិន្នផលនៃផលិតកម្មដំណាំស្រូវឆ្នាំ២០១៦-២០២០**




ការភ្ជួររាស់ដោយគ្រឿងយន្ត សម្រេចបានចំនួន ៣,៤៣លានហិកតា ស្មើនឹង៩៩,០៤% និងដោយគោក្របីសម្រេចបាន ០,៣៣លានហិកតា ស្មើនឹង ០,៩៦% នៃផ្ទៃដីភ្ជួររាស់សរុប។

តាមរយៈលទ្ធផលសម្រេចបានខាងលើនេះបង្ហាញថា ស្ថានភាពផលិតកម្មដំណាំស្រូវនៅឆ្នាំ២០២០ នៅតែល្អប្រសើរ ធានាបានសន្តិសុខស្បៀង និងអតិរេកស្រូវសម្រាប់ការកែច្នៃនាំចេញ បើទោះជាបានទទួលរងនូវឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុដូចជា គ្រោះរាំងស្ងួតនៅដើមរដូវ និងគ្រោះទឹកជំនន់ចុងរដូវវស្សាក៏ដោយ។

### ខ. ផលិតកម្មដំណាំសាកវប្បកម្ម

នៅឆ្នាំ២០២០ ផ្ទៃដីផលិតកម្មដំណាំសាកវប្បកម្មរយៈពេលខ្លីសម្រេចបានប្រមាណ ១០៥ ៣៥៦ហិកតា លើសឆ្នាំមុនចំនួន ១០ ៨១៥ហិកតា ស្មើនឹង១១% ក្នុងនោះផ្ទៃដីដាំដុះរដូវប្រាំងមានចំនួន ៣៧ ៦២៦ហិកតា និងផ្ទៃដីដាំដុះរដូវវស្សាមានប្រមាណ ៦៧ ៧៣០ហិកតា។ ផ្ទៃដីប្រមូលផលដំណាំសាកវប្បកម្មរយៈពេលខ្លីសរុបមានចំនួន ១០៣ ៥៦៦ហិកតា ក្នុងនោះផ្ទៃដីប្រមូលផលរដូវប្រាំងមានចំនួន ៣៧ ៦២៦ហិកតា និងផ្ទៃដីប្រមូលផលរដូវវស្សាមានចំនួន ៦៥ ៩៤០ហិកតា។ បរិមាណផលសរុបទទួលបានប្រមាណ ១ ០២០ ២១៤ តោន លើសឆ្នាំមុនចំនួន ១៤០ ៣៩៣តោន ដែលក្នុងនោះបរិមាណផលដំណាំសាកវប្បកម្មរដូវប្រាំងមានចំនួន ៣៦៧ ១២០តោន និងបរិមាណផលដំណាំសាកវប្បកម្មរដូវវស្សាមានប្រមាណ ៦៥៣ ០៩៤តោន។

ដោយឡែក ផ្ទៃដីដាំដុះដំណាំសាកវប្បកម្មរយៈពេលវែងសំខាន់ៗ រួមមាន ដំណាំចេក អនុវត្តសរុបបានចំនួន ៤៩ ១៥៧ហិកតា និងទទួលបានបរិមាណផលសរុបចំនួន ៩៣៥ ០៧២តោន (ក្នុងនោះ ចេកអំបូងលឿងមានប្រមាណ ១៥ ៩៤៥ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន ៤៧៨ ៣៥០តោន) ដំណាំស្វាយអនុវត្តសរុបបានចំនួន ១៣១ ៨៩០ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន ១ ៧៤៨ ៦៤២តោន ដំណាំមៀនអនុវត្តសរុបបានចំនួន ១៤ ៥០០ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន ១៩៦ ៧១២តោន ដំណាំទុរេនអនុវត្តសរុបបានចំនួន ៥

២៨៩ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន ៣៦ ៦៥៦តោន និងដំណាំស្រកានាគ អនុវត្តសរុប បានចំនួន ៧៣៧ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន ៨ ៧៥៩តោន។

**ក្រាហ្វិកទី៥៖ បង្ហាញពីកំណើនផលិតកម្មដំណាំសាកវប្បកម្មរយៈពេលខ្លីពីឆ្នាំ២០១៦-២០២០**




**គ. ផលិតកម្មដំណាំឧស្សាហកម្ម**

ផ្ទៃដីផលិតកម្មដំណាំឧស្សាហកម្មរយៈពេលខ្លីសម្រេចបានចំនួន ៨៧៥ ១៣៣ហិកតា ក្នុងនោះផ្ទៃដីដំណាំឧស្សាហកម្មរដូវប្រាំងចំនួន ៧៩ ២៧៤ហិកតា និងផ្ទៃដីដាំដុះដំណាំឧស្សាហកម្មរដូវវស្សាចំនួន ៧៩៥ ៨៥៩ហិកតា។ ផ្ទៃដីប្រមូលផលដំណាំឧស្សាហកម្មរយៈពេលខ្លីសរុបមានចំនួន ៨១៨ ១៣៣ហិកតា ក្នុងនោះផ្ទៃដីប្រមូលផលរដូវប្រាំងមានចំនួន ៧៨ ៩១៤ហិកតា និងផ្ទៃដីប្រមូលផលរដូវវស្សាមានចំនួន ៧៣៩ ២១៩ហិកតា។ បរិមាណផលដំណាំឧស្សាហកម្មរយៈពេលខ្លីសរុបទទួលបានចំនួន ១៣ ៥២៤ ០៨២តោន ក្នុងនោះបរិមាណផលរដូវប្រាំងមានចំនួន ៨៦១ ៧៥១តោន និងបរិមាណផលរដូវវស្សាមានចំនួន ១២ ៦៦២ ៣៣១តោន។ ជាការកត់សម្គាល់ ផ្ទៃដីដាំដុះដំណាំដំឡូងមីសម្រេចបានចំនួន ៦២៨ ៨៩៤ហិកតា ដោយទទួលបានបរិមាណផលប្រមាណចំនួន ១២ ០៤១ ៨១២តោន ដំណាំពោតក្រហមបានចំនួន ១៥៤ ៥៩៨ហិកតា ដោយទទួលបានបរិមាណផលចំនួន ៧៣៥ ៥៥១តោន និងដំណាំអំពៅបានចំនួន ១៥ ៩៩២ហិកតា ដោយទទួលបានបរិមាណផលចំនួន ៦៤៥ ១៣១តោន។

ដោយឡែកផ្ទៃដីដាំដុះដំណាំឧស្សាហកម្មរយៈពេលវែងសំខាន់ៗ អនុវត្តសរុបបានចំនួន ២៩១ ៨២៥ហិកតា ដោយទទួលបានបរិមាណផលសរុបប្រមាណ ៦៦៧ ៧២៩តោន។ ដំណាំឧស្សាហកម្មរយៈពេលវែងសំខាន់ៗរួមមាន៖ ដំណាំស្វាយចន្ទីអនុវត្តបានប្រមាណ ២៥៨ ៩៨៤ហិកតា ដោយទទួលបានបរិមាណផលសរុបប្រមាណ ២៤២ ៣២៤តោន ដំណាំម្រេចអនុវត្តបានប្រមាណ ៧ ២៩៣ហិកតា ដោយទទួលបានបរិមាណផលសរុបប្រមាណ ១៨ ២៤២តោន ដំណាំកាហ្វេអនុវត្តបានប្រមាណ ៤០៦ហិកតា ដោយទទួលបានបរិមាណផលសរុបប្រមាណ ៩៤០តោន និងដំណាំដូងអនុវត្តបានប្រមាណ ១៨ ០៧៤ហិកតា ដោយទទួលបានបរិមាណផលប្រមាណ ២៧៦ ២៤០តោន។

ក្រាហ្វិកទី៦៖ បង្ហាញពីស្ថានភាពផលិតកម្មដំណាំឧស្សាហកម្មរយៈពេលខ្លីឆ្នាំ២០១៦-២០២០




## ឃ. ការលើកកម្ពស់គុណភាព សុវត្ថិភាព និងការនាំចេញផលិតផលដំណាំកសិកម្ម

ក្នុងពេលបច្ចុប្បន្ននេះ កិច្ចខិតខំប្រឹងប្រែង ដើម្បីលើកកម្ពស់សុវត្ថិភាពស្បៀង កំពុងត្រូវបានយកចិត្តទុកដាក់យ៉ាងសកម្មតាមរយៈការអនុវត្តប្រព័ន្ធផលិតកម្ម ធានាសុវត្ថិភាពស្បៀងមានដូចជា៖ ការអនុវត្តកសិកម្មល្អសម្រាប់បន្លែ និងផ្លែឈើ និងការអនុវត្តកសិកម្មសរីរាង្គដើម្បីថែរក្សាលំនឹងគេ្យត្របរិស្ថាន។ ក្នុងឆ្នាំ២០២០នេះ បានចុះបញ្ជីជាចម្ការអនុវត្តកសិកម្មល្អចំនួន១៤៦ ចម្ការ/កសិដ្ឋាន។

ការវិនិយោគកន្លងមកនេះ ធ្វើឱ្យមានការផ្លាស់ប្តូរជាវិជ្ជមានគួរកត់សម្គាល់ក្នុងវិស័យកសិកម្មដែលបានប្រែក្លាយកម្ពុជាពីប្រទេសដែលជួបប្រទះបញ្ហាឱនភាពស្បៀង មកជាប្រទេសដែលសម្រេចបានសន្តិសុខស្បៀងតាំងពីឆ្នាំ១៩៩៥ កន្លងមកម្លេះ ហើយបច្ចុប្បននេះជាប្រទេសដែលមានអតិរេកផលិតផលកសិកម្មរាប់លានតោនក្នុងមួយឆ្នាំៗ សម្រាប់បម្រើឱ្យឧស្សាហកម្មកែច្នៃក្នុងស្រុក និងសម្រាប់ការនាំចេញ។ ជាក់ស្តែងក្នុងឆ្នាំ២០២០ ការនាំចេញផលិតផលកសិកម្មសរុបសម្រេចបានចំនួន ១២ ៩៧២ ៧៧៧តោន មានតម្លៃជាង ៣ ៤៣៣លានដុល្លារអាមេរិក (ការនាំចេញមានវិញ្ញាបនបត្រចំនួន ៤ ៨៧១ ៤៦២តោន មានតម្លៃជាង ១ ៩២៦លានដុល្លារអាមេរិក)។

ក្នុងឆ្នាំ២០២០ ការនាំអង្ករចេញ សម្រេចបានចំនួន ៦៩០ ៨២៩តោន ក្នុងនោះ ការនាំចេញទៅប្រទេសចិនបានច្រើនជាងគេ គឺ ២៨៩ ៤៣៩តោន ស្មើនឹង ៤១,៩០% ទៅសហភាពអឺរ៉ុប (២៤ប្រទេស) បានចំនួន ២០៣ ៧៩១តោន ស្មើនឹង ២៩,៥០% ទៅប្រទេសក្នុងតំបន់អាស៊ាន (៦ប្រទេស)បានចំនួន ៨៦ ៨៩៩តោន ស្មើនឹង ១២,៥៨% និងទៅប្រទេសផ្សេងៗទៀតបានចំនួន ១១០ ៧០០តោន ស្មើនឹង ១៦,០២% នៃការនាំចេញអង្ករសរុប។ ប្រភេទអង្ករនាំចេញរួមមាន អង្ករក្រអូបគ្រប់ប្រភេទចំនួន ៥៦៥ ៨៦៧តោន អង្ករសចម្រុះចំនួន ១១៣ ៦៣០តោន អង្ករចំហុយចំនួន ៦ ២០១តោន អង្ករក្រហមចំនួន ៦៨តោន និងអង្ករសម្រូបចំនួន ៥ ០៦៣តោន។ ចំណែកការនាំចេញស្រូវក្រៅផ្លូវការមានចំនួន ២ ២០៨ ១២៦តោន។

### ក្រាហ្វិកទី៧៖ ស្ថានភាពនៃការនាំចេញផលិតផលកសិកម្មសរុប និងការនាំចេញអង្ករផ្លូវការឆ្នាំ២០១៦-២០២០




ក្រៅពីនេះ ក្រសួងបានធ្វើការចរចាបើកទីផ្សារនាំចេញផលិតផលកសិកម្មសំខាន់ៗ រួមមាន៖ (១) ការចុះហត្ថលេខាលើពិធីសារស្តីពីលក្ខខណ្ឌតម្រូវភូតគាមអនាម័យ សម្រាប់ការនាំចេញផ្លែស្វាយស្រស់ទៅកាន់ប្រទេសចិន (២)បើកទីផ្សារជាមួយប្រទេសវៀតណាម ស្តីពីលក្ខខណ្ឌតម្រូវភូតគាមអនាម័យនៃការនាំចេញផ្លែក្រូចថ្លុង មៀន និងផ្លែខ្នុរ។

### ង. ការចងក្រង និងចុះបញ្ជីសហគមន៍កសិកម្ម

ក្នុងឆ្នាំ២០២០ ក្រសួងបានបង្កើតសហគមន៍កសិកម្មចំនួន១០ ដោយនៅទូទាំងប្រទេសមានសហគមន៍កសិកម្មសរុបចំនួន ១ ២០០សហគមន៍ ដែលមានម្ចាស់ភាគហ៊ុនសរុបចំនួន១៤៤ ១៨២នាក់ ក្នុងនោះមានសមាជិកនារីចំនួន ៩០ ៥៦២នាក់ ស្មើនឹង៦៣% ហើយមានប្រាក់ភាគហ៊ុនសរុបចំនួនជាង៤២ ៨៤១លានរៀល ស្មើនឹងជាង ១០លានដុល្លារអាមេរិក និងដើមទុនសរុបចំនួនជាង ៩៣ ៧៦៩លានរៀល ស្មើនឹងជាង ២៣,៤លានដុល្លារអាមេរិក។

ទន្ទឹមនឹងនេះ ក្រសួងបានចងក្រងសហគមន៍កសិកម្មទៅជាសហភាពសហគមន៍កសិកម្ម ដែលរហូតមកដល់បច្ចុប្បន្ននេះមានចំនួនសរុប ១១ និងមានសហគមន៍កសិកម្មជាសមាជិកមានចំនួន ២១៥សហគមន៍ មានដើមទុនសរុបចំនួនជាង ២ ៩១៥លានរៀល។ លើសពីនេះទៀត ក្រសួងបានបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ដែលជារចនាសម្ព័ន្ធចាត់តាំងកំពូលរបស់សហគមន៍កសិកម្មធ្វើជាតំណាងឱ្យសហគមន៍កសិកម្ម និងសហភាពសហគមន៍កសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ក្រាហ្វិកទី៨៖ ចំនួនសហគមន៍កសិកម្មចាប់ពីឆ្នាំ២០០៣-២០២០



**ច. ការគ្រប់គ្រង និងប្រើប្រាស់ធនធានដីកសិកម្ម**

ក្នុងឆ្នាំ២០២០ អគ្គនាយកដ្ឋានកសិកម្ម បានធ្វើបច្ចុប្បន្នភាពផែនទីចំណាត់ថ្នាក់ដីដាំដុះស្រូវ ការបង្កើនផលិតភាពដំណាំស្រូវក្រអូបតាមរយៈការប្រើប្រាស់ជីសមស្របតាមប្រភេទដី ការសិក្សាវាយតម្លៃបម្រែបម្រួលការប្រើប្រាស់ដីលើដំណាំស្រូវ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្ម ការសិក្សាពីជម្រើសបច្ចេកទេសកសិកម្មវៃឆ្លាតនឹងអាកាសធាតុលើការគ្រប់គ្រងទឹកនិងដី ការលើកកម្ពស់ការអនុវត្តល្អដើម្បីទប់ស្កាត់ការធ្លាក់ចុះគុណភាពដីនៅតំបន់ខ្ពង់រាប ការអង្កេតប្រមូលទិន្នន័យអំពីសេដ្ឋកិច្ចសង្គមបរិស្ថានសម្រាប់កំណត់តំបន់ដាំដុះកសិកម្ម និងការវាយតម្លៃកម្រិតសាយភាយបច្ចេកទេសគ្រប់គ្រងជីជាតិដី ការសិក្សាផ្ទៀងផ្ទាត់ទិន្នន័យស្ថិតិដំណាំស្រូវតាមប្រព័ន្ធព័ត៌មានផ្កាយរណប និងការងារចាំបាច់នានាតាមការចាំបាច់របស់ក្រសួងនិងអគ្គនាយកដ្ឋានកសិកម្ម។

រូបទី១. ផែនទីចំណាត់ថ្នាក់ដីសម្រាប់ដំណាំស្រូវនៅខេត្តព្រៃវែង និងខេត្តកំពង់ធំ។




រូបទី២. ផែនទីការប្រើប្រាស់ដីដំណាំស្រូវនៅក្នុងស្រុកអង្គរជុំ ស្រុកអង្គរធំ ស្រុកជីក្រែង និងស្រុកបន្ទាយស្រី ក្នុងខេត្តសៀមរាប ឆ្នាំ២០២០។












ក្រសួងបានប្រើប្រាស់បច្ចេកវិទ្យាផ្កាយរណបតាមរយៈគម្រោង RIICE (Remote Sensing-Based Information and Insurance for Crops in Emerging Economies) ជំហានទី៣ ដើម្បីធ្វើបច្ចុប្បន្នភាពចំណាត់ថ្នាក់ប្រព័ន្ធក្សេត្របរិស្ថាននៃតំបន់ដាំដុះដំណាំស្រូវនិងផលិតផែនទី។ កម្មវិធីឌីជីថលដែលបានប្រើប្រាស់ក្នុងការផលិតផែនទី រួមមាន MAPscapeArcGIS/QGIS Rice-YES និង Oryza Crop Model ដែលបង្កើតដោយក្រុមហ៊ុន Sarmap និងអង្គការ IRRI ដោយប្រើប្រាស់ទិន្នន័យរូបភាពផ្កាយរណបជាច្រើនប្រភេទ និងទិន្នន័យមួយចំនួនទៀតមានដូចជា រូបភាពផ្កាយរណប Sentinel-1A & 1B របស់សហភាពអឺរ៉ុប រូបភាពផ្កាយរណប Landsat 8 របស់អង្គការ NASA (USGS) Digital Elevation Model (DEM) របស់អង្គការ NASA (USGS) ប្រតិទិនដាំដុះដំណាំស្រូវ វិធីសាស្ត្រដាំដុះដំណាំស្រូវ ទិន្នន័យអាកាសធាតុ ទិន្នន័យដី ទីតាំងដាំដុះដំណាំស្រូវ ពេលវេលាចាប់ផ្តើមដាំដុះដំណាំស្រូវ ប៉ារ៉ាម៉ែត្រនៃការលូតលាស់របស់ដំណាំនិងក្រឡាផ្ទៃស្លឹក។ តាមរយៈការវិភាគទិន្នន័យទាំងនេះ និងការពិភាក្សាប្រព័ន្ធក្សេត្របរិស្ថានដាំដុះដំណាំស្រូវចំនួន០៦ចំណាត់ថ្នាក់ត្រូវបានកំណត់ រួមមាន៖ ១)-ស្រូវចម្ការ ២)-ស្រូវឡើងទឹក ៣)-ស្រូវដើមរដូវវស្សា (ស្រូវស្រាល) ៤)-ស្រូវតំបន់ទំនាបអាស្រ័យទឹកភ្លៀង (ដាំមួយដង) ៥)-ស្រូវ តំបន់ទំនាបអាស្រ័យទឹកភ្លៀង (ដាំពីរដង) និង៦)-ស្រូវប្រាំង (ស្រូវស្រាល)។ ព័ត៌មានអំពីផ្ទៃដីដាំដុះតាមប្រភេទនៃចំណាត់ថ្នាក់ប្រព័ន្ធក្សេត្របរិស្ថាននីមួយៗមានបង្ហាញក្នុងតារាងទី១។ ចំណែកឯផែនទីតំបន់ដាំដុះស្រូវនៃប្រព័ន្ធក្សេត្របរិស្ថាននីមួយៗ ត្រូវបានផលិតក្នុងខ្នាតមាត្រដ្ឋាន ១ : ៧០០ ០០០ ដូចមានបង្ហាញក្នុងទំព័រខាងក្រោម។

### តារាងទី២៖ ប្រភេទនៃចំណាត់ថ្នាក់ប្រព័ន្ធអេកូឡូស៊ីស្រូវ ក្នុងតំបន់ដាំដុះដំណាំស្រូវ ឆ្នាំ២០១៩

| ល.រ | ចំណាត់ថ្នាក់ប្រព័ន្ធអេកូឡូស៊ីស្រូវ | | ផ្ទៃដីដាំដុះ (ហ.ត) | សមាមាត្រនៃផ្ទៃដីដាំដុះសរុប (%) |
|---|---|---|---|---|
| ១ | ស្រូវចម្ការ | Upland rice | ៣ ១០៦ | < 0,១ |
| ២ | ស្រូវឡើងទឹក | Deepwater rice | ៤៦ ៦៥៦ | ១ |
| ៣ | ស្រូវដើមរដូវវស្សា (ស្រូវស្រាល) | Early wet season rice (Early maturity rice) | ១២១ ៨៣៦ | ៤ |
| ៤ | ស្រូវតំបន់ទំនាបអាស្រ័យទឹកភ្លៀង (ដាំមួយដង) | Rainfed lowland rice (Single crop) | ២ ៤៤០ ១៩៥ | ៧១ |
| ៥ | ស្រូវតំបន់ទំនាបអាស្រ័យទឹកភ្លៀង (ដាំពីរដង) | Rainfed lowland rice, favorable (Double crop) | ៣០១ ១៧១ | ៩ |
| ៦ | ស្រូវប្រាំង (ស្រូវស្រាល) | Dry season rice | ៥១៩ ៩១៥ | ១៥ |
| សរុប | | | ៣ ៤៤១ ៨៧៩ | ១០០ |



## ផែនទីតំបន់ដាំដុះស្រូវតំបន់ទំនាបអាស្រ័យទឹកភ្លៀងដែលមានអំណោយផល ( ដាំពីរដង ) នៅកម្ពុជា ឆ្នាំ២០១៩

Map of Rainfed Lowland Rice-Growing Area, Favorable ( Double crop ) in Cambodia




## ផែនទីតំបន់ដាំដុះស្រូវរដូវប្រាំងនៅកម្ពុជា ឆ្នាំ២០១៩

Map of Dry Season Rice-Growing Area in Cambodia






**ឆ. ការពិសោធន៍ និងអភិវឌ្ឍន៍បច្ចេកវិទ្យាកសិកម្ម**

- បានធ្វើពិសោធន៍អំពីកម្រិតប្រើប្រាស់ជី N, P, K តាមប្រភេទដីលើដំណាំស្រូវវស្សានៅក្នុងខេត្តបាត់ដំបង កំពង់ឆ្នាំង ព្រៃវែង ស្វាយរៀង តាកែវ កំពង់ធំ កំពង់ស្ពឺនិងក្នុងស្ថានីយពិសោធន៍នៃមណ្ឌលអភិវឌ្ឍន៍កសិកម្មខាងលិចរាជធានីភ្នំពេញ
- បានធ្វើការពិសោធន៍ប្រៀបធៀបពូជដំណាំឧស្សាហកម្ម នៅក្នុងស្ថានីយពិសោធន៍កសិកម្មបន្ទាយដែក ខេត្តកណ្តាល និងកសិដ្ឋានផលិតពូជដំណាំតំបន់ដីខ្ពស់ចម្ការលើ ខេត្តកំពង់ចាម ដែលក្នុងនោះទទួលបានលទ្ធផលរួមមាន៖ សណ្តែកបាយចំនួន១ពូជ (ពូជ BD-17) សណ្តែកសៀងចំនួន១ពូជ (ពូជ ពែកឌីស) ដំណាំពោតចំនួន១ពូជ (CHM01) ដំណាំដំឡូងមីចំនួន១ពូជ (Huybong-60) ស្វាយចន្ទីចំនួន១ពូជ (ពូជ M-23) ព្រមទាំងបានធ្វើបង្ហាញពូជដំណាំដំឡូងមីគ្មានជំងឺម៉ូសាអ៊ិក នៅខេត្តបាត់ដំបង កំពង់ចាម និងខេត្តត្បូងឃ្មុំ
- បានធ្វើអង្កេតដង្កូវហ្វូងប្រភេទថ្មី FAW ក្នុង៥ខេត្តរួមមានខេត្តបាត់ដំបង បន្ទាយមានជ័យ កំពង់ចាម ព្រះវិហារ និងខេត្តប៉ៃលិន ដើម្បីកំណត់ប្រជាករនិងអត្តសញ្ញាណកម្មប្រភេទដង្កូវ FAW និងសត្រូវធម្មជាតិ
- បានរៀបចំពិសោធន៍សម្តែងកម្មនៅទីវាលលើប្រភេទពូជដំណាំពោតដំណើប នៅស្ថានីយពិសោធន៍ពូជដំណាំក្បាលកោះ និងស្ថានីយពិសោធន៍កសិកម្មព្រៃផ្តៅ ព្រមទាំងបានរៀបចំធ្វើតេស្តបណ្តុះសាកល្បងប្រភេទពូជពោតក្រហម៩៩៩ ចំនួនបីសំណាក
- បានរចនាប្លង់ធុងប្រអប់ត្រជាក់ (Cool Box) សម្រាប់ដាក់បន្លែផ្លែឈើឱ្យបានយូរ គូសគ្រោងប្លង់អគារស្តុកទុកបន្លែផ្លែឈើ ប្លង់ផ្ទះសំណាញ់ប្រព័ន្ធស្រោចស្រពដោយដំណក់ទឹក ប្លង់ប្រព័ន្ធស្រោចស្រពឆ្លាតវៃសម្រាប់ផ្ទះសំណាញ់ ប្លង់ឧបករណ៍ដាំស្រូវបំពាក់ត្រាក់ទ័រ ប្លង់ឧបករណ៍ដាំស្រូវលើដីស្ងួត ព្រមទាំងស្រាវជ្រាវឯកសារបច្ចេកវិទ្យាក្រោយប្រមូលផលស្វាយ និងស្តង់ដារស្វាយកែវរមៀត

- ផលិតឧបករណ៍ពូនរងបន្លែបាន០១គ្រឿង និងកំពុងបន្តផលិតឧបករណ៍លើករងបន្លែគ្របកៅស៊ូនិងទុយោដំណក់ទឹក
- បានរៀបចំឯកសារបច្ចេកទេស និងបោះពុម្ពប័ណ្ណផ្សព្វផ្សាយ (Leaflet and Poster) ស្តីពី គោលការណ៍ណែនាំបច្ចេកទេសនៃស្តង់ដារការអនុវត្តកសិកម្មល្អ (GAP) គោលការណ៍ណែនាំ បច្ចេកទេសនៃស្តង់ដារកសិកម្មសរីរាង្គកម្ពុជា (CAMORG) គោលការណ៍ណែនាំបច្ចេកទេសនៃប្រព័ន្ធធានាដោយមានការចូលរួម (PGS) ស្តង់ដារដំណាំសាកវប្បកម្ម បច្ចេកទេសក្រោយពេលប្រមូលផលបន្លែ និងបច្ចេកទេសផលិតកម្មស្វាយខុសរដូវ។

**ជ. ការងារបណ្តុះបណ្តាលបច្ចេកទេសកសិកម្មក្នុងអនុវិស័យដំណាំ**

បានបណ្តុះបណ្តាលមន្ត្រីបច្ចេកទេសកសិកម្ម ម្ចាស់កសិដ្ឋាន និងកសិករគំរូ និងសហគមន៍កសិកម្មសរុបចំនួន ៣២ ៤៦១នាក់ ក្នុងនោះស្ត្រីចំនួន ១១ ៦៨៦នាក់ អំពីបច្ចេកទេសកសិកម្មថ្មីៗទំនើប ការគ្រប់គ្រងកសិដ្ឋាន ការត្រួតពិនិត្យគុណភាពនិងផលិតពូជដំណាំ បង្ហំបច្ចេកទេសដំណាំស្រូវ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្ម វិធានការចម្រុះគ្រប់គ្រងនិងថែរក្សាជីជាតិដី កសិកម្មអភិរក្ស វិធានការចម្រុះគ្រប់គ្រងដំណាំ កសិកម្មវៃឆ្លាតនឹងអាកាសធាតុ ការអនុវត្តកសិកម្មល្អ កសិកម្មសរីរាង្គ សុវត្ថិភាពនិងជីវសុវត្ថិភាពប្រើប្រាស់ថ្នាំកសិកម្ម វិធានការការពារដំណាំ អនាម័យនិងភូតគាមអនាម័យ ផលិតភាពនិងប្រសិទ្ធភាពក្នុងការប្រើប្រាស់គ្រឿងយន្តកសិកម្ម ប្រព័ន្ធបច្ចេកវិទ្យាស្រោចស្រពទំនើប ការគ្រប់គ្រងនិងធ្វើអាជីវកម្មក្នុងសហគមន៍កសិកម្ម និងការគ្រប់គ្រងស្ថិតិដំណាំ។

**ឈ. ការពង្រឹងសមត្ថភាពអង្គភាពនិងសេវាគាំទ្រ**

ក្របខ័ណ្ឌយុទ្ធសាស្ត្រនិងបទដ្ឋានគតិយុត្តនានា ត្រូវបានរៀបចំនិងដាក់ឱ្យប្រើប្រាស់សម្រាប់បម្រើឱ្យអនុវិស័យដំណាំកសិកម្មដែលរួមមាន អនុក្រឹត្យស្តីពីឯកសណ្ឋាន និងសញ្ញាសម្គាល់របស់ភ្នាក់ងារអធិការកិច្ចពូជដំណាំ។ ដោយឡែក ក្របខ័ណ្ឌយុទ្ធសាស្ត្រនិងបទដ្ឋានគតិយុត្តដែលកំពុងដំណើរការរៀបចំរួមមាន សេចក្តីព្រាងសេចក្តីសម្រេចពីការចាត់តាំងមន្ត្រីអធិការកិច្ចពូជដំណាំ សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ និងសេចក្តីព្រាងប្រកាសស្តីពីបែបបទនៃការពិន័យអន្តរការណ៍ និងតម្លៃទីផ្សារពូជដំណាំជាមូលដ្ឋានសម្រាប់អនុវត្តការពិន័យអន្តរការណ៍ សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាគោលនយោបាយសហគមន៍កសិកម្ម សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មូលនិធិអភិវឌ្ឍន៍សហគមន៍កសិកម្ម សេចក្តីព្រាងអនុក្រឹត្យស្តីពីការលើកទឹកចិត្តនិងសិទ្ធិអនុគ្រោះពន្ធរបស់រាជរដ្ឋាភិបាលចំពោះសហគមន៍កសិកម្ម។

**ញ. ការងារស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាកសិកម្ម**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា(CARDI) ជាអង្គភាពជំនាញបានប្រមូលនិងអភិរក្សប្រភេទពូជដំណាំកសិកម្ម បង្កើតប្រភេទពូជដំណាំកសិកម្មថ្មីៗ ថែរក្សានូវគុណភាពគ្រាប់ពូជនៃប្រភេទពូជដំណាំដែលបានបញ្ចេញ រួមទាំងផ្សព្វផ្សាយនូវពូជទាំងនោះ និងវិធីសាស្ត្រសម្រិតសម្រាំងគ្រាប់ពូជស្រូវបែបកសិករ បច្ចេកវិទ្យាដាំដុះ គ្រប់គ្រងសារធាតុចិញ្ចឹមដំណាំនិងជីជាតិដី ការពារនិងកម្ចាត់កត្តាចង្រៃ មុនពេលនិងក្រោយពេលប្រមូលផល បណ្តុះបណ្តាលធនធានមនុស្ស រួមទាំងចងក្រង បោះពុម្ព និងផ្សព្វផ្សាយអត្ថបទវិទ្យាសាស្ត្រ សៀវភៅ ព្រមទាំងឯកសារបច្ចេកទេស ជូនដល់អ្នកពាក់ព័ន្ធនិងកសិករទូទាំងប្រទេស។

ជាក់ស្តែងក្នុងឆ្នាំ២០២០នេះ ការងារជាច្រើនត្រូវបានអនុវត្តហើយខាងក្រោមនេះគឺជាសមិទ្ធផលសំខាន់ៗ៖

**១- ការអភិរក្សប្រភេទពូជដំណាំកសិកម្ម៖** បានប្រមូលប្រភេទពូជដំណាំថ្មីៗទៀតចំនួន៧៦សំណាកមករក្សាទុក ព្រមទាំងបានដាំ វាយតម្លៃនិងកំណត់លក្ខណៈពូជបន្លែ០៤មុខ សរុបចំនួន១៤៤សំណាក។ គិតជារួម ត្រឹមដំណាច់ឆ្នាំ២០២០នេះ ពូជដំណាំចំនួន៣៨មុខដែលសរុបទាំងអស់មានចំនួន៩ ១៨៧បញ្ជិក/សំណាក បានអភិរក្សនៅក្នុងធនាគារពន្ធុរបស់ CARDI ។

២- ការវាយតម្លៃពិពិធកម្មពន្ធុនៃសម្ភហជីវករ៖ ដោយមានការឧបត្ថម្ភពីមជ្ឈមណ្ឌលស្រាវជ្រាវអន្តរជាតិជប៉ុនសម្រាប់វិទ្យាសាស្ត្រកសិកម្មហៅកាត់ថា JIRCAS សម្ភហជីវករនិងពូជស្រូវរបស់កម្ពុជាសរុបចំនួន១៧៩ បញ្ជីក/ពូជ ត្រូវបានធ្វើការវិភាគរកពិពិធកម្មពន្ធុ (Genetic diversity) ដោយប្រើប្រាស់ Microsatelite Marker (SSR) ចំនួន៦៤ ដែលគ្របដណ្ដប់លើក្រូម៉ូសូមទាំង១២ របស់ស្រូវ។ ជាលទ្ធផលពន្ធុស្រូវរបស់កម្ពុជាមានពិពិធកម្មខ្ពស់ ហើយត្រូវបានបែងចែកជាបីក្រុមផ្សេងគ្នា។ ក្រុមនីមួយៗបានឆ្លុះបញ្ចាំងពីប្រព័ន្ធអេកូឡូស៊ីបរិស្ថាន ដាំដុះរបស់វាដូចជាស្រូវស្រាល ស្រូវកណ្ដាល និងស្រូវធ្ងន់។

៣- ការងារបសិដ្ឋកម្មពូជស្រូវ៖ បានជ្រើសរើសកូនបង្កាត់ជំនាន់ទី៣ដែលបានមកពីការបង្កាត់រវាងពូជស្រូវផ្ការំដួលជាមួយរាំងជ័យ ផ្ការំដួលជាមួយខា១១ និងសែនពិដោរជាមួយសែនក្រអូប០១ និងបានធ្វើវិយោគកម្មកូនបង្កាត់ ជំនាន់ទី១ ចំនួន១៤ប្រជាករ ក្នុងគោលបំណងអភិវឌ្ឍន៍ពូជស្រូវធន់នឹងភាពរាំងស្ងួត ធន់ទ្រាំនឹងមមាចត្នោត ប្រើប្រាស់ជីមានប្រសិទ្ធភាព អភិវឌ្ឍន៍ប្រព័ន្ធឬស មានក្លិនក្រអូប មានគុណភាពអង្ករល្អ និងទិន្នផលខ្ពស់។ ទន្ទឹមនឹងនេះដែរ វិទ្យាស្ថានបានធ្វើពិសោធន៍ជ្រើសរើសរកស្រឡាយស្រូវដែលមានទិន្នផលខ្ពស់ គុណភាពល្អ និងធន់នឹងការប្រែប្រួលអាកាសធាតុ ចំនួន៤០ប្រភេទ សរុបមាន៨២ពិសោធន៍ និងមាន ២០៨៩ ស្រឡាយ នៅក្នុងវិទ្យាស្ថានខេត្តព្រៃវែង ស្វាយរៀង ពោធិ៍សាត់ បាត់ដំបង កំពង់ធំ ឧត្ដរមានជ័យ សៀមរាប កំពត និងខេត្តតាកែវ។

៤- បង្កើតផែនទីក្រុមដីដាំដុះស្រូវចំនួន០១ស្រុក៖ បានធ្វើការសិក្សាវាយតម្លៃធ្វើចំណាត់ថ្នាក់ដីដាំដុះស្រូវនិងផលិតផែនទីក្រុមដីរបស់ស្រុកស្ទោង ខេត្តកំពង់ធំ។ ឯកសារព័ត៌មានលម្អិតនិងផែនទីនេះនឹងត្រូវបោះពុម្ពផ្សាយក្នុងរបាយការណ៍ស្រាវជ្រាវប្រចាំឆ្នាំ២០២០។ ទន្ទឹមនឹងនេះ បានចុះសិក្សានិងវាយតម្លៃចំនួន៨៩ប្រូហ្វីលដីនៅខេត្តចំនួន ៥ និងបានបញ្ចូលព័ត៌មានប្រូហ្វីលដីចំនួន៣៥កន្លែងនេះទៅក្នុងប្រព័ន្ធទិន្នន័យគ្រឹះនៃដី ហើយជាសរុបព័ត៌មានប្រូហ្វីលដីមានចំនួន២ ០៧៩ទីតាំង។

**ផែនទីចំណាត់ថ្នាក់ក្រុមដីនៃស្រុកស្ទូងខេត្តកំពង់ធំ**



៥- វិធានការគ្រប់គ្រងស្មៅក្នុងផលិតកម្មដំណាំស្រូវ៖ ឆ្លងតាមការពិសោធន៍ស្រាវជ្រាវលើការគ្រប់គ្រងស្មៅស្រូវដោយប្រើថ្នាំកម្ចាត់ស្មៅជាច្រើនករណីទាំងក្នុងលក្ខខណ្ឌផ្ទះកញ្ចក់ និងស្រែកសិករបានបង្ហាញឱ្យឃើញថា ប្រសិនបើកសិករចាំបាច់ត្រូវតែប្រើថ្នាំកម្ចាត់ស្មៅ គប្បីប្រើថ្នាំតាមកម្រិតណែនាំដូចតទៅ៖

លើកទី១៖ ត្រូវប្រើ Butachlor 60% EC ( ដីសើមគ្មានដក់ទឹក ) ឬថ្នាំ Pretilachlor 30% EC ( ដីដក់ទឹកតិចៗ ) នៅថ្ងៃទី២ បន្ទាប់ពីព្រោះ ឬស្ទូងរួចដើម្បីរារាំងគ្រាប់ស្មៅកុំឱ្យដុះពន្លក។

លើកទី២៖ ត្រូវប្រើថ្នាំ Byspyribac sodium 20%WP ឬស៊ីណាស៊ីបស៊ុពើ (Fenoxaprop-p-ethyl13%WC, Pyrazosul furon 7%, Quinchlorac 50%) នៅថ្ងៃទី១២ ទៅទី១៤ បន្ទាប់ពីព្រោះឬស្ទូងរួចដើម្បីកម្ចាត់ស្មៅ ដែលសេសសល់ទាំងបីក្រុម និង

ចុងក្រោយ៖ ប្រសិនបើមានស្មៅស្លឹកធំ និងកក់នៅសល់ខ្លះៗ អាចប្រើថ្នាំ 2.,4D Dimethylamine Salt 72% SL បន្ថែមទៀត នៅថ្ងៃទី២០បន្ទាប់ពីព្រោះឬស្ទូងរួច។ កសិករត្រូវធ្វើការពន្លិចទឹកស្រែក្នុងរយៈពេលពីរទៅបីថ្ងៃបន្ទាប់ពីរៀងរាល់បាញ់ថ្នាំរួចជាការស្រេច។ ការគ្រប់គ្រងស្មៅស្រូវចាំបាច់តែនៅក្នុងរយៈពេលពីចាប់ផ្តើមស្ទូង ឬព្រោះរួចបាន ៣០ ទៅ ៤០ថ្ងៃដំបូងប៉ុណ្ណោះ កសិករមិនត្រូវប្រើវិធានការណាមួយដើម្បីកម្ចាត់ស្មៅស្រូវនៅក្រោយពីស្ទូង ឬព្រោះរួចបាន៤០ថ្ងៃឡើយ ព្រោះស្មៅស្រូវដែលនៅសេសសល់មិនអាចប៉ះពាល់ដល់ការលូតលាស់របស់ដំណាំស្រូវទេ។ ការពិសោធន៍ផ្សេងទៀតលើការគ្រប់គ្រងស្មៅដោយប្រើកម្រិតកម្ពស់ទឹក បានបង្ហាញឱ្យឃើញថា ក្នុងករណីដែលកសិករអាចគ្រប់គ្រងទឹកបាន និងមានលទ្ធភាពកៀរពង្រាបដីបានស្មើល្អនោះ កសិករមិនត្រូវប្រើថ្នាំកម្ចាត់ស្មៅឡើយ។ កសិករគួរតែពន្លិចទឹកស្រែជម្រៅ ពី៨ទៅ១០សង់ទីម៉ែត្រ ក្នុងរយៈពេល១៥ថ្ងៃបន្ទាប់ពីព្រោះ ឬស្ទូងរួចបាន៧ថ្ងៃ គឺអាចកម្ចាត់ស្មៅទាំងបីក្រុមបាន ដោយមិនចាំបាច់បាញ់ថ្នាំស្មៅឡើយ។

៦- អត្ថបទវិទ្យាសាស្ត្រនិងការដឹកនាំនិស្សិត៖ បានសរសេរនិងបោះពុម្ពអត្ថបទនៅក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រអន្តរជាតិនិងជាតិបានចំនួន៥អត្ថបទ សៀវភៅបច្ចេកទេសស្តីពីសមូហកម្មពូជម្ទេស ចំនួន១ក្បាលនិងបានដឹកនាំ និស្សិតសរសេរសារណា ថ្នាក់បរិញ្ញាបត្រចំនួន១១នាក់ (នារី៣នាក់)។

៧. ការអភិវឌ្ឍធនធានមនុស្សនិងផ្សព្វផ្សាយ៖ បានធ្វើទិវាស្រែចំនួន ២០ លើក មានកសិករចូលរួម ៧៣៣នាក់ (នារី ៤១០ នាក់ ឬ ៥៥,៩%) ជួបប្រជុំជាមួយកសិករចំនួន ២០លើក មានកសិករចូលរួម ៣៨៥នាក់ (នារី ២០៤នាក់ ឬ ៥៣ %) វគ្គបណ្តុះបណ្តាលកសិករមានចំនួន ២៦លើក មានកសិករចូលរួម ៩២៥នាក់ (នារី៥៨៩នាក់ ឬ ៦៣,៦%) និងវគ្គបណ្តុះបណ្តាលជំនាញនៅ CARDI ចំនួន ២ លើក មានសិក្ខាកាមចូលរួម ៥៦នាក់ (នារី ១៤នាក់ ឬ ២៥ %)។ បានបោះពុម្ពឯកសារចំនួន ២៥ ៥២៣ច្បាប់ និងបែងចែកឯកសារ ១០ ៤៤៤ច្បាប់។ ចំនួនអ្នកប្រើប្រាស់ព័ត៌មានបច្ចេកវិទ្យារបស់ CARDI តាមរយៈគេហទំព័រ http://www.cardi.org.kh មានចំនួន សរុប ១ ៨៩១ ៧៧៥នាក់ គិតជាមធ្យមចំនួន ៥ ១៨៣នាក់/ថ្ងៃ លើសឆ្នាំ២០១៩ ចំនួន ២ ២៨៦នាក់/ថ្ងៃ (៧៨,៤%)។

នៅក្នុងឆ្នាំ២០២០វិទ្យាស្ថានបានផ្តល់ជូននូវគ្រាប់ពូជគ្រឹះស្រូវសែនក្រអូប០១ ចំនួន៤,១តោន ជូនអគ្គនាយកដ្ឋានកសិកម្ម និងបានចែកគ្រាប់ពូជគ្រឹះ និងគ្រាប់ពូជវិញ្ញាបនបត្រសរុបចំនួន៤,៤៣៥តោន ដែលក្នុងនោះមានពូជស្រូវផ្កាមាលតី ផ្ការំដួល ផ្ការមៀត រាំងជ័យ ខា៨ សែនពិដោរ សែនក្រអូប០១ ខា១៥ និងដំណើបស្បៃមង្គល ជូនដល់កសិករចំនួន៣៨៥គ្រួសារនៅខេត្តស្វាយរៀង ពោធិ៍សាត់ បាត់ដំបង កំពង់ធំ ព្រៃវែង ឧត្តរមានជ័យ កំពង់ចាម ត្បូងឃ្មុំ តាកែវ និងខេត្តកំពត សម្រាប់ផលិតក្នុងរដូវវស្សា និងរដូវទឹកស្រកឆ្នាំនេះទុកជាគ្រាប់ពូជសម្រាប់ប្រើប្រាស់ឆ្នាំបន្ទាប់ ដោយក្នុងរដូវវស្សានេះកសិករចំនួន១៩៥គ្រួសារនៅខេត្តត្បូងឃ្មុំ ព្រៃវែង តាកែវ និងខេត្តឧត្តរមានជ័យ ផលិតបានគ្រាប់ពូជសរុបចំនួន៥៣តោន។ វិទ្យាស្ថានបានផលិតគ្រាប់ពូជស្រូវសរុបចំនួន៣៩,៥តោន និងបានលក់ជូនអតិថិជនចំនួន ២១,២តោន។

## ង. ការងារនីតិកម្មគ្រប់គ្រងសម្ភារកសិកម្ម

### ១. ការផ្តល់លិខិតអនុញ្ញាតឱ្យនាំចូលថ្នាំកសិកម្ម និងជីកសិកម្ម

ក្នុងការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម ឱ្យទទួលបានប្រសិទ្ធភាពខ្ពស់ ក្នុងឆ្នាំ២០២០កន្លងទៅនេះ ក្រសួងបានចេញលិខិតអនុញ្ញាតឱ្យក្រុមហ៊ុនចំនួន២៣៧ នាំចូលថ្នាំកសិកម្ម និងជីកសិកម្ម ក្នុងនោះរួមមាន ក្រុមហ៊ុននាំចូលថ្នាំកសិកម្មចំនួន៦៥ក្រុមហ៊ុន ក្រុមហ៊ុននាំចូលជីកសិកម្មចំនួន១០០ក្រុមហ៊ុន ក្រុមហ៊ុននាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន៧២ ក្រុមហ៊ុន ដោយគិតជាបរិមាណសរុបមានចំនួន ១ ៥០៩ ៧៨១, ៤១៤ តោន ក្នុងនោះថ្នាំកសិកម្មមានចំនួន ១០៣ ០០៥,៨៧៣៥ តោន និងជីកសិកម្មមានចំនួន ១ ៤០៦ ៧៧៥,៥៤១ តោន។

### ២. ការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម៖

ក្រសួងបានចាត់មន្ត្រីជំនាញចុះត្រួតពិនិត្យការនាំចូលថ្នាំកសិកម្ម និងជីកសិកម្ម និងបានផ្តល់សុពលភាពផ្គត់ផ្គង់ ចែកចាយ ដល់ក្រុមហ៊ុនពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្ម ចំនួន១០២ក្រុមហ៊ុន ដែលមានបរិមាណ សរុបចំនួន ៤០៤ ៦០០,៥៨ តោន ក្នុងនោះ ថ្នាំកសិកម្មសរុបចំនួន៩៣៣ មុខ ស្មើនឹង ១៧ ០២៥,៤៧តោន និងជីកសិកម្មសរុបចំនួន៦០៤ មុខ ស្មើនឹង ៣៨៧ ៥៧៥,១១ តោន។ បានចាត់ក្រុមការងារអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្មចុះទៅធ្វើអធិការកិច្ចត្រួតពិនិត្យ បទល្មើស ថ្នាំកសិកម្ម និងជីកសិកម្ម នៅតាមខេត្តគោលដៅ រួមមានខេត្តសៀមរាប បន្ទាយមានជ័យ ប៉ៃលិន បាត់ដំបង កណ្តាល ឧត្តរមានជ័យ ព្រះវិហារ តាកែវ មណ្ឌលគិរី រតនគិរី កំពង់ចាម កំពត កំពង់ធំ ព្រះសីហនុ កោះកុង ពោធិ៍សាត់ ក្រចេះ និងរាជធានីភ្នំពេញ។ បានត្រួតពិនិត្យលើ១៦ ក្រុមហ៊ុន ០៣ឃ្លាំង សន្និធិ ៩៧ដេប៉ូ និង០១ មធ្យោបាយដឹកជញ្ជូន ដោយបានសម្រេចពិន័យអន្តរការណ៍ សរុបចំនួន ២៨ ករណី ស្មើនឹង ៩៨ ៦០០ ០០០ (កៅសិបប្រាំបីលានប្រាំមួយរយពាន់) រៀល។

### ៣. ការអភិវឌ្ឍបទដ្ឋានគតិយុត្ត៖

បានពិនិត្យសេចក្តីព្រាងប្រកាសស្តីពីនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត និងការកំណត់ការគ្រប់គ្រងចំណីសត្វ វត្ថុធាតុដើម ឬសារធាតុបន្ថែមដែលធ្វើពាណិជ្ជកម្ម ការផលិត និងការលាយផ្សំ។ បានជួយពិនិត្យ និងកែសម្រួលខ្លឹមសារមួយចំនួនក្នុងសេចក្តីព្រាងច្បាប់ស្តីពី "ផលិតកម្មកសិកម្មតាមកិច្ចសន្យា"។ បានជួយពិនិត្យ និងកែសម្រួលខ្លឹមសារមួយចំនួនក្នុងសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី "សហព័ន្ធដំណាំកសិឧស្សាហកម្មកម្ពុជា"។ បានប្រជុំពិភាក្សាលើលិខិតបទដ្ឋានគតិយុត្ត តាមការប្រគល់ភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ បានពិនិត្យលើសំណើសុំធាតុចូលលើសេចក្តីព្រាងគោលនយោបាយយុទ្ធសាស្ត្រជាតិ សម្រាប់ការរៀបចំបង្កើតភូមិ ឃុំ/ សង្កាត់ ស គ្មានគ្រឿងញៀនរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។ បានពិនិត្យផ្តល់យោបល់ផ្នែកច្បាប់ និងកិច្ចអន្តរាគមន៍ផ្លូវច្បាប់ចំពោះករណីផ្សេងៗ ចំនួន ៣៤ករណី។

### ៤. ការងារផ្សព្វផ្សាយ

បានរៀបចំសិក្ខាសាលាស្តីពី លទ្ធផលការងារប្រចាំឆ្នាំ២០១៩ និងទិសដៅការងារបន្តឆ្នាំ២០២០ នៅខេត្តសៀមរាប ក្រោមអធិបតីភាព **ឯកឧត្តម វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានអ្នកចូលរួមពីមន្ត្រីនាយកដ្ឋាននីតិកម្មកសិកម្ម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សរុបចំនួន ១៤៤នាក់។ បានរៀបចំសិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយពីនីតិវិធី និងវិធានបច្ចេកទេស នៃការធ្វើពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្ម" នៅខេត្តកំពត ដោយមានអ្នកចូលរួមជា ពាណិជ្ជករ ថ្នាំកសិកម្ម និងជីកសិកម្ម និងមន្ត្រីមកពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន ១០ខេត្ត សរុបចំនួន ១៣៣នាក់។ បានចុះធ្វើសិក្ខាសាលាផ្សព្វផ្សាយលើកកម្ពស់ ការយល់ដឹងបទដ្ឋាន គតិយុត្ត នីតិវិធី និងវិធានបច្ចេកទេសក្នុង ការគ្រប់គ្រង និងការធ្វើអាជីវកម្មថ្នាំកសិកម្ម និងជីកសិកម្ម ដល់អាជីវករលក់ដុំ លក់រាយ បានចំនួន០៣ខេត្ត រួមមាន ខេត្តកំពង់ចាម ខេត្តកំពង់ធំ និងខេត្តព្រៃវែង ដែលមានអ្នកចូលរួមសរុបចំនួន ១៧៨នាក់។ បានសហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត បើកវគ្គ

អប់រំសមត្ថភាព វិជ្ជាជីវៈដល់អាជីវករលក់ដុំ លក់រាយថ្នាំកសិកម្ម និងជីកសិកម្មបានចំនួន ០៦ខេត្ត នៅខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តរតនគិរី ខេត្តកំពង់ធំ ខេត្តបាត់ដំបង និងខេត្តតាកែវ សរុបចំនួន ៤៣៧នាក់។

**ថ. ការងារកសិ-ឧស្សាហកម្ម**

**១. ការរៀបចំលិខិតបទដ្ឋានគតិយុត្ត**

បានរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិ-ឧស្សាហកម្មកម្ពុជាឆ្នាំ២០១៩-២០៣០ និងបានបោះពុម្ពផ្សព្វផ្សាយជូនដល់អង្គភាពពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍។ បាននិងកំពុងបន្តរៀបចំសេចក្តីព្រាងច្បាប់ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា និងបានប្រជុំពិភាក្សាចំនួន១៧លើក ក្នុងនោះ ប្រជុំក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងច្បាប់នៃនាយកដ្ឋានកសិ-ឧស្សាហកម្មចំនួន ០៨លើក ប្រជុំក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងច្បាប់នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន ០៦លើក។ បានប្រជុំគណៈកម្មការបច្ចេកទេសរៀបចំតាក់តែងច្បាប់នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន០២លើក និងបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ចំនួន ០១លើក។ បានរៀបចំប្រកាសរួមជាមួយអគ្គនាយកដ្ឋានកសិកម្ម ស្តីពីវិធានកសិកម្មសរីរាង្គកម្ពុជា និងរូបសញ្ញាជាតិសម្រាប់អនុវត្តក្នុងផលិតកម្ម និងការកែច្នៃបឋមដំណាំស្បៀង។ បាននិងកំពុងរៀបចំគោលការណ៍ នីតិវិធីនិងបែបបទនៃការចេញវិញ្ញាបនបត្រផលិតផលសរីរាង្គកម្ពុជា តាមប្រកាសលេខ១៦៣ ស្តីពីវិធានកសិកម្មសរីរាង្គកម្ពុជា និងរូបសញ្ញាជាតិ សម្រាប់អនុវត្តក្នុងផលិតកម្ម និងការកែច្នៃបឋមដំណាំស្បៀង។ បានប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋាន ក្នុងការរៀបចំសេចក្តីព្រាងប្រកាសស្តីពីវិធានអនុវត្ត HACCP ស្លាកសញ្ញាសម្គាល់សម្រាប់ផលិតផលកសិកម្ម និងចំណីអាហារនៃផលិតផលកសិកម្ម។ បានប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋានក្នុងការរៀបចំសេចក្តីព្រាងប្រកាសស្តីពីវិធានអនុវត្តអនាម័យល្អ (GHP) និងស្លាកសញ្ញាសម្គាល់សម្រាប់ផលិតផលកសិកម្ម និងចំណីអាហារនៃផលិតផលកសិកម្ម។ បានប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋានក្នុងការរៀបចំសេចក្តីព្រាងប្រកាស ស្តីពីនីតិវិធីនៃការស្នើសុំ និងចេញវិញ្ញាបនបត្របញ្ជាក់គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម និងចំណីអាហារ។

**២. ការងារកិច្ចសន្យាផលិតកម្មកសិកម្ម**

ក្រសួងបានរៀបចំបង្កើតអនុគណៈកម្មាធិការសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្ម ថ្នាក់រាជធានី ខេត្ត បានចំនួន ២៥ រាជធានី/ខេត្ត និងបានរៀបចំផែនការយុទ្ធសាស្ត្រកសិ-ឧស្សាហកម្មឆ្នាំ២០១៩-២០៣០។ សហគមន៍កសិកម្មចំនួន ២៩២ សហគមន៍ ក្រុមកសិករ សមាគម និងកសិករផ្សេងទៀតបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុន ចំនួន ៩៣៦ កិច្ចសន្យា។ ប្រភេទផលិតផលសំខាន់ៗ រួមមាន ស្រូវមានចំនួន១៨៦កិច្ចសន្យា ក្នុងបរិមាណ៨២ ១៩៧តោន ដំឡូងមីមានចំនួន២៦កិច្ចសន្យាក្នុងបរិមាណ៥៤ ២៧២,២៧តោន គ្រាប់ស្វាយចន្ទីមានចំនួន ០៩កិច្ចសន្យាក្នុងបរិមាណ១០៥តោន អង្ករមានចំនួន០១កិច្ចសន្យាក្នុងបរិមាណ៣០១,១៩តោន ចុងអង្ករមានចំនួន ០១កិច្ចសន្យាក្នុងបរិមាណ១ ០៨០តោន ពោតមានចំនួន០៣កិច្ចសន្យាក្នុងបរិមាណ៥០៨តោន ជ្រូកមានចំនួន ២៣៥កិច្ចសន្យាក្នុងបរិមាណ៣៤ ៨៤៥តោន មាន់សាច់មានចំនួន២០៨កិច្ចសន្យាក្នុងបរិមាណ ២ ៧៦៨ ៨៩១ក្បាល មាន់ស្រែមានចំនួន៥៨កិច្ចសន្យាក្នុងបរិមាណ៧៣៩,៥៧តោន និង២៤១ ៣២៤ក្បាល គោមានចំនួន ០៥កិច្ចសន្យា ក្នុងបរិមាណ ១ ០៩៣ក្បាល កូនមាន់ស្រែមានចំនួន ២៤កិច្ចសន្យា ក្នុងបរិមាណ ៧៦៩ ៤២០ក្បាល ពូជត្រីគ្រប់ប្រភេទមានចំនួន ១៥កិច្ចសន្យាក្នុងបរិមាណ ៩៤,៩០តោន ៤ ៣២០ ០០០ក្បាល និងតាមតម្រូវការស៊ុតមាន់ស្រែមានចំនួន១៣កិច្ចសន្យា ក្នុងបរិមាណ១ ៣២៧ ៥៥០គ្រាប់ ស៊ុតទាមានចំនួន០២កិច្ចសន្យា ក្នុងបរិមាណ ១០០ ០០០គ្រាប់ បន្លែមានចំនួន៦២កិច្ចសន្យាក្នុងបរិមាណ១០ ៣០០,៤២តោន បន្លែផ្លែឈើមានចំនួន ១២កិច្ចសន្យាក្នុងបរិមាណ១៩៣,៤១ តោន ចេកមានចំនួន០២កិច្ចសន្យាក្នុងបរិមាណ២២,២០តោន ឪឡឹកមានចំនួន០២កិច្ចសន្យាក្នុងបរិមាណ ២០៥,២០តោន ល្ពៅមានចំនួន០១កិច្ចសន្យាក្នុងបរិមាណ២០,៥០តោន ជីធម្មជាតិមានចំនួន ០១កិច្ចសន្យាក្នុងបរិមាណ ១ ០០០តោន ខ្ទឹមានចំនួន០២កិច្ចសន្យាក្នុងបរិមាណ២,០៨តោន ខ្ទឹមស០២កិច្ចសន្យាក្នុងបរិមាណ

២,០០តោន ម្សៅដំឡូងមីមានចំនួន០១កិច្ចសន្យាក្នុងបរិមាណ ៥០,០០តោន ក្រូចឆ្មារមានចំនួន ០១កិច្ចសន្យាក្នុងបរិមាណ ៩១,២៥តោន ទំពាំងផ្អែមមានចំនួន ០២កិច្ចសន្យាក្នុងបរិមាណ ៣៨,០០តោន ក្រូចពោធិ៍សាត់មានចំនួន ០១កិច្ចសន្យាក្នុងបរិមាណ១ ៤០០,០០តោន ក្រូចវល្លិ៍មានចំនួន០១ កិច្ចសន្យា ក្នុងបរិមាណតាមតម្រូវការ អំពៅមានចំនួន ០១កិច្ចសន្យាក្នុងបរិមាណ ៣៦,៥០តោន ទាកាប៉ាមានចំនួន ០១កិច្ចសន្យា ក្នុងបរិមាណ ៩៨,៥៥តោន ស៊ុតមាន់ស្រែមានចំនួន ១៣កិច្ចសន្យា ក្នុងបរិមាណ ១ ៣២៧ ៥៥០គ្រាប់ ផលិតផលកែច្នៃមានចំនួន០១កិច្ចសន្យាក្នុងបរិមាណតាមតម្រូវការ ស្ករត្នោតមានចំនួន ០១កិច្ចសន្យា ក្នុងបរិមាណ១៣០,០០ តោន និងផ្គត់ផ្គង់ធាតុចូលសម្ភារកសិកម្មមានចំនួន ៥០កិច្ចសន្យាក្នុងបរិមាណតាមតម្រូវការ។







### ៣. ការងារមន្ទីរពិសោធន៍

បានរៀបចំកម្រៃសេវាកម្មវិភាគគុណភាព សុវត្ថិភាពផលិតផលកសិកម្ម និងចំណីអាហារ ដើម្បីភ្ជាប់ជាឧបសម្ព័ន្ធក្នុងប្រកាសរួមរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងបន្តពង្រឹងសមត្ថភាពមន្ទីរពិសោធន៍ដើម្បីទទួលបានអនុលោមភាពក្នុងកម្រិតស្តង់ដារ ១៧០២៥ Mycotoxin, Aflatoxin B1, Done...។ល។ បានវិភាគរកសមាសធាតុគីមី លោហៈធ្ងន់ (អាសេនិច) នៅក្នុងទឹកអណ្ដូង និងបន្លែស្រស់។ បានវិភាគរកសមាសធាតុ អាស៊ូត ផូស្វ័រ ប៉ូតាស្យូម អាស៊ីត និង pH នៅក្នុងទឹក ស្មោរ គ្រាប់ស្វាយចន្ទី។ បានវិភាគរកសមាសធាតុគីមីលោហៈធ្ងន់ (អាសេនិច) នៅក្នុងអង្ករសែនជ័យប្រេន SENCHEY BRAND អង្ករសែនក្រអូប SEN KRA-OB RICE និង ក្នុង

បន្លែជលវប្បកម្ម (Hydroponic Vegetable)។ បានវិភាគរកសមាសធាតុផេះ សំណើម ជាតិសរសៃ ខ្លាញ់ អាសូត ប្រូតេអ៊ីន ផូស្វ័រ ប៉ូតាស្យូម កាល់ស្យូម ដែក និងកាបូនអ៊ីដ្រាត នៅក្នុងអង្ករ និងចំណីសត្វចំនួន ១៨សំណាក។ បានវិភាគរកសមាសធាតុ GMO ដោយប្រើប្រាស់ឧបករណ៍ Florescence Quantitative Rapid Detection System for GMO លើសណ្តែកសៀង អង្ករ និងពោតលឿងដែលបានប្រមូលមកពីកន្លែងផ្សេងៗគ្នាក្នុងរាជធានីភ្នំពេញចំនួន ១០សំណាក។ បានវិភាគរកសមាសធាតុ Aflatoxin (B1) ដោយប្រើប្រាស់ឧបករណ៍ Florescence Quantitative Rapid Detection System លើអង្ករ និងចំណីសត្វចំនួន ១៨សំណាក។ បានរៀបចំគម្រោងសិក្សានិក្ខេបទរបស់និស្សិតមកពីសាកលវិទ្យាល័យអន្តរជាតិ លើការសិក្សា និងវិធីសាស្ត្រវិភាគរកបាក់តេរីចម្លងគ្រោះថ្នាក់ចំនួន ០៣ប្រភេទគឺ៖ ១) សាល់ម៉ូណេឡា ២) អ៊ីកូលី និង ៣) Total Plate Count។ បានវិភាគរកបាក់តេរីចម្លងគ្រោះថ្នាក់ចំនួន ០៤ប្រភេទគឺ៖ ១) សាល់ម៉ូណេឡា ២) អ៊ីកូលី ៣) Total Plate Count និង៤) ផ្សិតលើអង្ករសែនជ័យប្រេន SENCHEY BRAND អង្ករសែនក្រអូប SEN KRA-OB RICE និងបន្លែស្រស់។

### ៤. ការងារកែច្នៃផលិផលកសិកម្ម

បាននិងកំពុងរៀបចំប្រមូលចងក្រងទិន្នន័យសិប្បកម្ម សហគ្រាសកសិឧស្សាហកម្មតូចបំផុត តូច មធ្យម និងធំ ដើម្បីសិក្សាវិភាគនូវសមត្ថភាពផលិតកែច្នៃ តម្រូវការផលិតផលកសិកម្មជាវត្ថុធាតុដើម ឆ្លើយតបទាំងបរិមាណ និងគុណភាពដែលសហគ្រាសចង់បាន។ បណ្តុះបណ្តាល ផ្សព្វផ្សាយចំណេះដឹងការកែច្នៃផលិតផលកសិកម្ម ដើម្បីទទួលបានតម្លៃបន្ថែម និងរក្សាទុកបានយូរ។

### ខ. ការបង្កើនផលិតភាពដំណាំកៅស៊ូ

នៅឆ្នាំ២០២០នេះ ផ្ទៃដីកៅស៊ូកម្ពុជាសរុបមានចំនួន ៤០៣ ៩៧៥ហិកតា បើធៀបទៅនឹងឆ្នាំ២០១៩ ដែលមានចំនួន៤០៥ ៦៧១ ហិកតា គឺថយចុះចំនួន១ ៦៩៦ហិកតា ស្មើនឹង០,៤១%។ ការថយផ្ទៃដីនេះ ភាគច្រើនកើតមាននៅលើក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដោយក្រុមហ៊ុនមួយចំនួនបានផ្លាស់ប្តូរមុខដំណាំ ព្រោះដីមិនសមស្របនឹងដំណាំកៅស៊ូ និងក្រុមហ៊ុនមួយចំនួនទៀតគ្រប់គ្រងថែទាំកៅស៊ូមិនបានល្អ និងភ្លើងឆេះនៅរដូវប្រាំង។ ផ្ទៃដីកៅស៊ូទាំងនេះត្រូវបានបែងចែកជា០២ផ្នែកគឺ ក្រុមហ៊ុនកៅស៊ូកសិឧស្សាហកម្ម (ផ្ទៃដីអតីតចម្ការកៅស៊ូរដ្ឋ ផ្ទៃដីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងផ្ទៃដីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច) សរុបមានចំនួន ២៤២ ៨១៥ហិកតា ស្មើនឹង៦០,១១% និងកៅស៊ូគ្រួសារមានចំនួន ១៦១ ១៦០ហិកតា ស្មើនឹង៣៩,៨៩% នៃផ្ទៃដីកៅស៊ូសរុប។

**តារាងទី៣៖ ផលិតកម្មកៅស៊ូ២០១៩-២០២០**

| | ផលិតកម្មកៅស៊ូ | ប្រភេទចម្ការកៅស៊ូ | ឯកតា | ២០១៩ | ២០២០ | ២០២០/២០១៩ (Δ%) |
|---|---|---|---|---|---|---|
| 1 | ផ្ទៃដីដាំកៅស៊ូសរុប | កសិឧស្សាហកម្ម | ពាន់ហ.ត | 244,6 | 242,8 | -0,74 |
| | | កៅស៊ូគ្រួសារ | ពាន់ហ.ត | 161,1 | 161,2 | 0,06 |
| | | **សរុប** | **ពាន់ហ.ត** | 405,7 | 404,0 | -0,42 |
| 2 | ផ្ទៃដីចៀរជ័រ | កសិឧស្សាហកម្ម | ពាន់ហ.ត | 117,2 | 142,9 | 21,93 |
| | | កៅស៊ូគ្រួសារ | ពាន់ហ.ត | 133,3 | 149,7 | 12 |
| | | **សរុប** | **ពាន់ហ.ត** | 250,5 | 292,7 | 16,84 |
| 3 | ផលិតផលកៅស៊ូ | កសិឧស្សាហកម្ម | ពាន់តោន | 135,0 | 163,9 | 21,41 |
| | | កៅស៊ូគ្រួសារ | ពាន់តោន | 152,6 | 185,4 | 21,49 |
| | | **សរុប** | **ពាន់តោន** | 287,6 | 349,3 | 21,45 |

ក្រាហ្វិកទី៩៖ ប្រភេទផ្ទៃដីចម្ការកៅស៊ូឆ្នាំ២០១៦-២០២០




## ១. ការងារផលិតកម្ម

ឆ្នាំ២០២០នេះ ផ្ទៃដីកៅស៊ូចៀរអនុវត្តបានចំនួន ២៩២ ៦៤៧ហិកតា ធៀបនឹងផ្ទៃដីកៅស៊ូចៀរឆ្នាំ២០១៩ ដែលមាន២៥០ ៤៧៧ហិកតា គឺកើនឡើងចំនួន៤២ ១៧០ហិកតា ស្មើនឹង១៦,៨៣% (ក្រាហ្វិកទី៩)។ ផលិតផលកៅស៊ូសម្រេចបានចំនួន ៣៤៩ ៣០០តោន ធៀបនឹងឆ្នាំ២០១៩ដែលមានចំនួន២៨៧ ៦៣៨តោន គឺកើនឡើងចំនួន ៦១ ៦៦២តោន ស្មើនឹង២១,៤៤% (ក្រាហ្វិកទី១០)។ ទិន្នផលមធ្យមមានចំនួន១ ១៩៤គ.ក្រ./ហ.ត. បើធៀបនឹងឆ្នាំ២០១៩ ដែលមានចំនួន១ ១៤៨គ.ក្រ./ហ.ត. គឺកើនឡើងចំនួន៤៦គ.ក្រ./ហ.ត. ស្មើនឹង៤%។

**ក្រាហ្វិកទី១០៖** ផ្ទៃដីកៅស៊ូចៀរជ័រ ថែទាំ និងសរុប ឆ្នាំ២០១៦-២០២០




## ២. ការងារធុរកិច្ចកៅស៊ូ

ការនាំចេញកៅស៊ូឆ្នាំ២០២០ ប៉ាន់ស្មានចំនួនប្រមាណ ៣៣៨ ៣០០តោន ស្មើនឹងទឹកប្រាក់ប្រមាណ ៤៥៦,៧០៥លានដុល្លារអាមេរិក បើធៀបនឹងឆ្នាំ២០១៩ ដែលការនាំចេញមានចំនួន២៨២ ០៧១តោន គិតជាទឹកប្រាក់សរុប៣៧៦,៩៤លានដុល្លារអាមេរិក គឺបរិមាណនាំចេញកើនឡើងប្រមាណ៥៦ ២២៩តោន ស្មើនឹង ១៩,៩៣% និងប្រាក់ចំណូលកើនប្រមាណ៧៩,៧៦លានដុល្លារអាមេរិក ស្មើនឹង២១,១៦%។ តម្លៃកៅស៊ូនាំចេញប៉ាន់ស្មាន

ជាមធ្យមថ្លៃ១ ៣៥០ដុល្លារអាមេរិកក្នុងមួយតោន បើធៀបនឹងឆ្នាំ២០១៩ដែលតម្លៃមធ្យមស្មើនឹង ១ ៣៣៦ដុល្លារអាមេរិកក្នុងមួយតោន ឃើញថាមានការកើនឡើងចំនួន១៤ដុល្លារអាមេរិកក្នុងមួយតោន ស្មើនឹង ១,០៤%។

នៅក្នុងឆ្នាំ២០២០ ការនាំចេញឈើកៅស៊ូពីការកាប់ដើមកៅស៊ូចាស់ៗចំនួន១៥៨ ៤០០ម៉ែត្រគូប ទទួលបាន ទឹកប្រាក់ចំនួន២៣,៧៦លានដុល្លារអាមេរិក។

**ក្រាហ្វិកទី១១៖ ផលិតកម្មនិងការនាំចេញកៅស៊ូក្នុងឆ្នាំ២០១៦ - ២០២០**




ក្នុងឆ្នាំ២០២០នេះ រោងចក្រ សិប្បកម្មកែច្នៃផលិតផលកៅស៊ូមានសរុបចំនួន១៦០កន្លែង ក្នុងខេត្តចំនួន១១ (កំពង់ចាម ត្បូងឃ្មុំ កំពង់ធំ មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង រតនគិរី ឧត្តរមានជ័យ ព្រះវិហារ ព្រះសីហនុ និងប៉ៃលិន) កើនឡើងចំនួន៦កន្លែង ស្មើនឹង៣,៩០% បើប្រៀបធៀបទៅនឹងឆ្នាំ២០១៩ ដែលមានតែ១៥៤កន្លែង។ ក្នុងចំណោម រោងចក្រ សិប្បកម្មចំនួន១៦០កន្លែង មានរោងចក្រកែច្នៃកៅស៊ូបញ្ជាក់តាមលក្ខណៈបច្ចេកទេស (Technically Specified Rubber: TSR) ចំនួន៤៦កន្លែង រោងចក្រកែច្នៃទឹកជ័រខាប់ (Concentrated Latex) ចំនួន១កន្លែង សិប្បកម្មកែច្នៃ កៅស៊ូសន្លឹក៖ សិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយផ្សែង (Ribbed Smoked Sheet: RSS) និង សិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយខ្យល់ក្តៅ (Air-Dried Sheet: ADS) ចំនួន៩៦កន្លែង និងរោងចក្រកែច្នៃឈើកៅស៊ូ (Rubber Wood Factory: RWF) ចំនួន១៧កន្លែង។

**ក្រាហ្វិកទី១២៖** រោងចក្រ សិប្បកម្មកែច្នៃជ័រនិងឈើកៅស៊ូ ២០១៦-២០២០



**៣. ការងារផែនការ ហិរញ្ញវត្ថុ**

ការប្រមូលចំណូលរបស់អគ្គនាយកដ្ឋានកៅស៊ូឆ្នាំ២០២០ អនុវត្តបានចំនួន៨៩២ ៨២៧ ៦១៣រៀល (២១៣ ៩៦៩,៤៨ដុល្លារអាមេរិក) ក្នុងនោះរួមមាន៖ ការជួលដីក្រុមហ៊ុនទាំង០៧មានចំនួន៧៧១ ៧៤៧ ៥៦៦រៀល (១៨៩ ៣៣៨,៥៣ដុល្លារអាមេរិក), ប្រាក់ពិន័យមានចំនួន៥ ៩៩៤ ១៨៤រៀល (១ ៤៧៨,៩៥ដុល្លារអាមេរិក), និងការជួលអចលនវត្ថុ (អសង្ហារិម) ក្រុមហ៊ុននីហរ័ណ អាហរ័ណកៅស៊ូមានចំនួន៩៤ ៤១៣ ៨៥៦រៀល (២៣ ១៥២ដុល្លារអាមេរិក)។ បើធៀបនឹង គោលដៅចំនួន១ ៥៦៦ ០០០ ០០០រៀល(៣៨៦ ៦៨៨,១០ដុល្លារអាមេរិក) មានការថយចុះចំនួន៦៧៣ ១៧២ ៣៨៧រៀល ស្មើនឹង៤២,៩%។ ការថយចុះនេះដោយសារឆ្នាំនេះចម្ការកៅស៊ូ ចម្ការអណ្ដូង ចម្ការកៅស៊ូពាមជាំង ចម្ការកៅស៊ូបឹងកេត និងចម្ការកៅស៊ូឡាបានសៀក ពុំទាន់បង់ប្រាក់ឈ្នួលឆ្នាំ២០២០ ដែលមានចំនួន ៦៥៩ ២០០ ០០០រៀល។

**៤. ការងារផ្សព្វផ្សាយនិងបណ្ដុះបណ្ដាល**

ចុះបើកវគ្គបណ្ដុះបណ្ដាលបច្ចេកទេសដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារនៅតាមខេត្តគោលដៅ ចំនួន ០៤ គឺខេត្តកំពង់ចាម ស្ទឹងត្រែង ក្រចេះ និងខេត្តប៉ៃលិន ដោយមានកសិករចូលរួមសរុប ២៤០ នាក់ ក្នុងនោះ ស្រី៥៨ នាក់។ បានចងក្រងបង្កើតសហគមន៍កសិកម្មកៅស៊ូគ្រួសារនៅខេត្តគោលដៅចំនួន០១សហគមន៍ ស្ថិតនៅក្នុងស្រុកអូរយ៉ាដាវ ខេត្តរតនគិរី។ បានចុះពង្រឹងសហគមន៍កសិកម្មកៅស៊ូគ្រួសារបានចំនួន០៧សហគមន៍ ដែលស្ថិតនៅក្នុងខេត្តក្រចេះ ត្បូងឃ្មុំ បាត់ដំបង ប៉ៃលិន មណ្ឌលគិរី សៀមរាប និងខេត្តឧត្តរមានជ័យ។ បានបើកសិក្ខាសាលាស្ដីពី ការផ្ទេរបច្ចេកវិទ្យាដំណាំកៅស៊ូ ដល់មន្ត្រីបង្គោលមកពីការិយាល័យកៅស៊ូ តាមបណ្ដាខេត្តចំនួន២១ខេត្ត ចំនួន០១វគ្គ មានសិក្ខាកាមសរុបចំនួន៤៣នាក់ ស្រី០៧នាក់ចូលរួម។ បានចុះបើកវគ្គផ្សព្វផ្សាយ និងបណ្ដុះបណ្ដាលបច្ចេកទេសកែច្នៃដល់ប្រតិបត្តិករកៅស៊ូចំនួន៦វគ្គ នៅខេត្តគោលដៅចំនួន៥ គឺខេត្តមណ្ឌលគិរី ត្បូងឃ្មុំ កំពង់ចាម ស្ទឹងត្រែង និង ខេត្តកំពង់ធំ ដែលមានប្រតិបត្តិករកៅស៊ូ ចូលរួម សរុបចំនួន៣៣៧នាក់។ បានចុះបើកវគ្គបណ្ដុះបណ្ដាលស្ដីពីស្ថានភាពឧស្សាហកម្មកៅស៊ូធម្មជាតិពិភពលោកដល់មន្ត្រីរាជការ ចំនួន០២វគ្គ នៅខេត្តកំពង់ចាមដោយមានអ្នកចូលរួមសរុបចំនួន៦១នាក់។ បានបើកវគ្គបណ្ដុះបណ្ដាលសមត្ថភាពជំនាញដល់មន្ត្រីរាជការលើប្រធានបទការគ្រប់គ្រងមន្ត្រីរាជការចំនួន០១លើក ដោយមានអ្នកចូលរួមសរុប៤៥នាក់។ បានរៀបចំវគ្គបណ្ដុះបណ្ដាលនិងផ្សព្វផ្សាយអំពី "ទីផ្សារកៅស៊ូដល់សហគមន៍កៅស៊ូគ្រួសារ " បានចំនួន៤វគ្គ នៅខេត្តគោលដៅចំនួន៤ គឺខេត្តស្ទឹងត្រែង មណ្ឌលគិរី ត្បូងឃ្មុំ និងខេត្តកំពង់ចាម ដែលមានសិក្ខាកាមចូលរួមសរុប ១៧២នាក់។ បានចុះផ្សព្វផ្សាយបច្ចេកទេសកៅស៊ូដល់កសិករកៅស៊ូគ្រួសារ ចំនួន៥៥នាក់ នៅស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្ដីពី "ការផ្ទេរបច្ចេកវិទ្យាកៅស៊ូដល់ប្រតិបត្តិករកៅស៊ូ និងកៅស៊ូគ្រួសារ" ដែលមានអ្នកចូលរួមចំនួន១២៤នាក់ នៅខេត្តកំពង់ចាម។ បានបណ្ដុះបណ្ដាលធនធានមនុស្ស និងផ្ទេរនូវបច្ចេកវិទ្យាតាមរយៈការសម្របសម្រួលទស្សនកិច្ចសិក្សា ដឹកនាំសរសេរសារណាបញ្ចប់ការ សិក្សារបស់និស្សិតចំនួន០៣នាក់ និងបានបញ្ជូនមន្ត្រីចំនួន ៦នាក់ ទៅបង្រៀននិស្សិតនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម។ បានចុះបើកវគ្គផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធនឹងផ្នែកកៅស៊ូ នៅស្រុកគោលដៅចំនួន០៥ ក្នុងខេត្តរតនគិរី កោះកុង ឧត្តរមានជ័យ បាត់ដំបង និងខេត្តស្ទឹងត្រែង ដោយមានប្រតិបត្តិករកៅស៊ូចូលរួមសរុប២៥០នាក់។ បានផ្សាយតម្លៃកៅស៊ូប្រចាំសប្ដាហ៍តាមប៉ុស្ដិ៍វិទ្យុមណ្ឌលព័ត៌មានស្ត្រីកម្ពុជា (FM103.5) នឹងបន្តផ្ទាល់ទៅតាមបណ្ដាខេត្តចំនួន៤ ខេត្តបាត់ដំបង FM106.3 ខេត្តកំពង់ចាម FM99.3 ខេត្តកំពង់ធំ FM104 និងខេត្តសៀមរាប FM107 បានចំនួន២៤ដង (គ្រោង៤៨ដង/ឆ្នាំ) ដើម្បីឱ្យកសិករកៅស៊ូគ្រួសារ និងប្រតិបត្តិករកៅស៊ូក្ដាប់បានពីតម្លៃកៅស៊ូលើទីផ្សារ តាមតំបន់ក្នុងប្រទេស និងក្រៅប្រទេស។ បោះពុម្ពព្រឹត្តិបត្រកៅស៊ូធម្មជាតិប្រចាំខែបានចំនួន២ ១៦០ច្បាប់ សម្រាប់ចែកជូនកសិករកៅស៊ូគ្រួសារ និងអ្នកពាក់ព័ន្ធក្នុងគោលបំណងផ្សព្វផ្សាយចំណេះដឹងបន្ថែមអំពីអនុវិស័យកៅស៊ូ។ បានរៀបចំបង្កើតគេហទំព័រអគ្គនាយកដ្ឋានកៅស៊ូ (gdr1.maff.gov.kh) សំដៅ

ផ្សព្វផ្សាយ ព័ត៌មានកៅស៊ូឲ្យបានទូលំទូលាយដល់គ្រប់ភាគីពាក់ព័ន្ធ ជាពិសេសប្រតិបត្តិករកៅស៊ូ។ បានបញ្ជូនមន្ត្រីជំនាញចំនួន ០១នាក់ ទៅចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពី "ការធ្វើអង្កេតចន្លោះ ជំរឿនកសិកម្មកម្ពុជាឆ្នាំ ២០២០" ។

### ៤. ការងារពិសោធន៍ស្រាវជ្រាវកៅស៊ូ

ឆ្នាំ២០២០នេះ ក្រសួងបានអនុវត្តនិងបន្តការងារស្រាវជ្រាវ និងតាមដានទិន្នន័យចម្ការពិសោធន៍ទាំងនៅក្នុងស្ថានីយ ទាំងនៅតាមបណ្តាក្រុមហ៊ុនចម្ការកៅស៊ូ ដែលសរុបមាន៦២ពិសោធន៍។ ទន្ទឹមគ្នានឹងការស្រាវជ្រាវ ក្រសួងបានបណ្តុះបណ្តាលធនធានមនុស្ស ដោយបានផ្ទេរបច្ចេកវិទ្យាដល់ប្រតិបត្តិករកៅស៊ូ ព្រមជាមួយគ្នានោះ បានបណ្តុះបណ្តាលនូវធនធានមនុស្សតាមរយៈការបង្ហាត់បង្រៀននិស្សិតនៅតាមគ្រឹះស្ថានសិក្សា និងការសម្របសម្រួលឱ្យនិស្សិតធ្វើទស្សនកិច្ចសិក្សា ចម្ការពិសោធន៍ និងការដឹកនាំសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររបស់និស្សិតមកពីគ្រឹះស្ថានបណ្តុះបណ្តាលមួយចំនួនដើម្បីបន្តវេនក្នុងការអភិវឌ្ឍដំណាំកៅស៊ូនាអនាគត។

**ក. ការងារស្រាវជ្រាវផ្នែកក្សេត្រសាស្ត្រ៖**

- ការងារដាំដុះនិងការពារ៖ បានតាមដាន ស្រង់និងបញ្ចូលទិន្នន័យចម្ការពិសោធន៍លើផ្ទៃដី ៦០,៦៨ហិកតា អនុវត្តការងារបំបៅ កូនកៅស៊ូសម្រាប់ដាំដុះឆ្នាំ២០២០និងដាំជួសកៅស៊ូដាំឆ្នាំ២០១៩។ បានរៀបចំថ្នាលបណ្តុះកូនកៅស៊ូ ឆ្នាំ២០២០ លើផ្ទៃដី០,៣៥ហិកតា អនុវត្តការថែទាំដំណាំគ្របដីចំនួន ៣ប្រភេទ (*Stylosanthes guianesis, Mucuna aterrinum, Puraria phaseoloides*)។ បានដាក់ជីបំប៉នលើកូនកៅស៊ូមិនទាន់ផ្តល់ផលចំនួន២លើក លើផ្ទៃដី ៦៩ហិកតា និងចម្ការពិសោធន៍ ជីលើកៅស៊ូផ្តល់ផលចំនួន៤ចម្ការ។ បានថែទាំគ្រប់ចម្ការពិសោធន៍ ព្រមទាំង បាញ់ថ្នាំការពារ និងព្យាបាល ជំងឺផ្កាកុលាបនៅតាមប្រគៀបមែកកៅស៊ូចាប់ពីអាយុ៣-១០ឆ្នាំបានចំនួន២លើក លើផ្ទៃដី ២១២ហិកតា។ បានថែទាំដំណាំចន្លោះរងកៅស៊ូចំនួន៥ប្រភេទ ចេក ខ្នុរ ស្វាយ ម្នាស់ និងស្វាយចន្ទី។ បានរៀបចំប្រព័ន្ធស្រោចស្រពឡើងវិញ និងស្រោចជាប្រចាំលើចម្ការពិសោធន៍ឥទ្ធិពលនៃការស្រោចស្រព លើការលូតលាស់ និងទិន្នផលកៅស៊ូលើផ្ទៃដី ៦,២៥ហិកតា

- ការងារស្រាវជ្រាវអំពីការបង្កាត់ពូជ៖ បានតាមដាន ស្រង់និងបញ្ចូលទិន្នន័យចម្ការពិសោធន៍ក្នុង និងក្រៅស្ថានីយ បានចំនួន១៧ចម្ការពិសោធន៍ (ទំហំដើមកៅស៊ូ ទិន្នផលជ័រ មាឌឈើ និងជំងឺប្រផេះស Oidium) អនុវត្តការថែទាំច្បារពូជកៅស៊ូ ទំហំ ៨,៦០ហិកតា សម្រាប់បម្រើដល់ការពិសោធស្រាវជ្រាវ។ បានចុះអង្កេតការជ្រុះស្លឹក និងចេញផ្កានៅច្បារបង្កាត់ពូជលើក្លូនកៅស៊ូចំនួន១៦។ ដាំដុះកូនកៅស៊ូបំបៅរួចដែលទទួលបានក្លូនមកពីក្រុមហ៊ុន SOCFIN-KCD និង CATAS នៅក្នុងច្បារពូជ Collection សរុបបានចំនួន ១៧ក្លូន។ ដាក់ជីចំនួន២លើកនៅចម្ការពិសោធន៍ GSET02 និងច្បារបង្កាត់ពូជ និងរៀបចំតេស្តចៀរជ័រពិសោធន៍នៅចម្ការ GSET02

- សកម្មភាពស្រាវជ្រាវលើសរីរសាស្ត្រនិងការប្រមូលផលទឹកជ័រ៖ បានតាមដាន ស្រង់ បញ្ចូលទិន្នន័យគ្រប់ចម្ការពិសោធន៍នៅក្នុងស្ថានីយចំនួន១៣និងក្រៅស្ថានីយចំនួន១ (ទំហំដើម ទិន្នផល និងជំងឺស្ងួតមុខចៀរTPD)។ យកសំណាក និងវិភាគសរីរទឹកជ័រ (LD ពីចម្ការពិសោធន៍នានាក្នុងនិងក្រៅស្ថានីយបានចំនួន២៩ចម្ការពិសោធន៍ ស្មើនឹង ១ ២៨០សំណាក។

**ខ.ការងារផ្នែកមន្ទីរពិសោធន៍ជាតិយថាប្រភេទ៖**

បានបណ្តុះបណ្តាលការងារមន្ទីរពិសោធន៍ដល់មន្ត្រីកិច្ចសន្យា។ បានធ្វើតេស្ត និងបានចេញលទ្ធផលតេស្តជូនរោងចក្រកៅស៊ូសន្លឹករបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ចំនួន០៩ដង។ បានធ្វើតេស្ត និងបានចេញលទ្ធផលតេស្តជូនក្រុមហ៊ុន SOCFIN KCD CO., LTD បានចំនួន៦០សំណាក។ បានផ្សព្វផ្សាយសារាចរណែនាំស្តីពីការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ បានចំនួន១០រោងចក្រ។ បានជូនដំណឹងស្តីពី សំណើសុំចូលរួមធ្វើតេស្តប្រៀបធៀបមន្ទីរពិសោធន៍ក្នុងស្រុក (Parallel Tests) សម្រាប់ឆ្នាំ២០២០ ជូនដល់បណ្តាក្រុមហ៊ុន រោងចក្របានចំនួន១១

និងមន្ទីរពិសោធន៍មូលដ្ឋានចំនួន៥ ដែលបានចុះបញ្ជិកាជាមួយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។ បានចុះពិនិត្យ និងវាយតម្លៃរោងចក្រកែច្នៃកៅស៊ូតានបៀន កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ ខូអិលធីឌី និងបានចុះបញ្ជិកាជូនរោងចក្រ។ រៀបចំពិសោធន៍លើការប្រើប្រាស់អាស៊ីត៣ប្រភេទខុសគ្នា(អាស៊ីតស៊ុលផួរិក អាស៊ីតហ្វ័រមិក និងម្សៅ អាស៊ីត) លើទឹកជ័រកៅស៊ូក្លូន GT 1 និង PB 217 និងបានទទួលលទ្ធផលបឋមអំពីការប្រើសាជូរខៀវបង្កកទឹកជ័រ។ អនុវត្តការងារមន្ទីរពិសោធន៍ជាតិយថាប្រភេទតាមប្រព័ន្ធគ្រប់គ្រងគុណភាព ISO/IEC 17025: 2017។ ធ្វើតេស្តប្រៀបធៀបមន្ទីរពិសោធន៍ក្នុងស្រុក បានចំនួន៣០២សំណាក។ ចុះពិនិត្យនិងវាយតម្លៃរោងចក្រកែច្នៃកៅស៊ូ ដែលបានស្នើសុំចុះបញ្ជិកានិងចុះបញ្ជិកាជាថ្មី បានចំនួន៤ រោងចក្រ និងមន្ទីរពិសោធន៍ចំនួន១។

**គ. ការរៀបចំលិខិតបទដ្ឋានគតិយុត្តផ្នែកកៅស៊ូ**

បានពិនិត្យ កែសម្រួលឡើងវិញសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ ស្របតាមការណែនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ សេចក្តីព្រាងច្បាប់នេះ មានគោលបំណងធានាការគ្រប់គ្រង ការស្រាវជ្រាវ និងការអភិវឌ្ឍធានានិរន្តរភាពផលិតកម្មកៅស៊ូ ដើម្បីទទួលបានប្រសិទ្ធភាពខ្ពស់ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ការលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ និងរួមចំណែករក្សានិរន្តរភាពបរិស្ថានធម្មជាតិ។ បញ្ចប់សេចក្តីព្រាងសារាចរណែនាំស្តីពីវិធានការទប់ស្កាត់ការនាំចេញជ័រកៅស៊ូនិងឈើកៅស៊ូមិនទាន់កែច្នៃទៅបរទេស។ បញ្ចប់សេចក្តីព្រាងប្រកាសស្តីពីនីតិវិធីនៃការស្នើសុំបង្កើតរោងចក្រសិប្បកម្មកែច្នៃកៅស៊ូ និងឈើកៅស៊ូ។

**ឃ. ការងារសហប្រតិបត្តិការអន្តរជាតិ**

**ឃ.១ សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ (ANRPC)**

ឆ្នាំ២០២០នេះ ប្រទេសកម្ពុជាបានចូលរួមក្នុងព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំរបស់ ANRPC តាមអនឡាញ រួមមាន៖ (១.) កិច្ចប្រជុំ "ក្រុមការងារលើកទី២ ផ្នែកនិរន្តរភាពកៅស៊ូធម្មជាតិ" នៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២០ ក្នុងគោលបំណងដើម្បីអនុម័តលើលក្ខខណ្ឌយោង(TOR) ផ្អែកលើទស្សនៈដែលទទួលបានពីប្រទេសជាសមាជិកនិងពិភាក្សាបន្ថែម និងកំណត់ផែនការសកម្មភាពនិងកាលបរិច្ឆេទគោលដៅសម្រាប់ក្រុមការងារ។ (២.) កិច្ចប្រជុំលើកទី៧ "ក្រុមអ្នកជំនាញផ្នែកស្ថិរភាពថ្លៃកៅស៊ូធម្មជាតិ" នៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២០ ដោយផ្តោតទៅលើផលប៉ះពាល់នៃជំងឺ Covid-19 ទៅលើតម្រូវការនិងការផ្គត់ផ្គង់ ការធ្លាក់ចុះនៃការប្រើប្រាស់កៅស៊ូធម្មជាតិនៅក្នុងឧស្សាហកម្ម ស្រោមដៃ និងបញ្ហាទាក់ទងនឹងការផ្គត់ផ្គង់រយៈពេលវែង។

**ឃ.២ ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ** (IRRDB: International Rubber Research and Development Board ) បន្តចូលរួមកិច្ចប្រជុំតាមអនឡាញ ជាមួយក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ។

**ឃ.៣ ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ** (AFD: Agence Française de Développement)

បានចុះសម្របសម្រួលជំនួបប្រជុំពិភាក្សាការងារ រវាងទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ(AFD) ជាមួយសហគមន៍កៅស៊ូគ្រួសារ នៅស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ បានចូលរួមប្រជុំគម្រោង Rainfed Agriculture Technology Development Program for Cambodia (RAD4CAM) ដែលគម្រោងនេះត្រូវបានផ្តួចផ្តើមឡើងដោយទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD)។ បានចូលរួមប្រជុំជាមួយក្រុមហ៊ុនARTE-FACT Development & Agri Food cusulting Co., LTD ដែលបានចុះសិក្សាភាពអាចធ្វើបាន (Pre-Feasibilties study) គម្រោង RAD4CAM។

**ឃ.៤ កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយមជ្ឈមណ្ឌល CIRAD-បារាំង**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបញ្ជូនលិខិតគាំទ្រការទទួលយកនៃការរៀបចំគម្រោងស្តីពី " អនាគតនៃផលិតកម្មកៅស៊ូធម្មជាតិនៅអាស៊ីអាគ្នេយ៍ ផ្តោតលើកម្លាំងពលកម្មនិងការប្រែប្រួលអាកាសធាតុ "។

**ឃ.៥ កិច្ចសហប្រតិបត្តិការជាមួយក្រសួងកសិកម្មនៃសាធារណរដ្ឋប្រជាមានិតចិន**

បានចូលរួមពិភាក្សាជាមួយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូ នៃបណ្ឌិតសភាវិទ្យាសាស្ត្រកសិកម្មត្រូពិកចិន (CATAS) ក្នុងគោលបំណងដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការលើការងារស្រាវជ្រាវកៅស៊ូរួមគ្នា។ ក្រុមការងារ CATAS និង CRRI ក៏បានឯកភាពរួមគ្នាសិក្សាអង្កេតអំពី ការប្រើប្រាស់ក្លូនកៅស៊ូក្នុងការដាំដុះ ការប្រើប្រាស់ជីលើដំណាំកៅស៊ូ និងការចៀរយកផលកៅស៊ូនៅតាមបណ្តាក្រុមហ៊ុនចម្ការកៅស៊ូ និងចម្ការកៅស៊ូគ្រួសារ នៅក្នុងខេត្តក្រចេះ ស្ទឹងត្រែង រតនគិរី កំពង់ធំ ព្រះវិហារ និងខេត្តសៀមរាប។

**ឃ.៦ កិច្ចសហប្រតិបត្តិការតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា ឡាវ វៀតណាម**

បានប្រជុំពិនិត្យឡើងវិញ និងពិភាក្សាកែតម្រូវលើរបាយការណ៍ផែនការ អភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូនៅតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម ដែលភាគីកម្ពុជាបានស្នើឲ្យភាគីវៀតណាមធ្វើការកែតម្រូវតួលេខ អត្ថន័យ និងធ្វើបច្ចុប្បន្នភាពទិន្នន័យមួយចំនួនដល់ឆ្នាំ២០២០។ ភាគីវៀតណាមក៏បានផ្ញើរបាយការណ៍ CLV DTA ដែលបានកែតម្រូវតួលេខ និងធ្វើបច្ចុប្បន្នភាពទិន្នន័យមួយចំនួន ដើម្បីឲ្យភាគីកម្ពុជាពិនិត្យឡើងវិញ។ បានប្រជុំពិនិត្យនិងពិភាក្សារបាយការណ៍ CLV DTA លើចំណុចនានាដែលបានស្នើឱ្យភាគីវៀតណាម ធ្វើបច្ចុប្បន្នភាពនិងបានឯកភាពលើរបាយការណ៍ចុងក្រោយ និងបានបញ្ជូនទៅនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីមានវិធានការបន្ត។ បានបញ្ចប់ការបកប្រែរបាយការណ៍ CLV DTA និងបញ្ជូនទៅលេខាធិការដ្ឋាន CLV នៅក្រសួងពាណិជ្ជកម្ម ដើម្បីត្រៀមសម្រាប់កិច្ចប្រជុំកំពូល CLV DTA លើកទី១១ នៅប្រទេសឡាវ។ បានបញ្ចូលសមាគមអភិវឌ្ឍន៍កៅស៊ូកម្ពុជា ចូលជាសមាជិកពេញសិទ្ធិនៃសមាគមកៅស៊ូអន្តរជាតិ (International Rubber Association: IRA) និងក្រុមប្រឹក្សាធុរកិច្ចកៅស៊ូអាស៊ាន (Asian Rubber Buiness Council: ARBC) ។

**ឃ.៧ កិច្ចសហប្រតិបត្តិការជាមួយអង្គការមូលនិធិសកលសម្រាប់ធម្មជាតិ (World Wide Fund for Nature: WWF)**

បានរៀបចំកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងអនុស្សរណៈយោគយល់គ្នារវាងអគ្គនាយកដ្ឋានកៅស៊ូ និងអង្គការ WWF។ បានចុះបើកវគ្គផ្សព្វផ្សាយបច្ចេកទេសដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារ និងចុះពង្រឹងសហគមន៍កសិកម្មកៅស៊ូគ្រួសារស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី។ បានចុះសិក្សាពីលក្ខណសម្បត្តិ (Profile) ចម្ការកៅស៊ូគ្រួសារ នៅខេត្តមណ្ឌលគិរី។ បានចុះសិក្សានិងកំណត់ទីតាំងផែនទីចម្ការកៅស៊ូគ្រួសាររបស់សហគមន៍កសិកម្ម កៅស៊ូគ្រួសារ នៅស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី។ បានចុះរៀបចំចម្ការបង្ហាញអំពីការអនុវត្តកសិកម្មល្អ (GAP) លើការប្រមូលផលទឹកជ័រ និងចម្ការបង្ហាញ អំពីការកែលម្អបច្ចេកទេសលើការប្រមូលផលទឹកជ័ររបស់កៅស៊ូគ្រួសារ នៅខេត្តមណ្ឌលគិរី។

**ឃ.៨ កិច្ចសហប្រតិបត្តិការជាមួយអង្គការ OXFAM**

បានប្រជុំជាមួយអង្គការ OXFAM និងចុះសម្របសម្រួលជំនួបប្រជុំរវាងក្រុមការងារអគ្គនាយកដ្ឋានកៅស៊ូ អង្គការ OXFAM និងក្រុមហ៊ុនចំនួន០៨ នៅខេត្តមណ្ឌលគិរី ក្រចេះ ឧត្តរមានជ័យ និងខេត្តកំពង់ធំ ដូចជា៖ ១) ក្រុមហ៊ុន ដាក់ ឡាក់ អភិវឌ្ឍន៍កៅស៊ូ ខូអិលធីឌី ២)ក្រុមហ៊ុនធី ឌី ស៊ី ៣)សម្ព័ន្ធក្រុមហ៊ុន ផេស៊ីហ្វិកភើលយ៉ញស្តុក ខមភេនី លីមីធីត ៤)ក្រុមហ៊ុន ឈុន ហុង រ៉ាប់ប៊ើរបេតធើរខូអិលធីឌី ៥) ក្រុមហ៊ុនតៃនិញ សៀមរាប អភិវឌ្ឍន៍ កៅស៊ូ ខូ អិលធីឌី ៦)ក្រុមហ៊ុនសំរោងរ៉ាប់ប៊ើរ អ៊ិនដាស ស្ទ្រៀលភីធីអ៊ី អិលធីឌី ៧)ក្រុមហ៊ុនបៀន ហៀក អិនវេសមេន ខូ អិលធីឌី និង៨) ក្រុមហ៊ុនសម្បត្តិ ផ្លេធីណឹម ខូ អិលធីឌី។

## ២. ការលើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ

ផលិតកម្មសត្វមានសក្តានុពលក្នុងការរួមចំណែកបង្កើតការងារ សន្តិសុខស្បៀង អាហារូបត្ថម្ភ កំណើនសេដ្ឋកិច្ច និងចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ។ អនុវិស័យនេះជាផ្នែកមួយសំខាន់សម្រាប់ទ្រទ្រង់ដល់វិស័យកសិកម្ម និងសេដ្ឋកិច្ចជាតិ។ ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ បានដាក់បញ្ចូលវិស័យកសិកម្មក្នុងចតុកោណទី៤ មុំទី ១ ចំណុចអាទិភាពទី៧ ចែងពីការជំរុញការចិញ្ចឹមសត្វ និងវារីវប្បកម្ម ដើម្បីលើកកម្ពស់ការចិញ្ចឹមសត្វឱ្យកាន់តែទូលំទូលាយថែមទៀត តាមរយៈការបង្កើតក្របខ័ណ្ឌគោលនយោបាយផ្អែកលើខ្សែច្រវ៉ាក់តម្លៃ និងដោះស្រាយជាកញ្ចប់

នូវបញ្ហាជាឧបសគ្គដល់ការអភិវឌ្ឍអនុវិស័យនេះ ជាមួយនឹងការគិតគូរដល់បញ្ហាសុវត្ថិភាពចំណីអាហារ និងកិច្ចដំណើរការប្រកួតប្រជែងទីផ្សារ ពិសេសការបន្ថយថ្លៃដើមផលិត និងអនាម័យសាច់។

ក្នុងឆ្នាំ២០២០ ផលិតកម្មសត្វមានការកើនឡើង ជាពិសេសការចិញ្ចឹមសត្វសម្រាប់ឧស្សាហកម្ម។ ជាក់ស្តែងសត្វចិញ្ចឹមសរុបបានកើនដល់៥៣,៩០លានក្បាល គឺកើនលើសឆ្នាំ២០១៩ ចំនួន១៧,៦% ដែលធ្វើឱ្យកម្ពុជាមានសមត្ថភាពផលិតសាច់សម្រាប់បម្រើតម្រូវការក្នុងស្រុកបានប្រមាណជាង២៥៦ពាន់តោន ឬស្មើនឹង៨៥% នៃតម្រូវការសាច់សរុបប្រមាណ៣០១ពាន់តោនក្នុងមួយឆ្នាំ។

ទន្ទឹមនឹងនេះ ក៏មានការត្រៀមលក្ខណៈបានល្អ និងយកចិត្តទុកដាក់ខ្ពស់លើការងារអង្កេតតាមដាន ស្រាវជ្រាវប្រភពចម្លងជំងឺ និងមានប្រព័ន្ធរាយការណ៍ស្ថានភាពសុខភាពសត្វជាប្រចាំ ក្នុងករណីមានផ្ទុះជំងឺឆ្លងត្រូវបានរកឃើញដោយត្រូវរាយការណ៍ឱ្យបានឆាប់រហ័ស និងបានចាត់វិធានការឆ្លើយតបទាន់ពេលវេលា។

## ២.១. លទ្ធផលនៃការជំរុញផលិតកម្មសត្វ

### ២.១.១ ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ

ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារសរុបក្នុងឆ្នាំ២០២០ មានចំនួន៣៤,៩៨លានក្បាល ក្នុងនោះមានគោចំនួន២,៨៣លានក្បាល ក្របីចំនួន៤២៤ពាន់ក្បាល ជ្រូកចំនួន១,១៤លានក្បាល បក្សីចំនួន៣០,៥៥លានក្បាល សេះចំនួន៣ពាន់ក្បាល ចៀមចំនួន៩៤៤ក្បាល ពពែចំនួន៣០ពាន់ក្បាល និងជ្រូវចំនួន៥១ក្បាល។

បើប្រៀបធៀបឆ្នាំ២០១៩ ស្ថិតិសត្វសរុបកើនឡើងចំនួន៩,២% ក្នុងនោះគោ ក្របីកើនចំនួន១,៣% ជ្រូកកើនចំនួន១០,៣% និងបក្សីកើនចំនួន១០,០%។




**តារាងស្ថិតិផលិតកម្មសត្វ លក្ខណៈគ្រួសារពីឆ្នាំ២០១៦-២០២០**

| ល.រ | ប្រភេទសត្វ | ស្ថិតិសត្វ ៥ឆ្នាំចុងក្រោយ (២០១៦-២០២០) | | | | | ប្រៀបធៀប |
|---|---|---|---|---|---|---|---|
| | | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | (២០១៩&២០២០) |
| ១ | គោ | ២ ៨៩៧ ១២៦ | ២ ៩៥១ ៣៥៩ | ២ ៩១៧ ៣០២ | ២ ៧៦៩ ៨៨៥ | ២ ៨៣៥ ៣៦០ | ២,៤% |
| ២ | ក្របី | ៥២៣ ៣២០ | ៥០៨ ៤៥៨ | ៥០០ ៧៧៨ | ៤៤៧ ១៦៧ | ៤២៣ ៦១៤ | -៥,៣% |
| ៣ | គោ ក្របី | ៣ ៤២០ ៤៤៦ | ៣ ៤៥៩ ៨១៧ | ៣ ៤១៨ ០៨០ | ៣ ២១៧ ០៥២ | ៣ ២៥៨ ៩៧៤ | ១,៣% |
| ៤ | កម្លាំងអូសទាញ | ១ ០៥១ ៦២៥ | ៩៣៥ ២៣៩ | ៨៣៦ ៣០១ | ៧១៧ ៩០២ | ៦៤៨ ៧២៩ | -៩,៦% |
| ៥ | ជ្រូក | ២ ៣៧១ ២៨៣ | ២ ៣៣១ ៥១២ | ១ ៩៣៤ ៩១៧ | ១ ០៣០ ៤៩៤ | ១ ១៣៧ ០៥៦ | ១០,៣% |
| ៦ | បក្សី | ២៨ ៤០២ ៤៨៦ | ២៨ ៦៥២ ៤០៩ | ២៨ ៩៥៦ ៣៤២ | ២៧ ៧៦៣ ៤៧៩ | ៣ ០៥៥៣ ២៣៣ | ១០,០% |
| ៧ | សេះ | ៥ ៦១០ | ៥ ០៥៥ | ៤ ២០៧ | ៣ ៧៧១ | ២ ៩៧១ | -២១,២% |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៨ | ចៀម | ៤០០ | ៤៦១ | ៤៥៩ | ៦៤៨ | ៩៤៤ | ៤៥,៧% |
| ៩ | ពពែ | ២២ ៧១៩ | ២៨ ៥៤២ | ២៥ ៧៤៧ | ២៧ ៧៤០ | ២៩ ៩៨១ | ៨,១% |
| ១០ | ដំរី | ៦៣ | ៦៣ | ៥៨ | ១៨ | ៥១ | ១៨៣,៣% |
| ១១ | ស្វា | | | | ១៤៨ | ២១៩ | ៤៨,០% |
| ១២ | ទន្សាយ | | | | ១៨៥ | ៣១១ | ៦៨,១% |
| សរុប | | ៣៤ ២២៣ ០០៧ | ៣៤ ៤៧៧ ៨៥៥ | ៣៤ ៣៣៩ ៨១០ | ៣២ ០៤៣ ៥៣៥ | ៣៤ ៩៨៣ ៧៤០ | ៩,២% |

## ២.១.២. ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្ម

សត្វចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្មសរុបក្នុងឆ្នាំ២០២០ សរុបមានចំនួន១៨,៩២លានក្បាល ក្នុងនោះគោ ក្របីចំនួន១៣,៤២ពាន់ក្បាល ជ្រូកចំនួន១,៣៨លានក្បាល បក្សីចំនួន១៧,៥០លានក្បាល ចៀមចំនួន៧៨១ក្បាល ពពែចំនួន៣០០ក្បាល និងស្វាចំនួន១៧ពាន់ក្បាល។

បើប្រៀបធៀបឆ្នាំ២០១៩ ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មមានការកើនចំនួន៣៧,០% ក្នុងនោះ គោក្របីកើនចំនួន៣៣,០% ជ្រូកកើនចំនួន១៩,៤% និងបក្សីកើនចំនួន៣៨,៦%។

ក្រាហ្វិកទី១៤៖ ស្ថិតិផលិតកម្មសត្វ លក្ខណៈពាណិជ្ជកម្មពីឆ្នាំ២០១៦-២០២០




### ស្ថិតិផលិតកម្មសត្វ លក្ខណៈពាណិជ្ជកម្មពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២០

| ល.រ | ប្រភេទសត្វ | ស្ថិតិសត្វ ៥ឆ្នាំចុងក្រោយ (២០១៦-២០២០) | | | | | ប្រៀបធៀប (២០១៩&២០២០) |
|---|---|---|---|---|---|---|---|
| | | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | |
| ១ | គោ | ២៣ ១៨៨ | ២០ ៣៦៣ | ១១ ២៣២ | ៩ ៨៧៧ | ១៣ ២១៦ | ៣៣,៨% |
| ២ | ក្របី | ១៩៤ | ១៩៨ | ២១៧ | ២១៨ | ២១១ | -៣,២% |
| ៣ | គោ-ក្របី | ២៣ ៣៨២ | ២០ ៥៦១ | ១១ ៤៤៩ | ១០ ០៩៥ | ១៣ ៤២៧ | ៣៣,០% |
| ៤ | ជ្រូក | ៥៩៩ ៣៤១ | ៧៤២ ៧៧១ | ៨១២ ៩៣៨ | ១ ១៥៥ ៤៣១ | ១ ៣៧៩ ៦២៣ | +១៩,៤% |
| ៥ | បក្សី | ៧ ៣៣១ ២៧៥ | ៧ ៥៩២ ៥៣០ | ៩ ២១០ ៤០៩ | ១២ ៦៣១ ៩៧៤ | ១៧ ៥០៨ ៩៣៦ | ៣៨,៦% |
| ៦ | សេះ | ៦៤ | ៨២ | ៨៩ | ៣០ | ០ | -១០០% |
| ៧ | ចៀម | ៦៧ | ០ | ០ | ០ | ៧៨១ | ១០០% |
| ៨ | ពពែ | ៦ ២៥៨ | ៣៦៥ | ៧០០ | ០ | ៣០០ | ១០០% |
| ៩ | ស្វា | - | - | - | ១៤ ០៧៩ | ១៧ ០១០ | ២០,៨% |
| ១០ | ទន្សាយ | - | - | - | - | ០ | ០ |
| សរុប | | ៧ ៩៦០ ៣៨៧ | ៨ ៣៥៦ ៣០៩ | ១០ ០៣៥ ៥៨៥ | ១៣ ៨១១ ៦០៨ | ១៨ ៩២០ ០៧៧ | +៣៧,០% |

### ២.១.៣. ស្ថិតិសត្វសរុបទូទាំងប្រទេស (លក្ខណៈគ្រួសារ និងពាណិជ្ជកម្ម)

ជារួមផលិតកម្មសត្វគ្រប់ប្រភេទក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ មានអត្រាកំណើនគួរឱ្យកត់សម្គាល់ គឺចាប់ពី ៤២,១៨លានក្បាល នៅឆ្នាំ២០១៦ កើនដល់៥៣,៩០លានក្បាល នៅឆ្នាំ២០២០។ ដោយឡែកនៅក្នុងឆ្នាំ២០២០ នេះ ស្ថិតិសត្វសរុបមាន គោចំនួន២,៨៥លានក្បាល ក្របីចំនួន៤២៤ពាន់ក្បាល ជ្រូកចំនួន២,៥២លានក្បាល បក្សីចំនួន ៤៨,០៦លានក្បាល សេះចំនួន៣ពាន់ក្បាល ចៀមចំនួន១,៧២ពាន់ក្បាល ពពែចំនួន៣០,៣ពាន់ក្បាល ដំរីចំនួន៥១ក្បាល ស្វាចំនួន១៧,២ពាន់ក្បាល និងទន្សាយចំនួន៣១១ក្បាល។

បើប្រៀបធៀបទៅនឹងឆ្នាំ២០១៩ មានអត្រាកំណើនចំនួន១៧,៦% ក្នុងនោះ គោកើនចំនួន២,៥% ជ្រូកកើនចំនួន១៥,១% បក្សីកើនចំនួន១៩,០% ចៀមកើនចំនួន១៦៦,២% ពពែកើនចំនួន៩,២% ដំរីកើនចំនួន១៨៣,៣% ស្វាកើនចំនួន២១,១% ទន្សាយកើនចំនួន៦៨,១% ដោយឡែកក្របីថយចុះចំនួន៥,៣% និងសេះថយចុះចំនួន២១,៨%។

ក្រាហ្វិកទី១៥៖ ស្ថិតិផលិតកម្មសត្វសរុប (លក្ខណៈគ្រួសារ+ពាណិជ្ជកម្ម) ពីឆ្នាំ២០១៦-២០២០




**តារាងស្ថិតិផលិតកម្មសត្វសរុប ចិញ្ចឹមជាលក្ខណៈគ្រួសារ និងពាណិជ្ជកម្មពីឆ្នាំ២០១៦-២០២០**

| ល.រ | ប្រភេទសត្វ | ស្ថិតិសត្វ ៥ឆ្នាំចុងក្រោយ (២០១៦-២០២០) | | | | | ប្រៀបធៀបឆ្នាំ ២០១៩&២០២០ |
|---|---|---|---|---|---|---|---|
| | | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | |
| ១ | គោ | ២ ៩២០ ៣១៤ | ២ ៩៧១ ៧២២ | ២ ៩២៨ ៥៣៤ | ២ ៧៧៩ ៧៦២ | ២ ៨៤៨ ៥៧៦ | ២,៥% |
| ២ | ក្របី | ៥២៣ ៥១៤ | ៥០៨ ៦៥៦ | ៥០០ ៩៩៥ | ៤៤៧ ៣៨៥ | ៤២៣ ៨២៥ | -៥,៣% |
| ៣ | គោ-ក្របី | ៣ ៤៤៣ ៨២៨ | ៣ ៤៨០ ៣៧៨ | ៣ ៤២៩ ៥២៩ | ៣ ២២៧ ១៤៧ | ៣ ២៧២ ៤០១ | ១,៤% |
| ៤ | កម្លាំងអូសទាញ | ១ ០៥១ ៦២៥ | ៩៣៥ ២៣៩ | ៨៣៦ ៣០១ | ៧១៧ ៩០២ | ៦៤៨ ៧២៩ | -៩,៦% |
| ៥ | ជ្រូក | ២ ៩៧០ ៦២៤ | ៣ ០៧៤ ២៨៣ | ២ ៧៤៧ ៨៥៥ | ២ ១៨៥ ៩២៤ | ២ ៥១៦ ៦៧៩ | ១៥,១% |
| ៦ | បក្សី | ៣៥ ៧៣៣ ៧៦១ | ៣៦ ២៤៤ ៩៣៩ | ៣៨ ១៦៦ ៧៥១ | ៤០ ៣៩៥ ៤៥៣ | ៤៨ ០៦២ ១៦៩ | ១៩,០% |
| ៧ | សេះ | ៥ ៦៧៤ | ៥ ១៣៧ | ៤ ២៩៦ | ៣ ៨០១ | ២ ៩៧១ | ២១,៨% |
| ៨ | ចៀម | ៤៦៧ | ៤៦១ | ៤៥៩ | ៦៤៨ | ១ ៧២៥ | ១៦៦,២% |
| ៩ | ពពែ | ២៨ ៩៧៧ | ២៨ ៩០៧ | ២៦ ៤៤៧ | ២៧ ៧៤០ | ៣០ ២៨១ | ៩,២% |
| ១០ | ដំរី | ៦៣ | ៦៣ | ៥៨ | ១៨ | ៥១ | ១៨៣,៣% |
| ១១ | ស្វា | - | - | - | ១៤ ២២៨ | ១៧ ២២៩ | ២១,១% |
| ១២ | ទន្សាយ | - | - | - | ១៨៥ | ៣១១ | ៦៨,១% |
| **សរុប** | | **៤២ ១៨៣ ៣៩៤** | **៤២ ៨៣៤ ១៦៨** | **៤៤ ៣៧៥ ៣៩៥** | **៤៥ ៨៥៥ ១៤៣** | **៥៣ ៩០៣ ៨១៧** | **១៧,៦%** |

### ២.១.៤. ការប្រៀបធៀបបែបផែនផលិតកម្មតាមប្រភេទសត្វ

ការជំរុញផលិតកម្មសត្វ និងបង្កើនផលិតភាពសត្វ គឺជាគោលដៅអាទិភាពសម្រាប់ការធ្វើពាណិជ្ជកម្មសត្វ។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្ម មានអត្រាកើនឡើងគួរឱ្យកត់សម្គាល់ គឺចាប់ពីចំនួន៧,៩៦លានក្បាល នៅឆ្នាំ២០១៦ កើនដល់ចំនួន១៨,៩២លានក្បាល នៅក្នុងឆ្នាំ២០២០។ ដោយឡែក នៅក្នុងឆ្នាំ២០២០ ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្មមានកំណើនចំនួន៣៧,០% ក្នុងនោះផលិតកម្មគោ លក្ខណៈពាណិជ្ជកម្មមានកំណើនចំនួន៣៣,៨% ជ្រូកលក្ខណៈពាណិជ្ជកម្មមានកំណើនចំនួន១៩,៤% និងផលិតកម្មបក្សីមានកំណើនចំនួន៣៨,៦%។ អត្រានៃកំណើនផលិតសត្វលក្ខណៈពាណិជ្ជកម្មនេះបានឆ្លុះបញ្ចាំងឱ្យឃើញពីការផ្លាស់ប្តូរបែបផែនផលិតកម្មសត្វជាវិជ្ជមានមួយ ដើម្បីឈានទៅកែលម្អផលិតភាពសត្វ និងប្រសិទ្ធភាពសេដ្ឋកិច្ច កាន់តែល្អប្រសើរឡើង។

+ **ការប្រៀបធៀបបែបផែនផលិតកម្មសត្វ៖** អត្រានៃការចិញ្ចឹមសត្វលក្ខណៈពាណិជ្ជកម្មបានកើនពីចំនួន៣០% នៅឆ្នាំ២០១៩ ដល់ចំនួន៣៥% ក្នុងឆ្នាំ២០២០។ ដោយឡែកអត្រានៃការចិញ្ចឹមសត្វលក្ខណៈគ្រួសារបានថយចុះពីចំនួន៧០% នៅឆ្នាំ២០១៩ មកត្រឹមចំនួន៦៥% ក្នុងឆ្នាំ២០២០។

ក្រាហ្វិកទី១៦៖ ប្រៀបធៀបបែបផែនផលិតកម្មសត្វសរុបពីឆ្នាំ២០១៦-២០២០




**តារាងស្ថិតិផលិតកម្មសត្វសរុប តាមបែបផែនផលិតកម្ម ពីឆ្នាំ២០១៦-២០២០**

| បែបផែនផលិតកម្មសត្វ | ស្ថិតិផលិតកម្មសត្វសរុប ៥ឆ្នាំចុងក្រោយ (២០១៦-២០២០) | | | | | ប្រៀបធៀបឆ្នាំ ២០១៩ & ២០២០ |
|---|---|---|---|---|---|---|
| | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | |
| លក្ខណៈគ្រួសារ | ៣៤ ២២៣ ០០៧ | ៣៤ ៤៧៧ ៨៥៩ | ៣៤ ៣៣៩ ៨១០ | ៣២ ០៤៣ ៥៣៥ | ៣៤ ៩៨៣ ៧៤០ | ៩,២% |
| លក្ខណៈពាណិជ្ជកម្ម | ៧ ៩៦០ ៣៨៧ | ៨ ៣៥៦ ៣០៩ | ១០ ០៣៥ ៥៨៥ | ១៣ ៨១១ ៦០៨ | ១៨ ៩២០ ០៧៧ | ៣៧,០% |
| **សរុប** | **៤២ ១៨៣ ៣៩៤** | **៤២ ៨៣៤ ១៦៨** | **៤៤ ៣៧៥ ៣៩៥** | **៤៥ ៨៥៥ ១៤៣** | **៥៣ ៩០៣ ៨១៧** | **១៧,៦%** |

**តារាងអត្រាស្ថិតិផលិតកម្មសត្វសរុប តាមបែបផែនផលិតកម្ម ពីឆ្នាំ២០១៦-២០២០**

| បែបផែនផលិតកម្មសត្វ | អត្រាស្ថិតិផលិតកម្មសត្វសរុប ៥ឆ្នាំចុងក្រោយ (២០១៦-២០២០) | | | | | ប្រៀបធៀបឆ្នាំ ២០១៩ & ២០២០ |
|---|---|---|---|---|---|---|
| | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | |
| លក្ខណៈគ្រួសារ | ៨១% | ៨០% | ៧៧% | ៧០% | ៦៥% | -៧,១% |
| លក្ខណៈពាណិជ្ជកម្ម | ១៩% | ២០% | ២៣% | ៣០% | ៣៥% | ១៦,៥,% |

+ **ការប្រៀបធៀបបែបផែនផលិតកម្មជ្រូក៖** អត្រានៃការចិញ្ចឹមជ្រូកជាលក្ខណៈពាណិជ្ជកម្មបានកើនពីចំនួន ៥៣% នៅឆ្នាំ២០១៩ ដល់ចំនួន៥៥% ក្នុងឆ្នាំ២០២០។ ដោយឡែកអត្រានៃការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ បាន ថយចុះពីចំនួន៤៧% នៅឆ្នាំ២០១៩ មកត្រឹមចំនួន៤៥% ក្នុងឆ្នាំ២០២០។




**តារាងស្ថិតិផលិតកម្មជ្រូកតាមបែបផែនផលិតកម្មពីឆ្នាំ២០១៦-២០២០**

| បែបផែន ផលិតកម្មជ្រូក | ស្ថិតិផលិតកម្មជ្រូក ៥ឆ្នាំចុងក្រោយ (២០១៦-២០២០) | | | | | ប្រៀបធៀបឆ្នាំ ២០១៩ & ២០២០ |
|---|---|---|---|---|---|---|
| | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | |
| លក្ខណៈគ្រួសារ | ២ ៣៧១ ២៨៣ | ២ ៣៣១ ៥១២ | ១ ៩៣៤ ៩១៧ | ១ ០៣០ ៤៩៤ | ១ ១៣៧ ០៥៦ | ១០,៣% |
| លក្ខណៈពាណិជ្ជកម្ម | ៥៩៩ ៣៤១ | ៧៤២ ៧៧១ | ៨១២ ៩៣៨ | ១ ១៥៥ ៤៣១ | ១ ៣៧៩ ៦២៣ | +១៩,៤% |
| **សរុប** | **២ ៩៧០ ៦២៤** | **៣ ០៧៤ ២៨៣** | **២ ៧៤៧ ៨៥៥** | **២ ១៨៥ ៩២៤** | **២ ៥១៦ ៦៧៩** | **១៥,១%** |

+ **ការប្រៀបធៀបបែបផែនផលិតកម្មបក្សី៖** អត្រានៃការចិញ្ចឹមបក្សីជាលក្ខណៈពាណិជ្ជកម្មបានកើនពីចំនួន ៣១% នៅឆ្នាំ២០១៩ ដល់ចំនួន៣៦% ក្នុងឆ្នាំ២០២០។ ដោយឡែកអត្រានៃការចិញ្ចឹមបក្សីជាលក្ខណៈគ្រួសារ បាន ថយចុះពីចំនួន៦៩% នៅឆ្នាំ២០១៩ មកត្រឹមចំនួន៦៤% ក្នុងឆ្នាំ២០២០។

**តារាងស្ថិតិផលិតកម្មបក្សីតាមបែបផែនផលិតកម្មពីឆ្នាំ២០១៦-២០២០**

| បែបផែន ផលិតកម្មបក្សី | ស្ថិតិផលិតកម្មបក្សី ៥ឆ្នាំចុងក្រោយ (២០១៦-២០២០) | | | | | ប្រៀបធៀបឆ្នាំ ២០១៩ & ២០២០ |
|---|---|---|---|---|---|---|
| | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | |
| លក្ខណៈគ្រួសារ | ២៨ ៤០២ ៤៨៦ | ២៨ ៦៥២ ៤០៩ | ២៨ ៩៥៦ ៣៤២ | ២៧ ៧៦៣ ៤៧៩ | ៣០ ៥៥៣ ២៣៣ | ១០,០% |
| លក្ខណៈពាណិជ្ជកម្ម | ៧ ៣៣១ ២៧៥ | ៧ ៥៩២ ៥៣០ | ៩ ២១០ ៤០៩ | ១២ ៦៣១ ៩៧៤ | ១៧ ៥០៨ ៩៣៦ | ៣៨,៦% |
| **សរុប** | **៣៥ ៧៣៣ ៧៦១** | **៣៦ ២៤៤ ៩៣៩** | **៣៨ ១៦៦ ៧៥១** | **៤០ ៣៩៥ ៤៥៣** | **៤៨ ០៦២ ១៦៩** | **១៩,០%** |




### ២.១.៥. តម្រូវការសត្វ និងសាច់

ផ្អែកតាមការសិក្សារបស់អង្គការស្បៀង និងកសិកម្មនៃអង្គការសហប្រជាជាតិ ការបរិភោគសាច់សត្វនៅកម្ពុជាក្នុងឆ្នាំ២០២០នេះ មនុស្សម្នាក់ក្នុងមួយឆ្នាំហូបសាច់ជាមធ្យមប្រមាណ១៨គីឡូក្រាម ក្នុងនោះមានសាច់គោ ក្របីចំនួន ០៥គីឡូក្រាម សាច់ជ្រូកចំនួន៩,២៩គីឡូក្រាម សាច់បក្សីចំនួន៣,៦៩គីឡូក្រាម និងសាច់ចៀម ពពែចំនួន ០,០២ គីឡូក្រាម។

ក្នុងរយៈពេល០៥ឆ្នាំចុងក្រោយនេះ តម្រូវការសាច់សត្វសម្រាប់ការបរិភោគ មានការកើនឡើងគួរឱ្យកត់សម្គាល់ គឺកើនពីចំនួន២៧៦ពាន់តោន នៅឆ្នាំ២០១៦ ឡើងដល់ចំនួន៣០១ពាន់តោន នៅក្នុងឆ្នាំ២០២០។ ដោយឡែក នៅក្នុងឆ្នាំ២០២០នេះ តម្រូវការសាច់សរុបមានចំនួន៣០១ពាន់តោន ក្នុងនោះសាច់គោ ក្របីចំនួន៨៤ពាន់តោន សាច់ជ្រូកចំនួន១៥៥ពាន់តោន សាច់បក្សីចំនួន៦២ពាន់តោន និងសាច់ចៀម ពពែ ឬសាច់ផ្សេងទៀតចំនួន៣៣៤តោន។ ផលិតកម្មសត្វក្នុងស្រុកមានលទ្ធភាពអាចផ្គត់ផ្គង់សាច់បានប្រមាណ២៥៦ពាន់តោន ឬស្មើនឹងចំនួន៨៥% ក្នុងនោះសាច់គោ ក្របីចំនួន៩០ពាន់តោន (៨១៥ពាន់ក្បាល) សាច់ជ្រូកចំនួន១០៩ពាន់តោន (២ ១៧៩ពាន់ក្បាល) និងសាច់បក្សីចំនួន៥៨ពាន់តោន (៤៨ ១២៨ពាន់ក្បាល)។ បរិមាណដែលខ្វះខាត ត្រូវបាននាំចូលដើម្បី បំពេញតម្រូវការបន្ថែម ជាក់ស្តែងនៅក្នុងឆ្នាំ២០២០ កម្ពុជាបាននាំចូលសាច់ និងផលិតសត្វមួយចំនួនរួមមានជ្រូកសាច់រស់ចំនួន ១,៦៨លានក្បាល មាន់សាច់រស់ចំនួន៥,១១លានក្បាល ទាសាច់រស់ចំនួន១០៥ ពាន់ក្បាល ចៀម ពពែរស់ចំនួន ៤,១ពាន់ក្បាល និងសាច់ចម្រុះចំនួន៤,៩៣ពាន់តោន (សាច់ជ្រូក ចៀម មាន់ ទា ក្ងាន ក្រួច ព្រាប គោ ក្របី ប្រហិត និងផលិតផលសាច់សត្វ)។

**តារាងតម្រូវការប្រើប្រាស់ ការផ្គត់ផ្គង់ និងការបំពេញបន្ថែមឆ្នាំ២០២០**

| ប្រភេទសត្វ | តម្រូវការប្រើប្រាស់ | | លទ្ធភាពផ្គត់ផ្គង់ក្នុងស្រុក | | លើស/ខ្វះ | |
|---|---|---|---|---|---|---|
| | តោន | ពាន់ក្បាល | តោន | ពាន់ក្បាល | តោន | ពាន់ក្បាល |
| គោ ក្របី | ៨៣ ៦១៤ | ៧៦០ | ៨៩ ៥៩៨ | ៨១៥ | ៥ ៩៨៤ | ៥៤ |
| ជ្រូក | ១៥៥ ៣៥៥ | ៣ ១០៧ | ១០៨ ៩៥៣ | ២ ១៧៩ | -៤៦ ៤០១ | -៩២៨ |
| បក្សី | ៦១ ៧០៧ | ៥១ ៤២៣ | ៥៧ ៧៥៤ | ៤៨ ១២៨ | -៣ ៩៥៣ | -៣ ២៩៤ |
| ចៀម ពពែ & ផ្សេងៗ | ៣៣៤ | ៣៣ | ១៥២ | ១៥ | -១៨២ | -១៨ |
| **សរុប** | **៣០១ ០១០** | | **២៥៦ ៤៥៧** | | **-៤៤ ៥៥៣** | |

## ក្រាហ្វិកទី១៩៖ បង្ហាញពីតម្រូវការសាច់ ការផ្គត់ផ្គង់ និងកង្វះខាត




## ក្រាហ្វិកទី២០៖ បង្ហាញពីការផ្គត់ផ្គង់សាច់ តាមប្រភេទសត្វ




## ក្រាហ្វិកទី២១៖ បង្ហាញពីការផ្គត់ផ្គង់សាច់ តាមប្រភេទសត្វ



**ក្រាហ្វិកទី២២៖ បង្ហាញពីអត្រានៃការផ្គត់ផ្គង់សាច់ និងកង្វះខាត**




### ២.១.៦. ការនាំចេញសត្វ និងផលិតផលសត្វ

កម្ពុជាមានលទ្ធភាពធ្វើការនាំចេញគោ ក្របី ជ្រូក មាន់ ស្វាក្ដាម សាច់ ផលិតផលសត្វ ចំណីសត្វ និងទឹកដោះគោមួយចំនួនទៅបរទេសផងដែរ។ សរុបក្នុងរយៈពេល០៥ឆ្នាំកន្លងមកនេះ កម្ពុជាបាននាំចេញគោ ក្របីចំនួន៩០,២ពាន់ក្បាល ជ្រូកពូជ(មេ,បា,កូន) ចំនួន៤២,៥ពាន់ក្បាល កូនមាន់ពូជចំនួន៥៦ពាន់ក្បាល ស្វាក្ដាមចំនួន១០៩ពាន់ក្បាល សាច់គោចំនួន៨៧តោន ទឹកដោះគោចំនួន១២ពាន់តោន ចំណីឆ្អែតចំនួន៧,៥ពាន់តោន រោមសត្វចំនួន ១១២,៨ តោន និងស្បែកគោ ក្របី ជ្រូកចំនួន៧,៧ពាន់តោន។ ដោយឡែកនៅឆ្នាំ២០២០ បាននាំចេញគោ ក្របីចំនួន៩,៧ពាន់ក្បាល ជ្រូកពូជចំនួន២០០ក្បាល ស្វាក្ដាមចំនួន២៤ពាន់ក្បាល ចំណីឆ្អែតចំនួន២ ២៧៦តោន រោមសត្វចំនួន ២,៨តោន និងស្បែកគោ ក្របីប្រឡាក់អំបិលចំនួន១ ៥៥៤តោន។

**តារាងស្ថិតិនាំចេញសត្វ សាច់ ផលិតផលសត្វ និងចំណីសត្វ ពីឆ្នាំ២០១៦-២០២០**

| ប្រភេទសត្វ និងផលិតផលសត្វ | ឯកតា | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | សរុប |
|---|---|---|---|---|---|---|---|
| គោ ក្របី | ក្បាល | ៦ ២៣៥ | ១១ ២៤០ | ៦ ៧៨៦ | ៥៦ ២១៨ | ៩ ៧៤២ | ៩០ ២២១ |
| ជ្រូកពូជ (មេ បា) | ក្បាល | ១ ២៥០ | ១ ១៤០ | ៥០៥ | ២០០ | ២០០ | ៣ ២៩៥ |
| ជ្រូកពូជ (កូន) | ក្បាល | ៣៤ ២០០ | - | ៥ ០០០ | - | - | ៣៩ ២០០ |
| ស្វាក្ដាម | ក្បាល | ៥១ ៥៣០ | ៦ ៩៣៤ | ១០ ៤៧២ | ១៦ ១៩៦ | ២៣ ៧៧០ | ១០៨ ៩០២ |
| កូនមាន់ | ក្បាល | ៥៦ ០០០ | - | - | - | - | ៥៦ ០០០ |
| សាច់គោ | តោន | ៦៨ | ៧ | ១២ | - | - | ៨៧ |
| ទឹកដោះគោ | តោន | - | ៤៥១ | ៧ ៥៥៨ | ៣ ៩៨៤ | - | ១១ ៩៩៣ |
| ចំណីឆ្អែត | តោន | ១ ៣៧០ | ១ ៣៦៥ | ១ ៤៩៤ | ១ ០១១ | ២ ២៧៦ | ៧ ៥១៦ |
| រោមសត្វ | តោន | ៥០ | ២៨ | ២៤ | ៨ | ២,៨ | ១១២,៨ |
| ស្បែកគោ ក្របីសើម | តោន | ១ ៤៨៣ | ១ ៩៧២ | ១ ២៧៥ | ១ ៤៤០ | ១ ៥៥៤ | ៧ ៧២៤ |

### ២.១.៧. កម្មវិធីកែលម្អពូជ

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានបើកវគ្គបណ្ដុះបណ្ដាលបច្ចេកទេសបង្កាត់សិប្បនិម្មិតគោ និងជ្រូក ព្រមទាំងផ្សព្វផ្សាយបច្ចេកទេស និងផលប្រយោជន៍នៃការបង្កាត់សិប្បនិម្មិតគោ និងជ្រូកដល់មន្ត្រីជំនាញផលិតកម្ម និងបសុព្យាបាលទាំង២៥រាជធានី ខេត្ត។ តាមរយៈការអនុវត្តកម្មវិធីជំរុញកំណើនវិស័យកសិកម្មប្រកបដោយ

ចីរភាព និងបរិយាប័ន្នអនុវិស័យវិស័យផលិតកម្មសត្វ បានបង្កើតមជ្ឈមណ្ឌល និងកន្លែងបង្កាត់សិប្បនិម្មិតគោបានចំនួន ១១កន្លែង នៅក្នុងខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ ព្រៃវែង ពោធិ៍សាត់ ស្ទឹងត្រែង ស្វាយរៀង តាកែវ និងខេត្តឧត្តរមានជ័យ ព្រមទាំងមជ្ឈមណ្ឌល និងកន្លែងបង្កាត់សិប្បនិម្មិតជ្រូក១២កន្លែង នៅក្នុងខេត្តចំនួន១១គឺ ខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ឆ្នាំង កំពង់ស្ពឺ កំពត ព្រៃវែង ស្ទឹងត្រែង ស្វាយរៀង តាកែវ ឧត្តរមានជ័យ ត្បូងឃ្មុំ និងនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម។

នៅឆ្នាំ២០២០ នេះ ការបង្កាត់គោដោយសិប្បនិម្មិតបានចំនួន១ ៣៥៧ក្បាល និងមេកើនកូនបានចំនួន៤៥៣ ក្បាល (ញី២១៧ក្បាល) ស្មើនឹងចំនួន៣៤% មេដែលបានបង្កាត់សិប្បនិម្មិតមិនទាន់កើតកូនចំនួន៩០៤ក្បាល ស្មើនឹង ចំនួន៦៦%។ ការបង្កាត់គោដោយសិប្បនិម្មិតមានការចូលរួមចំណែកពីវិស័យឯកជនផងដែរ ប៉ុន្តែតួលេខនៃការកើតកូន គោមិនស្មើទៅនឹងតួលេខបង្កាត់ពីព្រោះគោផើមមានរយៈពេល០៩ខែ និង១០ថ្ងៃ ដូច្នេះមេគោមួយចំនួនត្រូវកើតកូន នៅឆ្នាំបន្ទាប់ និងបង្កាត់ជ្រូកសិប្បនិម្មិតបានចំនួន១៤ ០០២ក្បាល បង្កើតកូនជ្រូកបានចំនួន១១២ ៥១១ក្បាល (ញី ៥១ ៧៩៧ក្បាល)។ ជាការកត់សម្គាល់ពិនិត្យឃើញថា ពូជជ្រូកត្រូវបានកែលម្អយ៉ាងឆាប់រហ័យនៅទូទាំងប្រទេស។

**២.១.៨. អំពីចំណីសត្វ**

កម្មវិធីកែលម្អចំណីសត្វ និងផ្សព្វផ្សាយពូជស្មៅ ដែលសម្បូរទៅដោយសារធាតុចិញ្ចឹម និងផ្តល់ទិន្នផលខ្ពស់ គឺជាសកម្មភាពអាទិភាពមួយដើម្បីជំរុញផលិតកម្មសត្វ។ បច្ចុប្បន្នការដាំដុះដំណាំចំណីសត្វ បានរីកសាយភាយ យ៉ាងទូលំទូលាយនៅទូទាំង២៥រាជធានី ខេត្ត ជាក់ស្តែងក្នុងឆ្នាំ២០២០នេះ កន្លែងដាំដុះ និងធ្វើបង្ហាញដំណាំចំណី សត្វ សរុបមានចំនួន១ ៩៨០កន្លែង លើផ្ទៃដីចំនួន២ ៣០៧,១៣ហិកតា។

ក្នុងឆ្នាំ២០២០នេះ ក្រុមហ៊ុនដែលបានវិនិយោគសាងសង់រោងចក្រផលិតចំណីសត្វ នៅក្នុងប្រទេសកម្ពុជា សរុបមានចំនួន១៩ក្រុមហ៊ុន រួមមានក្រុមហ៊ុនស៊ីភី, អេហ្វ្រីម៉ាស្ទ័រ, ហ្វ្រីនហ្វីត, បេតាហ្គ្រោ, ញ៉ូវហូប, អ៊ីស្តហូប, ស៊ីជេ, សាណាហ្គ្រូ, អិមភិក.អេស៊ីអិមស៊ី, ស៊ីខេវ៉ាយអ៊ី, អិលវីអេស, វើលដ៍វេត, ភីធិបបែលយូអ, អេអែនធីហ្វីដ, ដេហ៊ីស ធីអិម អេច, អាយតាវ ផេត សិបផ្លាយ, នូបល ថេស្ត ហ្វូដ, ឡូឌី ផេត ប្រូដាក និងរោងចក្រចំណីសត្វកណ្តោលដុំ (ហុក ហៀង) ដែលមានរោងចក្រផលិតចំណីសត្វសរុបចំនួន២១រោងចក្រ និងមានសមត្ថភាពអាចផលិតចំណីសត្វបាន ប្រមាណជាង ២,១៦លានតោន/ឆ្នាំ។ នៅក្នុងឆ្នាំ២០២០ ក្រុមហ៊ុនដែលបាននិងកំពុងដំណើរការផលិតចំណីសត្វយ៉ាងសកម្មចំនួន ១៧ក្រុមហ៊ុន មានរោងចក្រផលិតចំណីសត្វចំនួន១៩រោងចក្រ និងផលិតចំណីសត្វបានប្រមាណជាង១,១៣លាន តោន ស្មើនឹងចំនួន៥២% នៃសមត្ថភាពផលិតរបស់រោងចក្រ។

ម្យ៉ាងទៀត ក្រៅពីចំណីសត្វដែលផលិតបាននៅក្នុងស្រុក ក៏មានក្រុមហ៊ុនមួយចំនួនទៀត បាននាំចូលបន្ថែម នូវចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែម ដើម្បីបំពេញសេចក្តីត្រូវការប្រើប្រាស់ និងផលិតចំណីសត្វក្នុងស្រុក។ ជាក់ស្តែងក្នុងឆ្នាំ២០២០ កម្ពុជាបាននាំចូលនូវចំណីសត្វចំនួន២០៨ពាន់តោន វត្ថុធាតុដើមចំនួន ២៥៨ពាន់តោន និង សារធាតុបន្ថែមចំនួន១៤ពាន់តោន បសុឱសថចំនួន២ ៤៧០តោន វ៉ាក់សាំងចំនួន៤៥តោន សម្ភារបសុពេទ្យ និង ឧបករណ៍ចិញ្ចឹមសត្វចំនួន៧៥តោន។

**២.១.៩. ការគ្រប់គ្រងកាកសំណល់សត្វ**

ការសាងសង់ឡជីវឧស្ម័ន ត្រូវបានជំរុញ និងលើកទឹកចិត្តឱ្យសាងសង់យ៉ាងទូលំទូលាយ ដើម្បីគ្រប់គ្រងកាក សំណល់សត្វ ដោយបានទាញយកនូវថាមពលកកើតឡើងវិញ និងផ្តល់នូវជីធម្មជាតិ។ កម្មវិធីឡជីវឧស្ម័នជាតិបាន អនុវត្តតាំងពីឆ្នាំ២០០៦ រហូតមកដល់បច្ចុប្បន្ននេះ ឡជីវឧស្ម័នគ្រួសារបានសាងសង់ចំនួន២៨ ៦៨៥ឡ ក្នុងខេត្ត ចំនួន១៤ គឺខេត្តបាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កំពត កណ្តាល ព្រៃវែង ពោធិ៍សាត់ សៀមរាប ស្វាយរៀង តាកែវ ត្បូងឃ្មុំ និងខេត្តបន្ទាយមានជ័យ។ ដោយឡែកក្នុងឆ្នាំ២០២០ កម្មវិធីឡជីវឧស្ម័នជាតិ សាងសង់ឡជីវឧស្ម័ន គ្រួសារបានចំនួន៧០៣ឡ។

គម្រោងសាងសង់ឡជីវឧស្ម័នកម្ពុជា-ចិនចំនួន១ ៥០០ឡ ក្រោមហិរញ្ញប្បទានឥតសំណងពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន បានអនុវត្តចាប់ពីចុងឆ្នាំ២០១៩ រហូតមកដល់បច្ចុប្បន្ននេះ ការសាងសង់ឡជីវឧស្ម័នគ្រួសារបានចំនួន៤០ឡ ក្នុងខេត្តចំនួន០៧ គឺខេត្តកំពង់ចាម កំពង់ឆ្នាំង ព្រៃវែង ពោធិ៍សាត់ ស្វាយរៀង ព្រះវិហារ និងខេត្តត្បូងឃ្មុំ។ ជាក់ស្ដែងនៅក្នុងឆ្នាំ២០២០នេះ ការសាងសង់ឡជីវឧស្ម័នគ្រួសារសម្រេចបានចំនួន០៥ឡបន្ថែមទៀតនៅខេត្តព្រះវិហារ។ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ កំពុងជំរុញនិងកំណត់អត្តសញ្ញាណកសិករដែលស្ម័គ្រចិត្តទទួលឡជីវឧស្ម័នឱ្យបានចំនួនជាក់លាក់ ដើម្បីលើកសំណើសុំថវិកាបដិភាគ របស់រាជរដ្ឋាភិបាល បន្ថែមសម្រាប់អនុវត្តគម្រោងឡជីវឧស្ម័នបន្តទៀត ក្រោមក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណងរបស់រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន។

ម៉្យាងទៀត គម្រោងខ្សែច្រវ៉ាក់ផលិតកម្មដោយភាពតរៈបរិស្ថាន ក្រោមហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ីបានចាប់ផ្ដើមអនុវត្តក្នុងឆ្នាំ២០២០ នេះ ក្នុងផែនការសាងសង់ឡជីវឧស្ម័នគ្រួសារចំនួន១២ ០០០ឡ ក្នុងខេត្តចំនួន០៤គឺ ខេត្តកំពង់ចាម ត្បូងឃ្មុំ តាកែវ និងខេត្តកំពត។ ក្នុងឆ្នាំទី១ នេះ គម្រោងពុំទាន់បានសាងសង់ឡជីវឧស្ម័ននៅឡើយទេ ព្រោះកំពុងដំណើរការនីតិវិធីលទ្ធកម្មដើម្បីរកអ្នកផ្ដល់សេវាកម្មសាងសង់ឡនេះ។






## ២.២. ការលើកកម្ពស់សុខភាពសត្វ និងសុខភាពសាធារណ:

សកម្មភាពសំខាន់ៗក្នុងផ្នែកនេះ គឺការពង្រឹងសុខភាពសត្វ អនាម័យសត្វ សាច់ និងផលិតផលសត្វ ដោយផ្តោតសំខាន់លើការត្រួតពិនិត្យអនាម័យ គុណភាព សុវត្ថិភាព ពង្រឹងការផ្តល់សេវាបសុព្យាបាល កាត់បន្ថយការឆ្លងរាលដាលជំងឺសត្វ និងការផ្គត់ផ្គង់សាច់ប្រកបដោយអនាម័យ គុណភាព និងសុវត្ថិភាពនៅលើទីផ្សារ ដើម្បីការពារ សុខភាពសត្វ សុខភាពសាធារណៈ និងបរិស្ថាន។

### ២.២.១. ការលើកកម្ពស់សុខភាពសត្វ

នៅឆ្នាំ២០២០ នេះ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានពង្រឹងសកម្មភាពត្រួតពិនិត្យ និងទប់ស្កាត់បទល្មើសចរាចរណ៍សត្វ និងការធ្វើអាជីវកម្មសត្វ ដោយបានសហការជាមួយការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្ត និងសមត្ថកិច្ចពាក់ព័ន្ធ បានបន្តអនុវត្តសេចក្តីណែនាំអំពីលក្ខខណ្ឌតម្រូវសម្រាប់ការនាំចូល នាំចេញ និងនាំឆ្លងកាត់សត្វ និងផលិតផលសត្វ។ ជាលទ្ធផលក្នុងរយៈពេលមួយឆ្នាំនេះ នៅទូទាំងប្រទេសបានធ្វើការត្រួតពិនិត្យចរាចរណ៍សត្វ និងផលិតផលសត្វសរុប១៨៣ករណី ក្នុងនោះអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វបានត្រួតពិនិត្យចរាចរណ៍សត្វ និងផលិតផលសត្វមានលិខិតអនុញ្ញាតត្រឹមត្រូវចំនួន១៥៣ករណី និងបង្ក្រាបបទល្មើសបានចំនួន៣០ករណី (ដឹកជញ្ជូនមាន់រស់ចំនួន១០ករណី ជ្រូករស់ចំនួន១០ករណី ទារស់ចំនួន ០១ករណី ស៊ុតទាចំនួន០១ករណី ប្រហិតចំនួន០១ករណី គោរស់ចំនួន០២ករណី ក្របីចំនួន០២ករណី ក្រួចបង្កក និងសាច់គោចំនួន ០៣ករណី) និងការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្ត បង្ក្រាបបទល្មើសបានចំនួន ៣៦ករណី (ដឹកជញ្ជូនមាន់រស់ចំនួន១៥ករណី ជ្រូករស់ចំនួន១៨ករណី គោរស់ចំនួន០១ករណី និងផលិតផលកែច្នៃពីសត្វចំនួន០២ករណី)។ ជាមួយគ្នានេះដែរ បានធ្វើការអង្កេតតាមដាន បង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងជំងឺឆ្លងសត្វ ព្រមទាំងបានរៀបចំប្រព័ន្ធព័ត៌មាន និងរាយការណ៍ជំងឺឆ្លងសត្វទាំងថ្នាក់ជាតិ និងអន្តរជាតិ ចាត់វិធានការណ៍ជីវសុវត្ថិភាព និងកម្មវិធីឆ្លើយតបបន្ទាន់ករណីផ្ទុះជំងឺឆ្លងសត្វ។ លទ្ធផលសំខាន់ៗសម្រេចបានក្នុងឆ្នាំ២០២០ រួមមានៈ

១.ចាក់វ៉ាក់សាំងការពារជំងឺឆ្លងសំខាន់ៗដែលកើតមានលើគោ ក្របី ពពែ ចៀម ដូចជាជំងឺអុតក្តាម បូសខ្យល់ និងសារទឹកសរុបចំនួន ១ ៦៤៩ ៦១០ក្បាល ចាក់វ៉ាក់សាំងការពារជំងឺឆ្លងលើជ្រូកចំនួន ១ ៦៥៦ ៦៤៦ក្បាល ចាក់វ៉ាក់សាំងការពារជំងឺបក្សីបានចំនួន ២១ ៧០២ ១២៤ក្បាល និងចាក់វ៉ាក់សាំងការពារជំងឺឆ្កែ និងឆ្មាចំនួន ១០ ៧២៤ក្បាល។

២.ចាត់វិធានការជីវសុវត្ថិភាព ផ្សព្វផ្សាយ និងអនុវត្តផ្ទាល់នៅសត្តឃាតដ្ឋាន ទីផ្សារសត្វ កសិដ្ឋានចិញ្ចឹមសត្វ កន្លែងចិញ្ចឹមសត្វ មធ្យោបាយដឹកជញ្ជូនសត្វ និងផលិតផលសត្វ និងកន្លែងផ្ទុះជំងឺសត្វសរុបចំនួន១៦៩ ៣៤១លើក។

### ២.២.២. ការពង្រឹងសុខភាពសាធារណៈបសុព្យាបាល

សុខភាពសាធារណៈបសុព្យាបាលជាផ្នែកមួយ មានភារកិច្ចវាយតម្លៃ ផ្តល់ការអនុញ្ញាតបង្កើតសត្តឃាតដ្ឋាន និងកន្លែងកែច្នៃសាច់ និងផលិតផលសត្វ ដើម្បីធានាសុខភាពសាធារណៈតាមរយៈការពង្រឹងការត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋាន អនាម័យសត្វ សាច់ និងផលិតផលសត្វ ដោយបង្កើនសមត្ថភាពមន្ត្រី និងផ្សព្វផ្សាយដល់អាជីវករពាក់ព័ន្ធលើការអនុវត្តវិធានអនាម័យសត្វ សាច់ និងផលិតផលសត្វ។ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វបានសហការជាមួយការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្ត ចុះផ្សព្វផ្សាយច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ អនុក្រឹត្យលេខ១០៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រង សត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានយកចិត្តទុកដាក់ខ្ពស់ក្នុងការរៀបចំចងក្រងឯកសារបច្ចេកទេសនានា និងផ្តល់ការបណ្តុះបណ្តាលបច្ចេកទេសពាក់ព័ន្ធនឹងការធ្វើអាជីវកម្មសត្វ ផលិតផលសត្វ ការពិឃាតសត្វតាមបទដ្ឋានបច្ចេកទេសដល់អ្នកពាក់ព័ន្ធ ក្នុងនោះបានចុះណែនាំការអនុវត្តល្អក្នុងសត្តឃាតដ្ឋានតាមលក្ខណៈ

បច្ចេកទេសចំនួន៣២លើក បានបណ្តុះបណ្តាលមន្ត្រីជំនាញ អ្នកពិឃាតសត្វ និងការធ្វើជីវសុវត្ថិភាពចំនួន១៤វគ្គ ដែលមានអ្នកចូលរួមសរុប៤៦៦នាក់ ក្នុងនោះ មានស្ត្រីចំនួន៨៩នាក់ បានចុះត្រួតពិនិត្យបច្ចេកទេសការស្នើសុំបង្កើត និងបន្តសុពលភាពសត្តឃាតដ្ឋានចំនួន៣១ លើក ដែលមានសត្តឃាតដ្ឋានសរុបចំនួន៥៦កន្លែង និងបានចុះត្រួតពិនិត្យ និងគាំទ្រសត្តឃាតដ្ឋាន ក្នុងការកែលម្អជាសត្តឃាតដ្ឋានស្តង់ដាអនាម័យបច្ចេកទេសគំរូចំនួន០៣កន្លែង។ សត្តឃាតដ្ឋានចំនួន២៩កន្លែងត្រូវបានកែលម្អ តាមស្តង់ដាអនាម័យបច្ចេកទេស។ គិតមកដល់ដំណាច់ឆ្នាំ២០២០នេះ សត្តឃាតដ្ឋាននៅទូទាំងប្រទេសមានចំនួន២២៤កន្លែង ដែលបាននិងកំពុងប្រតិបត្តិការពិឃាដសត្វ។ សត្តឃាតដ្ឋានដែលបានបន្តសុពលភាពមានចំនួន០៦កន្លែង សត្តឃាតដ្ឋានពិឃាតបក្សីទំនើបនៅខេត្តកណ្តាលចំនួន០១កន្លែង និង សត្តឃាតដ្ឋានពិឃាតគោទំនើបនៅខេត្តតាកែវចំនួន០១កន្លែង។

### ២.៣. ការផ្សព្វផ្សាយបច្ចេកទេសផលិតកម្មនិងបសុព្យាបាល និងនីតិកម្ម

#### ២.៣.១. ការងារផ្សព្វផ្សាយបច្ចេកទេស

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានរៀបចំកម្មវិធីផ្សព្វផ្សាយ សម្ភាសន៍ វេទិកាសាធារណៈសម្រាប់អ្នកពាក់ព័ន្ធលើប្រធានបទសំខាន់ៗ និងបានផ្សព្វផ្សាយឯកសារបទសម្ភាសន៍ វីដេអូអប់រំបច្ចេកទេសផលិតកម្ម និងបសុព្យាបាល ច្បាប់ បទដ្ឋានគតិយុត្ត ព័ត៌មាន សេចក្តីណែនាំ សារាចរ ប្រកាស និងឯកសារពាក់ព័ន្ធនានាតាមវិទ្យុ ទូរទស្សន៍ គេហទំព័រ ហ្វេសប៊ុក និងចែកជូនការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្តទាំង២៥ និងសាធារណៈជននូវឯកសារបង្ហាញពីការចិញ្ចឹមសត្វ និងការដាំដំណាំចំណីសត្វ និងជំងឺឆ្លងសត្វ។ លើសពីនេះ ទៀតមន្ត្រីជំនាញបានរៀបចំប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ ដាំដំណាំចំណីសត្វ និងជំងឺឆ្លងសត្វជាពិសេសជំងឺប៉េស្តជ្រូកអាហ្វ្រិក និងជំងឺផ្តាសាយបក្សី ដល់កសិករចិញ្ចឹមសត្វ និងអ្នកពាក់ព័ន្ធសរុបចំនួន ៣ ១១៩នាក់ ស្ត្រីចំនួន១ ៦០០នាក់។ បានចុះពង្រឹងសហគមន៍ចំនួន១១ ដែលមានស្រាប់ និងប្រមូលទិន្នន័យពីក្រុមកសិករចិញ្ចឹមសត្វ និងសហគមន៍កសិកម្មដែលមានចិញ្ចឹមសត្វ សមាគមភ្នាក់ងារសុខភាពសត្វភូមិរួមជាមួយការចុះវាយតម្លៃដោយផ្ទាល់ជាមួយកសិករសកម្មដែលចិញ្ចឹមសត្វ ក្នុងគោលបំណងដើម្បីរៀបចំសហគមន៍សុខភាពសត្វ និងផលិតកម្មសត្វ និងបណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមសត្វ បណ្តុះបណ្តាលពីខ្សែច្រវ៉ាក់ផលិតកម្មសត្វ និងទីផ្សារ ផលិតផលសត្វ រួមទាំងការផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមសត្វផងដែរ។ ឆ្នាំ២០២០នេះ សមាជិកក្រុមកសិករចិញ្ចឹមសត្វ សហគមន៍កសិកម្មដែលមានចិញ្ចឹមសត្វ និងសហគមន៍សុខភាពសត្វ និងផលិតកម្មសត្វ ចំនួន១៥ខេត្ត ទទួលបានការបណ្តុះបណ្តាលដោយមានអ្នកចូលរួមសរុបចំនួន ៩៤៣នាក់ ក្នុងនោះស្ត្រីមានចំនួន ៥១២នាក់។

#### ២.៣.២. ការងារនីតិកម្ម

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បាននិងកំពុងរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ចំនួន ១៥ ដែលក្នុងនោះមានលិខិតបទដ្ឋានក្រោមច្បាប់មួយចំនួនត្រូវបានរៀបចំរួចរាល់ និងមួយចំនួនទៀតកំពុងស្ថិតក្នុងដំណើរការរៀបចំ និងបន្តពិភាក្សា។

**ក. លិខិតបទដ្ឋានគតិយុត្តដែលបានរៀបចំរួចរាល់**

- ប្រកាសលេខ២២៣ ប្រក.កសក ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០ ស្តីពីនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត និងកំណត់ការគ្រប់គ្រងចំណីសត្វ វត្ថុធាតុដើម ឬសារធាតុបន្ថែមដែលធ្វើពាណិជ្ជកម្ម ការផលិត និងការលាយផ្សំ
- ប្រកាសលេខ៣៤៣ ប្រក.កសក.ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីនីតិវិធី និងសិទ្ធិពិន័យអន្តរការណ៍លើបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ
- ប្រកាសលេខ៣៨៤ ប្រក.កសក ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០២០ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបសុឱសថ និងវត្ថុធាតុជីវៈបសុព្យាបាលដែលធ្វើពាណិជ្ជកម្ម និងលាយផ្សំ។

**ខ.លិខិតបទដ្ឋានគតិយុត្តដែលកំពុងពិនិត្យ បន្តការរៀបចំ និងពិភាក្សា**

- ព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈបសុពេទ្យ
- អនុក្រឹត្យស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាស័ក្តិរបស់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតផលសត្វ
- អនុក្រឹត្យស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការធ្វើអាជីវកម្មពិឃាតសត្វ និងទីកន្លែងកែច្នៃបឋមផលិតសត្វ
- ធ្វើការកែសម្រួលប្រកាសអន្តរក្រសួងស្តីពីសេវាសាធារណៈរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ប្រកាសអន្តរក្រសួងស្តីពីគំរូសំណុំលិខិតដោះស្រាយបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងយុត្តិធម៌
- ប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងការគ្រប់គ្រងសហគមន៍សុខភាពសត្វ និងផលិតកម្មសត្វ
- ប្រកាសស្តីពីនីតិវិធីក្នុងការត្រួតពិនិត្យនូវបសុឱសថ ចំណីសត្វ និងវត្ថុធាតុដើម សារធាតុសកម្ម ឬសារធាតុបន្ថែមដែលនាំចេញ នាំចូល ផលិតលាយផ្សំ និងវេចខ្ចប់ជាថ្មី
- កែសម្រួលប្រកាសស្តីពីនីតិវិធីនៃការជ្រើសរើសការបណ្តុះបណ្តាល ការគ្រប់គ្រងឱ្យមាននិរន្តរភាព និងភារកិច្ចភ្នាក់ងារសុខភាពសត្វភូមិ
- ប្រកាសស្តីពីនីតិវិធីនៃការចេញលិខិតអនុញ្ញាត វិញ្ញាបនបត្របសុព្យាបាល និងបទដ្ឋានបច្ចេកទេស បសុព្យាបាលសម្រាប់ចរាចរណ៍សត្វ និងផលិតផលសត្វ
- ប្រកាសស្តីពីនីតិវិធីនៃការចេញលិខិតអនុញ្ញាត និងបទដ្ឋានបច្ចេកទេសបសុព្យាបាលសម្រាប់ទីកន្លែងព្យាបាលសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ
- ប្រកាសស្តីពីនីតិវិធី និងការតម្រូវសម្រាប់ការទទួលស្គាល់កិច្ចប្រតិបត្តិការរបស់មន្ទីរពិសោធន៍រដ្ឋ និងឯកជនសម្រាប់វិស័យសុខភាពសត្វ និងផលិតកម្មសត្វ
- ប្រកាសស្តីពីនីតិវិធី និងការតម្រូវបទដ្ឋានបច្ចេកទេសសម្រាប់ការបង្កើត ការគ្រប់គ្រង និងការអនុញ្ញាតបង្កើតស្ថានីយចត្តាឡីស័កសត្វ និងផលិតផលសត្វ។

**២.៣.៣. ការងារចេញលិខិតអនុញ្ញាត និងចុះបញ្ជិកា**

ក្រុមហ៊ុនចំណីសត្វចំនួន០២ បានការអនុញ្ញាតឱ្យផលិត លាយផ្សំ វេចខ្ចប់ជាថ្មី ក្នុងនោះមានក្រុមហ៊ុនប្រាយច៍ អេហ្គ្រីស្តារ ឯ.ក និងក្រុមហ៊ុន ខេមបូឌាន ណ្យូបិល ថេស្ត ហ្វីដ ឯ.ក។ ក្រុមហ៊ុនចំណីសត្វចំនួន២៧ ក្រុមហ៊ុនបានចុះបញ្ជិកាចំណីសត្វសរុបចំនួន៤៨១មុខ ក្នុងនោះមានចំណីសត្វចំនួន៤១៦មុខ សារធាតុបន្ថែមចំនួន ៥៨មុខ និងវត្ថុធាតុដើមចំនួន០៧មុខ និងបានចុះបញ្ជិកាបសុឱសថចំនួន១៣ ក្រុមហ៊ុន សរុបចំនួន៤៦៩មុខ ក្នុងនោះបសុឱសថចំនួន៤១៤មុខ វ៉ាក់សាំងចំនួន៤៩មុខ និងសារធាតុសកម្ម ចំនួន ០៦មុខ។ បានចុះបញ្ជីឃ្លាំងសន្និធិ និង ផ្គត់ផ្គង់ចែកចាយបានចំនួន០៥ក្រុមហ៊ុនមាន ក្រុមហ៊ុន ប្រាយច៍ អេហ្គ្រីស្តារ ឯ.ក, គាត ខេង ឌីវេឡុបមេន, ជា សំរឹទ្ធ អ៊ីមផត អិចផត ឯ.ក, ខេមបូឌាន ណ្យូបិល ថេស្ត ហ្វីដ ឯ.ក និងក្រុមហ៊ុន អេស ស៊ី អិល អ ប៊ី ចំរើនផានិត ឯ.ក។

**២.៣.៤.ការងារស្រាវជ្រាវ និងអធិការកិច្ច**

ក្នុងឆ្នាំ២០២០ នេះ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ ក្នុងការអនុវត្ត ច្បាប់ស្តីពីនីតិវិធីធ្វើអធិការកិច្ច ស្រាវជ្រាវ ត្រួតពិនិត្យ និងចងក្រងសំណុំរឿងបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ ដោយមានអ្នកចូលរួមសរុបចំនួន ២៦៩នាក់ ក្នុងនោះស្រីចំនួន៣៥នាក់។ បានចាត់មន្ត្រីចុះធ្វើអធិការកិច្ចប្រកាសប្រតិវេទន៍ចំណីសត្វ និងបសុឱសថ នៅតាមដេប៉ូលក់ចំណីសត្វ និងបសុឱសថក្នុងបណ្តារាជធានី ខេត្តចំនួន៥៨ក្រុមហ៊ុន និងធ្វើអធិការកិច្ចតាមដេប៉ូ លក់ដុំ លក់រាយ ចំណី

សត្វ និងបសុឱសថក្នុងបណ្តារាជធានី ខេត្ត បានចំនួន៥៧ដេប៉ូ ក្នុងចំណោមដេប៉ូសរុបចំនួន៨៨៤ ដេប៉ូនៅទូទាំង២៥ រាជធានី ខេត្ត។

**២.៤. ការងារស្រាវជ្រាវ និងអនីវឌ្ឍន៍សុខភាពសត្វ និងផលិតកម្មសត្វ**

វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ មានសមត្ថភាពធ្វើរោគវិនិច្ឆ័យរកមេរោគបង្កជំងឺឆ្លងសត្វសំខាន់ៗ ភាពស៊ាំបសុឱសថប្រឆាំងនឹងមេរោគ ពិនិត្យកោសិកា/ជាលិកា ឈាម វះពិនិត្យសាកសពសត្វ វិភាគចំណីសត្វ កាកសំណល់បសុឱសថ និងសារធាតុគីមីនៅក្នុងសត្វ និងផលិតផលសត្វ ផលិតទឹកមេជីវិតគោបង្កកបង្កាត់សិប្បនិម្មិតគោពិសោធន៍ ផលិតថ្នាំសម្លាប់មេរោគ និងបណ្តុះបណ្តាលមន្ត្រីជំនាញលើការងារស្រាវជ្រាវ។

**២.៤.១.ការងារស្រាវជ្រាវសុខភាពសត្វ**

វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ មានសមត្ថភាពធ្វើរោគវិនិច្ឆ័យជំងឺសត្វ តាមដានភាពស៊ាំបសុឱសថប្រឆាំងនឹងមេរោគ វិភាគកាកសំណល់បសុឱសថ និងសារធាតុគីមីនៅក្នុងផលិតផលសត្វ។

**ក.ការងារធ្វើរោគវិនិច្ឆ័យជំងឺសត្វ**

បច្ចុប្បន្នវិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ មានសមត្ថភាពធ្វើរោគវិនិច្ឆ័យជំងឺគោ ក្របី ជ្រូក បក្សី ឆ្កែ ឆ្មា ស្វា ចៀម ពពែ ដូចជាជំងឺផ្តាសាយបក្សី ញូវកាស ប៉េស្តទា អាសន្នរោគបក្សី ប៉េស្តជ្រូក ប៉េស្តជ្រូកអាហ្វ្រិក ជ្រូកត្រចៀកខៀវ សាល់ម៉ូណែលឡូស៊ីស អឺកូលី កូលីហ្វម ក្លស្ទ្រីឌីយ៉ូម សារទឹក អុតក្តាម បូសខ្យល់ ឈាមខ្មៅ រលូតកូន ឆ្កែឆ្កួត ឡិបតូស្ពីរ៉ូស៊ីស ស៊ីហ្សែលឡា កាំហ្វីឡូបាក់ទែរ រលាកទងសួត ប៊ីវីរុស អេសអរវី ធីអិលវី ជំងឺបណ្តាលមកពីចំណីអាហារ (សាច់ និងផលិតផលសាច់សត្វ ចំណីសត្វ ទឹកដោះគោ ស្បែកគោ ក្របី) និងជំងឺបង្កដោយប៉ារ៉ាស៊ីត។

ក្នុងឆ្នាំ២០២០ វិទ្យាស្ថានបានយកវត្ថុវិភាគមកធ្វើរោគវិនិច្ឆ័យជំងឺសរុបចំនួន៣០ ៦៣២វត្ថុវិភាគ ក្នុងនោះ រកឃើញវត្ថុមានជំងឺឆ្លងសំខាន់ដូចជា ជំងឺបង្កឡើងដោយវីរុសមានជំងឺអុតក្តាម ជំងឺញូវកាស ជំងឺជ្រូកត្រចៀកខៀវ ជំងឺបង្កឡើងដោយបាក់តេរីមានជំងឺសារទឹក បូសខ្យល់គោ ក្របី ជំងឺសាល់ម៉ូណេឡា និងជំងឺបង្កឡើងដោយប៉ារ៉ាស៊ីតមានទ្រីប៉ាណូសូម ប៉ារ៉ាមហ្វីស្តូមូម Paramphystomum និងអេម៉ុងឃុស (Haemoncus)។ បន្ថែមពីនេះ វិទ្យាស្ថានបានអង្កេតឃ្លាំមើលវត្ថុមានជំងឺផ្តាសាយបក្សីនៅទីផ្សារបក្សីរស់ក្នុងរាជធានី ខេត្តនានាចំនួន១០។ ជំងឺផ្តាសាយជ្រូក ប៉េស្តជ្រូក ប៉េស្តជ្រូកអាហ្វ្រិក ជ្រូកត្រចៀកខៀវ និងជំងឺគ្រុន Q-Fever លើគោយកនៅតាមសត្តឃាតដ្ឋាន ក្នុងរាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ ព្រៃវែង សៀមរាប បាត់ដំបង និងខេត្តតាកែវ។ ជំងឺប៉េស្តសត្វ ទំពារអៀងតូចនៅលើពពែយកពីរាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ចាម ព្រៃវែង ត្បូងឃ្មុំ និងខេត្តតាកែវ។

**ខ.តាមដានភាពស៊ាំបសុឱសថប្រឆាំងនឹងមេរោគ**

ភាពស៊ាំនឹងឱសថប្រឆាំងនឹងមេរោគកំពុងចោទជាបញ្ហាដល់សុខភាពមនុស្ស សត្វ និងបរិស្ថាននៅក្នុងប្រទេសជាច្រើននៅលើពិភពលោក។ ការប្រើប្រាស់អង់ទីប៊ីយ៉ូទិកនៅក្នុងការចិញ្ចឹមសត្វនៅកម្ពុជាអាចនាំទៅរកភាពស៊ាំនឹងឱសថ ដោយសារមិនមានការគ្រប់គ្រងច្បាស់លាស់។ ឆ្លើយតបទៅនឹងបញ្ហានេះ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បាននិងកំពុងធ្វើការតាមដានអំពីស្ថានភាពនៃភាពស៊ាំនឹងបសុឱសថនៅកម្ពុជាជាប្រចាំ។

**គ.វិភាគកាកសំណល់បសុឱសថ និងសារធាតុគីមីនៅក្នុងផលិតផលសត្វ**

សមត្ថភាពមន្ត្រីលើការវិភាគគុណភាពបសុឱសថ និងកាកសំណល់បសុឱសថ បានពង្រឹងតាមរយៈការចូលរួមវគ្គបណ្តុះបណ្តាលលើការប្រើប្រាស់ឧបករណ៍ UPLC-MS MS និង CHARM II លើការវិភាគកាកសំណល់បសុឱសថ និងសារធាតុគីមីនៅក្នុងផលិតផលសត្វ។ វិទ្យាស្ថានបានយកវត្ថុវិភាគសាច់សត្វតាមទីផ្សារនៅរាជធានីភ្នំពេញ ខេត្តកំពង់ចាម ត្បូងឃ្មុំ ព្រៃវែង ស្វាយរៀង កំពង់ស្ពឺ តាកែវ និងខេត្តកំពង់ឆ្នាំង សរុបចំនួន២១០ វត្ថុវិភាគបន្ថែមទៀត (សាច់គោចំនួន១០៩ សាច់ជ្រូកចំនួន៣៤ សាច់មាន់ចំនួន០៤ សត្វក្រួចបង្កកចំនួន២៥ ទឹកដោះគោឆៅ

ចំនួន០៣ ស៊ុតចំនួន០៣ និងគ្រឿងសមុទ្រចំនួន៣២) ដើម្បីវិភាគរកកាកសំណល់អង់ទីប៊ីយ៉ូទិកក្នុងក្រុមតេត្រាស៊ីគ្លីន និងស៊ុលហ្វា បេតាអាហ្គោនីស និងសារធាតុហ្វរម៉ុល។ លទ្ធផលនៃការវិភាគបង្ហាញថា មានវត្តមានកាកសំណល់ អង់ទីប៊ីយ៉ូទិក ក្រុមតេត្រាស៊ីគ្លីន ក្នុងសាច់ជ្រូកមកពីស្រុកជើងព្រៃ ខេត្តកំពង់ចាម ប៉ុន្តែមិនមានវត្តមានអ័រម៉ូន ឬហ្វរម៉ុល នៅក្នុងផលិតផលទាំងនោះទេ។ បានសហការជាមួយអ្នកជំនាញជនជាតិរុស្សីធ្វើការពិសោធន៍ និងផលិតថ្នាំសម្លាប់មេរោគ ដោយប្រើបច្ចេកទេសអេឡិកត្រូលីត្រទឹកដែលមានលទ្ធភាព និងប្រសិទ្ធភាពក្នុងការសម្លាប់មេរោគ បានយ៉ាងល្អ។

### ២.៤.២.ការងារស្រាវជ្រាវផលិតកម្មសត្វ

#### ក.សេនេទិក និងការបង្កាត់ពូជសត្វ

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វមានស្ថានីយពិសោធន៍ស្រាវជ្រាវចំនួន២កន្លែង សម្រាប់ធ្វើការពិសោធន៍ស្រាវជ្រាវពូជសត្វគឺ ស្ថានីយចិញ្ចឹមគោពូជភ្នំតាម៉ៅដែលមានគោសរុបចំនួន១០៣ក្បាល និងស្ថានីយចិញ្ចឹមជ្រូកពូជបង្ហាញកម្ពុជា ចិន ដែលបច្ចុប្បន្នត្រូវបានផ្អាកដំណើរការ។ វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ បានសហការជាមួយអង្គការសិក្សាស្រាវជ្រាវពូជសត្វល្អៗ ដែលមានស្រាប់ក្នុងស្រុក ដើម្បីផលិតទឹកមេជីវិត ពិនិត្យគុណភាព ធ្វើការបង្កក បង្កាត់សិប្បនិម្មិត ដើម្បីកាត់បន្ថយការនាំចូលទឹកមេជីវិតបង្កកពីបរទេស។ នៅឆ្នាំ២០២០នេះ វិទ្យាស្ថានបានផលិតទឹកមេជីវិតគោបង្កកចំនួន២ ៥០០កម្រិត និងបានធ្វើការចែកទៅតាមបណ្ដាខេត្តនានាចំនួន៩៨០កម្រិត។ បានបង្កាត់សិប្បនិម្មិតគោពិសោធន៍បានចំនួន១ ០០០ក្បាល និងកើតកូនបានចំនួន ១២៨ ក្បាល។ ចាប់តាំងពីឆ្នាំ២០១៨ រហូតមកទល់បច្ចុប្បន្ន វិទ្យាស្ថានជាតិមានលទ្ធភាពផលិត និងចែកទឹកមេជីវិតបង្កកគោ និងទឹកនីត្រូសែនដល់បណ្ដាខេត្តនានា ដើម្បីធានាដល់ការងារបង្កាត់សិប្បនិម្មិតគោ។

**តារាងលទ្ធផលនៃការផលិត និងចែកទឹកមេជីវិតបង្កកគោ និងទឹកនីត្រូសែនពីឆ្នាំ២០១៨-២០២០**

| សកម្មភាព | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ |
|---|---|---|---|
| ការផលិតទឹកមេជីវិត (ដើម) | ១ ៥៥០ | ១ ៥១០ | ២ ៥០០ |
| ការបែងចែកទឹកមេជីវិត (ដើម) | ៣ ៤៨០ | ៦០០ | ៩៨០ |
| ការបង្កាត់សិប្បនិម្មិត (ក្បាល) | ៨៣៨ | ៨៨០ | ២ ៣៥៧ |
| ការបែងចែកទឹកនីត្រូសែន (លីត្រ) | - | ៣៩០ | ១ ០២៥ |

**តារាងប្រៀបធៀបការបែងចែកទឹកមេជីវិតបង្កកគោ និងការបង្កាត់សិប្បនិម្មិតគោពីឆ្នាំ២០១៨-២០២០**

| ខេត្ត | ការបែងចែកទឹកមេជីវិត (ដើម) | | | ការបង្កាត់សិប្បនិម្មិត (ក្បាល) | | |
|---|---|---|---|---|---|---|
| | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ |
| បន្ទាយមានជ័យ | ២០ | ០ | ០ | ៣៧ | ១៨ | ២២ |
| បាត់ដំបង | ០ | ០ | ០ | ០ | ១០៥ | ១៣៦ |
| កំពង់ចាម | ០ | ០ | ១២០ | ១៣៧ | ១៨ | ៨០ |
| កំពង់ឆ្នាំង | ២៥០ | ២០ | ០ | ១៣ | ៥៤ | ៣១ |
| កំពង់ស្ពឺ | ៤០ | ០ | ១១៥ | ៨៣ | ៤៦ | ៦៥ |
| កំពង់ធំ | ០ | ៦០ | ០ | ០ | ២៣ | ១៥ |
| កំពត | ០ | ០ | ០ | ៥៤ | ០ | ៦ |
| កណ្ដាល | ០ | ០ | ០ | ០ | ០ | ១ |

| | | | | | | |
|---|---|---|---|---|---|---|
| ព្រៃវែង | ១ ៣៨០ | ៥០ | ១៥០ | ១៨៧ | ៨៣ | ៧៦ |
| ពោធិ៍សាត់ | ២៥០ | ២៥០ | ៣៥០ | ១៩០ | ១៤៧ | ១៦០ |
| រតនគីរី | 0 | 0 | 0 | 0 | 0 | ៥៥ |
| សៀមរាប | 0 | 0 | ៦៥ | ៤ | 0 | ១២៨ |
| ស្ទឹងត្រែង | 0 | ៣០ | ១០០ | ៣ | ១៤ | ៩០ |
| ស្វាយរៀង | 0 | ១៤០ | 0 | ១០ | ២ | ៥ |
| តាកែវ | ៨០ | ៥០ | ៨០ | ៣៣ | ១៥១ | ២៧៩ |
| ឧត្តរមានជ័យ | ១ ៥០០ | 0 | 0 | ៤៧ | ១៦៧ | ១៧២ |
| ប៉ៃលិន | 0 | 0 | 0 | 0 | ៥ | ១៨ |
| ត្បូងឃ្មុំ | 0 | 0 | 0 | 0 | 0 | ១៨ |
| វិទ្យាស្ថានជាតិ | 0 | 0 | 0 | ៤០ | ៤៧ | ១ ០០០ |
| **សរុប** | **៣ ៤៨០** | **៦០០** | **៩៨០** | **៨៣៨** | **៨៨០** | **២ ៣៥៧** |

**ខ.ការវិភាគចំណីសត្វ**

វិទ្យាស្ថាន បានវិភាគគុណភាពចំណីសត្វដោយពិនិត្យទៅលើប៉ារ៉ាម៉ែតសំខាន់ៗមួយចំនួនដូចជា ប្រូតេអ៊ីន ខ្លាញ់ ផូស្វរ សារធាតុសរសៃ សំណើម ផេះ ជាតិម្សៅ និងវត្ថុធាតុដើមផ្សំចំណីសត្វសរុបចំនួន៣៤ប្រភេទ ដើម្បីធានាថាចំណីសត្វដែលដាក់លក់នៅលើទីផ្សារពិតជាមានគុណភាពល្អត្រឹមត្រូវប្រាកដមែន។ ក្រុមការងាររបស់វិទ្យាស្ថានក៏បានចុះទៅសិក្សាពីសក្តានុពលដំណាំចំណីសត្វនៅតាមបណ្តាខេត្តមួយចំនួន។

## ២.៥.ការពង្រឹងការផ្តល់សេវាកម្មសុខភាពសត្វ និងផលិតកម្មសត្វ

### ២.៥.១.ការពង្រឹងការគ្រប់គ្រងអង្គភាព

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងការតែងតាំង ផ្ទេរ និងប្រគល់ភារកិច្ចថ្នាក់ដឹកនាំជាមួយនឹងការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាន នាយកដ្ឋាន វិទ្យាស្ថាន ការិយាល័យ មន្ទីរពិសោធន៍ និងស្ថានីយស្រាវជ្រាវផលិតកម្ម និងបសុព្យាបាល ស្របតាមតាមអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្ម និងបសុព្យាបាលទៅជាអគ្គនាយកដ្ឋាន សុខភាពសត្វ និងផលិតកម្មសត្វ និងប្រកាសលេខ៣៨១ ប្រក.កសក.ប ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៧ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ និងអង្គភាពចំណុះនាយកដ្ឋាន និងវិទ្យាស្ថាននៃអគ្គនាយកដ្ឋាន សុខភាពសត្វ និងផលិតកម្មសត្វស្របតាមការតែងតាំងរបស់រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

នៅទូទាំងប្រទេសមន្ត្រីបម្រើការងារសុខភាពសត្វ និងផលិតកម្មសត្វសរុបចំនួន៧៩៨រូប ស្រីចំនួន១៧៧រូប ដែលក្នុងនោះមន្ត្រីបម្រើការងារនៅថ្នាក់កណ្តាលសរុបចំនួន២៩៣រូប ស្រីចំនួន៨៧រូប និងមន្ត្រីបម្រើការងារនៅទូទាំង ២៥ រាជធានី ខេត្ត សរុបចំនួន៥០៥រូប ស្រីចំនួន៩០រូប។

### ២.៥.២.ការអភិវឌ្ឍធនធានមនុស្ស

ឆ្លើយតបទៅនឹងការកំណត់អាទិភាពនៃកម្មវិធីអភិវឌ្ឍន៍ធនធានមនុស្សរបស់រាជរដ្ឋាភិបាលកម្ពុជា អគ្គនាយកដ្ឋាន សុខភាពសត្វ និងផលិតកម្មសត្វ បានយកចិត្តទុកដាក់ដល់ការបង្កើនសមត្ថភាពមន្ត្រីជាបន្តបន្ទាប់ ទាំងសមត្ថភាពរៀបចំ និងអនុវត្តផែនការ និងសមត្ថភាពបច្ចេកទេសសម្រាប់ផ្តល់សេវាសុខភាពសត្វ និងផលិតកម្មសត្វឱ្យកាន់តែប្រសើរថែម

ទៀត ដោយបានកៀរគរជំនួយ និងការគាំទ្រនានាពីរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍សម្រាប់បង្កើនសមត្ថភាពមន្ត្រី និងអ្នកពាក់ព័ន្ធ ផ្តោតលើអាទិភាពនៃការសិក្សាពីតម្រូវការបណ្តុះបណ្តាលទាំងចំណេះដឹង សមត្ថភាពគ្រប់គ្រង និងសមត្ថភាពបច្ចេកទេស ដែលរួមមានជាអាទិ៍ការបណ្តុះបណ្តាលការបញ្ច្រាបយេនឌ័រនិងកុមារ ផ្សព្វផ្សាយអប់រំពីការប្រើប្រាស់អង់ទីប៊ីយូទិចដោយការទទួលខុសត្រូវនៅក្នុងវិស័យកសិកម្ម ការងាររដ្ឋបាលនិងបុគ្គលិក ពង្រឹងការរៀបចំនិងគ្រប់គ្រងគម្រោង ការគ្រប់គ្រងនិងភាពជាអ្នកដឹកនាំ ជំនាញគណនេយ្យ ការរៀបចំផែនការតាមទម្រង់P3 P4 ការតាមដានត្រួតពិនិត្យ វាយតម្លៃ និងនីតិវិធីទូទាត់ថវិកានិងរៀបចំរបាយការណ៍តាមទម្រង់M1និងM2 ប្រកបដោយគុណភាព ដោយបានប្រជុំ ផ្សព្វផ្សាយ បណ្តុះបណ្តាល និងសិក្ខាសាលា៣៧លើក ដែលមានអ្នកចូលរួមចំនួន ២ ៩៤០នាក់ ក្នុងនោះស្រីចំនួន៩៧៥នាក់។

### ២.៥.៣.ការងាររៀបចំផែនការ

ឆ្នាំ២០២០ នេះ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានចូលរួមរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រនានា ផែនការអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យកសិកម្ម កសាងផែនការមេសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០៣០ សម្រាប់ត្រៀមរៀបចំយុទ្ធសាស្ត្រ ផែនការសកម្មភាព និងទិសដៅការងារសម្រាប់អនុវត្តបន្ត ដោយធ្វើបច្ចុប្បន្នភាពលើផែនការ និងកម្មវិធីសម្រាប់ទិសដៅសំខាន់ៗ រួមមាន ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣ ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ ផែនការសកម្មភាពថវិកាកម្មវិធីឆ្នាំ២០២១ កម្មវិធីវិនិយោគសាធារណៈ០៣ឆ្នាំរំកិល ២០២១-២០២៣ និងផែនការអភិវឌ្ឍន៍ធនធានមនុស្សសម្រាប់ឆ្នាំ២០២១។ លើសពីនេះទៀត អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានចូលរួមផ្តល់ធាតុចូលលើផែនការសកម្មភាពពហុវិស័យជាតិ ស្តីពីការការពារ និងប្រយុទ្ធជំងឺមិនឆ្លងឆ្នាំ២០១៨-២០២៧ ផែនការសកម្មភាពដំណាក់កាលទី២ ឆ្នាំ ២០២១-២០២៥ ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០ សេចក្តីព្រាងផែនការលម្អិតឆ្នាំ២០២១-២០៣០ សម្រាប់កិច្ចសន្ធានានៃកិច្ចសហប្រតិបត្តិការអាស៊ី និងបានកែសម្រួលរបាយការណ៍ចុងក្រោយនៃការអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩។

### ២.៥.៤.ការពង្រឹងការផ្តល់សេវាកម្មសុខភាពសត្វ និងផលិតកម្មសត្វ

សេវាសំខាន់ៗ ដែលអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បាននិងកំពុងអនុវត្តរួមមានការត្រួតពិនិត្យ និងការផ្តល់វិញ្ញាបនបត្របញ្ជាក់អនាម័យសត្វ និងផលិតផលសត្វ ការចេញលិខិតអនុញ្ញាតធ្វើអាជីវកម្មសត្វ និងផលិតផលសត្វ ការវិភាគគុណភាពចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែម បសុឱសថ វត្ថុធាតុជីវបសុព្យាបាល សារធាតុសកម្ម សមាសធាតុគ្រប់ប្រភេទ ការផ្តល់លិខិតអនុញ្ញាតធ្វើចរាចរណ៍សត្វ និងផលិតផលសត្វ ការអនុញ្ញាតនាំចេញ នាំចូល នាំឆ្លងកាត់សត្វរស់ និងផលិតផលសត្វ ការចេញលិខិតអនុញ្ញាតសម្រាប់បង្កើតសត្តឃាតដ្ឋាន លិខិតអនុញ្ញាតបង្កើតកសិដ្ឋានចិញ្ចឹមសត្វ និងបង្កាត់ពូជសត្វ ការចុះបញ្ជីចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែម បសុឱសថ វត្ថុធាតុជីវបសុព្យាបាល សារធាតុសកម្ម សមាសធាតុគ្រប់ប្រភេទ ឃ្លាំងសន្និធិ និង បង្ក្រាបបទល្មើសចលនាសត្វ និងផលិតផលសត្វ។

ក្នុងការបង្កើនគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្តទាំង២៥ នៅឆ្នាំ២០២០ បានប្រមូលចំណូលសរុបចំនួន ១៧ ៨៩៦ ២៥៧ ៦២២រៀល ធៀបនឹងឆ្នាំ២០១៦ មានកំណើនចំនួន១៤១,០៦% និងធៀបនឹងឆ្នាំ២០១៩ មានកំណើនចំនួន៥០,១៤% ដែលក្នុងនោះថ្នាក់កណ្តាលកើនឡើងចំនួន៨១,៧០% និងរាជធានី ខេត្តថយចុះចំនួន៥,៩០%។

**ក្រាហ្វិកទី២៥៖ ប្រៀបធៀបលទ្ធផលប្រមូលពីឆ្នាំ២០១៦-២០២០**




### ២.៥.៥.ការងារសហប្រតិបត្តិការ

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ អង្គការជាតិ និងអង្គការអន្តរជាតិ ដែលរួមមាន៖ OIE, FAO, ASEAN, CHINA, ACIAR, IAEA, JICA, UNIDO, WB, ADB, DTRA, USAID ដើម្បីពង្រឹង និងពង្រីកស្របតាមអភិក្រម ភាពជាម្ចាស់ និងបម្រើឱ្យកម្មវិធីអភិវឌ្ឍន៍នៃអនុវិស័យ។ ទន្ទឹមនឹងនេះ កិច្ចសហការជាមួយអង្គការសង្គមស៊ីវិល អង្គការដៃគូ និងសមាគម ដែលបាននិងកំពុងចូលរួមអភិវឌ្ឍន៍អនុវិស័យនេះ រួមមាន៖ សមាគមអ្នកចិញ្ចឹមសត្វកម្ពុជា អង្គការ JICA ,FAO។ ក្រៅពីកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ អង្គការជាតិ អង្គការអន្តរជាតិ និងអង្គការសង្គមស៊ីវិល អង្គការដៃគូ សមាគម អគ្គនាយកដ្ឋាន សុខភាពសត្វ និងផលិតកម្មសត្វ បានសហការចូលរួមអនុវត្តគម្រោងមួយចំនួន រួមមាន៖

- គម្រោងថវិកាតាមកម្មវិធីរបស់រដ្ឋាភិបាល កម្មវិធីឡជីវឧស្ម័នថ្នាក់ជាតិ (NBP)
- គម្រោងតាមដានហានិភ័យជំងឺមនុស្សបណ្ដាលមកពីប៉ារ៉ាស៊ីតនៃថនិកសត្វតូច និងប្រចៀវ
- គម្រោងពង្រឹងសមត្ថភាពចំណីអាហារ និងចំណីសត្វថ្នាក់ជាតិ គម្រោងសុវត្ថិភាពចំណីអាហារ និងចំណីអាហារសមស្របសម្រាប់កម្ពុជា
- គម្រោងគាំទ្របច្ចេកទេសដើម្បីអភិវឌ្ឍ និងអនុវត្តប្រព័ន្ធអត្តសញ្ញាណកម្មនិងចុះបញ្ជីសត្វ
- គម្រោង Understanding the Risk of Zoonotic disease from swine production and exchange systems in Cambodia
- គម្រោងខ្សែច្រវ៉ាក់ផលិតកម្មដោយភាគរបរិស្ថាន និងកម្មវិធីឡជីវឧស្ម័នពីរដ្ឋាភិបាលចិន។

## ៣. លទ្ធផលនៃការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម

នៅក្នុងឆ្នាំ២០២០នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំបំពេញភារកិច្ចយ៉ាងសកម្ម ដោយសម្រេចបានលទ្ធផលគ្រប់ផ្នែកលើអនុវិស័យជលផល ក្នុងនោះមានការរៀបចំលិខិតបទដ្ឋានក្រោមច្បាប់ ការពង្រឹងសហគមន៍នេសាទ ការគ្រប់គ្រងកន្លែងអភិរក្សជលផល ការបង្ក្រាបបទល្មើសជលផល ការអភិវឌ្ឍវារីវប្បកម្ម ការសិក្សាស្រាវជ្រាវនិងការផ្សព្វផ្សាយជាដើម។ល។ ដោយឡែក ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានបច្ចេកទេសមួយចំនួនទៀតដែលបានរៀបចំរួចហើយកំពុងត្រូវបានពិនិត្យ កែសម្រួលនិងអនុម័តដើម្បីដាក់ឱ្យអនុវត្ត ធានាដល់ការគ្រប់គ្រងអនុវិស័យជលផលប្រកបដោយប្រសិទ្ធភាព។ ជាមួយគ្នានេះដែរ ក្រសួងក៏បានសហការជាមួយដៃគូអភិវឌ្ឍន៍

នានាក្នុងការផ្សព្វផ្សាយច្បាប់ ពង្រឹងសមត្ថភាពមន្ត្រី ពង្រឹងសហគមន៍នេសាទ ផ្សព្វផ្សាយបច្ចេកទេសវារីវប្បកម្ម និងការអភិរក្សធនធានជលផល ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

**៣.១.ការបង្ក្រាបបទល្មើសជលផល**

ក្នុងឆ្នាំ២០២០នេះ សំណុំរឿងនៃបទល្មើសជលផលសរុបចំនួន៣ ១៦២ករណី (សមុទ្រ២៣៩ករណី) ប្រៀបធៀបឆ្នាំមុនកើនឡើងចំនួន៦១ករណី ក្នុងនោះបានបំផ្លាញចោលវត្ថុតាងចំនួន២ ៨៦៥ករណី ពិន័យអន្តរការណ៍ចំនួន១៤៣ករណី បញ្ជូនទៅតុលាការចំនួន១៥៤ករណី ទោសជាប់ពន្ធនាគារចំនួន៧នាក់ ប្រាក់ពិន័យនិងលក់វត្ថុតាងចំនួន២៥៩ ៩៦១ ០០០រៀល។

**៣.២. ការអភិវឌ្ឍសហគមន៍នេសាទ**

ក្នុងឆ្នាំ២០២០នេះ សហគមន៍នេសាទទូទាំងប្រទេសមានចំនួនសរុប៥១៦សហគមន៍ ក្នុងនោះ សហគមន៍នេសាទទឹកសាបចំនួន៤៧៥ និងសហគមន៍នេសាទសមុទ្រ ចំនួន៤១ ដែលមានសមាជិកសរុបចំនួន៣៣២ ១៦៨នាក់ (ស្ត្រី៣៥%) ។ ក្នុងចំណោមសហគមន៍ខាងលើនេះ មានសហគមន៍នេសាទចំនួន៤២៤ ត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសហគមន៍នេសាទចំនួន១១ទៀត ត្រូវបានស្នើសុំចុះបញ្ជីបន្ថែមទៀត។ ចំពោះសហគមន៍នេសាទដែលផុតអាណត្តិការបោះឆ្នោតជ្រើសរើសគណៈកម្មការថ្មី បាននិងកំពុងអនុវត្តជាបន្តបន្ទាប់ ជាក់ស្តែងក្នុងឆ្នាំ២០២០ សហគមន៍នេសាទចំនួន៤១ ត្រូវបានបោះឆ្នោតជ្រើសរើសគណៈកម្មការឡើងវិញ។ ទន្ទឹមនេះ ការរៀបចំនិងការធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រងកន្លែងសហគមន៍ក៏អនុវត្តផងដែរ ជាលទ្ធផលបានរៀបចំផែនការគ្រប់គ្រងថ្មីចំនួន៧សហគមន៍នេសាទ និងធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រងចំនួន៣៩សហគមន៍នេសាទ។

**៣.៣. ការងារកិច្ចការជលផល**

ក្នុងឆ្នាំ២០២០នេះ បានចុះកំណត់ព្រំប្រទល់ការពារព្រៃលិចទឹក និងបោះបង្គោលកម្ពស់៨ម៉ែត្រ ចំនួន៧២ដើម ក្នុងនោះ ថវិកាគាំទ្រដោយរាជរដ្ឋាភិបាលកម្ពុជាចំនួន០៨បង្គោល និងថវិកាគាំទ្រដោយសហភាពអឺរ៉ុប(EU) តាមរយៈគម្រោង CAPFSH Capture ចំនួន៦៤បង្គោល។ បង្គោលទាំងនោះ បានបោះនៅតាមព្រំប្រទល់ការពារព្រៃលិចទឹកដោយផ្អែកតាមអនុក្រឹត្យលេខ១៩៧ អនក្រ.បក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១១ របស់រាជរដ្ឋាភិបាល។ ចាប់ពីឆ្នាំ២០១៥ មកដល់ឆ្នាំ២០២០នេះ ការបោះបង្គោលព្រំប្រទល់ការពារព្រៃលិចទឹកសម្រេចបានចំនួន១០៨បង្គោល។ ទន្ទឹមនឹងនេះ បានចុះផ្សព្វផ្សាយចំនួន៣១វគ្គ ដែលមានអ្នកចូលរួម១ ៩២០នាក់ នៅខេត្តពោធិ៍សាត់ កំពង់ធំ បាត់ដំបង ព្រះសីហនុ កំពត និងខេត្តកែប អំពីប្រកាសស្តីពីការកំណត់ប្រភេទឧបករណ៍នេសាទគ្រួសារ សារសំខាន់នៃព្រៃលិចទឹក និងប្រកាសដែលពាក់ព័ន្ធការនេសាទក្នុងដែនសមុទ្រ។ បានបាញ់ស្លាកលេខសម្គាល់លើទូកនេសាទសមុទ្រសរុបចំនួន៧ ៥៥២គ្រឿង ក្នុងនោះ ខេត្តកែបចំនួន ៥៩៤ គ្រឿង ខេត្តកំពត ចំនួន១ ០៣៩ គ្រឿង ខេត្តព្រះសីហនុចំនួន២ ៥២៣គ្រឿង និងខេត្តកោះកុងចំនួន ៣ ៣៩៦គ្រឿង។

**៣.៤. ការអភិរក្សធនធានជលផល**

ក្រោយការរំសាយឡូត៍នេសាទឆ្នាំ២០១២មក មានកន្លែងអភិរក្សជលផលទឹកសាបដែលបានបង្កើតថ្មីចំនួន៥០កន្លែងដែលមានទំហំសរុប៩៧ ៥៨៣ហិកតា។ រហូតដល់ឆ្នាំ២០២០នេះ បើគិតរួមទាំងកន្លែងអភិរក្សជលផលនៅតាមដែនសហគមន៍នេសាទ កន្លែងអភិរក្សប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ កន្លែងការពារ និងអភិរក្សនៅតាមតំបន់ឆ្នេរ និងកន្លែងអភិរក្សជលផលផ្សេងៗទៀតដែលបង្កើតឡើងមានចំនួនសរុប រហូតដល់ ៦៨២កន្លែង។

ទន្ទឹមនឹងនេះ ក្រសួងបានសាងសង់បង្គោលកំណត់ព្រំប្រទល់កន្លែងអភិរក្សជលផលចំនួន៤៨បង្គោល ក្នុងនោះ ២៣បង្គោល គាំទ្រថវិកាដោយរាជរដ្ឋាភិបាលកម្ពុជា និង២៥បង្គោល ត្រូវបានគាំទ្រដោយថវិកា EU តាមរយៈគម្រោង CAPFISH-Capture (កម្ពស់៨ម៉ែត្រចំនួន៣៥បង្គោល និងកម្ពស់១២ម៉ែត្រចំនួន១៣បង្គោល) ព្រមទាំងស្នាក់ការ

ល្បាតចំនួន០២ខ្ទង។ បូកយោងពីឆ្នាំ២០១៣ ដល់ឆ្នាំ២០២០ មានបង្គោលអភិរក្សជលផលចំនួន៣៣៨ បង្គោលត្រូវបានសាងសង់រួច (១២ម៉ែត្រចំនួន១០០បង្គោល និង៨ម៉ែត្រចំនួន២៣៨បង្គោល) និងស្នាក់ការល្បាត កន្លែងអភិរក្សជលផលចំនួន៨៨ខ្ទង។ សកម្មភាពអភិរក្សជលផលផ្សេងៗទៀត រួមមាន អភិរក្សថ្កា ស្មៅសមុទ្រចំនួន៨ ៥០០ហិកតា នៅតាមតំបន់ឆ្នេរ។ បានដាំព្រៃលិចទឹកនិងព្រៃកោងកាងបានចំនួន២ ៥២០ហិកតា។ បានទម្លាក់ប្រអប់បេតុងចំនួន ១១៧ប្រអប់ ក្នុងកន្លែងអភិរក្សជលផលសមុទ្រខេត្តកែប និងកន្លែងអភិរក្សជលផលបឹងទន្លេសាប ក្នុងខេត្តកំពង់ធំ និងខេត្តសៀមរាប ដោយគិតមកដល់ឆ្នាំ២០២០នេះ មានប្រអប់បេតុង ចំនួន១ ១៥០ប្រអប់។ បានបង្កើតនិងបន្តគ្រប់គ្រងដែនជម្រកសុវត្ថិភាពត្រីកាម៉ុង ក្ដាមសេះ និងក្រែងឈាម បីកន្លែងមានទំហំ១ ៨១៦ហិកតា។ កូនផ្សោតកើតបានចំនួន ៨ក្បាល និងស្លាប់ចំនួន៧ក្បាល។ បានការពារសំបុកអណ្តើកហ្លួងបានចំនួន៣សំបុក ដែលមានគ្រាប់ពងចំនួន៥១គ្រាប់ និងញាស់បានចំនួន ២៣កូន។ បានការពារសំបុកកន្ធាយក្បាលកង្កែបបានចំនួន៤៩សំបុក ដែលមានពងសរុប ១ ៧៨៦គ្រាប់ និងទទួលបាន កូនញាស់សរុប៨៤៥ក្បាល។ បានលែងកូនត្រីនិងកូនបង្កងចំនួន ៥០០ ០០០កូន ទៅក្នុងបឹងធម្មជាតិនិងត្រីមេពូជជាច្រើនតោន។ បានចុះបញ្ជីកសិដ្ឋានចិញ្ចឹមក្រពើចំនួន២០៣កសិដ្ឋាន ដែលមានក្រពើសរុបចំនួន១១៨ ៨២៩ក្បាល ព្រមទាំងបានចេញលិខិតអនុញ្ញាតដឹកជញ្ជូនក្រពើបានចំនួន ១២០សន្លឹក។

**៣.៥. ការអភិវឌ្ឍវារីវប្បកម្ម**

ក្នុងឆ្នាំ២០២០នេះ ការអភិវឌ្ឍវារីវប្បកម្មរួមមាន ការចិញ្ចឹមត្រី-បង្គា សម្រេចបានចំនួន ៤០០ ៤០០តោន ស្មើ ១១១,២២% នៃផែនការ ៣៦០ ០០០តោន ធៀបរយៈពេលដូចគ្នាកើនឡើង ៩២ ៩៩២តោន។ ការចិញ្ចឹមក្រពើ សម្រេចបានចំនួន ៣១៣ ១០០ក្បាល ស្មើ១០៤,៣៧% នៃផែនការ៣០០ ០០០ក្បាល ធៀបរយៈពេលដូចគ្នា ថយចុះ ៩៩ ៧១១ក្បាល។ ការភ្ញាស់កូនត្រីពូជសម្រេចបានចំនួន ២៣៥ ០០០ ០០០ក្បាល ស្មើ៩៧,៩២% នៃផែនការ ២៤០ ០០០ ០០០ក្បាល ធៀបរយៈពេលដូចគ្នាកើន ឡើង១៣ ០០០ ០០០ក្បាល។

**៣.៦. ការបង្កើតស្រះជម្រកត្រីសហគមន៍**

មកដល់ឆ្នាំ២០២០នេះ រដ្ឋបាលជលផល និងខណ្ឌរដ្ឋបាលជលផលខេត្ត បានបង្កើតស្រះជម្រកត្រីសហគមន៍ បានចំនួន៩០៦កន្លែង ក្នុងនោះខេត្តកំពង់ស្ពឺមានចំនួនច្រើនជាងគេរហូតដល់១៧៦កន្លែង។

**៣.៧. ការអភិវឌ្ឍបច្ចេកវិទ្យាកែច្នៃ និងគុណភាព**

ការងារបច្ចេកវិទ្យាកែច្នៃ និងគុណភាពមានសក្តានុពលមួយយ៉ាងសំខាន់សម្រាប់អនុវិស័យជលផលក្នុងការចូលរួមចំណែកផ្គត់ផ្គង់សន្តិសុខស្បៀង អាហារូបត្ថម្ភ ជីវភាពរស់នៅរបស់ប្រជាជន និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

ក្នុងឆ្នាំ២០២០នេះ រដ្ឋបាលជលផលបានរៀបចំបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសមួយចំនួន រួមមាន៖ បានផ្ដល់បច្ចេកទេសស្ដីពីការអនុវត្តអនាម័យល្អ ការផលិតល្អ និងតាមដានការអនុវត្តបច្ចេកទេសនៅតាមទីតាំងកែច្នៃចំនួន០៥កន្លែង បានធ្វើសវនកម្មលើការអនុវត្តអនាម័យល្អ និងការផលិតល្អសម្រាប់ការផ្ដល់សិទ្ធិឱ្យប្រើប្រាស់និមិត្តសញ្ញាគុណភាពផលផលិតផលជលផលបានចំនួន០៥កន្លែង បានកំពុងសហការជាមួយអង្គការ UNIDO ដើម្បីសិក្សានិងពិគ្រោះយោបល់លើការរៀបចំនូវម៉ូឌែលនៃការផ្ដល់មូលនិធិ ការទទួលបានហិរញ្ញប្បទាន និងការគាំទ្របច្ចេកទេសដោយគម្រោង ក្នុងការគាំទ្រដល់ប្រតិបត្តិករក្នុងការលើកកម្ពស់ការផលិតតាមស្តង់ដារ គុណភាព និងសុវត្ថិភាពដើម្បីទទួលបានតម្លៃបន្ថែម សុវត្ថិភាពអាហារ និងការប្រកួតប្រជែងទីផ្សារក្នុងស្រុកនិងអន្តរជាតិ។ បានចេញបញ្ជាក់វិញ្ញាបនបត្រសុខភាពឱ្យក្រុមហ៊ុនចំនួន០៨ បានចំនួន៧១វិញ្ញាបនបត្រ។ បានផ្ដល់ការបណ្ដុះបណ្ដាលស្ដីពីការអនុវត្តអនាម័យល្អ ការផលិតល្អក្នុងការលើកដាក់ និងកែច្នៃផលផលិតផលជលផល ដល់អ្នកកែច្នៃ ពាណិជ្ជករ និងអ្នកពាក់ព័ន្ធផ្សេងៗទៀតបានចំនួន០៤វគ្គ។ បានបណ្ដុះបណ្ដាលគ្រូបង្គោល (TOT) តាមអនឡាញស្ដីពីសុវត្ថិភាព និងវិធានត្រួតពិនិត្យគុណភាព សុវត្ថិភាពផលផលិតផលជលផលដល់គ្រូបង្គោលចំនួន ៣៤នាក់ (ស្រី០៩នាក់) ដើម្បីឱ្យពួកគាត់ក្លាយជាគ្រូបង្គោលសម្រាប់បណ្ដុះបណ្ដាលដល់មន្ត្រីជលផល និងប្រតិបត្តិករខ្សែច្រវ៉ាក់តម្លៃជលផល។

### ៣.៨. ការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រភពធនធានជលផលទាំងទឹកសាប និងសមុទ្របានដំណើរការល្អ ដោយសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍នានា ដូចជា EU, UNIDO, MRC, FAO, WWF, IUCN, World Fish Center ជាដើម ។ល។ ដោយមានវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍នេសាទទឹកសាប និងសមុទ្រ ជាអង្គភាពអនុវត្តផ្ទាល់លើសកម្មភាពមួយចំនួនដូចជា៖ ការសិក្សាស្រាវជ្រាវជីវសាស្ត្រវារីសត្វ សិក្សាតាមដានផលនេសាទតាមដាយត្រី សិក្សាតាមដានប្រភេទកូនត្រី សិក្សា DNA ប្រភេទត្រីទឹកសាប សិក្សាស្រាវជ្រាវការធ្វើចរាចរណ៍និងការពងកូនរបស់ត្រីនៅតំបន់មេគង្គលើ និងសិក្សាតាមដានសុខភាពអេកូឡូស៊ីនៅកម្ពុជា (Ecological Health Monitoring in Cambodia)។ល។ លទ្ធផលស្រាវជ្រាវត្រូវបានបោះពុម្ពសៀវភៅផ្សព្វផ្សាយជាច្រើនពាន់ក្បាល។

### ៣.៩.ស្ថិតិជលផល

ផលនេសាទសរុបមានចំនួន៩៣៦ ៣០០តោន កើនជាងឆ្នាំមុនចំនួន២៧ ៧៩២តោន ស្មើ៣,០៦% ក្នុងនោះ៖ ផលនេសាទទឹកសាបសម្រេចបាន ៤១៣ ២០០តោន ថយចុះ ៦៥ ៦៥០តោន ស្មើ១៣,៧១% ក្នុងនោះ៖ ដាយត្រីថយចុះ ៤ ៤២០តោន ស្មើនឹង ៣០.៨៧% ផលនេសាទក្នុងដែននេសាទថយចុះ៥៨ ៥០០តោន ស្មើនឹង១៧,៩២% ផលនេសាទតាមវាលស្រែថយចុះ២ ៧៣០ តោន ស្មើនឹង ១,៩៨%។ ផលនេសាទសមុទ្រសម្រេចបានចំនួន ១២២ ៧០០ តោន កើនឡើង៤៥០តោន ស្មើ០,៣៧%។ ផលវារីវប្បកម្មសម្រេចបានចំនួន ៤០០ ៤០០តោន កើនឡើង ៩២ ៩៩២ តោន ស្មើ៣០,២៥%។ ចំពោះថវិកាប្រមូលបានចំនួន១ ៥៥៩ ៧៨៥ ៧៧០រៀល ថយចុះ៧២៧ ៧១៤ ៣៩៨រៀល។

**ក្រាហ្វិកទី២៦៖ ផលនេសាទទឹកសាប ផលនេសាទសមុទ្រ និងវារីវប្បកម្មរយៈពេល៥ឆ្នាំ២០១៦-២០២០**




## ៤. លទ្ធផលនៃការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើនិងសត្វព្រៃ

### ៤.១ ការគ្រប់គ្រង និងអភិវឌ្ឍន៍ព្រៃឈើ

#### ក- សហគមន៍ព្រៃឈើ

គិតត្រឹមឆ្នាំ២០២០ សហគមន៍ព្រៃឈើបានបង្កើតសរុបចំនួន ៦៣៨សហគមន៍ គ្របដណ្តប់លើផ្ទៃដី ៥១៨ ៧៧០ហ.ត ក្នុងនោះ៖ ក្រសួងបានចេញប្រកាសចំនួន ៥២០សហគមន៍ លើផ្ទៃដី ៤៤៤ ៨៥៣ហ.ត បានចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ចំនួន ៤៤៧សហគមន៍ លើផ្ទៃដី ៣៦៩ ២៣៣ហ.ត និងបានអនុម័តផែនការគ្រប់គ្រងព្រៃសហគមន៍ចំនួន១០៣សហគមន៍ គ្របដណ្តប់លើផ្ទៃដីទំហំ ៧០ ៩៩១ហ.ត។ ការបង្កើតសហគមន៍ព្រៃឈើមានសន្ទុះកើនឡើងគួរឲ្យកត់សម្គាល់។

**ក្រាហ្វិកទី២៧៖ ចំនួនសហគមន៍ព្រៃឈើពីឆ្នាំ២០១៥-២០២០**




| | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|---|
| ចំនួនសហគមន៍ព្រៃឈើសរុប | 499 | 580 | 610 | 636 | 636 | 638 |
| ចំនួនសហគមន៍ព្រៃឈើ ទទួលបានប្រកាស | 404 | 404 | 464 | 484 | 517 | 520 |

**ខ- គម្របព្រៃឈើ**

- ការវាយតម្លៃគម្របព្រៃឈើឆ្នាំ២០១៤ មានផ្ទៃដីទំហំសរុប ៨ ៩៨៥ ១៦៤ហិកតា ស្មើនឹង ៤៩,៤៨% នៃផ្ទៃដីសរុបទូទាំងប្រទេស
- ការវាយតម្លៃគម្របព្រៃឈើឆ្នាំ២០១៨ មានផ្ទៃដីគម្របព្រៃឈើ ៨ ៥២៩ ៣៧២ហិកតា ស្មើនឹង ៤៦,៩៧%
- បច្ចុប្បន្នបាននិងកំពុងវាយតម្លៃ និងផ្ទៀងផ្ទាត់គម្របព្រៃឈើលើរូបភាពផ្កាយរណប ឆ្នាំ២០២០។

**គ- ការគ្រប់គ្រងផល អនុផលព្រៃឈើ**

- បានផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្តចំនួន ១៩៨គ្រឿង និងយានយន្តចំនួន ២០៨គ្រឿង ជូនក្រុមហ៊ុនចំនួន ១៤ និងអ្នកស្នើសុំចំនួន ០៤នាក់
- បានផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន ១១ក្រុមហ៊ុន និងអ្នកស្នើសុំ ចំនួន ២០នាក់ ដែលមានឈើហ៊ុបមូលចំនួន ២០ ៩៩៧ម៉ែត្រត្រីគុណ ឈើអារចម្រុះខ្នាតចំនួន ៩ ៨៦១ ម៉ែត្រត្រីគុណ កូនឈើនិងបង្គោលក្រាក់ចំនួន ២៦៤ ៦៩៤ដើម អុសចម្រុះចំនួន ៥៨ ១០៧ស្ទែរ ជ័រទឹកចំនួន ១ ១៣០ តោន ឬស្សីព្រៃ-ឃ្លៃចំនួន ៣ ៦៥៥តោន ពកនិងគល់ឈើចំនួន ៩ ៥៨០គីឡូក្រាម ផ្សូងចំនួន ២០៦ ៩៨៦ គីឡូក្រាម ផ្តៅចំនួន ៣ ០០០គីឡូក្រាម ម្រះព្រៅចំនួន ២ ៧៨០គីឡូក្រាម ព្រមទាំងគ្រឿងសង្ហារិម និងអនុផលមួយចំនួនទៀត
- បានធ្វើសារពើភ័ណ្ឌវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើ និងបានរាយការណ៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន ០៤ក្រុមហ៊ុន គឺ៖ ក្រុមហ៊ុន ស៊ីវ ហ្គេក អិនវេសមេន ខេត្តស្ទឹងត្រែង ក្រុមហ៊ុន ភី អិន ធី ខូអិលធីឌី ខេត្តព្រះវិហារ ក្រុមហ៊ុនហ្គ្រីនស៊ី អេហ្គ្រីខលឈ័រ ខេត្តស្ទឹងត្រែង និងក្រុមហ៊ុនចំការកៅស៊ូមេមត់ នៅខេត្តក្រចេះ។

**ឃ- ការងារដាំឈើ**

- បានថែទាំចម្ការឈើចាស់ ចម្ការពូជឈើ និងឡូត៍បង្ហាញកសិ-រុក្ខកម្មចំនួន ៩៣២ហិកតា និងដាំឈើជាចម្ការថ្មីលើផ្ទៃដីទំហំ ១៥០ហិកតា។ ជាមួយគ្នានេះវិស័យឯកជន ក្រុមហ៊ុនដៃគូសហការ និងលក្ខណៈគ្រួសារបានដាំឈើជាចម្ការថ្មីលើផ្ទៃដីទំហំ ២ ០២៩ហិកតា និងបានបណ្តុះកូនឈើចំនួន ៥៣៧ ៥៣៨ដើម និងចែកចាយកូនឈើដល់ប្រជាពលរដ្ឋដាំអាស្រ័យផលចំនួន ៥២៩ ៣១៧ដើម។ ទន្ទឹមនឹងនេះបានអនុវត្តសកម្មភាពជីក

ប្រឡាយការពារចម្ការឈើគ្រញូងប្រវែង ៨ ០០០ម៉ែត្រ នៅក្នុងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអន្លង់ថ្ម ស្ថិតក្នុងភូមិសាស្ត្រស្រុកសន្ទុក ខេត្តកំពង់ធំ

- បានបង្កើតស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើមួយកន្លែងស្ថិតក្នុងឃុំរស្មីសាមគ្គី ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ មានផ្ទៃដីទំហំ ២ ២៥៩ហិកតា តាមប្រកាសលេខ២៥៨ ប្រក.កសក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០
- បាននឹងកំពុងចុះបញ្ជីដីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើចំនួន០៥ទីតាំងលើផ្ទៃដីសរុបទំហំ ៤៧ ១០១ហិកតា ស្ថិតនៅក្នុងខេត្តរតនគិរី ស្ទឹងត្រែង ក្រចេះ និងខេត្តកំពង់ធំ ក្នុងនោះបានបញ្ចប់នីតិវិធី និងត្រៀមចេញប័ណ្ណសម្គាល់កាន់កាប់អចលនវត្ថុលើផ្ទៃដីទំហំ ១៣ ០៩៤ហិកតា ព្រមទាំងបាននិងកំពុងចុះអង្កេតវាស់វែងនៅទីវាលជាក់ស្តែងលើផ្ទៃដី ៣៤ ០០៧ហិកតា។

**ង- ការងារឧស្សាហកម្ម ពាណិជ្ជកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ**

- បានបង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើប្រភេទធំ (ច្រកចេញចូលតែមួយ) ក្នុងខេត្តតាកែវ ស្វាយរៀង រតនគិរី ព្រៃវែង កំពង់ធំ កណ្តាល កំពង់ស្ពឺ រាជធានីភ្នំពេញ កំពង់ចាម ត្បូងឃ្មុំ សៀមរាប ព្រះវិហារ កំពង់ឆ្នាំង និងខេត្តកំពត ស្មើនឹង ២០កន្លែង
- បានពិនិត្យបង្កើតរោងម៉ាស៊ីនអារកែច្នៃឈើ ឡជ្បូងចំនួន ១២កន្លែង ហើយបានពិនិត្យពន្យារសុពលភាពរោងម៉ាស៊ីនអារ-កែច្នៃឈើមានចំនួន ១៣កន្លែង និងបានចុះសិក្សាអត្រាកែច្នៃកូនឈើអង្កត់ផ្ចិតទំហំ ១៥-៣០ស.ម ចំនួន ០២ក្រុមហ៊ុន
- បាននាំចេញផលិតផលរានទេវតា ឈើកែច្នៃ ជ័រទឹក កម្ទេចឈើ និងប្រេងខ្យល់កាត់ជាកង់ៗទៅក្រៅប្រទេស មានបរិមាណចំនួន ២ ៣៥៩ម៉ែត្រត្រីគុណ ជ័រទឹកចំនួន ៥២៦តោន កម្ទេចឈើចំនួន ៩ ០០០តោន និងប្រេងខ្យល់កាត់ជាកង់ៗចំនួន ១០២ស្ទេរ ដោយក្រុមហ៊ុនចំនួន០៩
- បានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន១៤ មានបរិមាណឈើកែច្នៃចំនួន ៥ ១៦១ម៉ែត្រត្រីគុណ ប្រេងខ្យល់កាត់ជាកង់ៗចំនួន ៣ ៥០០ស្ទេរ កម្ទេចឈើចំនួន ៩ ០០០តោន ធ្យូងអាកាស្យាចំនួន ៤១តោន ឫស្សីកែច្នៃចំនួន ៤២តោន និងជ័រទឹកចំនួន ៤៧៦តោន
- បានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលជូនក្រុមហ៊ុនចំនួន០៥ មានបរិមាណឈើកែច្នៃចំនួន ៣ ០៦១ម៉ែត្រត្រីគុណ
- គម្រោងសហប្រតិបត្តិការក្នុងរដ្ឋបាលព្រៃឈើសរុបមានចំនួន ២០គម្រោង។

## ៤.២ ពង្រឹងការគ្រប់គ្រងសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ និងសត្វព្រៃ

**ក-ការពង្រឹងការស្រាវជ្រាវ ថែរក្សា និងអភិវឌ្ឍសត្វព្រៃ និងជីវចម្រុះ**

- បានចុះអន្តរាគមន៍ទប់ស្កាត់ និងបង្ក្រាបការជួញដូរសត្វព្រៃចំនួន ០៣ លើក នៅខេត្តរតនគិរី មណ្ឌលគិរី និងខេត្តព្រះវិហារ ដោយរឹបអូសបានសត្វអណ្តើករស់ចំនួន ០៨ ក្បាល សត្វត្រកួតរស់ចំនួន ០២ ក្បាល និងដោះអន្ទាក់សត្វព្រៃបានចំនួន ១៥ខ្សែ
- បានចុះសិក្សាស្រាវជ្រាវ និងធ្វើការតាមដានវត្តមានសត្វព្រៃចំនួន ០៦លើក នៅក្នុងតំបន់ព្រៃបម្រុងទុក អចិន្ត្រៃយ៍ និងសហគមន៍ព្រៃឈើស្ថិតក្នុងខេត្តរតនគិរី ក្រចេះ ព្រះវិហារ និងខេត្តកំពង់ស្ពឺ ដោយកត់ត្រាបានសត្វព្រៃចំនួន ១៥៥ប្រភេទ ក្នុងនោះមាន ថនិកសត្វចំនួន ៥១ ប្រភេទ បក្សីចំនួន ៦៨ប្រភេទ និងឧរង្គសត្វចំនួន ៣៦ ប្រភេទ
- បានសហការជាមួយអង្គការ FFI ចុះពិនិត្យម៉ាស៊ីនថតស្វ័យប្រវត្តិចំនួន ២៣គ្រឿង នៅតំបន់ជួរភ្នំក្រវាញ ក្នុងខេត្តកោះកុង ដោយថតជាប់សត្វព្រៃចំនួន ៤៧៧ក្បាល

- មានកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្ដាមយកកូននាំចេញចំនួន ០៨កន្លែង ស្ថិតនៅក្នុងរាជធានីភ្នំពេញ ខេត្តកំពង់ធំ សៀមរាប កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង គ្រប់គ្រងដោយក្រុមហ៊ុនចំនួន ០៧ មានសត្វស្វាក្ដាមសរុបចំនួន ៦៩ ២១៥ក្បាល ក្នុងនោះកូនកើតក្នុងខែចំនួន ៤២ ៧៩២ក្បាល ដឹកជញ្ជូនក្នុងស្រុកចំនួន ៨ ៤៩០ក្បាល និងដឹកជញ្ជូនឆ្លងទៅកាន់មាត់ច្រកអន្តរជាតិសម្រាប់នាំចេញទៅក្រៅប្រទេសចំនួន ២២ ៥៩៤ក្បាល
- បានចេញលិខិតអនុញ្ញាតដឹកជញ្ជូនសត្វព្រៃ (ស្វាក្ដាម) ចំនួន ៥៩ច្បាប់ (ពន្យារពេលចំនួន ០៤ច្បាប់) ជូនក្រុមហ៊ុន ក្នុងនោះការដឹកជញ្ជូនក្នុងស្រុកចំនួន ១៦ ច្បាប់ មានសត្វស្វាក្ដាមចំនួន ៨ ៤៩០ក្បាល និងដឹកជញ្ជូនឆ្លងទៅកាន់ច្រកអន្តរជាតិសម្រាប់នាំចេញទៅក្រៅប្រទេសចំនួន ៤៣ច្បាប់ (ពន្យារពេលចំនួន ០៤ច្បាប់) មានសត្វស្វាក្ដាមចំនួន ២២ ៥៩៤ក្បាល
- បានចេញលិខិតអនុញ្ញាតនាំចូល នាំចេញសត្វព្រៃមានដោយបង្ខូរចំនួន ០៤ច្បាប់ រួមមានឩកឡើចំនួន ៤ ០០០ក្បាល ជូនមជ្ឈមណ្ឌលសួនមេអំបៅបន្ទាយស្រី សម្រាប់នាំចេញទៅកាន់ប្រទេសអង់គ្លេសចំនួន ១ ០០០ក្បាល និងប្រទេសហូឡង់ចំនួន ៣ ០០០ក្បាល
- បានចុះជំរុញការចុះបញ្ជិកាថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារ ត្រួតពិនិត្យទីតាំងស្នើថែរក្សាសត្វព្រៃ និងត្រួតពិនិត្យការចិញ្ចឹមសត្វស្វាក្ដាមនៅតាមកសិដ្ឋានចិញ្ចឹមបង្កាត់ពូជស្វាក្ដាមរបស់ក្រុមហ៊ុនចំនួន ៣២លើក មានទីតាំងនៅរាជធានីភ្នំពេញ ខេត្តកណ្ដាល កំពង់ចាម ត្បូងឃ្មុំ កំពង់ស្ពឺ តាកែវ កំពង់ឆ្នាំង ពោធិ៍សាត់ ប៉ៃលិន បាត់ដំបង សៀមរាប ឧត្តរមានជ័យ កោះកុង កំពត រតនគិរី និងខេត្តមណ្ឌលគិរី។

**ខ-ការសិក្សាស្រាវជ្រាវ និងស្ដារព្រៃឈើឡើងវិញ**

- បានបើកវគ្គបណ្ដុះបណ្ដាលចំនួន ១០វគ្គ ស្ដីពី "ការបញ្ជ្រាបយេនឌ័រក្នុងសកម្មភាពគម្រោង" "ការអភិរក្ស និងអភិវឌ្ឍប្រភេទឈើក្នុងអំបូរគ្រញូង" "បច្ចេកទេសដាំ និងថែទាំដំណាំកសិ-រុក្ខកម្ម" "ការឆ្លុះបញ្ចាំងផ្លាស់ប្ដូរបទពិសោធន៍នៃការអនុវត្តការងារកសិ-រុក្ខកម្ម" "កសិកម្មចម្រុះ" "ការផ្សព្វផ្សាយពីផែនការដែលត្រូវអនុវត្តក្នុងការស្ដារព្រៃឈើ និងការរៀបចំជួយបង្កើនជីវភាពរស់នៅរបស់ប្រជាជនក្នុងភូមិ" "ការណែនាំឱ្យស្គាល់អំពីការប្រែប្រួលអាកាសធាតុ និងមូលហេតុ និងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ" ដោយមានអ្នកចូលរួមចំនួន ៦២៥នាក់ ក្នុងនោះមានស្ត្រីចំនួន ១៧៣នាក់ ស្ថិតក្នុងខេត្តមណ្ឌលគិរី ខេត្តកោះកុង ខេត្តសៀមរាប និងខេត្តកំពង់ធំ
- បានរៀបចំសិក្ខាសាលាស្ដីពី "បច្ចេកទេសគ្រាប់ពូជឈើ និងការកាត់បណ្ដុះឈើ" ចំនួន ០១វគ្គ ដល់សហគមន៍ព្រៃឈើត្រពាំងផ្គាំ ខេត្តកំពង់ឆ្នាំង មានអ្នកចូលរួមចំនួន ៥៨នាក់ ក្នុងនោះមានស្ត្រីចំនួន ០៨នាក់
- បានបង្កើតឡូត៍ពិសោធន៍ជ្រើសរើសប្រភពកំណើតនៃប្រភេទឈើគ្រញូងលើផ្ទៃដីទំហំ ១ហិកតា នៅក្នុងស្រុកបន្ទាយស្រីខេត្តសៀមរាប។ ឡូត៍ពិសោធន៍នេះ បង្កើតឡើងដើម្បីវាយតម្លៃដំណុះលូតលាស់នៃកូនឈើគ្រញូងដែលមានប្រភពមកពីខេត្តកំពង់ស្ពឺ ខេត្តកំពង់ធំ ខេត្តពោធិ៍សាត់ ខេត្តសៀមរាប និងខេត្តកោះកុង។ លទ្ធផលពីឡូត៍ពិសោធន៍នេះនឹងបង្ហាញថា តើកូនឈើគ្រញូងដែលមកពីប្រភពណាដុះលូតលាស់ល្អជាងគេ ហើយផ្ដើមចេញពីលទ្ធផលនេះគេអាចពង្រីកការងារដាំឈើ (ដាំដើមគ្រញូង) នៅក្នុងទីតាំងខាងលើដោយប្រើប្រាស់តែគ្រាប់ពូជមកពីប្រភពដែលល្អនោះ
- បានជួយបណ្ដុះបណ្ដាលកសិករម្នាក់នៅក្នុងខេត្តពោធិ៍សាត់ដែលជាអ្នកផលិត និងលក់កូនឈើគ្រញូង ផ្ទង់ និងនាងនួន ឲ្យបង្កើតចម្ការពូជឈើគ្រញូងទំហំកន្លះហិកតា នៅលើដីចម្ការរបស់គាត់។ ចម្ការពូជនេះនឹងផ្ដល់ផ្លែផ្កាក្នុងរយៈពេល ៣ ទៅ ៤ ឆ្នាំតែប៉ុណ្ណោះ ព្រោះវាបង្កើតឡើងដោយការ "តមែក"

- បានបោះពុម្ពឯកសារសម្រាប់ការស្រាវជ្រាវក្នុងបន្ទប់ពិសោធន៍មានដូចជា "ការប្រៀបធៀបការលូតលាស់ដំណុះគ្រាប់ពូជអ័រគីដេ *Dendrobuim draconis* Rchb.f. ដោយប្រើប្រាស់សារធាតុចិញ្ចឹមផ្សេងគ្នា" និង "ប្រៀបធៀបការបណ្តុះគ្រាប់ពូជ តាមបែបបច្ចេកទេសជាលិកាវប្បកម្ម" មានចំនួន ១០ក្បាល
- បានបោះពុម្ពខិតបណ្ណផ្សព្វផ្សាយ លទ្ធផលសិក្សាស្រាវជ្រាវមានដូចជា "វិធីសាស្ត្រផលិតកូនឈើតាមរយៈការតដើម" "វិធីសាស្ត្រផលិតកូនឈើតាមរយៈ កំណាត់បណ្តុះ ឬការកាត់ដោត" មានចំនួន ១ ០០០ច្បាប់
- បានបោះពុម្ពឯកសារ "គោលការណ៍ណែនាំអំពីការអភិវឌ្ឍគំរូស្តារព្រៃឈើ ការថែរក្សា និងការត្រួតពិនិត្យតាមដានឡូត៍ស្តារព្រៃឈើគំរូ" និង "បច្ចេកទេសអំពី ការបង្កើត ការថែទាំ និងការតាមដានប្រព័ន្ធកសិរុក្ខកម្ម និងសួនបន្លែលំនៅដ្ឋាន" មានចំនួន ២០០ក្បាល
- បានរៀបចំឯកសារត្រៀមនឹងបោះពុម្ពស្តីពីគោលការណ៍ណែនាំការបង្កើនគុណភាពព្រៃឈើនៅកម្ពុជា ចំនួន ៥០០ក្បាល
- បានសហការជាមួយ Korea Institute of Material Sciences នៃសាធារណរដ្ឋកូរ៉េ លើការស្រាវជ្រាវផលិតថង់បណ្តុះកូនឈើសរីរាង្គសម្រាប់ប្រើប្រាស់ក្នុងការបណ្តុះកូនឈើ។ តាមលទ្ធផលពិសោធន៍បង្ហាញថា កូនឈើដែលបណ្តុះក្នុងថង់ដែលផ្ទុកសារធាតុចិញ្ចឹម និងរលួយដោយធម្មជាតិមានសុខភាពល្អក្នុងការបណ្តុះកូនឈើអាកាស្យា ប្រេងខ្យល់ និងអាចប្រើប្រាស់ចំពោះប្រភេទកូនឈើហូបផ្លែ។ បច្ចុប្បន្នការសិក្សា ស្រាវជ្រាវនេះកំពុងត្រូវបានធ្វើបន្ត ដើម្បីបង្កើនគុណភាព បន្ថយកម្រាស់ថង់ និងកាត់បន្ថយថ្លៃដើម សំដៅឈានទៅរកការផលិតថង់បណ្តុះកូនឈើ សរីរាង្គជាលក្ខណៈឧស្សាហកម្ម ដើម្បីអាចប្រើប្រាស់បានទូលំទូលាយចូលរួមកាត់បន្ថយការបំពុលបរិស្ថាន
- បានចងក្រង និងបោះពុម្ពឯកសារស្រាវជ្រាវគម្រោងស្តីពី "ការគ្រប់គ្រងដីប្រកបដោយនិរន្តរភាពរបស់កសិករក្នុងការអនុវត្តប្រព័ន្ធកសិកម្មតំបន់ទំនាប" "ការប្រើប្រាស់ដីប្រកបដោយនិរន្តរភាពរបស់ជនជាតិដើមភាគតិចនៅតំបន់ភ្នំ" "សក្តានុពលនៃការប្រើផើងផ្ទុកទឹក និងជីសរីរាង្គសម្រាប់ផលិតកម្មបន្លែ សំដៅលើកកម្ពស់ជីវភាពសហគមន៍ និងកាត់បន្ថយសម្ពាធលើព្រៃឈើ" "សម្រង់បទពិសោធន៍ស្តីពីការស្តារដីរេចរឹល និងធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅតាមរយៈការអនុវត្តកសិកម្មចម្រុះ" ជាភាសារខ្មែរ-អង់គ្លេស ចំនួន ៣០០ក្បាល។
- បានបង្កើត និងថែរក្សាឡូត៍ស្រាវជ្រាវបង្កាត់ពូជឈើសំខាន់ៗចំនួន ៣២ហិកតា។

## ៤.៣ ការគ្រប់គ្រងឧទ្យានសួនសត្វ និងសង្គ្រោះថែរក្សាសត្វព្រៃ

- បានកំពុងថែរក្សាសត្វព្រៃចំនួន ១ ៦១៣ក្បាល (បក្សីចំនួន ៥៦ប្រភេទ ថនិកសត្វចំនួន ៤៥ប្រភេទ និងល្មូនចំនួន ១៦ប្រភេទ)។
- បានសង្គ្រោះសត្វព្រៃថ្មីចំនួន ១ ៧៦៤ក្បាល និងស្តារលទ្ធភាពជីវសាស្ត្ររួចលែងទៅព្រៃធម្មជាតិនូវសត្វព្រៃចំនួន១ ៣៩៦ក្បាល
- គម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការ FFI បានល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន០៥ គឺ អារ៉ែង ឆាយរាប តំបន់ស្តារក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)
- តាមដានវាយតម្លៃការអភិរក្សក្រពើប្រចាំឆ្នាំនៅតំបន់អភិរក្សសំខាន់ៗទាំង៥ខាងលើ បានរកឃើញលាមកចំនួន ៩០សំណាក ដានជើងចំនួន២៣កន្លែង និងឃើញក្រពើផ្ទាល់ចំនួន៥៣ក្បាល
- បានជួសជុលផ្លូវដោយក្រាលគ្រួសក្រហមបាន២៩ គីឡូម៉ែត្រ និងកាប់ឆ្ការអនាម័យព្រៃបានទំហំ ៥៤ហិកតា នៅក្នុងតំបន់សួនសត្វ។
-

### ៤.៤ ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ

- សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃទទួលបានពីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងក្រុមអន្តរាគមន៍បង្ក្រាបបទល្មើសសត្វព្រៃចល័តនៃរដ្ឋបាលព្រៃឈើសរុបចំនួន១ ៤៦២ករណី ក្នុងនោះសំណុំរឿងបទល្មើសព្រៃឈើត្រូវពិន័យអន្តរការណ៍ចំនួន៥៨៥ករណី និងសំណុំរឿងបទល្មើសព្រៃឈើដែលត្រូវបញ្ជូនទៅតុលាការចំនួន៨៧៧ករណី

- បានធ្វើបច្ចុប្បន្នភាពសំណុំរឿងបទល្មើសព្រៃឈើ និងសត្វព្រៃ តាមរយៈការបង់ប្រាក់ពិន័យដោយតុលាការចំនួន៤៧ករណី (ក្រុមអន្តរាគមន៍បង្ក្រាបបទល្មើសសត្វព្រៃចល័តនៃរដ្ឋបាលព្រៃឈើ០៣ករណី ខណ្ឌរដ្ឋបាលព្រៃឈើក្រចេះចំនួន២២ករណី ត្បូងឃ្មុំចំនួន០២ករណី ស្វាយរៀងចំនួន០៦ករណី រតនគិរីចំនួន ០៥ករណី កំពង់ស្ពឺចំនួន០៣ករណី កំពង់ចាមចំនួន០៥ករណី និងខណ្ឌរដ្ឋបាលព្រៃឈើកំពង់ធំចំនួន០២ករណី)។

**ក្រាហ្វិកទី២៨៖ ការទប់ស្កាត់ និងការបង្ក្រាបបទល្មើសព្រៃឈើពីឆ្នាំ២០១៥-២០២០**




**ក្រាហ្វិកទី២៩៖ បទល្មើសព្រៃឈើពិន័យអន្តរការណ៍ និងទៅតុលាការពីឆ្នាំ២០១៥-២០២០**




## ៥. លទ្ធផលនៃការពង្រឹងសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស

### ៥. ១. ការលើកកម្ពស់ការកសាង និងការអនុវត្តគោលនយោបាយ និងការវិនិយោគឯកជនកសិកម្ម

ក្នុងអាណត្តិទី៦នេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ ហើយនៅតែចាត់ទុកវិស័យកសិកម្មជាវិស័យអាទិភាព ដើម្បីចូលរួមជំរុញកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។ ក្នុងគោលដៅជំរុញការធ្វើទំនើបកម្មក្នុងវិស័យកសិកម្ម ដើម្បីឆ្លើយតបទៅនឹងការវិវឌ្ឍផ្នែកសេដ្ឋកិច្ច

របស់ប្រទេស ជាពិសេសការប្រែប្រួលពីប្រទេសដែលមានការអភិវឌ្ឍតិចតួច មកជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាននិងកំពុងជំរុញការងាររៀបចំក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រមួយចំនួនដូចខាងក្រោម៖

**ក. លទ្ធផលនៃការរៀបចំផែនការ គោលនយោបាយ និងការគ្រប់គ្រងការងារវិនិយោគ**

**ក.១ លទ្ធផលនៃការរៀបចំផែនការ គោលនយោបាយ**

ដោយមានការគាំទ្រពីថ្នាក់ដឹកនាំក្រសួង ក៏ដូចជាការចូលរួមសហការពីគ្រប់អង្គភាពជំនាញថ្នាក់កណ្តាល និងរាជធានីខេត្ត ក្នុងឆ្នាំ២០២០នេះ នាយកដ្ឋានជំនាញបានរៀបចំសេចក្តីព្រាងឯកសារគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្ម និងបានធ្វើការពិគ្រោះយោបល់ តាមរយៈកិច្ចប្រជុំក្នុងកម្រិតបច្ចេកទេសជាបន្តបន្ទាប់ (Zoom Meeting) ដើម្បីពិនិត្យពិភាក្សា និងប្រមូលធាតុចូលបន្ថែមពីអ្នកពាក់ព័ន្ធក្នុងវិស័យកសិកម្ម។ បានពិនិត្យឡើងវិញនូវរាល់ឯកសារគោលនយោបាយជាតិ និងគោលនយោបាយវិស័យពាក់ព័ន្ធ ផែនការយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍ និងឯកសារសំខាន់ៗពាក់ព័ន្ធមួយចំនួនទៀត ដើម្បីជាគោលគំនិតសម្រាប់ដាក់បញ្ចូលទៅក្នុងឯកសារគោលនយោបាយនេះ។ បានចូលរួមប្រជុំ សិក្ខាសាលា បណ្តុះបណ្តាល ពិនិត្យផ្តល់យោបល់ និងសហការសម្របសម្រួលការងារជាមួយបណ្តា ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអង្គការជាតិនិងអន្តរជាតិនានា ស្តីពីផែនការមេអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០៣០ ផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី។ បានសម្របសម្រួលរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ២០២១-២០២៣ ផែនការសកម្មភាពថវិកាកម្មវិធីឆ្នាំ២០២១ គោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មឆ្នាំ២០១៩-២០២៣ សម្រាប់មន្ទីរកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ រាជធានី ខេត្ត។ បានរៀបចំរបាយការណ៍សមិទ្ធផល ការងារក្នុងវិស័យកសិកម្មដែលចូលរួមអនុវត្តនូវគោលនយោបាយជាតិពាក់ព័ន្ធរួមមាន គោលនយោបាយជាតិស្តីពី ការអភិវឌ្ឍឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ (២) គោលនយោបាយជាតិស្តីពីមុខរបរនិងការងារឆ្នាំ២០១៥-២០២៥ (៣) គោលនយោបាយជាតិប្រជាជនឆ្នាំ២០១៦-២០៣០ (៤) គោលដៅអភិវឌ្ឍន៍ដោយ ចីរភាពឆ្នាំ២០១៦-២០៣០។

**ក.២. ការពង្រឹងប្រព័ន្ធព័ត៌មានស្ថិតិកសិកម្ម និងប្រព័ន្ធទីផ្សារកសិផល**

បានសហការជាមួយក្រសួងផែនការក្នុងការចុះធ្វើការអង្កេត ជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២០។ បានចុះពិនិត្យតាមដានសភាពការណ៍និងការងារបង្កបង្កើនផលស្រូវឆ្នាំ២០២០ និងចូលរួមចុះត្រួតពិនិត្យ គ្រោះធម្មជាតិ (ជំនន់ទឹកភ្លៀង) នៅតាមបណ្តាខេត្តដែលទទួលរងគ្រោះ។ បានរៀបចំរបាយការណ៍ការងារបង្កបង្កើនផលប្រចាំសប្តាហ៍ ជូនប្រមុខរាជរដ្ឋាភិបាល និងបានផ្សព្វផ្សាយដល់គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ថ្នាក់ដឹកនាំក្រសួង និងអង្គភាពជំនាញក្រោមឱវាទ។ បានរៀបចំរបាយការណ៍សមិទ្ធផលក្នុងវិស័យកសិកម្ម និងទិសដៅអនុវត្តបន្ត ព្រមទាំងបានផ្សព្វផ្សាយដល់គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ថ្នាក់ដឹកនាំក្រសួង និងអង្គភាពជំនាញក្រោមឱវាទ។ បានចុះស្រង់ទិន្នន័យតម្លៃទីផ្សារកសិផលទូទាំង២៥ រាជធានី ខេត្ត ដើម្បីផលិតព្រឹត្តិប័ត្រព័ត៌មានទីផ្សារ ប្រចាំខែ ប្រចាំឆ្នាំ និងបានផ្សព្វផ្សាយ ជូនគ្រប់ថ្នាក់ដឹកនាំក្រសួង និងអង្គភាពជំនាញក្រោមឱវាទ។ បានចុះប្រមូលទិន្នន័យ និងវាយតម្លៃទៅលើស្ថានភាព មានសក្តានុពលនៃផលិតភាពកសិកម្ម ព្រមទាំងកំណត់សហគមន៍គោលដៅ ដើម្បីជំរុញការអនុវត្ត និងឆ្លើយតបជាបន្ទាន់ក្នុងដំណាក់កាលនៃជំងឺកូវីដ-១៩។ បានចុះពិនិត្យតាមដានការស្រង់ព័ត៌មានតម្លៃទីផ្សារកសិកម្មនៅតាមបណ្តាខេត្តគោលដៅ និងរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ការពង្រឹងវិធីសាស្ត្រប្រមូលព័ត៌មានថ្លៃកសិផល និងអង្កេតតម្លៃកសិផលដែលមានសិក្ខាកាមសរុប ៤៤នាក់ ស្ត្រី ២០នាក់។ សិក្សាស្រាវជ្រាវព័ត៌មានតម្លៃអង្ករលើទីផ្សារអន្តរជាតិ តាមរយៈគេហទំព័រ www.haroonabdulsaltar.com; www.thairiceexporters.or.th/price.htm; www.vietnamrice. netfirms.com; www.oryza.com និងត្រួតពិនិត្យ តាមដានការប្រើប្រាស់សារជាអក្សរ និងបញ្ចូលតម្លៃជាប្រចាំក្នុងគេហទំព័រ www.amis.org.kh។

**ក.៣. ការពង្រឹងប្រព័ន្ធតាមដាន និងវាយតម្លៃ**

រៀបចំបូកសរុបរបាយការណ៍សមិទ្ធកម្មស្តីពីលទ្ធផលនៃការអនុវត្តថវិកាកម្មវិធីប្រចាំ២០២០ និងបញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ បានរៀបចំផ្ញើរបាយការណ៍សមិទ្ធផលនៃការអនុវត្តគម្រោង និងថវិកាកម្មវិធីប្រចាំឆ្នាំជូនក្រសួង។ បានបើវគ្គបណ្តុះបណ្តាល និងកិច្ចប្រជុំពិភាក្សាលើប្រព័ន្ធផែនការ តាមដាន និងវាយតម្លៃ។ បានសហការជាមួយអង្គភាពថវិកាថ្នាក់កណ្តាល និងរាជធានីខេត្ត ចុះពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តថវិកាឆ្នាំ២០២០។ បានសម្របសម្រួល និងសហការបើកវគ្គបណ្តុះបណ្តាលស្តីពី ប្រព័ន្ធតាមដាន និងវាយតម្លៃគម្រោង និងថវិកាកម្មវិធីដល់អង្គភាពពាក់ព័ន្ធ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត។ បានចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំពិគ្រោះយោបល់ពាក់ព័ន្ធនឹងផែនការអភិវឌ្ឍន៍តាមបណ្តាវិស័យ ប្រព័ន្ធតាមដាន និងវាយតម្លៃ ពង្រឹងសមត្ថភាពស្ថាប័ន សុវត្ថិភាពស្បៀង ពិពិធកម្មកសិកម្ម ការរៀបចំថវិកាកម្មវិធី និងផែនការយុទ្ធសាស្ត្រថវិកាកម្មវិធីវិនិយោគសាធារណៈ និងការងារសម្របសម្រួលនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

**៥.២. ការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបន្តរៀបចំផែនការថវិកា ដោយឈរលើគោលបំណង គោលនយោបាយរួមគឺ "ជំរុញកំណើនកសិកម្មនិងបង្កើនការនាំចេញផលិតផលកសិកម្មប្រកបដោយគុណភាព និងសុវត្ថិភាព តាមរយៈការលើកកម្ពស់ផលិតភាពកសិកម្មបង្កើនតម្លៃបន្ថែមនិងពង្រីកការប្រកួតប្រជែងទីផ្សារព្រមទាំងរក្សាបាននូវតុល្យភាពនៃការប្រើប្រាស់ដីកសិកម្ម និងធានាការគ្រប់គ្រងធនធានព្រៃឈើនិងជលផលប្រកបដោយនិរន្តរភាព"។ ក្នុងការឈានទៅសម្រេចគោលបំណងនេះ ក្រសួងបានដាក់ចេញនូវយុទ្ធសាស្ត្រសម្រាប់អនុវត្តកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ទៅតាមផ្នែកជំនាញនៃអង្គភាពថវិកាទាំង ៤៥អង្គភាព ក្នុងនោះថ្នាក់កណ្តាលមានចំនួន២០អង្គភាពថវិកានិងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន២៥ រាជធានី ខេត្ត។

ក្នុងឆ្នាំ២០២០នេះ ក្រសួងបានទទួលកញ្ចប់ថវិកាដែលជាថវិការបស់រាជរដ្ឋាភិបាល សម្រាប់ចំណាយក្នុងការអនុវត្តចង្កោម សកម្មភាពនៃអនុកម្មវិធី កម្មវិធី សរុបចំនួន ២៨០ ៩២៤លានរៀល។ ថវិកានេះបានបែងចែកសម្រាប់រដ្ឋបាលកណ្តាលចំនួន ១៧១ ៣២៥លានរៀល និងមន្ទីររាជធានីខេត្តចំនួន ១០៩ ៥៩៩លានរៀល។ ចំពោះលទ្ធផលនៃការអនុវត្តថវិកាក្នុងឆ្នាំ២០២០ សម្រេចបានដូចខាងក្រោម:

**១-ផ្នែកចំណូល**: ក្រសួងសម្រេចអនុវត្តប្រមូលចំណូលសរុបបានចំនួន ៤៨ ០៨២,២លានរៀល ស្មើនឹង ១១៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ ក្នុងនោះចំណូលពីផលទុននៃទ្រព្យសម្បត្តិរដ្ឋមានចំនួន១៦ ២៧២,៤ ស្មើនឹង ៥៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ ចំណូលពីផលទុននៃការលក់ ជួលទ្រព្យសម្បត្តិ និងសេវាមានចំនួន ១៩ ៤៩៣,៧ ស្មើនឹង១៨១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ ចំណូលពីការផាកពិន័យ និងការដាក់ទណ្ឌកម្មអនុវត្តមានចំនួន១២ ២១៧,២ លានរៀល ស្មើនឹង ៤២៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ និងផលហិរញ្ញវត្ថុមានចំនួន៩៨,៩លានរៀល។

**២-ផ្នែកចំណាយ**: បានអនុវត្តចំណាយថវិកាសរុបបានចំនួន ១២៥ ០៧៣,៦លានរៀល ស្មើនឹង៧៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ និងស្មើនឹង៨៦%ធៀបនឹងឥណទានកែតម្រូវ ក្នុងនោះចំណាយលើការទិញមានចំនួន១៥ ២៣៤,៨លានរៀល ស្មើនឹង៨២% ធៀបនឹងឥណទានកែតម្រូវ ចំណាយលើសេវាកម្មមានចំនួន២២ ០៦៩,៧លានរៀល ស្មើនឹង៩៥% ធៀបនឹងឥណទានកែតម្រូវ។ ចំពោះចំណាយលើអត្ថប្រយោជន៍សង្គមមិនបានអនុវត្ត ដោយបញ្ហាជំងឺកូវីដ-១៩ (រាជរដ្ឋាភិបាលបានផ្អាកការប្រឡងជ្រើសរើសមន្ត្រីរាជការចូលក្របខ័ណ្ឌថ្មី)។ ចំណាយលើពន្ធអាករមានចំនួន ២៤១,៥លានរៀល ស្មើនឹង៨៤% ធៀបនឹងឥណទានកែតម្រូវ ចំណាយលើបន្ទុកបុគ្គលិកមានចំនួន៦៨ ៥៤៣,៨លានរៀល ស្មើនឹង៩៤% ធៀបនឹងឥណទានកែតម្រូវ និងចំណាយលើការឧបត្ថម្ភធនដល់គ្រឹះស្ថានសាធារណៈមានលក្ខណៈរដ្ឋបាល មានចំនួន១៨ ៩៨៣,៨លានរៀល ស្មើនឹង៩៧%ធៀបនឹងច្បាប់ហិរញ្ញវត្ថុ។

៣. **គម្រោងថវិកាវិនិយោគរបស់រាជរដ្ឋាភិបាលៈ** ក្នុងឆ្នាំ២០២០នេះ បានទូទាត់ចំណាយថវិកាវិនិយោគ ជំពូក២១ (**គម្រោងវិនិយោគផ្ទាល់**) ក្នុងនោះ បានទូទាត់លើការចំណាយថវិកាវិនិយោគក្នុងជំពូក២១ មានចំនួន ១៦ ០០០ ០០០ ០០០រៀល។ បានទូទាត់ថវិកាវិនិយោគជំពូក២១ សរុបមានចំនួន ៨ ៩៥១ ៨៦៦ ០០០រៀល ក្នុងនោះ កិច្ចសន្យាដើម្បីទូទាត់ជូនក្រុមហ៊ុនសំណង់បុរីកម្មករ លើការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធគាំទ្រផ្នែកបន្លែ (ផ្ទះសំណាញ់ បំពាក់ស៊ីទែនទឹកចំណុះ១ ៥០០លីត្រ និងប្រព័ន្ធលាយជីស្វ័យប្រវត្តិ) សម្រាប់គាំទ្រគម្រោង កម្មវិធីជំរុញផលិតកម្មស្បៀងដែលមានតម្លៃ ១ ៦១៥ ៨៦៦ ០០០រៀល ស្មើនឹង១០០% នៃតម្លៃកិច្ចសន្យា បានទូទាត់ដំណាក់កាលទី១ ជូនក្រុមហ៊ុន សំណង់ បុរី កម្មករ ខូអិលធីឌី លើការងារសាងសង់សំណង់ ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត នៅតាមស្ថានីយពិសោធន៍កសិកម្ម ស្ថិតនៅខេត្តកំពង់ស្ពឺ និងខេត្តកណ្ដាល សរុបចំនួន២ ៩៣៤ ៤០០ ០០០រៀល ស្មើនឹង ៤០% នៃតម្លៃកិច្ចសន្យា និងបានទូទាត់ដំណាក់កាលទី២ ជូនក្រុមហ៊ុនសំណង់បុរីកម្មករ ខូអិលធីឌី លើការងារសាងសង់សំណង់ហេដ្ឋារចនាសម្ព័ន្ធ រូបវ័ន្តនៅតាមស្ថានីយពិសោធន៍កសិកម្ម ស្ថិតនៅក្នុងខេត្តកំពង់ស្ពឺ និងខេត្តកណ្ដាល សរុបចំនួន៤ ៤០១ ៦០០ ០០០រៀល ស្មើនឹង៦០% នៃតម្លៃកិច្ចសន្យា។

៤. **ប្រាក់កក់ និងថ្លៃសម្បទានដីសេដ្ឋកិច្ចៈ** បានទទួលបង្កាន់ដៃបង់ប្រាក់កក់ពីក្រុមហ៊ុនចំនួន ០១ ( Pacific Victory Joint-Stock Company limited)។ បានចុះបំពេញបេសកកម្មប្រមូលថ្លៃសម្បទានដីសេដ្ឋកិច្ចសរុបមានចំនួន ៦៧ ក្រុមហ៊ុន ក្នុងខេត្តចំនួន ០៨។ បានទទួលចំណូលពីការបង់ថ្លៃសម្បទានដីសេដ្ឋកិច្ចពីក្រុមហ៊ុនចំនួន៣៩ ដែលមានទឹកប្រាក់សរុប ចំនួន១ ៤២១ ៤៣៣,៧៥$ ស្មើនឹង ៥ ៨០០ ៦៦០ ៣៩២រៀល និងបានធ្វើបច្ចុប្បន្នភាពព័ត៌មានក្នុងបញ្ជីតាមដានក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច។

៥. **ការងារបិទ និងបើកបញ្ជីប្រគល់ ទទួលទ្រព្យសម្បត្តិៈ** បានចុះបិទ និងបើកបញ្ជីប្រគល់ទទួលថវិកា និងទ្រព្យសម្បត្តិសម្រាប់ការផ្ទេរតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំដែលត្រូវផ្លាស់ប្តូរ និងចូលនិវត្តន៍ នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្វាយរៀង វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម និងវិទ្យាស្ថានស្រាវជ្រាវ កៅស៊ូកម្ពុជា។ បានចុះពិនិត្យ និងវាយតម្លៃទ្រព្យសម្បត្តិរបស់គម្រោងកម្មវិធី "ជំរុញកំណើនវិស័យកសិកម្មប្រកបដោយចីរភាព និងបរិយាប័ន្នអនុវិស័យជលផល និងផលិតកម្មសត្វ" របស់អនុវិស័យបសុសត្វ ក្រោមជំនួយឥតសំណងរបស់សហភាពអឺរ៉ុបដែលបានបញ្ចប់ ដើម្បីប្រគល់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ បានពិនិត្យ វាយតម្លៃបញ្ចប់សុពលភាពស្តីពីការសាងសង់ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព ឃ្លាំងដាក់គ្រឿងយន្ត ផ្ទះសំណាញ់ លានហាលស្រូវ អាងស្តុកទឹកអាកាស អាងស្តុកទឹកបឋម នៅតាមមណ្ឌលអភិវឌ្ឍន៍កសិកម្ម និងស្ថានីយពិសោធន៍ កសិកម្មចំនួន ០៤កន្លែងរបស់អគ្គនាយកដ្ឋានកសិកម្ម នៅខេត្តកណ្ដាល តាកែវ ស្វាយរៀង និងខេត្តឧត្តរមានជ័យ។ បានចុះពិនិត្យ និងវាយតម្លៃទ្រព្យសម្បត្តិរបស់គម្រោងកម្មវិធី "ជំរុញកំណើនវិស័យកសិកម្មប្រកបដោយចីរភាពនិងបរិយាប័ន្នៈ អនុវិស័យជលផល និងផលិតកម្មសត្វ" របស់អនុវិស័យជលផល ក្រោមជំនួយឥតសំណងរបស់សហភាពអឺរ៉ុបដែលបានបញ្ចប់ ដើម្បីប្រគល់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ បានចូលរួមដេញថ្លៃ លក់ជាសាធារណៈនូវទ្រព្យសម្បត្តិចាស់ៗ ខូចទ្រុឌទ្រោមប្រើប្រាស់លែងកើត ដែលស្នើសុំជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តបាត់ដំបង។

៦. **ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** បានចូលរួមប្រជុំ Online ជាមួយក្រុមបេសកកម្មរបស់ ADB លើវឌ្ឍនភាពនៃការអនុវត្តគម្រោងពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ បានចូលរួមកិច្ចប្រជុំបូកសរុបស្តីពីការអនុវត្តគម្រោងពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំឆ្នាំ២០២០ ក្រោមកិច្ចព្រមព្រៀងហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ីតាមរយៈប្រព័ន្ធវីឌីអូអនឡាញ។ បានរៀបចំរបាយការណ៍សមិទ្ធកម្មនៃការអនុវត្តផែនការសកម្មភាពប្រចាំត្រីមាសទី៣ ឆ្នាំ២០២០ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ បានចូលរួមកិច្ចប្រជុំ ស្តីពីការរៀបចំថវិកា និងលទ្ធផលគន្លឹះក្នុងឆ្នាំ២០២១ ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមរយៈប្រព័ន្ធវីឌីអូ ឯកឧត្តមអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**៧ . ការងារផ្គត់ផ្គង់ និងគ្រប់គ្រងសន្និធិ:** បានទទួលគ្រប់គ្រងសន្និធិឃ្លាំងដោយបានធ្វើការបញ្ចូលបញ្ចេញ និងបែងចែកបើកផ្តល់ជូនបណ្តាអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនូវប្រេងឥន្ធនៈ សម្ភារការិយាល័យ សម្ភារបរិក្ខារ និងសង្ហារិម សម្រាប់ការប្រើប្រាស់ប្រចាំឆ្នាំ២០២០ ដែលមានថវិកាសរុបចំនួន ១ ៣១៣ ១៦៣ ០០០រៀល ក្នុងនោះ ប្រេងឥន្ធនៈមានថវិកាចំនួន ៨៣៤ ៨៥០ ០០០រៀល សម្ភារការិយាល័យ មានថវិកាចំនួន ១១៥ ១០២ ០០០រៀល សម្ភារបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា មានថវិកាចំនួន ២៨៤ ២៤១ ០០០រៀល សម្ភារបរិក្ខារបច្ចេកទេសមិនមែន ព័ត៌មានវិទ្យា មានថវិកាចំនួន ៧៨ ៩៧០ ០០០រៀល។

**៨. ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ:** បានចូលរួមពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០១៩ របស់អង្គភាពថ្នាក់កណ្តាល ក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី-ខេត្តទាំង២៥។ បានជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលព្រៃឈើ អគ្គាធិការ-ដ្ឋាន នាយកដ្ឋានកិច្ចការរដ្ឋបាល នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបង។ បានចូលរួមដេញថ្លៃលក់ជាសាធារណៈនូវសត្វគោចំនួន០៤ក្បាល ដែលបានស្នើសុំជម្រះចេញពីបញ្ជីរបស់ស្ថានីយចិញ្ចឹមគោពូជភ្នំតាម៉ៅ នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ។ បានចុះពិនិត្យ និងវាយតម្លៃទ្រព្យសម្បត្តិរបស់គម្រោងកម្មវិធី "ជំរុញវិស័យកសិកម្មប្រកបដោយចីរភាព និងបរិយាប័ន្នៈអនុវិស័យជលផល និងផលិតកម្មសត្វ" របស់អនុវិស័យផលិតកម្មសត្វ និងអនុវិស័យជលផល ក្រោមជំនួយហិរញ្ញប្បទានឥតសំណងរបស់សហភាពអឺរ៉ុប និងគម្រោង FAO ស្តីពីគំនិត ផ្តួចផ្តើមគ្រប់គ្រងសុខភាពសត្វ បរិស្ថានអនុតំបន់សម្រាប់ផលិតកម្មសត្វតាមគ្រួសារ-(EAHIM) ដែលត្រូវប្រគល់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ រដ្ឋបាលជលផល និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តទាំង២៥។ បានចូលរួមប្រជុំពិនិត្យ វាយតម្លៃទីតាំងដី០១កន្លែង ដែលស្នើសុំកត់ត្រាចូលក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលជលផល ទីតាំងដីកសិដ្ឋានផលិតពូជស្រូវទួលសំរោងរបស់អគ្គនាយកដ្ឋានកសិកម្ម ទីតាងដី០១កន្លែងនៅភូមិប្រសូតិ២ ឃុំកណ្តៀងរាយ ស្រុកស្វាយទាប ខេត្តស្វាយរៀង។ ពិនិត្យ សិក្សានិងវាយតម្លៃទីតាំងដីរដ្ឋបាលជលផល ដែលត្រូវធ្វើការដោះដូរជាមួយក្រុមហ៊ុនម៉ូឌែនវីសិនគ្រុប ខូអិលធីឌី ទីតាំងដីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តព្រះសីហនុ ដែលត្រូវធ្វើការដោះដូរជាមួយក្រុមហ៊ុន ស៊ីខេខេ អ៊ិនវេសមិន ឯ.ក ការដោះដូរទីតាំងដី អធិការដ្ឋាន រដ្ឋបាលព្រៃឈើ ឈូងសមុទ្រនៃរដ្ឋបាលព្រៃឈើ ពិនិត្យនិងវាយតម្លៃការលក់ផ្តាច់ចំណែកដីសម្បទានរបស់ក្រុមហ៊ុន អាហ្គ្រោស្តារវិនិយោគ ពិនិត្យនិងផ្ទៀងផ្ទាត់បញ្ជីគណនេយ្យឆ្នាំ២០១៩ របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តទាំង២៥។

**៩. ការងារលទ្ធកម្មសាធារណៈ** បានចូលរួមនិងជួយរៀបចំឯកសារអង្គភាពលទ្ធកម្មសម្រាប់ដំណើរការអនុវត្តកិច្ចលទ្ធកម្មសម្រាប់បម្រើឱ្យការផ្គត់ផ្គង់ទំនិញ ការសាងសង់ ជួសជុលសំណង់ សេវាកម្ម និងសេវាទីប្រឹក្សាជូនអង្គភាពនានាក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សរុបចំនួន២៥គម្រោង ដែលមានថវិកាសរុបចំនួន ២១ ៧៦៤ ៨៩៥ ៩០០រៀល ក្នុងនោះ កិច្ចលទ្ធកម្មទំនិញមានចំនួន ១៤គម្រោង មានទឹកប្រាក់សរុបចំនួន ៧ ៨៨២ ៣៦៥ ៩០០រៀល កិច្ចលទ្ធកម្មសំណង់មានចំនួន ០៧គម្រោង មានទឹកប្រាក់សរុបចំនួន ១១ ០១៩ ៩៨២ ០០០ រៀល កិច្ចលទ្ធកម្មសេវាកម្មមានចំនួន ០៤គម្រោង មានទឹកប្រាក់សរុបចំនួន ២ ៨៦២ ២៧៨ ០០០រៀល។ បានចូលរួមចុះពិនិត្យវាយតម្លៃបញ្ចប់សុពលភាពថែទាំគុណភាពសំណង់សម្រាប់ការអនុវត្តកិច្ចសន្យាលទ្ធកម្ម សំណង់ចំនួន ០៦គម្រោង ដែលរួមមាន៖ (១) បានចុះពិនិត្យវាយតម្លៃបញ្ចប់សុពលភាពការងារជីកប្រឡាយ ការពារ តំបន់ចម្ការឈើដាំគ្រញូងនៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើនៅខេត្តកំពង់ធំ និងខេត្តព្រះសីហនុ ប្រចាំឆ្នាំ ២០១៩ (២) បានចុះពិនិត្យវាយតម្លៃបញ្ចប់សុពលភាពស្តីពីការងារជួសជុល កែលម្អអគាររដ្ឋបាលប្រចាំឆ្នាំ២០១៩ របស់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (៣) បានចុះពិនិត្យ វាយតម្លៃបញ្ចប់សុពលភាព ស្តីពីការងារជួសជុលប្រព័ន្ធការពារភ្លើងឆេះ អនាម័យទ្រុងសត្វ និងបណ្តាញផ្លូវទឹកពីទន្លេបាទីនៅឧទ្យានសួនសត្វ និងមណ្ឌលសង្គ្រោះសត្វ

ព្រៃភ្នំតាម៉ៅ ជួសជុលរបង និងក្លោងទ្វារវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើសត្វព្រៃ និងអគាររដ្ឋបាលរបស់រដ្ឋ-បាលព្រៃឈើប្រចាំឆ្នាំ២០១៩ (៤) ការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព ឃ្លាំងដាក់គ្រឿងយន្ត ផ្ទះសំណាញ់ លានហាលស្រូវ អាងស្តុកទឹកអាកាស អាងស្តុកទឹកបឋម នៅតាមមណ្ឌលអភិវឌ្ឍន៍ កសិកម្ម និងស្ថានីយពិសោធន៍កសិកម្មចំនួន០៤កន្លែង របស់អគ្គនាយកដ្ឋានកសិកម្ម នៅខេត្តកណ្តាល តាកែវ ស្វាយរៀង និងខេត្តឧត្តរមានជ័យ (៥) ការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធគាំទ្រផ្នែកបន្លែ និងស្រូវសម្រាប់ដំណើរការគម្រោងកម្មវិធីជំរុញផលិតកម្មស្បៀងឆ្នាំ២០១៨ របស់អគ្គនាយកដ្ឋានកសិកម្ម នៅតាមខេត្តគោលដៅដូចជា ខេត្តកណ្តាល តាកែវ កំពង់ស្ពឺ កំពង់ធំ បាត់ដំបង និងខេត្តព្រៃវែង (៦) ការងារបោះបង្គោលព្រំប្រទល់ ព្រៃលិចទឹក បង្គោលអភិរក្សជលផល និងស្នាក់ការបណ្តែតទឹកប្រចាំឆ្នាំ២០១៩ របស់រដ្ឋបាលជលផល។

## ៥.៣. ការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យកសិកម្ម

### ៥.៣.១. ការគ្រប់គ្រងធនធានមនុស្ស

ក្នុងឆ្នាំ២០១៩នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានមន្ត្រីរាជការសរុបចំនួន៥ ៩៣៩នាក់ នារី ១ ៤៥៣នាក់ ស្មើនឹង២៤,៤៦% ក្នុងនោះអង្គភាពថ្នាក់កណ្តាលមានចំនួន២ ៩១៥នាក់ នារី៨៣៣នាក់ ស្មើនឹង ២៨,៥៧% ថ្នាក់រាជធានី ខេត្តមានចំនួន៣ ០២៤នាក់ នារី៦២០នាក់ ស្មើនឹង២០,៥០%។ ទន្ទឹមនឹងនេះ ក្រសួងបានដាក់មន្ត្រីឱ្យចូលនិវត្តន៍ចំនួន១១៣នាក់ នារី១៧នាក់ និងចូលនិវត្តន៍មុនអាយុចំនួន១១នាក់ នារី០១នាក់ មន្ត្រីស្ថិតក្នុងភាពទំនេរគ្មានបៀវត្សចំនួន៥៩នាក់ នារី១៩នាក់ និងបានលុបឈ្មោះមន្ត្រីចេញពីក្របខ័ណ្ឌចំនួន ៤៦នាក់ នារី១១នាក់ (បោះបង់ការងារ លាឈប់ពីការងារ និងមរណភាព)។ ក្រសួងបានធ្វើការប្រឡងប្រជែងជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មីចំនួន១២០នាក់ (ក្របខ័ណ្ឌ"ក"ចំនួន១១៧នាក់ នារីចំនួន៣៨នាក់ និង"ខ"ចំនួន០៣នាក់ និងបានតែងតាំង និងផ្ទេរសម្រួលភារកិច្ចមន្ត្រីរាជការបានចំនួន៤២៣នាក់ នារីចំនួន១១៧នាក់។

ផ្អែកតាមក្រាហ្វិកនៃស្ថានភាពក្របខ័ណ្ឌមន្ត្រីរាជការក្នុងរយៈពេល០៥ឆ្នាំ (២០១៥-២០១៩) ឃើញថាចំនួនក្របខ័ណ្ឌបានថយចុះជាបន្តបន្ទាប់ទន្ទឹមនឹងក្របខ័ណ្ឌថ្មីទទួលបាន មិនមានតុល្យភាពនឹងក្របខ័ណ្ឌដែលបានបាត់បង់។ ករណីនេះជាបញ្ហាប្រឈមសម្រាប់ការចូលរួមអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសកម្មវិធីកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការធ្វើឱ្យសម្រេចជោគជ័យនូវផែនការយុទ្ធសាស្ត្ររបស់ក្រសួង ។

### ៥.៣.២. ការអភិវឌ្ឍធនធានមនុស្ស

ក្នុងឆ្នាំ២០២០នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានមន្ត្រីរាជការសរុបចំនួន៥ ៨៥០នាក់ ស្ត្រី ១ ៤២០នាក់ ស្មើនឹង២៤,២៧% ក្នុងនោះអង្គភាពថ្នាក់កណ្តាលមានចំនួន២ ៩២០នាក់ ស្ត្រី៨២៤នាក់ ស្មើនឹង ២៨,២១% ថ្នាក់រាជធានី ខេត្តមានចំនួន២ ៩៣០នាក់ ស្ត្រី៥៩៦នាក់ ស្មើនឹង២០,៣៤%។ ទន្ទឹមនឹងនេះ ក្រសួងបានដាក់មន្ត្រីឱ្យចូលនិវត្តន៍ចំនួន ២៣នាក់ ស្ត្រី១៣នាក់ និងចូលនិវត្តន៍មុនអាយុចំនួន៣៧នាក់ ស្ត្រី០៩នាក់ ដាក់មន្ត្រីស្ថិតក្នុងភាពទំនេរគ្មានបៀវត្សចំនួន៤៥នាក់ ស្ត្រី១៤នាក់ និងបានលុបឈ្មោះមន្ត្រីចេញពីក្របខ័ណ្ឌចំនួន២៧នាក់ ស្ត្រី ០៤នាក់ (បោះបង់ការងារ លាឈប់ពីការងារ និងមរណភាព)។ ក្រសួងបានទទួលមន្ត្រីក្របខ័ណ្ឌថ្មីចំនួន១២នាក់ (ក្របខ័ណ្ឌ"ក"ចំនួន០៤នាក់ និង"ខ"ចំនួន០៨នាក់) ពីសាលាភូមិន្ទរដ្ឋបាល តាមរយៈសេចក្តីសម្រេចរបស់ក្រសួងមុខងារសាធារណៈ និងបានតែងតាំងដំឡើងឋានៈ និងផ្ទេរសម្រួលភារកិច្ចមន្ត្រីរាជការបានចំនួន១១៩នាក់ ស្ត្រីចំនួន៣៤នាក់។ ម្យ៉ាងវិញទៀត ក្រសួងបានធ្វើសមាហរណកម្មមន្ត្រីរាជការដែលកំពុងបំពេញការងារនៅការិយាល័យកសិកម្មក្រុង ស្រុក ខណ្ឌ នៅតាមបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ចំនួន ៧៧៤នាក់ ក្នុងនោះស្ត្រី១៥០នាក់ និងមន្ត្រីជាប់កិច្ចសន្យាចំនួន១៨នាក់ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ (រាជធានី ក្រុង ស្រុក ខណ្ឌ)នៃក្របខ័ណ្ឌក្រសួងមហាផ្ទៃ។

ផ្អែកតាមក្រាហ្វិកនៃស្ថានភាពក្របខ័ណ្ឌមន្ត្រីរាជការក្នុងរយៈពេល០៥ឆ្នាំ (២០១៦-២០២០) ឃើញថាចំនួនក្របខ័ណ្ឌបានថយចុះជាបន្តបន្ទាប់ទន្ទឹមនឹងក្របខ័ណ្ឌថ្មីទទួលបាន មិនមានតុល្យភាពនឹងក្របខ័ណ្ឌដែលបានបាត់បង់។ ករណីនេះជាបញ្ហាប្រឈមសម្រាប់ការចូលរួមអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសកម្មវិធីកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការធ្វើឱ្យសម្រេចជោគជ័យនូវផែនការយុទ្ធសាស្ត្ររបស់ក្រសួង។

**ក្រាហ្វិកទី៣០៖ ស្ថានភាពមន្ត្រីរាជការក្រខ័ណ្ឌឆ្នាំ២០១៦-២០២០**




ជាមួយគ្នានេះ ដើម្បីឆ្លើយតបទៅនឹងកំណែទម្រង់ស៊ីជម្រៅនិងកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកំពុងរៀបចំប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមព័ត៌មានវិទ្យា (HRMIS) ដោយនឹងដាក់ឱ្យដំណើរការជាផ្លូវការនៅឆ្នាំ២០២១នេះ និងបានរៀបចំគោលនយោបាយធនធានមនុស្សសម្រាប់វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទផងដែរ។

### ៥.៣.៣. ការងារបណ្តុះបណ្តាលនិស្សិត

នៅក្នុងនីតិកាលកន្លងមក យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលបានកំណត់អាទិភាពចម្បងចំនួន៤ គឺៈ ផ្លូវ ទឹក ភ្លើង និងមនុស្ស។ ប៉ុន្តែនៅក្នុងបរិបទសេដ្ឋកិច្ចពុទ្ធិ និងបច្ចេកវិទ្យាទំនើបប្រកបដោយឧត្តមភាព និងការប្រកួតប្រជែងដែលមានសន្ទុះយ៉ាងខ្លាំងក្លា រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា បានផ្តល់ការយកចិត្តទុកដាក់កាន់តែខ្លាំងលើការអភិវឌ្ឍធនធានមនុស្ស មានន័យថា ប្រែក្លាយអាទិភាពចម្បងចំនួន៤ នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ គឺៈ មនុស្ស ផ្លូវ ភ្លើង និងទឹក ដែលត្រូវអនុវត្តបន្តទៀតនៅក្នុងដំណាក់កាលទី៤នេះ ។

ដើម្បីឆ្លើយតបទៅនឹងការកំណត់អាទិភាព "មូលធនមនុស្ស" របស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការប្រកបដោយគុណវុឌ្ឍិខ្ពស់តាមរយៈការបណ្តុះបណ្តាលរយៈពេលខ្លី មធ្យម និងរយៈពេលវែងទាំងក្នុង និងក្រៅប្រទេស។

ជាក់ស្តែងក្នុងឆ្នាំ២០២០ ក្រសួងបានបណ្តុះបណ្តាលមន្ត្រីរាជការសរុបចំនួន២ ៧៣៤នាក់ ស្ត្រី៦២៦នាក់។ វគ្គបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លីនិងមធ្យមសរុបមានចំនួន២ ៣៤១នាក់ ស្ត្រី៥៣៤នាក់ និងវគ្គបណ្តុះបណ្តាលក្រៅប្រទេសសរុបមានចំនួន៣៩៣នាក់ ស្ត្រី៩២នាក់ ក្នុងនោះ៖ វគ្គបណ្តុះបណ្តាលរយៈពេលខ្លី និងមធ្យម មានចំនួន៣៧៣នាក់ ស្ត្រី៨៤នាក់ និងវគ្គបណ្តុះបណ្តាលរយៈពេលវែងមានចំនួន២០នាក់ ស្ត្រីចំនួន ០៨នាក់ (ថ្នាក់បណ្ឌិតចំនួន ០៥នាក់ និងបរិញ្ញាជាន់ខ្ពស់ចំនួន១៥នាក់)។

នៅក្នុងបរិបទនៃវិបត្តិជំងឺឆ្លងកូវីដ-១៩ បានកំពុងរីករាលដាលជាសាកលនិងជះឥទ្ធិពលអាក្រក់ដល់សេដ្ឋកិច្ច និងសង្គមនៅតាមបណ្តាប្រទេសស្ទើរតែទាំងអស់ពេញពិភពលោក រួមទាំងកម្ពុជាយើងយ៉ាងណាក្តី ក៏ក្រសួងនៅតែ

ផ្ដោតការយកចិត្តទុកដាក់លើការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ ដោយបានធ្វើការសម្របសម្រួល និងសហការជាមួយអង្គភាពក្រោមឱវាទនិងដៃគូអភិវឌ្ឍន៍នានាធ្វើការបណ្ដុះបណ្ដាលពាក់ព័ន្ធតាមរយៈប្រព័ន្ធអនឡាញ (Online)។

តារាងទី១៖ ស្ថិតិបណ្ដុះបណ្ដាលវគ្គខ្លី មធ្យម និងវែង របស់មន្ត្រីរាជការ និស្សិត នៅក្នុងប្រទេសនិងក្រៅប្រទេស របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០២០

| ល.រ | ប្រទេស | បណ្ដុះបណ្ដាលវគ្គខ្លី(នាក់) | ថ្នាក់កម្រិតសញ្ញាបត្រ | | | សរុប | |
|---|---|---|---|---|---|---|---|
| | | | ថ្នាក់បរិ. | ថ្នាកបរិ.ជាន់ខ្ពស់ | ថ្នាក់បណ្ឌិត | ចំនួន (នាក់) | ស្ត្រី |
| I. វគ្គបណ្ដុះបណ្ដាលនៅក្នុងប្រទេស | | | | | | | |
| ១ | ក្នុងប្រទេស | ២ ៣៤១ | | | | ២ ៣៤១ | ៥៣៤ |
| សរុប I | | ២ ៣៤១ | | | | ២ ៣៤១ | ៥៣៤ |
| II. វគ្គបណ្ដុះបណ្ដាលនៅក្រៅប្រទេស | | | | | | | |
| ២ | កូរ៉េ | ២២ | | ១០ | ១ | ៣៣ | ១០ |
| ៣ | ជប៉ុន | ២០ | | ៤ | ២ | ២៦ | ១៤ |
| ៤ | ឡាវ | ៩ | | | | ៩ | ១ |
| ៥ | ថៃ | ២៦ | | ១ | ១ | ២៨ | ៩ |
| ៦ | ចិន | ៤ | | | | ៤ | ០ |
| ៧ | វៀតណាម | ៤៦ | | | | ៤៦ | ១១ |
| ៨ | ហ្វីលីពីន | ៣ | | | | ៣ | ១ |
| ៩ | កោះតៃវ៉ាន់ | ២ | | | | ២ | ០ |
| ១០ | អូស្ត្រាលី | ៣ | | | | ៣ | ២ |
| ១១ | នូវែលហ្សឺឡង់ | ៤ | | | | ៤ | ១ |
| ១២ | សហរដ្ឋអាមេរិក | ២ | | | | ២ | ០ |
| ១៣ | ព័រទុយហ្គាល់ | ៥ | | | | ៥ | ២ |
| ១៤ | បែលហ្ស៊ិក | ១ | | | | ១ | ១ |
| ១៥ | មីយ៉ាន់ម៉ា | ១០ | | | | ១០ | ២ |
| ១៦ | ម៉ាឡេស៊ី | ៥ | | | | ៥ | ០ |
| ១៧ | រុស្ស៊ី | ៣ | | | | ៣ | ០ |
| ១៨ | ហូឡង់ | ២ | | | | ២ | ១ |
| ១៩ | ឥណ្ឌា | ១ | | | | ១ | ០ |
| ២០ | ឥណ្ឌូនេស៊ី | ៥ | | | | ៥ | ១ |
| ២១ | អាឡឺម៉ង់ | | | | ១ | ១ | ០ |
| ២២ | អ៊ីស្រាអែល (និស្សិត១១ខែ) | ២០០ | | | | ២០០ | ៣៦ |
| សរុប II | | ៣៧៣ | ០ | ១៥ | ៥ | ៣៩៣ | ៩២ |
| សរុប I+II | | ២ ៧១៤ | ០ | ១៥ | ៥ | ២ ៧៣៤ | ៦២៦ |

តារាងទី២៖ ស្ថិតិមន្ត្រីដែលបានបញ្ចប់ការសិក្សារយៈពេលវែង នៅក្រៅប្រទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០២០

| ល.រ | ឈ្មោះប្រទេស | កម្រិតសញ្ញាបត្រ | | សរុប | |
|---|---|---|---|---|---|
| | | បរិញ្ញាជាន់ខ្ពស់ | បណ្ឌិត | ចំនួន(នាក់) | ស្ត្រី |
| ១ | ថៃ | | ១ | ១ | |
| ២ | ជប៉ុន | ១ | ១ | ២ | |
| ៣ | កូរ៉េ | ៥ | | ៥ | ១ |
| ៤ | ចិន | | ១ | ១ | |
| ៥ | វៀតណាម | ១ | | ១ | |
| ៦ | អូស្ត្រាលី | ១ | | ១ | |
| ៧ | ម៉ាឡេស៊ី | ១ | | ១ | |
| ៨ | ហុងគ្រី | | ១ | ១ | |
| **សរុប** | | **៩** | **៤** | **១៣** | **១** |

### ៥.៣.៣. ការងារបណ្តុះបណ្តាលនិស្សិត

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានគ្រឹះស្ថានសិក្សាបច្ចេកទេសកសិកម្មចំនួនបីគឺ សាកលវិទ្យាល័យភូមិន្ទកសិកម្ម (ស.រ.ភ.ក) វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប (វ.ជ.ក.ព.ល) និងវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម (វ.ជ.ក.ក.ច)។

តារាងទី៣៖ ស្ថិតិមន្ត្រី គ្រូបង្រៀន និស្សិត របស់គ្រឹះស្ថានសិក្សាបច្ចេកទេសកសិកម្មទាំងបី ឆ្នាំ២០២០

| ល.រ | គ្រឹះស្ថានសិក្សា | បណ្ឌិត | | អនុបណ្ឌិត | | បរិញ្ញាបត្រ | | បរិញ្ញាបត្ររង | | បឋម | | គ្មានជំនាញ | | សរុបរួម | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី |
| **១** | **សាកលវិទ្យាល័យភូមិន្ទកសិកម្ម** | | | | | | | | | | | | | | |
| ក | *ចំនួនមន្ត្រី* | ៣០ | ៥ | ១០៤ | ៣៣ | ២៧ | ១០ | - | - | ៦ | ៥ | - | - | ១៦៧ | ៥៣ |
| ខ | *ចំនួននិស្សិត* | ៣០ | ២ | ៩០ | ៣០ | ៣១១៥ | ១២៥៩ | ១៣៥ | ៥៦ | - | - | - | - | ៣៣៧០ | ១៣៤៧ |
| | អាហារូបករណ៍ | - | - | - | - | ៨០៤ | ៤០៧ | ៤ | ១ | - | - | - | - | ៨០៨ | ៤០៨ |
| | សិក្សាបង់ថ្លៃ | ៣០ | ២ | ៩០ | ៣០ | ២៣១១ | ៨៥២ | ១៣១ | ៤១ | - | - | - | - | ២៥៦២ | ៩៣៩ |
| **២** | **វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប** | | | | | | | | | | | | | | |
| ក | *ចំនួនមន្ត្រី* | ៧ | ០ | ៤៦ | ១០ | ៦៣ | ២៣ | ២០ | ០ | - | - | ៣ | ២ | ១២១ | ៣៥ |
| ខ | *ចំនួននិស្សិត* | - | - | - | - | ៩៦៣ | ៤១៣ | ១២៥ | ៤១ | - | - | - | - | ១០៨៨ | ៤៥៤ |
| | អាហារូបករណ៍ | - | - | - | - | ៦៧៣ | ៣៣០ | ៦២ | ២៨ | - | - | - | - | ៧៣៥ | ៣៥៨ |
| | សិក្សាបង់ថ្លៃ | - | - | - | - | ២៩០ | ៨៣ | ៦៣ | ១៣ | - | - | - | - | ៣៥៣ | ៩៦ |
| ៣ | **វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម** | | | | | | | | | | | | | | |
| ក | *ចំនួនមន្ត្រី* | - | - | ៣៦ | ៧ | ២៣ | ៩ | ១ | ០ | - | - | - | - | ៦០ | ១៧ |
| ខ | *ចំនួននិស្សិត* | - | - | - | - | ៣៦២ | ១៦៣ | ១០ | ៣៥ | - | - | - | - | ៤៦៣ | ១៩៨ |
| | អាហារូបករណ៍ | - | - | - | - | ២៦៤ | ១៣៣ | ៨៥ | ៣១ | - | - | - | - | ៣៤៩ | ១៦៤ |
| | សិក្សាបង់ថ្លៃ | - | - | - | - | ៩៨ | ៣០ | ១៥ | ៤ | - | - | - | - | ១១៣ | ៣៤ |

ក្នុងរយៈពេល០៥ឆ្នាំនេះ គ្រឹះស្ថានសិក្សាបច្ចេកទេសកសិកម្មទាំងបី បានទទួលនិស្សិតឱ្យចូលរៀន និងបញ្ចប់ការសិក្សាដោយជោគជ័យ មានដូចក្រោម៖

តារាងទី៤៖ ស្ថិតិនិស្សិតបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម

| និស្សិត / ឆ្នាំសិក្សា | បរិញ្ញារង | | បរិញ្ញា | | បរិញ្ញាជាន់ខ្ពស់ | | បណ្ឌិត | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី |
| ២០១៥-២០១៦ | ៩៣ | ២០ | ១ ០២៤ | ៣០២ | ៣៧ | ៩ | ១ | ១ | ១ ១៥៥ | ៣៣២ |
| ២០១៦-២០១៧ | ៥១ | ១០ | ៥៨៦ | ១៨៧ | ១៣ | ៣ | ០ | ០ | ៦៥០ | ២០០ |
| ២០១៧-២០១៨ | ៥ | ៣ | ៤៦០ | ១៤២ | ០ | ០ | ០ | ០ | ៤៦៥ | ១៤៥ |
| ២០១៨-២០១៩ | ៤៩ | ១២ | ៥៨៩ | ២២៩ | ២២ | ៤ | ០ | ០ | ៦៦០ | ២៤៥ |
| ២០១៩-២០២០ | ២៧ | ៧ | ៦០១ | ២៣៦ | ២២ | ១០ | ២ | ០ | ៦៥២ | ២៥៣ |
| សរុប | ២២៥ | ៥២ | ៣ ២៦០ | ១ ១៦៩ | ៩៤ | ២៦ | ៣ | ១ | ៣ ៥៨២ | ១ ១៧៥ |

តារាងទី៥៖ ស្ថិតិនិស្សិតចូលរៀនសរុបរបស់សាកលវិទ្យាល័យភូមិន្ទកសិកម្ម

| និស្សិត / ឆ្នាំសិក្សា | បរិញ្ញាបត្ររង | | បរិញ្ញាបត្រ | | អនុបណ្ឌិត | | បណ្ឌិត | | សរុបរួម | |
|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី |
| ២០១៥-២០១៦ | ៩៣ | ២០ | ៩៤៥ | ៣៦៤ | ៤០ | ១៣ | ០ | ០ | ១ ០៧៨ | ៣៩៧ |
| ២០១៦-២០១៧ | ៦១ | ១៧ | ៩២០ | ៣៣៩ | ៦០ | ២៤ | ០ | ០ | ១ ០៤១ | ៣៨០ |
| ២០១៧-២០១៨ | ៧២ | ១៩ | ៧៦៨ | ៣០៣ | ០ | ០ | ០ | ០ | ៨៤០ | ៣២២ |
| ២០១៨-២០១៩ | ៧៩ | ២៧ | ៨៨៨ | ៣៩៦ | ១៧ | ៦ | ០ | ០ | ៩៨៤ | ៤២៩ |
| ២០១៩-២០២០ | ៨៥ | ៣៦ | ៩៩៩ | ៤២៥ | ៣៨ | ១១ | ០ | ០ | ១ ១២២ | ៤៧២ |
| សរុប | ៣៩០ | ១១៩ | ៤ ៥២០ | ១ ៨២៧ | ១៥៥ | ៥៤ | ០ | ០ | ៥ ០៦៥ | ២ ០០០ |

តារាងទី៦៖ ស្ថិតិនិស្សិតចូលរៀនរបស់វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

| ឆ្នាំសិក្សា | បរិញ្ញាបត្ររង | | បរិញ្ញាបត្រ | | សរុបរួម | |
|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី |
| ២០១៥-២០១៦ | ១៧០ | ៥០ | ២៥៨ | ៨៥ | ៤២៨ | ១៣៥ |
| ២០១៦-២០១៧ | ១១៩ | ៤៩ | ១០៤ | ៤០ | ២២៣ | ៨៩ |
| ២០១៧-២០១៨ | ១១៩ | ៣៤ | ១៨០ | ៧៩ | ២៩៩ | ១១៣ |
| ២០១៨-២០១៩ | ៥៣ | ២៣ | ២៣៦ | ១១៦ | ២៨៩ | ១៣៩ |
| ២០១៩-២០២០ | ១៤៩ | ៤០ | ១៩៧ | ៧២ | ៣៤៦ | ១១២ |
| សរុប៥ឆ្នាំ | **៦១០** | **១៩៦** | **៩៧៥** | **៣៩២** | **១៥៨៥** | **៥៨៨** |

តារាងទី៧៖ ស្ថិតិនិស្សិតបញ្ចប់ការសិក្សារបស់វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

| ឆ្នាំសិក្សា | បរិញ្ញាបត្ររង | | បរិញ្ញាបត្រ | | សរុបរួម | |
|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី |
| ២០១៥-២០១៦ | ៣៩៦ | ១៥ | ៣៧៨ | ១១១ | ៧៧៤ | ១២៦ |
| ២០១៦-២០១៧ | ១០៤ | ២៤ | ២៨៨ | ១០៨ | ៣៩២ | ១៣២ |
| ២០១៧-២០១៨ | ១៣៧ | ៥២ | ២០៧ | ៧៣ | ៣៤៤ | ១២៥ |

| | | | | | | |
|---|---|---|---|---|---|---|
| ២០១៨-២០១៩ | ១១០ | ៤៣ | ១៦៥ | ៤៧ | ២៧៥ | ៩០ |
| ២០១៩-២០២០ | ១៤៩ | ៤០ | ១៩៧ | ៧២ | ៣៤៦ | ១១២ |
| សរុប៥ឆ្នាំ | **៨៩៦** | **១៧៤** | **១ ២៣៥** | **៤១១** | **២ ១៣១** | **៥៨៥** |

តារាងទី៨៖ ស្ថិតិនិស្សិតចូលរៀនរបស់វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

| ឆ្នាំសិក្សា | បរិញ្ញាបត្ររង | | បរិញ្ញាបត្រ | | សរុបរួម | |
|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី |
| ២០១៥-២០១៦ | ៦៥ | ១៦ | ១២២ | ៧០ | ២០១ | ១០២ |
| ២០១៦-២០១៧ | ៦២ | ២៦ | ១៩៦ | ១១៥ | ២៥៨ | ១៤១ |
| ២០១៧-២០១៨ | ៥៨ | ១៨ | ១៩៣ | ១០៨ | ២២០ | ១២១ |
| ២០១៨-២០១៩ | ៧០ | ១៨ | ៣០៣ | ១៤៧ | ៣៧៣ | ១៦៥ |
| ២០១៩-២០២០ | ៩០ | ៣៤ | ៣៥៧ | ១៦៣ | ៤៤៧ | ១៩៧ |
| សរុប៥ឆ្នាំ | **៣៤៥** | **១១២** | **១ ១៧១** | **៦០៣** | **១ ៤៩៩** | **៧២៦** |

តារាងទី៩៖ ស្ថិតិនិស្សិតបញ្ចប់ការសិក្សារបស់វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

| ឆ្នាំសិក្សា | បរិញ្ញាបត្ររង | | បរិញ្ញាបត្រ | | សរុបរួម | |
|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី |
| ២០១៥-២០១៦ | ២២១ | ៧០ | ២៤៤ | ១២៣ | ៤៦៥ | ១៩៣ |
| ២០១៦-២០១៧ | ៨២ | ៤៦ | ១៩៥ | ៩៩ | ២៧៧ | ១៥៤ |
| ២០១៧-២០១៨ | ១១៤ | ៤៨ | ១៨៩ | ៧៣ | ៣០៣ | ១២១ |
| ២០១៨-២០១៩ | ៥៣ | ១៥ | ១៤១ | ៥៤ | ១៩៤ | ៦៩ |
| ២០១៩-២០២០ | ៣៦ | ១៣ | ១២១ | ៤៩ | ១៥៧ | ៦២ |
| សរុប៥ឆ្នាំ | **៥០៦** | **១៩២** | **៨៩០** | **៣៩៨** | **១ ៣៩៦** | **៥៩៩** |

គ្រឹះស្ថានសិក្សាបច្ចេកទេសកសិកម្មទាំងបី បាននិងកំពុងរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមរយៈការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា ដើម្បីពង្រឹងគុណភាពបណ្តុះបណ្តាល ស្រាវជ្រាវ និងសេវាកម្មសម្រាប់សហគមន៍ក្នុងបរិបទសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន និងសកលភាវូបនីយកម្ម។ នៅឆ្នាំ២០២០នេះ គ្រឹះស្ថានសិក្សាបច្ចេកទេសកសិកម្មទាំងបី បានធ្វើកិច្ចសហប្រតិបត្តិការអន្តរជាតិ ទាំងទ្វេភាគី និងពហុភាគី កាន់តែល្អប្រសើរ ជាមួយដៃគូអភិវឌ្ឍន៍នានា។

សាកលវិទ្យាល័យភូមិន្ទកសិកម្មបាននិងកំពុងដំណើរការអនុវត្តគម្រោងពិសោធន៍ស្រាវជ្រាវតូចៗ ចំនួន៤១គម្រោង ក្នុងនោះគម្រោងចំនួន២២ ទទួលបានថវិកាពីរាជរដ្ឋាភិបាលតាមរយៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គម្រោងចំនួន០៧ ទទួលបានថវិកាពីគម្រោងកែលម្អការអប់រំឧត្តមសិក្សា (HEIP) និងគម្រោងចំនួន១២ ជាកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិដូចជា៖ ជាមួយសហភាពអឺរ៉ុប (EU) អង្គការសុខភាពសត្វពិភពលោក (OIE) ជំនួយការរបស់ទីភ្នាក់ងារអាមេរិក (USAID) មជ្ឈមណ្ឌលឧត្តមភាពប្រពលវប្បកម្មកសិកម្មប្រកបដោយនិរន្តរភាពនិងអាហារូបត្ថម្ភ (CESAIN) អង្គការ SIIL សម្រាប់កម្មវិធីមន្ទីរពិសោធន៍នវានុវត្តប្រកបដោយចីរភាព មជ្ឈមណ្ឌលអូស្ត្រាលីសម្រាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ (ACIAR) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) ក្រុមប្រឹក្សានៃប្រទេសស៊ុយអ៊ែត (Sweden Council) និង មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម (IFAD)។

វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប មានកិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុនចំនួន០៤ មានដូចជា៖ ក្រុមហ៊ុន Cambojob ក្រុមហ៊ុន Mopo Energy (Cambodia) Co., Ltd ក្រុមហ៊ុន Khmer Sight Foundation និង ក្រុមហ៊ុន Young Development Research and Consulting Co., Ltd។ ជាពិសេសវិទ្យាស្ថានបាននិងកំពុងបន្ត អនុវត្តកម្មវិធីដែលបានចុះអនុស្សរណៈនិងកិច្ចព្រមព្រៀង ជាមួយរាជបណ្ឌិតសភាកម្ពុជានិងសាកលវិទ្យាល័យជាតិគ្រប់គ្រង និងអន្តរជាតិ និងត្រៀមបន្តឆ្នាំ២០២១។

វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម នៅឆ្នាំ២០២០ បានធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការ KOICA និងសាកលវិទ្យាល័យជាតិ Kangwon របស់សាធារណរដ្ឋកូរ៉េ ដើម្បីបង្កើនគុណភាព និងនវានុវត្តន៍របស់វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម ដែលមានជំនាញការចូលរួមចំនួន១៥រូប និងបណ្តុះបណ្តាលដល់មន្ត្រីចំនួន២៥រូប ព្រមទាំងបន្តអនុវត្តកម្មវិធីកសាងធនធានមនុស្ស ផ្នែកមន្ទីរពិសោធន៍ របស់វិទ្យាស្ថានជាតិកសិកម្មកំពង់ចាមបន្ថែមទៀត។ ជាមួយគ្នានេះដែរវិទ្យាស្ថានក៏បានចុះអនុស្សរណៈ កិច្ចព្រមព្រៀងជាមួយនឹង Hainan Institute of Vocational and Technique នៃសាធារណរដ្ឋប្រជាមានិតចិន ដើម្បីធ្វើការផ្លាស់ប្តូរនិស្សិតទៅសិក្សា។ ជាងនេះទៅទៀត វិទ្យាស្ថានបាននិងកំពុងអនុវត្តគម្រោងជាមួយសាកលវិទ្យាល័យ Shinju និងក្រុមហ៊ុន Shikibo Co. Ltd. នៃប្រទេសជប៉ុន បានបង្កើតបន្ទប់ពិសោធន៍ដង្កូវនាងព្រៃ នៅវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម ដោយមាននិស្សិតចូលរួមសិក្សា និងស្រាវជ្រាវ ចំនួន១១នាក់។

ក្រៅពីការងារសហប្រតិបត្តិការខាងលើ គ្រឹះស្ថានសិក្សាបច្ចេកទេសកសិកម្មទាំងបី បានទទួលនូវកម្មវិធីផ្លាស់ប្តូរនិស្សិត និងមន្ត្រីរាជការ ទៅប្រទេសអេស្ប៉ាញ ថៃឡង់ដ៏ ជប៉ុន ចិន និងប្រទេសអ៊ីស្រាអែល សរុបចំនួន២២២នាក់ ដើម្បីស្វែងយល់ និងដកស្រង់បទពិសោធន៍លើវិស័យកសិកម្ម។

### ៥.៤. ការងារកិច្ចការរដ្ឋបាល

**ក.ការងារកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត:** ក្រសួងបានសាងសង់អគាររដ្ឋបាលនៃទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កម្ពស់៤ជាន់ មានទំហំ ១៨ម x ៣២ម និងចំណាយថវិកាអស់ចំនួន ២ ៣០០ ៦៣១,៥ដុល្លារអាមេរិក សម្ភារបរិក្ខារបច្ចេកទេសបំពាក់នៅអគាររដ្ឋបាលទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សរុបស្មើនឹងទំហំទឹកប្រាក់ចំនួន ៣៩៤ ០៦៩ដុល្លារអាមេរិក។

**ខ.ការគ្រប់គ្រងលិខិតចូល-ចេញ:** ទទួលពីក្រសួងស្ថាប័ននានាបានចំនួន ៣ ៥១៧ច្បាប់ និងពីអង្គភាពជំនាញក្រោមឱវាទបានចំនួន ៣ ៣៥៥ច្បាប់។ បានបញ្ជូនលិខិតទៅក្រសួង ស្ថាប័ននានា និងអង្គភាពជំនាញក្រោមឱវាទចំនួន ១១ ២៨០ច្បាប់។ បានរៀបចំសេចក្តីសម្រេច ប្រកាស សេចក្តីណែនាំ និងសេចក្តីអំពាវនាវ មានចំនួន ៥០៤ ច្បាប់។ រៀបចំចាត់ចែង ដីកាអម លិខិតឆ្លើយតប លិខិតអញ្ជើញប្រជុំ និងចម្លងជូន និងបញ្ជូនទៅតាមអង្គភាពជំនាញក្រោមឱវាទក្រសួងដើម្បីចាត់ការបន្ត។ បានពិនិត្យផ្តល់យោបល់លើឯកសាររដ្ឋបាល ឯកសារបច្ចេកទេស ឯកសារគតិយុត្តជូនថ្នាក់ដឹកនាំ។ បានរៀបលិខិតបញ្ជាបេសកកម្មជូនថ្នាក់ដឹកនាំ អង្គភាពក្រោមឱវាទក្រសួង និងក្រុមការងារផ្សេងៗដែលដឹកនាំដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ រៀបចំលិខិតបទដ្ឋានផ្សេងៗទៀតតាមការប្រគល់ជូនពីថ្នាក់ដឹកនាំ។ ចូលរួមធ្វើកំណត់ហេតុក្នុងកិច្ចប្រជុំអន្តរនាយកដ្ឋាននានា តាមការចាត់តាំងរបស់ថ្នាក់ដឹកនាំក្រសួង និងក្រុមការងារផ្សេងៗ។ បានធ្វើការបូកសរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់ក្រសួងយ៉ាងទៀងទាត់ និងបញ្ជូនទៅតាមគោលដៅបានទាន់ពេលវេលា។

### ៥.៥. ការងារសវនកម្មផ្ទៃក្នុង

ក្នុងឆ្នាំ២០២០ ក្រសួងបានខិតខំអនុវត្តភារកិច្ចរបស់ខ្លួនមានការរីកចម្រើនច្រើនទាំងការគ្រប់គ្រងលិខិតស្នាមទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស អង្គភាពថវិកា ការកសាងរចនាសម្ព័ន្ធ និងការធ្វើសវនកម្មផ្ទៃក្នុងតាមនីតិវិធីស្តង់ដា

ដោយសម្រេចបានលទ្ធផល រួមមាន បានចុះធ្វើសវនកម្មចំនួន៣៨សវនដ្ឋាន ដោយរកឃើញលទ្ធផលសវនកម្ម និងផ្តល់អនុសាសន៍សម្រាប់សវនដ្ឋានកែលម្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងចំនួន១៩៦អនុសាសន៍។ ទទួលលិខិតចូលចំនួន៥៤០លិខិត បញ្ជូនលិខិតចេញចំនួន៣៨៥លិខិត និងសរុបរបាយការណ៍ស្តីពីសកម្មភាពនិងលទ្ធផលការងារប្រចាំខែនីមួយៗ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូនក្រសួង ព្រមទាំងចរាចរឯកសារ នានាក្នុងនាយកដ្ឋានបានទាន់ពេលវេលា។ បានរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០១៩(ឆ្នាំគោល) ធ្វើការគ្រប់គ្រង និងបែងចែកសម្ភារការិយាល័យ សង្ហារិម សម្ភារបរិក្ខារបច្ចេកទេស ថែទាំ ជួសជុល និងផ្គត់ផ្គង់សម្រាប់បម្រើការងារពុំមានការរាំងស្ទះឡើយ។ បានរៀបចំផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុងឆ្នាំ២០២១-២០២៣ ផែនការសវនកម្មផ្ទៃក្នុងឆ្នាំ២០២១ ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ ផែនការថវិកាឆ្នាំ២០២១ ផែនការលទ្ធកម្មសាធារណៈឆ្នាំ២០២១ និងផែនការរជ្ជទេយ្យបុរេប្រទានឆ្នាំ២០២១។

**៥.៦. ការងារអធិការកិច្ច**

នៅក្នុងឆ្នាំ២០២០នេះ បានចុះធ្វើអធិការកិច្ចលើការងារដឹកនាំ និងគ្រប់គ្រងតាមបណ្តាអង្គភាព នានាក្រោមឱវាទក្រសួង ដោយទទួលបានលទ្ធផលដូចខាងក្រោមៈ

**ក.ការងារអធិការកិច្ចៈ** ចុះធ្វើអធិការកិច្ចលើការងារដឹកនាំ និងគ្រប់គ្រងតាមបណ្តាអង្គភាពក្រោមឱវាទក្រសួងមានបេសកកម្មចំនួន២៥លើក។ បានចូលរួមជួបពិភាក្សាការងារជាមួយឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង លើការងារ ដឹកនាំរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបង។ បានចុះធ្វើអធិការកិច្ចលើការងារដឹកនាំ និងគ្រប់គ្រងរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តពោធិ៍សាត់ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ឆ្នាំង និងពិនិត្យលើចំណុចខ្វះខាតមួយចំនួនរបស់មន្ទីរដែលក្រសួងបានណែនាំឱ្យកែលម្អកន្លងមក។ បានចូលរួមជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តមអភិបាលនៃគណៈអភិបាល ខេត្តតាកែវ និងថ្នាក់ដឹកនាំមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តតាកែវ ពាក់ព័ន្ធការងារដឹកនាំ និងគ្រប់គ្រងរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តតាកែវ។ បានចូលរួមជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង និងថ្នាក់ដឹកនាំមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រៃវែង។ បានអញ្ជើញថ្នាក់ដឹកនាំមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តប៉ៃលិន ធ្វើការណែនាំ និងជំរុញឱ្យអនុវត្តកែលម្អ ចំណុចខ្វះខាតរបស់មន្ទីរដែលក្រសួងចេញលិខិតឱ្យកែលម្អកន្លងមក តាមរយៈលិខិតលេខ១១៧១ កសក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ លិខិតលេខ០៨៦/២០ ទរពអរ.ប ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច និងលិខិតលេខ២០៦ សហវ.អ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយអនុវត្តតាមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំក្រសួង។ បានចុះពិនិត្យ និងប្រជុំ ពិភាក្សាជាមួយឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត និងសមត្ថកិច្ចពាក់ព័ន្ធពីបញ្ហាគ្រប់គ្រងវិស័យជលផល និង ព្រៃកោងកាងនៅខេត្តកែប។ បានចុះធ្វើអធិការកិច្ចលើការងារដឹកនាំ និងគ្រប់គ្រងរបស់ខណ្ឌរដ្ឋបាលព្រៃឈើឧត្តរមានជ័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តឧត្តរមានជ័យ។ បានចុះត្រួតពិនិត្យ និងប្រជុំពិភាក្សាជាមួយថ្នាក់ដឹកនាំ មន្ទីរលើការងារដឹកនាំ និងគ្រប់គ្រងរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តរតនគិរី មណ្ឌលគិរី កំពង់ឆ្នាំង ពោធិ៍សាត់ កោះកុង ព្រះសីហនុ កំពង់ធំ បាត់ដំបង ប៉ៃលិន ព្រះវិហារ សៀមរាប ស្ទឹងត្រែង ក្រចេះ កែប កំពត កំពង់ចាម ត្បូងឃ្មុំ ស្វាយរៀង ឧត្តរមានជ័យ កំពង់ស្ពឺ និងខេត្តបាត់ដំបង និងជំរុញការកែលម្អចំណុចខ្វះខាតដែល ក្រសួងបានណែនាំឱ្យកែលម្អកន្លងមក។ បានចុះត្រួតពិនិត្យទីតាំងដីស្ថានីយបណ្តុះឈើហូបផ្លែរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តប៉ៃលិន។ បានចុះ ធ្វើអធិការកិច្ចលើការងារដឹកនាំ និងគ្រប់គ្រងរបស់ការិយាល័យផលិតកម្ម និងបសុព្យាបាល នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ធំ។ បានចុះពិនិត្យ និងស្រាវជ្រាវលើការទប់ស្កាត់ បទល្មើសនេសាទក្នុងភូមិសាស្ត្រខេត្តសៀមរាប អនុវត្តតាមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំក្រសួង។

**ខ.ការងារទទួលពាក្យបណ្ដឹងៈ**

ក្នុងឆ្នាំ២០២០ អគ្គាធិការដ្ឋានទទួលពាក្យបណ្ដឹងបានចំនួន០៦ករណី ពាក់ព័ន្ធនឹងភាពមិនប្រក្រតីក្នុងការងារ អនុវត្តការងាររបស់ការិយាល័យផលិតកម្ម និងបសុព្យាបាលនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ ករណីមកបំភ្លឺពាក់ព័ន្ធការងារដឹកនាំ និងគ្រប់គ្រងរបស់ថ្នាក់ដឹកនាំមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ ករណីសុំផ្ទេរភារកិច្ចនាយរងផ្នែករដ្ឋបាលព្រៃឈើវើនសៃ ឱ្យទៅបម្រើការងារនៅរដ្ឋបាលព្រៃឈើថ្នាក់កណ្ដាលវិញ ករណីបណ្ដឹងប្ដឹងរបស់នាយសង្កាត់រដ្ឋបាលព្រៃឈើអូររាំង ខណ្ឌរដ្ឋបាលព្រៃឈើមណ្ឌលគិរីនៃមន្ទីរកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទខេត្តមណ្ឌលគិរី យកឈើបទល្មើសដែលបង្ក្រាបបានឱ្យគេកែច្នៃធ្វើសម្ភារប្រើប្រាស់ផ្ទាល់ខ្លួន ករណីចុះផ្សាយលើព័ត៌មានស្លឹករឹតពីការឱ្យប្រមូលលុយ៥០០ដុល្លារ ពីម្ចាស់កសិដ្ឋានចិញ្ចឹមមាន់សម្រាប់ថ្លៃរត់ការសុំធ្វើច្បាប់អនុញ្ញាតបង្កើតកសិដ្ឋាន។ ករណីប្ដឹងពីភាពមិនប្រក្រតីលើការងារដឹកនាំ និងគ្រប់គ្រងរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប។ បានរៀបចំទទួលពាក្យបណ្ដឹងតាមរយៈគេហទំព័ររបស់អគ្គាធិការដ្ឋាននៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (www.gi.maff.gov.kh) និងធ្វើសេចក្ដីជូនដំណឹង ស្ដីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទទួលពាក្យបណ្ដឹងតាមរយៈគេហទំព័ររបស់អគ្គាធិការដ្ឋាន នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ៥.៧. ការងារសហប្រតិបត្តិការអន្តរជាតិ

នៅក្នុងឆ្នាំ២០២០ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ បានធ្វើការសម្របសម្រួល និងរៀបចំលិខិតបទដ្ឋាន ព្រមទាំងឯកសារជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីក្រោមឱវាទក្រសួង ដើម្បីចូលរួមសិក្ខាសាលា ទស្សនកិច្ច ទិវាផ្សេងៗ កិច្ចប្រជុំ និងកិច្ចប្រជុំតាមប្រព័ន្ធវីដេអូពីចម្ងាយ សន្និសីទ និងវគ្គបណ្ដុះបណ្ដាលនៅបរទេស និងបានសម្របសម្រួលការទទួលជួបភ្ញៀវអន្តរជាតិរបស់ថ្នាក់ដឹកនាំ ព្រមទាំងបានរៀបចំកិច្ចប្រជុំ ទិវាផ្សេងៗ និងវគ្គបណ្ដុះបណ្ដាលក្នុងប្រទេស ដោយទទួលបានលទ្ធផលដូចខាងក្រោមៈ

១. ចំនួននៃការទទួលជួបភ្ញៀវអន្តរជាតិរបស់ថ្នាក់ដឹកនាំក្រសួង

| លរ | ទទួលជួបពិភាក្សាការងារជាមួយ | ចំនួននៃការទទួលជួប | សេចក្ដីផ្សេង |
|---|---|---|---|
| ១ | ស្ថាប័នរដ្ឋ (ក្រសួង ស្ថាប័ន) | ០០ | |
| ២ | ស្ថានទូត | ០៨ | |
| ៣ | អង្គការអន្តរជាតិ | ០០ | |
| ៤ | វិស័យឯកជន | ១០ | |
| ៥ | ផ្សេងទៀត | ០៣ | |
| | **សរុប** | **២១** | |

២. ចំនួននៃការចូលរួមកិច្ចប្រជុំ ទស្សនកិច្ច និងសន្និសីទក្រៅប្រទេសរបស់ថ្នាក់ដឹកក្រសួង និងមន្ត្រី

| លរ | ការចូលរួមក្នុងព្រឹត្តិការណ៍ | ចំនួនព្រឹត្តិការណ៍ | ចំនួនសមាជិកប្រតិភូ | សេចក្ដីផ្សេងៗ |
|---|---|---|---|---|
| I. | **ក្រោមក្របខ័ណ្ឌទ្វេភាគី និងពហុភាគី** | | | |
| ១ | កិច្ចប្រជុំ | ១២ | ២៣ | |
| ២ | សិក្ខាសាលា | ០១ | ០២ | |
| ៣ | ទស្សនកិច្ច | ០២ | ០៣ | |
| ៤ | សន្និសីទ | ០១ | ០៤ | |
| II. | **ក្រោមក្របខ័ណ្ឌអាស៊ាន** | | | |

| | | | | |
|---|---|---|---|---|
| ១ | កិច្ចប្រជុំ | ៥ | ១១ | |
| ២ | ទស្សនកិច្ច | ០ | ០ | |
| | **សរុប** | **២១** | **៤៧** | |

៣. ចំនួននៃការចូលរួមសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលក្រៅប្រទេសរបស់មន្ត្រី

| លរ | ការចូលរួមក្នុងព្រឹត្តិការណ៍ | ចំនួនព្រឹត្តិការណ៍ | ចំនួនមន្ត្រី | សេចក្តីផ្សេងៗ |
|---|---|---|---|---|
| **I.** | **ក្រោមក្របខ័ណ្ឌទ្វេភាគី និងពហុភាគី** | | | |
| ១ | សិក្ខាសាលា | ៥ | ១០ | |
| ២ | វគ្គបណ្តុះបណ្តាល | ១០ | ១៤ | |
| **II.** | **ក្រោមក្របខ័ណ្ឌអាស៊ាន** | | | |
| ១ | សិក្ខាសាលា | ១ | ២ | |
| ២ | វគ្គបណ្តុះបណ្តាល | ១ | ១ | |
| | **សរុប** | **១៧** | **២៧** | |

៤. ចំនួននៃការសម្របសម្រួលរៀបចំកិច្ចប្រជុំដោយផ្ទាល់ កិច្ចប្រជុំពីចម្ងាយ ទិវា និងវគ្គបណ្តុះបណ្តាល នៅក្នុងប្រទេស

| លរ | ការរៀបចំព្រឹត្តិការណ៍ | ចំនួនព្រឹត្តិការណ៍ | ចំនួនអ្នកចូលរួម | សេចក្តីផ្សេងៗ |
|---|---|---|---|---|
| ១ | កិច្ចប្រជុំតាមប្រព័ន្ធវីដេអូពីចម្ងាយ | ២០ | ៣៣២ | |
| ២ | កិច្ចប្រជុំដោយផ្ទាល់ | ៨ | ១៣០ | |
| ៣ | ទិវា | ២ | ១២០០ | |
| ៤ | វគ្គបណ្តុះបណ្តាល/សិក្ខាសាលា | ៥ | ២០៥ | |
| **សរុប** | | **៣៥** | **១៨៦៧** | |

**I. ការចុះអនុស្សរណៈនៃការយោគយល់គ្នា និងកិច្ចព្រមព្រៀង**

ក.ក្រោមក្របខ័ណ្ឌទ្វេភាគី និងពហុភាគី

| លរ | អនុស្សរណៈ/កិច្ចព្រមព្រៀង | រវាង | កាលបរិច្ឆេទចុះហត្ថលេខា | សុពលភាព |
|---|---|---|---|---|
| 1 | Technical Cooperation and Join Research on Integrated Water Resources Management and Development in Cambodia | China | | |
| 2 | គម្រោងហិរញ្ញប្បទានទៅរដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ សម្រាប់ឆ្នាំសារពើពន្ធ ២០២២ មានគម្រោងចំនួន ០៧ | Korea | | |
| 3 | Safe Vegetable Development for Domestic Market and Export | Yamato Green, Japan | ១៥ សីហា ២០២០ | 2019-2023 |

| | | | | |
|---|---|---|---|---|
| 4 | Cooperation in the Field of Agriculture | Hungary | ០៣ វិច្ឆិកា ២០២០ | ៥ឆ្នាំ |
| 5 | "Research and Development of Hemorrhagic Septicemia (HS) Vaccines in Cambodia" សម្រាប់អនុវត្តក្នុងឆ្នាំ ២០២១ | Korea | កំពុងស្នើ | ១ឆ្នាំ |

**ខ.កិច្ចព្រមព្រៀងជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ**

ការិយាល័យការងារអង្គការអន្តរជាតិបានសម្របសម្រួលកិច្ចការងារ ចុះកិច្ចព្រមព្រៀងអនុវត្តគម្រោងរវាងអង្គការមិនមែនរដ្ឋាភិបាល ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចំនួន១២គម្រោង គិតជាទឹកប្រាក់សរុបចំនួន ៥៦ ៩៣៤ ៨០៩ ដុល្លារអាមេរិក ។

| ល.រ | ឈ្មោះអង្គការ | ឈ្មោះគម្រោង | រយៈពេលអនុវត្ត | ថវិកាគម្រោង |
|---|---|---|---|---|
| ១ | Dana Asia | មជ្ឈមណ្ឌលខ្មែរ-ជប៉ុនបណ្តុះបណ្តាល ចិញ្ចឹមមាន់ | ២០២០ - ២០២២ | ៩៩៥,៤២០ $ |
| ២ | FIDR | សន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅក្នុងខេត្តកំពង់ឆ្នាំង | ២០២០-២០២១ | ២៥៣ ១២៣$ |
| ៣ | ADDA | គម្រោងពង្រឹងសមត្ថភាពសហគមន៍កសិកម្ម និងសង្គមស៊ីវិល នៅខេត្តសៀមរាប និងខេត្តឧត្តរមានជ័យ (EAC) | ២០២០-២០២៣ | ៦៩៨ ៤៦៤$ |
| ៤ | FAO | ពង្រឹងសមត្ថភាពស្ថានប័ន និងសមត្ថភាពបច្ចេកទេស ផ្តោតលើអាហារមានសុវត្ថិភាព តាមរយៈការអនុវត្តវិធានការសុវត្ថិភាពអាហារ និងការផ្តល់លិខិតបញ្ជាក់កសិផល នៅកម្ពុជា | ២០២០-២០២១ | ៣០០ ០០០$ |
| ៥ | FAO | ការពិនិត្យការធ្វើផែនការនិងកិច្ចពិគ្រោះយោបល់កម្រិតគោលនយោបាយសម្រាប់វិស័យកសិកម្មនិងវិស័យបរិស្ថាន | ២០២០-២០២១ | ២០០ ០០០$ |
| ៦ | FAO | TCP/CMB/3801- Support to Agriculture sector strategic review and development towards 2030 and 2050 | ២០២០-២០២២ | ២៦៣ ០០០$ |
| ៧ | FAO | Request for MAFF's signature on Project Agreement "TCP/CMB/3803" | ២០២០-២០២២ | ៣៩៤ ០០០$ |
| ៨ | FAO | Request for MAFF's signature on Country Programming Framework2019-2023 | ២០២០-២០២២ | ៤៨ ៥៥៤ ៦០០$ |
| ៩ | FAO | Strengthening Institution and technical capacity for safe food through implementation of food safety measures and certification schemes for agricultural products in Cambodia to combat"COVID-19" | ២០២០-២០២២ | ៣៩៤ ០០០$ |
| ១០ | FAO | Request for Signature on the Project Agreement "GCP/CMB/037/LDF Climate Adaptation and Resilience in Cambodia's Coastl Fishery Dependent Communities | ២០២០-២០២៥ | ២ ៥៥០ ០០០$ |
| ១១ | FAO | Gender Equality and Women's Empowerment in Agriculture, Food Security and Nutrition FMM /GLO (under umbrella | | ១ ៥០០ ០០០$ |

| | | | | |
|---|---|---|---|---|
| | | programme FMM / Gernder- DRE / MUL) (Gender) | | |
| ១២ | FAO | UN -REDD- Technical Assistance for REDD+Implementation | ២០២០-២០២២ | ១ ១៨៦ ៨០២$ |
| សរុប | | | | **៥៦ ៩៣៤ ៨០៩ $** |

**គ. សមិទ្ធផលដែលទទួលបានក្រោមក្របខ័ណ្ឌទ្វេភាគី និងពហុភាគី**

ក្រោយពីការចុះហត្ថលេខាលើ MOU ជាមួយក្រុមហ៊ុនវិទ្យាសាស្ត្រឧស្សាហកម្មធុនធ្ងន់ និងបច្ចេកវិទ្យា Zoomlion កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩កន្លងមក ក្រុមហ៊ុនបានបញ្ជូនគ្រឿងយន្តកសិកម្មដែលគិតជាទឹកប្រាក់សរុបមានចំនួនប្រមាណ ១៣ម៉ឺនដុល្លារអាមេរិក ហើយសម្ភារដែលទទួលបានមានដូចខាងក្រោម៖

| **ល.រ** | **បរិយាយ** | **ម៉ូដែល** | **ចំនួន** |
|---|---|---|---|
| 1 | ម៉ាស៊ីនត្រាក់ទ័រ | RC904-A | 3 |
| 2 | គ្រឿងយន្តប្រមូលផលពោត | 4YZ-4CM2 | 1 |
| 3 | គ្រឿងយន្តរាស់ដី | 1BZ-2.0 | 1 |
| 4 | គ្រឿងយន្តដាំដុះ | TMZ200 | 2 |
| 5 | គ្រឿងយន្តសាបគ្រាប់ពូជ | 2BYFSF-8 | 2 |
| 6 | Round Baler | 9YY-1000 | 1 |
| 7 | គ្រឿងយន្តសណ្តោង | 7C-4T | 1 |
| 8 | Drone | Z-Lion-20L | 2 |
| 9 | ម៉ាស៊ីនសម្ងួត | DC150 | 1 |
| សរុប | | | 14 |

- បានសម្របសម្រួលជាមួយភាគីចិន ដោយបានទទួលវ៉ាក់សាំងការពារជំងឺ Foot and Mouth Disease ប្រមាណ ២០០ ០០០ដូស គិតជាទឹកប្រាក់ប្រមាណ ៦០០ ០០០ ដុល្លារអាមេរិក សម្រាប់ជូនអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វអនុវត្តសកម្មភាពបន្ត
- បានសម្របសម្រួលបានសម្របសម្រួលជូន CARDI ដើម្បីស្នើសុំឲ្យភាគីអូស្ត្រាលីបន្តជួយគាំទ្រដល់សកម្មភាពរបស់ CARDI ដោយផ្តល់ជារថយន្ត pick up ចំនួន ០៣គ្រឿង សម្រាប់អនុវត្តការងារបន្ត
- បានសម្របសម្រួលបញ្ចប់នូវរបាយការណ៍ Development Plan for Sustainable Rubber Industry ដើម្បីដាក់ជូនថ្នាក់ដឹកនាំកំពូលអនុម័តនៅក្នុងកិច្ចប្រជុំកំពូល CLV។

**II. គម្រោងក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការស្បៀង កសិកម្ម និងព្រៃឈើ ឆ្នាំ២០១៩- ២០២០**

| ល.រ | កាលបរិច្ឆេទដាក់ស្នើ | ថវិកាដែលបានស្នើ | ប្រទេស | ហិរញ្ញវត្ថុនៃសមាជិកអាស៊ាន | ហិរញ្ញវត្ថុនៃកម្ពុជា | តំណាងគាំទ្រ | ស្ថានភាព |
|---|---|---|---|---|---|---|---|
| 1 | 31-Jan-2019 | JAIF - EEA Part A | Japan | ៣៧៤ ៨៦៧,៨៥ | ៣៧ ៤៨៦,៧៨៥ | ASEAN Plant Health Cooperation Network (APHCN) | Ongoing |
| 2 | 6-Mar-2019 | ARDPFF | Russia | ៦១៥ ២២៨,០០ | ៦១ ៥២២,៨ | Ministry of Science and Higher Education of the Russian | Ongoing |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | | Federation and Ministry of Agriculture, Republic of Indonesia | |
| 3 | 2-Aug-2019 | MAFF Japan | Japan | ៥០៥ ៩៦៨,០០ | ៥០ ៥៩៦,៨ | Statistics Planning Division, Statistics Department, Ministry of Agriculture, Forestry and Fisheries (MAFF) of Japan | Implemented |
| 4 | 28-Aug-2019 | ARDPFF | Russia | ៣៨៧ ៦៣១,០០ | ៣៨ ៧៦៣,១ | 1.Ministry of Agriculture of the Russian Federation<br>2.Ministry of Agriculture and Rural Development of the Socialistic Republic of Vietnam | Ongoing |
| 5 | 28- Aug-2019 | ARDPFF | Russia | ៣៧៨ ០២០,០០ | ៣៧ ៨០២ | Ministry of Agriculture of the Russian Federation | Pending DP |
| 6 | 2-Sep-2019 | JAIF-EEA Part a | Japan | ៧៩០ ១២៣,៤០ | ៧៩ ០១២,៣៤ | Southeast Asian Fisheries Development Center (SEAFDEC), Thailand | Ongoing |
| 7 | 27-Sep-2019 | ARDPFF | Russia | ៥០៥ ៣២៩,០០ | ៥០ ៥៣២,៩ | Department of Agriculture Office of the Secretary Building, Philippines | Pending DP |
| 8 | 20-Apr-2020 | MAFF Japan | Japan | ១ ៦៨០ ០០០,០០ | ១៦៨ ០០០ | Ministry of Agriculture, Forestry and Fisheries, Japan | Pending CPR |
| 9 | 27-Apr-2020 | ARDPFF | Russia | ៣៤៩ ៦៥៦,០០ | ៣៤ ៩៦៥,៦ | Department of Agriculture and Agrifood, Ministry of Primary Resources and Tourism, Brunei Darussalam | Pending ASEC |
| 10 | 22-May-2020 | JAIF - EEA Part A | Japan | ៩៤៧ ៨៣១,៩០ | ៩៤ ៧៨៣,១៩ | Ministry of Agriculture and Rural Development, Viet Nam<br>Ministry of Agriculture, Livestock and Irrigation, Myanmar | Pending CPR |
| 11 | 18-Jun-2020 | MAFF Japan | Japan | ២ ៨០០ ០០០,០០ | ២៨០ ០០០,០០ | Intellectual Property Division, Ministry of Agriculture, Forestry and Fisheries, Japan (MAFF)<br>Food Manufacture Affairs Division, Ministry of Agriculture, Forestry and Fisheries, Japan (MAFF) | Pending Sponsoring Body |
| 12 | 6-Jun-2020 | APTERR | ASEA N+3 | | ២០០ ០០០,០០ | Japan’s contribution of 300MT of milled rice under Tier3 programme implementation in 2020 to CAMBODIA. | Ongoing |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 13 | 24-Jun-2020 | JICA | Japan | ២ ៥៤២ ៧៩១,០០ | ២៥៤ ២៧៩,១ | Food, Agriculture and Forestry Division Sectoral Development Directorate, ASEAN Economic Community Department ASEAN Secretariat, Jakarta, Indonesia | Pending ASEC |
| 14 | 2020 - 2022 | AFSIS | ASEAN | ៥០៥ ៩៦៨,០០ | ៥០ ៥៩៦,៨ | Conducting of Pilot Survey USD 2,500 per country National Consultant for Country Workshop USD 6,750 per country | Ongoing |

**ឯកសារដែលបានអនុម័តក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីកសិកម្ម និងព្រៃឈើអាស៊ាន**

ឆ្នាំ២០២០នេះ បានអនុម័តលើឯកសារចំនួន ២៣ឯកសារ និងកត់សម្គាល់ចំនួន ០២ឯកសារ ក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីកសិកម្ម និងព្រៃឈើអាស៊ានលើកទី៤២ តាមរយៈប្រព័ន្ធវីដេអូពីចម្ងាយ ដូចមានរៀបរាប់ខាងក្រោម ៖

1. Priority deliverables of the food, agriculture and forestry sector for 2021
2. Mid-Term Review (MTR) of the Vision and Strategic Plan for ASEAN Cooperation in Food, Agriculture and Forestry (SP-FAF), 2016-2025 And its Sectoral Plans of Action (SPAs), 2016-2020
3. ASEAN Integrated Food Security (AIFS) Framework, Strategic Plan of Action on Food Security (SPA-FS), 2021-2025
4. ASEAN Regional Guideline for the Implementation of International Standards related to Sanitary and Phytosanitary (SPS) Measures
5. Strategic Plan of Action of the ASEAN SPS Contact Point (ASCP) 2021-2025
6. Plan of Action for ASEAN Cooperation in Halal Food 2021-2025
7. The Certificate of Approval for the National Veterinary Drugs Assay Laboratory, Gunung Sindur, Bogor, Indonesia
8. ASEAN Strategic Plan of Action for Cooperation in Livestock, 2021-2025
9. Proposal paper for a Regional Reference Centre (RRC) for Biorisk Management and Quality Assurance in Singapore
10. ASEAN Strategic Plan of Action for Cooperation in Crops, 2021-2025
11. ASEAN Phytosanitary Guidelines for Importation of Mangosteen fruit
12. ASEAN Plan of Action for Fall Army Worm Control 2020-2025
13. Four ASEAN Harmonised MRLs: Deltamethrin in jackfruit (0.2 mg/kg), Trifloxystrobin in curry leaf (3 mg/kg), Carbaryl in mangosteen (20 mg/kg), Metalaxyl in pomelo (0.8 mg/kg)
14. ASEAN Standards for: i) Strawberry, ii) Straw mushroom and iii) White potato.
15. ASEAN Phytosanitary Guidelines for the Importation of Pineapple Fruit (Ananas Comosus) for Consumption
16. ASEAN Strategic Plan of Action for Cooperation in Fisheries, 2021-2025
17. Resolution and Plan of Action on Sustainable Fisheries for Food Security for the ASEAN Region Toward 2030
18. Cooperation Framework, Terms of Reference and Rules of Procedure of ASEAN Network for Combating Illegal, Unreported and Unregulated Fishing
19. ASEAN Good Aquaculture Practices for Food Fish: Trainers' Guide
20. ASEAN General Fisheries Policy (AGFP) Feasibility Study Report
21. Concept Note on Promoting the Network for ASEAN Rural Product Development on One Village One Product Model
22. Prioritisation of SPA for ASEAN Cooperation in Forestry 2021-2025
23. The revised ASEAN Criteria and Indicators for Legality of Timber
24. ASEAN Guidelines for sustainable harvest and resource management protocols for selected NTFPs

**25.** ASEAN-Russia Agriculture and Food Security Cooperation Work Programme (2021-2025)។

## III. កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា

### ក. កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីធន់នឹងការប្រែប្រួលអាកាសធាតុ (ASPIRE)

កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់នឹងការប្រែប្រួលអាកាសធាតុ (ASPIRE) គឺជាកម្មវិធីរបស់រាជរដ្ឋាភិបាលកម្ពុជា (RGC) ដែលមានរយៈពេល៧ឆ្នាំ ដោយទទួលបានការគាំទ្រហិរញ្ញប្បទានពីមូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម (IFAD)។ កិច្ចព្រមព្រៀងហិរញ្ញប្បទានរវាងរាជរដ្ឋាភិបាលកម្ពុជា និង IFAD ក្នុងការអនុវត្តកម្មវិធីនេះត្រូវបានចុះហត្ថលេខានៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៥ ។ កាលបរិច្ឆេទអនុវត្តកម្មវិធី ASPIRE គឺចាប់ពីខែមិថុនា ឆ្នាំ២០១៥ ហើយកម្មវិធីនេះត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការ នៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៥ និង គ្រោងបញ្ចប់សកម្មភាពនៅត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ និងបិទបញ្ចប់កម្មវិធីជាផ្លូវការ នៅថ្ងៃទី៣១ ខែកញ្ញា ឆ្នាំ២០២២។

គោលដៅអភិវឌ្ឍន៍រួមនៃកម្មវិធី ASPIRE គឺដើម្បីកាត់បន្ថយភាពក្រីក្រ និងបង្កើនភាពធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុដល់គ្រួសារកសិករក្រីក្រ និងជនងាយរងគ្រោះចំនួន ១៤៤ ០០០គ្រួសារ នៅក្នុងប្រទេសកម្ពុជា ដោយបង្កើនតម្លៃផលិតកម្មកសិកម្មជាមធ្យម ២០% និងតម្លៃទ្រព្យសម្បត្តិគ្រួសារ ២៥%។ គោលបំណងនៃការអភិវឌ្ឍគឺ ដើម្បីបង្កើត នូវគំរូសេវាផ្សព្វផ្សាយកសិកម្មរបស់កម្ពុជាឱ្យកាន់តែប្រសើរឡើង ដែលសេវានេះមានប្រសិទ្ធភាពក្នុងការជួយដល់កសិករខ្នាតតូចដើម្បីរួមចំណែកដល់កំណើនសេដ្ឋកិច្ច តាមរយៈការអនុវត្តការងារកសិកម្មដែលមានភាពធន់ទ្រាំ និងមានប្រាក់ចំណេញ ហើយត្រូវបានអនុម័តយកជាគោលនយោបាយនៅឆ្នាំ២០២១។ បច្ចុប្បន្នកម្មវិធី ASPIRE បាននិងកំពុងអនុវត្តក្នុងខេត្តគោលដៅចំនួន២៤ក្នុងប្រទេសកម្ពុជា ដោយក្នុងនោះមានខេត្តថ្មីចំនួន៤ គឺ ខេត្តកោះកុង ព្រះសីហនុ កែប និងខេត្តឧត្តរមានជ័យ ដែលទើបត្រូវបានដាក់បញ្ចូលនៅក្នុងឆ្នាំ២០២០ នេះ។

សមាសភាគដែលអនុវត្តកម្មវិធីនេះមាន៤គឺ៖ សមាសភាគទី១៖ ការអភិវឌ្ឍនិងអនុវត្តគោលនយោបាយដែលអនុវត្តដោយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងនាយកដ្ឋានផែនការនិងស្ថិតិ។ សមាសភាគទី២៖ ការអភិវឌ្ឍសមត្ថភាពសម្រាប់ផ្នែកសេវាផ្សព្វផ្សាយ ដែលអនុវត្តដោយ អគ្គនាយកដ្ឋានកសិកម្ម សាកលវិទ្យាល័យភូមិន្ទកសិកម្ម វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប និងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ សមាសភាគទី៣៖ ការពង្រឹងសេវាកម្មផ្សព្វផ្សាយកសិកម្ម ដែលអនុវត្តដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសមាសភាគទី៤៖ ការកែលម្អហេដ្ឋារចនាសម្ព័ន្ធដើម្បីគាំទ្រផ្នែកកសិកម្មដែលមានភាពធន់ទ្រាំនឹងអាកាសធាតុ ដែលអនុវត្តដោយលេខាធិការគណៈកម្មការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ (NCDDs)។

កម្មវិធី ASPIRE បានគាំទ្រគ្រួសារកសិករបានចំនួន ១២៣ ៧៦៧ គ្រួសារ ដែលស្មើនឹង៨៦% នៃគ្រួសារកសិករគោលដៅសរុបចំនួន ១៤៤ ០០០គ្រួសារ។ ជារួមក្នុងឆ្នាំ២០២០ នេះ កម្មវិធី ASPIRE អនុវត្តសកម្មភាពសម្រេចបាន៨៤% និងផ្នែកហិរញ្ញវត្ថុបានចំនួន៨៣% ធៀបទៅនឹងផែនការការងារនិងថវិកាប្រចាំឆ្នាំ២០២០។ សមិទ្ធផលការងារសម្រេចបាន តាមសមាសភាគនីមួយៗមានដូចខាងក្រោម៖

**សមាសភាគទី១៖** ការអភិវឌ្ឍនិងអនុវត្តគោលនយោបាយ៖ បញ្ចប់ការរៀបចំផែនការមេវិស័យកសិកម្មឆ្នាំ២០៣០ Agricultural Sector Master Plan 2030 (ASMP)។ បញ្ចប់ការរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់លើកកម្ពស់ភូមិមួយផលិតផលមួយនៅក្នុងវិស័យកសិកម្ម strategic Plan for Promoting One Village One Product in Agriculture Sector។ បញ្ចប់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មរាជធានី ខេត្ត ឆ្នាំ២០១៩-២០២៣ Provincial agricultural Strategic Development Plan 2019-2023 (PASDP)។ បញ្ចប់ការពិនិត្យឡើងវិញលើគោលនយោបាយផ្សព្វផ្សាយកសិកម្ម Agricultural Extension Policy Review។ បញ្ចប់ការរៀបចំប្រព័ន្ធ Online សម្រាប់ការត្រួតពិនិត្យនិងវាយតម្លៃ និងការកសាងសមត្ថភាពអង្គភាពនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ Monitoring & Evaluation online and capacity building

to national sub-sector entities។ បញ្ចប់ការសិក្សាអំពីលទ្ធភាពនៃការបង្កើតតំបន់ពិសេសសម្រាប់ការកែច្នៃផលិតផលកសិកម្មនៅកម្ពុជា Feasibility Study of Establishing Special Zone for Agro-Processing in Cambodia ដោយបានប្រជុំពិគ្រោះយោបល់ និងចុះមូលដ្ឋានដើម្បីប្រមូលទិន្នន័យ ពីអ្នកពាក់ព័ន្ធ។

**សមាសភាគទី២៖** ការអភិវឌ្ឍសមត្ថភាពសម្រាប់ផ្នែកសេវាផ្សព្វផ្សាយ៖ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយវិធីសាស្ត្រនៃសេវាកម្មផ្សព្វផ្សាយទាំង៥។ បានផ្សព្វផ្សាយ Extension Hub, Extension Portal and Call center ដល់ មន្ត្រីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត និងភ្នាក់ងារផ្សព្វផ្សាយឃុំក្នុងការបើកដំណើរការ រួមមានវិធីចូល គេហទំព័រ ទាញយកនិងបញ្ចូលឯកសារបន្ថែម វិធីចុះឈ្មោះអ្នកផ្តល់សេវាកម្ម ណែនាំអំពីរបៀបគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយសង្គម ដូចជា *facebook, telegram, YouTube*។ល។ បានបង្កើតអនុគណៈកម្មាធិការជាតិផ្នែកបច្ចេកទេស កសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ (NAFFTSC) និងគណៈកម្មាធិការប្រឹក្សាយោបល់ផ្នែកផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (AFFEAC) ។ សម្ភារផ្សព្វផ្សាយច្រើនជាង៥០ ដែលទទួលបានពីមន្ទីរនិងស្ថាប័នពាក់ព័ន្ធ ត្រូវបានប្រមូល ពិនិត្យកែសម្រួល និងបញ្ចូលក្នុង Extension Portal។ ឯកសារផ្សព្វផ្សាយកសិកម្មចំនួន៦៧៧ ឯកសារ ត្រូវបានដាក់ក្នុងបណ្តុំព័ត៌មានផ្សព្វផ្សាយកសិកម្ម (Extension Portal) ដោយមានអ្នកចូលមើលចំនួន៤០២ ៤០៨នាក់ ហើយឯកសារផ្សព្វផ្សាយកសិកម្ម ចំនួន៧៨ ៩៣៤ ត្រូវបានគេទាញយក (Download) ទៅប្រើប្រាស់។ បានរៀបចំសិក្ខាសាលាស្តីពីការវាយតម្លៃការអនុវត្តរបស់មន្ត្រី DEAFF និង PDAFF ដែលបានអនុវត្តកន្លងមកនៅ ក្នុងឆ្នាំ២០១៩។ ជាលទ្ធផលមានបញ្ហាប្រឈម និងបទពិសោធន៍ ដោយបានបូកសរុប និងរៀបចំពង្រាងសម្រាប់សិក្ខាសាលាឆ្លុះបញ្ចាំងដល់មន្ត្រី PDAFF ទាំង២៥ខេត្ត/ក្រុង។ បានធ្វើបច្ចុប្បន្នភាព និងបោះពុម្ពគោលការណ៍ណែនាំ ស្តីពីការចុះកិច្ចសន្យាខាងក្រៅ និងការអនុវត្តការងារបញ្ជ្រាបការប្រែប្រួលអាកាសធាតុក្នុងការផ្សព្វផ្សាយកសិកម្ម។ បានបណ្តុះបណ្តាលស្តីពីភាពធន់នឹងអាកាសធាតុនិងប្រព័ន្ធកសិកម្មកសិ-អេកូឡូស៊ីចម្រុះ។ បានបញ្ចប់ឯកសារលើវិទ្យាសាស្ត្រផ្នែកអនុបណ្ឌិតលើការផ្សព្វផ្សាយកសិកម្មនិងការអភិវឌ្ឍជនបទ (AERD) ។

**សមាសភាគទី ៣៖** ជំរុញសេវាកម្មផ្សព្វផ្សាយ៖ បានរៀបចំសិក្ខាសាលាតម្រង់ទិសស្តីពីការប្រើប្រាស់វិធីសាស្ត្រទាំង៥ ជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទខេត្តគោលដៅ។ បានសម្រេចចំនួនគ្រួសារទទួលផលពីកម្មវិធី ASPIRE ចំនួន ១២៣ ៧៦៧ គ្រួសារ (ស្ត្រីជាមេគ្រួសារចំនួន៦០ ៤៥០គ្រួសារ) ដែលស្មើនឹង៨៦% នៃគ្រួសារកសិករគោលដៅសរុបចំនួន ១៤៤ ០០០គ្រួសារ។ បានបង្កើតបណ្តុំអាជីវកម្មចំនួន ១ ៩២០ បណ្តុំ ដែលមានសមាជិក ចំនួន ៦១ ៧៣៥នាក់ ក្នុងនោះស្រី ២៥ ៩០៤ នាក់ (៤២%)។ ប្រព័ន្ធតាមដាននិងវាយតម្លៃ និងប្រព័ន្ធគ្រប់គ្រងព័ត៌មានត្រូវបានកែលម្អដើម្បីឱ្យការប្រមូលទិន្នន័យស្តីពីសមិទ្ធផលសេដ្ឋកិច្ច ភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងការចុះបញ្ជីកសិករអ្នកទទួលផលបណ្តុំអាជីវកម្ម។ ការបង្កើនមូលនិធិកសិកម្មធន់នឹងអាកាសធាតុ (SUCRA) ដោយបានធ្វើការជាមួយកសិករខ្នាតតូច ១ ៥០០ នាក់ក្នុងការបង្កើតប្រព័ន្ធកសិកម្មចម្រុះ (IFS) និងបានផលិតឯកសារចំណេះដឹងប្រព័ន្ធកសិកម្មចម្រុះរួមមាន ខិត្តប័ណ្ណ គោលការណ៍ណែនាំរៀបចំគំរូប្រព័ន្ធកសិកម្មចម្រុះ (៧ ម៉ូដែល) និងផ្ទាំង រូបភាព។

**សមាសភាគទី ៤៖** ហេដ្ឋារចនាសម្ព័ន្ធគាំទ្រផ្នែកកសិកម្មដែលមានភាពធន់ទ្រាំនឹងអាកាសធាតុ៖ បានបញ្ចប់ការងារ ហេដ្ឋារចនាសម្ព័ន្ធគាំទ្រផ្នែកកសិកម្មចំនួន ១១០ គម្រោង នៅក្នុងឃុំចំនួន ១០៤ នៃស្រុកចំនួន ៣២ ក្នុងខេត្តគោលដៅ ចំនួន៨។ បានបញ្ចប់សិក្ខាសាលាស្តីពីការវាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ (VRA) ដោយមានការបញ្ជ្រាប ភាពបន្សាំទៅនឹងការផ្លាស់ប្តូរអាកាសធាតុ (CCA) ផែនការអភិវឌ្ឍន៍ឃុំរយៈពេល៥ឆ្នាំ (CDP) និងកម្មវិធីវិនិយោគឃុំសង្កាត់រយៈពេល៣ឆ្នាំ (CIP)។ បានប្រជុំស្តីពីការវាយតម្លៃនៃការកាត់បន្ថយភាពងាយរងគ្រោះ (VRA) នៅ៤៤ឃុំក្នុងការរៀបចំផែនទីតំបន់ងាយរងគ្រោះស្តីពីការប្រែប្រួលអាកាសធាតុ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុក្នុងរយៈពេល៥ឆ្នាំ CDP និង៣ឆ្នាំ CIP។ បានរៀបចំសិក្ខាសាលាស្តីពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុថ្នាក់ ស្រុកដើម្បីពិនិត្យនិងធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្របន្សាំនឹងការប្រែប្រួលអាកាសធាតុស្រុកចំនួន១២ស្រុកគោលដៅ។

### ខ. កសាងសមត្ថភាពបន្សាំតាមរយៈការពង្រីកបច្ចេកវិទ្យាថាមពលកកើតឡើងវិញក្នុងវិស័យកសិកម្ម (S-RET)

S-RET គឺជាគម្រោងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលអនុវត្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រោមក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណងរបស់មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម (IFAD) ដែលទទួលបានការគាំទ្រថវិកាពីមូលនិធិបរិស្ថានពិភពលោក (GEF)។ គោលដៅរបស់គម្រោងគឺធ្វើឱ្យកាន់តែប្រសើរឡើងនូវជីវភាពរស់នៅរបស់កសិករក្រីក្រតាមជនបទនៃខេត្តគោលដៅចំនួន៥ គឺខេត្តកំពត កណ្តាល ព្រៃវែង ស្វាយរៀង និងខេត្តតាកែវ តាមរយៈការពង្រីកឱ្យកាន់តែទូលាយនូវការទទួលយក និងប្រើប្រាស់បច្ចេកវិទ្យាថាមពលកកើតឡើងវិញ (RET) ដើម្បីគាំទ្រការផលិត ការកែច្នៃ និងការធ្វើអាជីវកម្មកសិកម្មរបស់កសិករ។

ទន្ទឹមនឹងនេះ គម្រោងក៏បានពង្រីកទៅខេត្តទាំងអស់ដែលគាំទ្រដោយកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE) ដែលកម្មវិធីនេះ បាននិងកំពុងអនុវត្តសកម្មភាពនៅខេត្តគោលដៅចំនួន២៥ រាជធានី ខេត្ត ក្នុងប្រទេសកម្ពុជា។ គម្រោង S-RET មានរយៈពេល ៥ ឆ្នាំ ចាប់ផ្តើមពី ខែតុលា ឆ្នាំ ២០១៦ ដល់ ខែមិថុនា ឆ្នាំ២០២១ (ពន្យារពេលអនុវត្តចំនួន៦ ខែ គឺចាប់ពីខែមករាដល់ខែមិថុនា ឆ្នាំ២០២១) ដោយមានថវិកាសរុបចំនួន ៨,៦លានដុល្លារអាមេរិក។

គម្រោងបានជ្រើសរើសក្រុមហ៊ុនចំនួន១១ សម្រាប់ធ្វើការសាកល្បង ពង្រីកបច្ចេកវិទ្យាឱ្យសាយភាយតាមរយៈការបង្កើតបណ្តាញចែកចាយ ការលក់ និងសេវាជួសជុសក្រោយពីពេលលក់ ជាលទ្ធផលសម្រេចបាន ចំនួន១ ៦៩១ គ្រឿង រួមមាន៖ ម៉ូទ័របូមទឹកប្រើថាមពលព្រះអាទិត្យចំនួន ៧៧៥ គ្រឿង ទូភ្ញាស់ស៊ុតមាន់ប្រើថាមពលព្រះអាទិត្យចំនួន ១៣០ គ្រឿង ធុងអនាម័យសម្រាប់ដុតកម្តៅកូនមាន់ចំនួន ៦២៧ កញ្ចប់ ឧបករណ៍ហាលសម្ងួតប្រើថាមពលព្រះអាទិត្យចំនួន ៦២ គ្រឿង ប្រព័ន្ធកម្តៅទឹកសម្រាប់ត្រាំ និងលាងសម្អាតបន្លែនិងផ្លែឈើ ប្រើថាមពលព្រះអាទិត្យចំនួន ១៥គ្រឿង ប្រព័ន្ធដាំបន្លែលើទឹកប្រើថាមពលព្រះអាទិត្យចំនួន ៧បណ្តុំ ដែលមានចំនួន ២១ថ្នាល សម្រាប់សហគមន៍ក្នុងខេត្តកំពត និងខេត្តព្រៃវែង និងទូភ្ញាស់ និងចិញ្ចឹមចង្រិត ប្រើថាមពលព្រះអាទិត្យចំនួន ១២គ្រឿង ក្នុងខេត្តស្វាយរៀង។ ប្រព័ន្ធសូឡាផ្គួបជាមួយជីវឧស្ម័ន សម្រាប់ដំណើរការសត្តឃាតដ្ឋានចំនួន ១០ទីតាំង ក្នុងខេត្ត បាត់ដំបង កំពត កណ្តាល កំពង់ឆ្នាំង កំពង់ធំ ស្វាយរៀង និង ខេត្តតាកែវ។ ម៉ាស៊ីនកែច្នៃចំណីសត្វប្រើថាមពល ព្រះអាទិត្យចំនួន ២៣គ្រឿង និងធុងត្រជាក់ ប្រើថាមពលព្រះអាទិត្យសម្រាប់រក្សាទុកវ៉ាក់សាំងចំនួន ១៦គ្រឿង ក្នុងខេត្តតាកែវ ព្រៃវែង ស្វាយរៀង កំពង់ធំ សៀមរាប និងខេត្តកំពង់ឆ្នាំង។ គម្រោងក៏បានជ្រើសរើសយកកម្មវិធី ឡជីវឧស្ម័នជាតិ ដើម្បីដំឡើង ឡជីវឧស្ម័ន ប្រភេទទន្សានុវត្តន៍ចំនួន ២ ២១១កន្លែង និងសាងសង់រោងជីកំប៉ុស្តសម្រាប់ដាក់ជីឡជីវឧស្ម័ន និងកាកសំណល់ផ្សេងៗចំនួន ៣០០កន្លែង ដើម្បីប្រើប្រាស់ក្នុងប្រព័ន្ធកសិកម្ម។

កសិករទទួលផលមានចំនួន ៧ ៩១៦គ្រួសារ បានបង្ហាញនូវការចាប់អារម្មណ៍ខ្ពស់ និងពេញចិត្តក្នុងការចូលរួម និងវិនិយោគលើការប្រើប្រាស់បច្ចេកវិទ្យាទាំងនេះ។ ទន្ទឹមនេះ គម្រោងកំពុងរៀបចំគោលនយោបាយលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាថាមពលកកើតឡើងវិញក្នុងវិស័យកសិកម្មនៅកម្ពុជា ឆ្នាំ២០២១-២០៣០។

### គ. គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប ជំហាន២

គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាបជំហានទី២ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្តល់ហិរញ្ញប្បទានរវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី(ADB) នាថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៨ មានថវិកាសរុប ៦៦លានដុល្លារអាមេរិក ដែលក្នុងនោះធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់ហិរញ្ញប្បទាន ៥០ លានដុល្លារអាមេរិក មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្មបានផ្តល់ហិរញ្ញប្បទាន១០លាន ដុល្លារអាមេរិក និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា មានចំនួន ០៦លានដុល្លារអាមេរិក ។

គម្រោងមានរយៈពេលអនុវត្ត០៥ឆ្នាំ ចាប់ផ្តើមអនុវត្តពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨ ហើយនឹងត្រូវបញ្ចប់នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ ។ គម្រោងបានអនុវត្តក្នុងខេត្តគោលដៅចំនួន០៧ រួមមាន ខេត្តបាត់ដំបង បន្ទាយមានជ័យ

សៀមរាប កំពង់ធំ កំពង់ចាម ត្បូងឃ្មុំ និងខេត្តព្រៃវែង ស្រុកគោលដៅមានចំនួន ៣៧ស្រុក ឃុំគោលដៅមានចំនួនសរុប២៧០ឃុំសង្កាត់។ រចនាសម្ព័ន្ធរបស់គម្រោងមានពីរផ្នែក៖ (១)ភ្នាក់ងារប្រតិបត្តិគម្រោង ដែលមានអង្គភាពសម្របសម្រួលការអភិវឌ្ឍ (DCU) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង(២)លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអនុវត្តតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរបស់ក្រសួងមហាផ្ទៃ។

លទ្ធផលរំពឹងទុកនៃគម្រោង រួមមាន (១)ការកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទគាំទ្រផលិតភាពកសិកម្ម និងកែលម្អជីវភាពដោយបង្កើន សមត្ថភាពគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ (២)កែលម្អបរិយាកាសសម្រាប់ការបង្កើនផលិតភាពកសិកម្ម ពិពិធកម្មកសិកម្ម និងភាពធន់នឹងអាកាសធាតុសម្របសម្រួលអនុវត្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានសកម្មភាពគាំទ្រខ្សែច្រវ៉ាក់ផលិតកម្មតម្លៃ និងទំនាក់ទំនងទីផ្សារ ការបង្កើនលទ្ធភាពទទួលបានព័ត៌មានកសិកម្ម និងទិន្នន័យទីផ្សារ(ព័ត៌មានទីផ្សារជនបទ និងខ្សែសង្វាក់ផលិតកម្ម ដំណាំបន្លែ ស្រូវចិញ្ចឹមមាន់ និងការចិញ្ចឹមត្រី និង(៣)ការពង្រឹងការគ្រប់គ្រងគម្រោងអនុវត្តរួមគ្នាដោយលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអនុវត្តតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ការចំណាយថវិកាសម្រាប់អង្គភាពសម្របសម្រួលការអភិវឌ្ឍក្នុងឆ្នាំ២០២០ មានចំនួន ១ ២៩៣ ២៦០ដុល្លារអាមេរិក ក្នុងនោះមានថវិកាកម្ចីហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ចំនួន ១ ១៥៨ ០៦៩ដុល្លារអាមេរិក ថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា មាន ១៣៥ ១៩១ដុល្លារអាមេរិក និងលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអនុវត្តតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានចំណាយថវិកា ៩ ៤៤៩ ០២៩ដុល្លារអាមេរិក ដែលក្នុងនោះមានកម្ចីហិរញ្ញប្បទាន និងជំនួយហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី មានចំនួន ៩ ០៦៥ ៤៥៦ ដុល្លារអាមេរិក និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជាមានចំនួន ៣៨៣ ៥៧៣ដុល្លារអាមេរិក។ សរុបថវិកាចំណាយរួមរបស់គម្រោងក្នុងឆ្នាំ២០២០ មានចំនួនសរុប ១០ ៧៤២ ២៨៩ដុល្លារអាមេរិក (១៦%)។

ចំពោះផ្នែកកសិកម្ម ការអនុវត្តគម្រោងជាលក្ខណៈរូបវន្តក្នុងឆ្នាំ២០២០ សម្រេចបាន ៤៧% ដោយប្រើប្រាស់ពេលវេលាអស់ ៥៦% និងការអនុវត្តគម្រោងជាលក្ខណៈរូបវន្តរបស់គម្រោងមកដល់ពេលបច្ចុប្បន្នសម្រេចបាន ៤៤% (សមាសភាគ១ស្មើនឹង៤២% សមាសភាគ២ស្មើនឹង ៤៧% និងសមាសភាគ៣ស្មើនឹង៤៧%)។ ការចំណាយរបស់គម្រោង ចាប់តាំងពីគម្រោងចាប់ផ្តើមមកដល់បច្ចុប្បន្នមានចំនួន ១៧ ៥៨១ ៧៣៤ដុល្លារអាមេរិក (២៧%)។ ផ្នែកកសិកម្ម កសិករដែលទទួលផលប្រយោជន៍ដោយផ្ទាល់ពីគម្រោងមានចំនួន ១១៥៤គ្រួសារ ដោយមិនផ្ទាល់ពីគម្រោងមាន២៨ ៧៣០គ្រួសារ។ គណៈកម្មាធិការជាតិសម្រាប់ការអនុវត្តតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កសិករដែលទទួលផលប្រយោជន៍ដោយផ្ទាល់ពីគម្រោងមាន ១៧ ៥៤៣គ្រួសារ (ក្រុមកែលម្អជីវភាព) និងមិនផ្ទាល់ពីគម្រោង (គម្រោងហេដ្ឋារចនាសម្ព័ន្ធ និងស្រោចស្រព) តាំងពីចាប់ផ្តើមមកដល់បច្ចុប្បន្នមាន ៤១ ៧៥៥គ្រួសារ។ ការអនុវត្តគម្រោងជាលក្ខណៈរូបវន្តក្នុងឆ្នាំ២០២០ សម្រេចបាន ៧០% និងការអនុវត្តគម្រោងជាលក្ខណៈរូបវន្តរបស់គម្រោងមកដល់ពេលបច្ចុប្បន្នបានចំនួន ៤២%។

**ឃ. គម្រោងខ្សែច្រវ៉ាក់ផលិតកម្មដោយភាតរៈបរិស្ថាន** (Climate-Friendly Agribusiness Value Chains Sector Project-CFACV)

គម្រោងខ្សែច្រវ៉ាក់ផលិតកម្មដោយភាតរៈបរិស្ថាន(CFACV) បានជួយគាំទ្រផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម និងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មរបស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់ការប្រកួតប្រជែងនៃខ្សែច្រវ៉ាក់តម្លៃកសិពាណិជ្ជកម្មនៅខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ តាមដងទន្លេមេគង្គនៃច្រករបៀងសេដ្ឋកិច្ច ភាគខាងត្បូងរបស់អនុតំបន់ទន្លេមេគង្គ (GMS) និងនៅខេត្តកំពត និងតាកែវ តាមបណ្តោយច្រករបៀងសេដ្ឋកិច្ច ឆ្នេរប៉ែកខាងត្បូង។

គម្រោងនេះជួយលើកកម្ពស់ភាពធន់ទ្រាំនឹងអាកាសធាតុ ដោយគាំទ្រហេដ្ឋារចនាសម្ព័ន្ធកសិកម្មសំខាន់ៗ និងខ្សែច្រវ៉ាក់ផលិតកម្មដំណាំស្រូវ ពោត ដំឡូងមី និងស្វាយ ដោយជួយបង្កើនផលិតភាព និងពិពិធកម្មដំណាំ ការកែលម្អសមត្ថភាពឃ្លាំងស្តុកទុកដាក់ ការកែច្នៃ និងការធ្វើតេស្តគុណភាព និងសុវត្ថិភាពផលិតផល ព្រមទាំងលើកកម្ពស់ការប្រើប្រាស់ថាមពលព្រះអាទិត្យ និងជីវថាមពល។ គម្រោងនឹងជួយពង្រឹងសមត្ថភាពបច្ចេកទេស និងស្ថាប័នសម្រាប់វិស័យកសិកម្មវៃឆ្លាត (CSA) និងបង្កើតបរិយាកាសនៃគោលនយោបាយមួយដែលអាចធ្វើទៅបានសម្រាប់ផលិតកម្មប្រកបដោយភាពតរៈបរិស្ថាន នឹងនាំមកនូវនិរន្តរភាពបរិស្ថានយូរអង្វែង និងបង្កើនប្រាក់ចំណេញដល់កសិករក្នុងផលិតកម្មកសិកម្ម។

ក្នុងឆ្នាំ២០២០នេះ គម្រោងសម្រេចលទ្ធផលសំខាន់ៗរួមមាន៖ គម្រោងបានរៀបចំបង្កើតគណៈកម្មាធិការដឹកនាំគម្រោង ដែលមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ជាប្រធាន តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអនុប្រធាន និងមានសមាជិកដែលជាតំណាងមកពីក្រសួងធនធានទឹក និងឧតុនិយម ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងបរិស្ថាន។ បានរៀបចំបង្កើតអង្គភាពគ្រប់គ្រងគម្រោង (ភ្នាក់ងារប្រតិបត្តិគម្រោង) និងភ្នាក់ងារអនុវត្តគម្រោងថ្នាក់ខេត្ត។ បានរៀបចំធ្វើ និងបំពេញនិតិវិធីលទ្ធកម្មតាមគោលការណ៍ណែនាំអនុវត្តគម្រោង និងមានគណៈកម្មការលទ្ធកម្មរៀបចំលើការដេញថ្លៃទិញទំនិញ និងសេវាការងារ។ បានរៀបចំធ្វើរបាយការណ៍វាយតម្លៃ និងកំណត់ហេតុផ្លាស់ប្តូរទីប្រឹក្សាបច្ចេកទេសមួយចំនួននៅក្នុងកញ្ចប់ Project Implementation Consultant (PIC) - Package CS1), CS2 (Capacity Building and Climate Smart Agriculture consulting firm - Package CS2), CS5 (Feasibility Studies and Detailed Engineering Design consulting firm–Package CS5)។ បានផ្គត់ផ្គង់សង្ហារិម និងសម្ភារការិយាល័យសម្រាប់ PMU បានផ្គត់ផ្គង់ឧបករណ៍អេឡិចត្រូនិកជូនផ្នែកគ្រប់គ្រងនិងអនុវត្ត និងបានចុះកិច្ចសន្យាបោះពុម្ព Poster និងធ្វើស្លាកសញ្ញាសម្រាប់ផ្សព្វផ្សាយ ឡជីវឧស្ម័ន និងរោងជីកំប៉ុស្ត។ បានផ្សព្វផ្សាយជាសាធារណៈ បើកកញ្ចប់ និងកំពុងវាយតម្លៃឯកសារដេញថ្លៃ សាងសង់អគាររោងជាង ឃ្លាំងស្តុកសម្រាប់សហគមន៍កសិកម្ម សាងសង់អគារបណ្តុះបណ្តាល អភិវឌ្ឍន៍កសិកម្ម សាងសង់ឡជីវឧស្ម័នចំនួន៥០០ឡ និងរោងជីកំប៉ុស្តចំនួន២៥០រោង សម្រាប់ខេត្តគោលដៅរបស់គម្រោង។ បានរៀបចំបើកគណនីរួចរាល់សម្រាប់អនុវត្តគម្រោងដែលមាន គណនីធនាគារជាតិនៃកម្ពុជា NBC (Account N: 000000017348 គណនីឈ្មោះ CFAVC-MAFF-ADB-L គណនីឈ្មោះCFAVC-MAFF ADB-GCF-G គណនីឈ្មោះ CFAVC-MAFF-RGC។ ហេដ្ឋារចនាសម្ពន្ធ័ខ្សែសង្វាក់តម្លៃ កសិពាណិជ្ជកម្មសំខាន់ៗ ត្រូវបានកែលម្អ និងធ្វើឱ្យមានភាពធន់ និង អាកាសធាតុ រួមមាន ការងារសាងសង់សំណង់ស៊ីវិល ប្រព័ន្ធធារាសាស្ត្រ ផ្លូវ ឃ្លាំង និងឡជីវឧស្ម័ន។

### ង. គម្រោងជំរុញផលិតកម្មស្បៀង (Rice SDP)

កម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ (Rice-SDP) ត្រូវបានអនុម័តដោយធនាគារអភិវឌ្ឍន៍អាស៊ីនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ និងដាក់ឱ្យដំណើរការនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៣ ដែលមានថវិកាសរុបចំនួន ៨៧,៤៤ លានដុល្លារអាមេរិក។ កម្មវិធីទទួលបានកម្ចី២ប្រភេទ [កម្ចីពីមូលនិធិអភិវឌ្ឍន៍អាស៊ី (ADF) ចំនួន ៥៥លានដុល្លារអាមេរិក និងកម្ចីពីមូលនិធិសម្រាប់យុទ្ធសាស្ត្រអាកាសធាតុ (SCF) ចំនួន ៥លានដុល្លារអាមេរិក ជំនួយឥតសំណង២ប្រភេទ [ជំនួយពីកម្មវិធីសន្តិសុខស្បៀងនិងកសិកម្មសកល (GAFSP) ចំនួន១៤,៦លានដុល្លារអាមេរិក និងជំនួយពី SCF ចំនួន៤,៥លានដុល្លារអាមេរិក] និងបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជាចំនួន ៨,៣៣លានដុល្លារអាមេរិក។ ក្នុងចំនួនថវិកាសរុបខាងលើនេះមាន២៤លានដុល្លារអាមេរិកសម្រាប់រៀបចំគោលនយោបាយ និងឯកសារ បទដ្ឋានគតិយុត្តពាក់ព័ន្ធក្រោមច្បាប់ និង ៦៣,៤៤លានដុល្លារអាមេរិកសម្រាប់ដំណើរការអនុវត្តសកម្មភាពកម្មវិធីនៅ ខេត្តគោលដៅ ទាំងបី (ខេត្តបាត់ដំបង ព្រៃវែង និងខេត្តកំពង់ធំ)។ ជាក់ស្តែង ថវិកាដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបានសម្រាប់ការអនុវត្តកម្មវិធីខាងលើមានចំនួនសរុប ១២,៦៧៥លានដុល្លារអាមេរិក។ កាលបរិច្ឆេទ

បញ្ចប់កម្មវិធីសម្រាប់ការងាររៀបចំគោលនយោបាយនិងបទដ្ឋានគតិយុត្តពាក់ព័ន្ធក្រោមច្បាប់ (Program Loan Closing Date) គឺនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ ប៉ុន្តែបានពន្យារពេលចំនួន០៣លើក ដែលក្នុងនោះលើកទី១ រហូតទៅដល់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ លើកទី២រហូតទៅដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ និងលើកទី៣ រហូតទៅដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១។ ដោយឡែក កាលបរិច្ឆេទនៃការបញ្ចប់ការអនុវត្តសកម្មភាពគម្រោង (Project Loan Closing Date) គឺនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ ប៉ុន្តែបានពន្យារពេលចំនួន០១លើករហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១។

កម្មវិធី Rice-SDP អនុវត្តដោយក្រសួងចំនួន០៤ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាភ្នាក់ងារប្រតិបត្តិ (EA) និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ដែលជាភ្នាក់ងារអនុវត្ត (IAs) នៅថ្នាក់ជាតិ និងខេត្តគោលដៅចំនួន០៣ (ខេត្តកំពង់ធំ បាត់ដំបង និងខេត្តព្រៃវែង ដែលជាភ្នាក់ងារអនុវត្ត (IAs) នៅថ្នាក់ក្រោមជាតិ។

ក្នុងឆ្នាំ២០២០នេះ គម្រោងសម្រេចបានលទ្ធផល ដូចខាងក្រោម៖

- កម្មវិធីបានបំពេញលក្ខខណ្ឌនៃការកសាងច្បាប់និងបទដ្ឋានគតិយុត្តក្រោមច្បាប់ដើម្បីសម្របសម្រួលដល់ការធ្វើពាណិជ្ជកម្មស្រូវ-អង្ករដែលធន់នឹងអាកាសធាតុ ចំនួន១២ឯកសារ
- បានបញ្ចប់ទាំងស្រុងនូវការងារវិភាគប្រព័ន្ធក្សេត្របរិស្ថានឃុំ (៩០ឃុំ) ហើយបានបញ្ជូនទិន្នន័យនេះទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីធ្វើសមាហរណកម្មទៅក្នុងផែនការប្រើប្រាស់ដី ថ្នាក់ឃុំ (CLUP)។ ទាក់ទងនឹងការងារផលិតផែនទី គម្រោងបានបញ្ចប់ផែនទី ប្រព័ន្ធក្សេត្របរិស្ថាន ដំណាំ ស្រូវ ចំណាត់ថ្នាក់ប្រភេទដីនិងការប្រើប្រាស់ដីនៃខេត្តគោលដៅទាំងបី
- ការសាងសង់ឃ្លាំងស្តុកនិងឡសម្ងួត (SPS) ៖ បានចុះកិច្ចសន្យានៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០ និងបានបញ្ចប់ការរៀបចំផែនការអាជីវកម្ម ផែនការគ្រប់គ្រងបរិស្ថាន និងកំពុងរៀបចំឯកសារស្នើសុំ សាងសង់ និងឯកសារបើកការដ្ឋានសាងសង់
- ការអភិវឌ្ឍរោងម៉ាស៊ីនកិនស្រូវ៖ បានគាំទ្រក្រុមហ៊ុន អា ក្រូ និច រៀបចំសិក្ខាសាលាសរុបចំនួន០៦វគ្គ នៅតាមខេត្តគោលដៅ
- ការបង្កើនសេវាកម្មគាំទ្រខ្សែច្រវ៉ាក់ផលិតកម្មស្រូវ-អង្ករដើម្បីលើកកម្ពស់គុណភាពអង្ករកម្ពុជា គម្រោងបានរៀបចំវគ្គបណ្តុះបណ្តាលសរុបចំនួន ៨៧វគ្គ ដោយមានអ្នកចូលរួមសរុបចំនួន៥ ៨៧២នាក់ (ស្ត្រីចំនួន២ ៨២០នាក់) និងវគ្គបណ្តុះបណ្តាលស្តីពីសាលារៀនស្រែកសិករចំនួន១៦៥សាលា (សម្រាប់ផលិតកម្មគ្រាប់ពូជស្រូវ) និង៦០សាលា (សម្រាប់ផលិតកម្មដំណាំស្រូវនិរន្តរភាព) ដែលមានសិក្ខាកាមសរុបចំនួន ៥ ៦២៥ នាក់ (ស្ត្រីចំនួន ២ ៥០០នាក់)
- បានផលិតគ្រាប់ពូជស្រូវក្រអូបបានចំនួន ៨ ០៤០ តោន (ស្មើនឹង ៨៤% បើធៀបនឹងទិសដៅកំណត់ ២ ៤០០តោន x ៤ឆ្នាំ=៩ ៦០០តោន)
- បានរៀបចំឯកសារគោលការណ៍ណែនាំបច្ចេកទេសចំនួន០៨ និងកំពុងបោះពុម្ពឯកសារទាំងអស់នោះ
- បានបញ្ចប់ការរៀបចំស្លាកសញ្ញាដើម្បីបិទលើបាវអង្ករ បញ្ជាក់គុណភាពគ្រាប់ពូជស្រូវដែលបានត្រួតពិនិត្យដោយមន្ត្រីអធិការកិច្ច។ បានចុះទីវាលពិនិត្យមើលការងារសាលារៀនស្រែកសិករ (FFSs) និងផលិតកម្មគ្រាប់ពូជស្រូវរបស់សហគមន៍កសិកម្ម និងស្ថានីយកសិកម្ម នៅខេត្តគោលដៅទាំងបី
- ការសាកល្បង ការធានារ៉ាប់រងដំណាំផ្អែកលើសន្ទស្សន៍អាកាសធាតុ បានប្រគល់ជូនអង្គភាពគ្រប់គ្រងនិងសម្របសម្រួលការអនុវត្តកម្មវិធី (PMO, MEF) ជាអ្នកអនុវត្ត ហើយអង្គភាព MAFF-NIO ជាអ្នកផ្តល់ការគាំទ្រផ្នែកបច្ចេកទេសកសិកម្មវិញ

- ការអនុវត្ត និងការគ្រប់គ្រងកម្មវិធីប្រកបដោយប្រសិទ្ធភាព គម្រោងបានរៀបចំវគ្គបណ្តុះបណ្តាលពាក់ព័ន្ធនឹងការងារត្រួតពិនិត្យនិងវាយតម្លៃគម្រោង និងការងារយេនឌ័រ និងបម្រែបម្រួលអាកាសធាតុសរុបចំនួន ៣៥ វគ្គ ដោយមានអ្នកចូលរួមសរុបចំនួន ១ ៣៨៦នាក់ (ស្ត្រី ៧៥៧នាក់)
- បានរៀបចំកិច្ចប្រជុំផ្ទៃក្នុងអង្គភាព និងកិច្ចប្រជុំជាមួយអង្គភាពពាក់ព័ន្ធផ្សេងៗដើម្បីសម្របសម្រួលការងារជាបន្តបន្ទាប់ជាមួយមន្ត្រីបង្គោលកសិកម្មក្នុងខេត្តគោលដៅ និងបានចុះបំពេញបេសកកម្មតាមខេត្តគោលដៅទាំងបី ដើម្បីពិនិត្យតាមដានស្ថានភាពជាក់ស្តែង ពិភាក្សាការងារ និងផ្តល់ជំនួយបច្ចេកទេសបន្ថែមជូនអង្គភាពអនុវត្តន៍កម្មវិធីថ្នាក់ខេត្ត ដើម្បីយកទៅអនុវត្តសកម្មភាពបន្តនៅក្នុងខេត្តរបស់ខ្លួន។

**ច.គម្រោងពិពិធកម្មកសិកម្មកម្ពុជា** (WB)

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានកិច្ចសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធានទឹក និងឧតុនិយម និងដោយមានការគាំទ្រពីជំនាញការរបស់ធនាគារពិភពលោក បានរៀបចំគម្រោងមួយឈ្មោះថា **គម្រោងពិពិធកម្មកសិកម្មកម្ពុជា**។ កិច្ចព្រមព្រៀងឥណទានសម្បទានសម្រាប់គម្រោងពិពិធកម្មវិស័យកសិកម្មកម្ពុជាបានចុះហត្ថលេខារវាងព្រះរាជាណាចក្រកម្ពុជា និងធនាគារពិភពលោក នាថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ ហើយកិច្ចព្រមព្រៀងឥណទានសម្បទាននេះមានសុពលភាពនៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩។ ថវិកាសរុបសម្រាប់គម្រោងមានចំនួន ១០១,៦៧ លានដុល្លារអាមេរិក មានរយៈពេលអនុវត្តពីឆ្នាំ២០១៩ ដល់ឆ្នាំ ២០២៤ ដែលក្នុងនោះមានថវិកាសម្បទានឥណទានចំនួន ៩១,៦៧លានដុល្លារអាមេរិក ពីធនាគារពិភពលោក និងថវិកាបដិភាគ មានចំនួន១០លានដុល្លារអាមេរិកពីរាជរដ្ឋាភិបាលកម្ពុជា។

ខេត្តគោលដៅគម្រោង រួមមាន៖ កំពង់ឆ្នាំង បាត់ដំបង សៀមរាប ព្រះវិហារ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ក្រចេះ ត្បូងឃ្មុំ កំពង់ចាម កណ្តាល កំពង់ស្ពឺ និងរាជធានីភ្នំពេញ។ គោលបំណងរបស់គម្រោង គឺជួយសម្រប សម្រួលដល់ការអភិវឌ្ឍខ្សែច្រវ៉ាក់ ពិពិធកម្មកសិកម្មក្នុងខេត្តគោលដៅរបស់គម្រោង និងផ្តល់ការគាំទ្រក្នុងករណីមានវិបត្តិ ឬ សង្គ្រោះបន្ទាន់។

គម្រោងពិពិធកម្មកសិកម្មកម្ពុជា មានសមាសភាគបួនគឺ៖ (ក) ការជំរុញពិពិធកម្មកសិកម្ម (ខ) គាំទ្រលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ (ប្រព័ន្ធស្រោចស្រព និងផ្លូវជនបទ) (គ) លើកកម្ពស់ប្រព័ន្ធព័ត៌មានកសិកម្ម និងគ្រប់គ្រងការត្រួតពិនិត្យគុណភាព (ឃ) ការសម្របសម្រួលការគ្រប់គ្រងគម្រោង និងការតាមដាន និងវាយតម្លៃគម្រោង (ង) ការឆ្លើយតបនៅពេលមានវិបត្តិ។

ក្នុងឆ្នាំ២០២០ គម្រោងសម្រេចបានលទ្ធផល ដូចខាងក្រោម៖

- អង្គភាពសម្របសម្រួលគម្រោងបានបង្កើត ហើយនាយកគម្រោង និងប្រធានគ្រប់គ្រងគម្រោងក៏ដូចជាមន្ត្រីគម្រោងថ្នាក់ជាតិ និងថ្នាក់ខេត្ត ត្រូវបានចាត់តាំង
- បានបង្កើតគណៈកម្មាធិការការតម្រង់ទិសគម្រោង (Project Steering Committee “PSC”)
- សៀវភៅណែនាំស្តីពីប្រតិបត្តិការគម្រោង (POM) ត្រូវបានបោះពុម្ព
- បេសកកម្មគាំទ្រការអនុវត្តគម្រោង (ISM) លើកទីពីរត្រូវបានអនុវត្ត
- ផែនការសកម្មភាព និងថវិកាឆ្នាំ២០២០ត្រូវបានបូកសរុប និងទទួលបានការឯកភាពពីធនាគារពិភពលោក និង MEF និងបានចំណាយអស់ ៤១%ធៀបទៅនឹងការអនុម័តឆ្នាំ២០២០
- សិក្ខាសាលាចាប់ផ្តើមអនុវត្តគម្រោង សិក្ខាសាលាតម្រង់ទិសដើម្បីផ្សព្វផ្សាយពីគោលបំណង គោលដៅគម្រោង និងនីតិវិធីអនុវត្តគម្រោងទៅដល់គ្រប់ស្ថាប័នពាក់ព័ន្ធត្រូវបានរៀបចំ

- សមាសភាគឆ្លើយតបសង្គ្រោះបន្ទាន់ (CERC) និងផែនការសកម្មភាពសង្គ្រោះបន្ទាន់ (EAP) សម្រាប់អន្តរាគមន៍កូវីដ-១៩ ត្រូវបានរៀបចំ និងទទួលបានការឯកភាពពីធនាគារពិភពលោកនាថ្ងៃទី៩ ខែតុលា ឆ្នាំ២០២០
- ចុះអង្កេត និងសិក្សាវាយតម្លៃដល់សហគមន៍កសិកម្ម និងក្រុមផលិតពីផលប៉ះពាល់ដោយកូវីដ-១៩ និងធ្វើការឆ្លើយតបនៅតាមខេត្តគោលដៅ
- បានជ្រើសរើស និងចុះកិច្ចសន្យាជាមួយក្រុមការងារអ្នកផ្តល់សេវាបច្ចេកទេស(TSP)ចំនួនពីរគឺ ក្រុមហ៊ុន SBK Research and Development និង អង្គការ Actions for Research and Development ដើម្បីជួយដល់សហគមន៍កសិកម្មក្នុងការរៀបចំសំណើពិពិធកម្មកសិកម្ម និងផែនការអាជីវកម្ម
- ក្រុមការងារអ្នកផ្តល់សេវាបច្ចេកទេស(TSP) បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីគម្រោងលើកទីមួយសម្រាប់ថ្នាក់ខេត្តមានអ្នកចូលរួមសរុប ៧៩៩នាក់ ស្រី ១៨៨នាក់ ដែលមកពីសហគមន៍កសិកម្មចំនួន ១២២ ក្រុមផលិតចំនួន ៣៧ និងកសិធុរកិច្ចចំនួន ៧៥នាក់ និងលើកទីពីរសម្រាប់ថ្នាក់ស្រុក មានអ្នកចូលរួមសរុប ៤៥២នាក់ ស្រី ៩៩នាក់ ដែលមកពីសហគមន៍កសិកម្មចំនួន ១៥៤ ម្ចាស់កសិដ្ឋានចំនួន ៣នាក់ អង្គការក្រៅរាជរដ្ឋាភិបាលចំនួន ៤២ និងកសិធុរកិច្ចចំនួន ៣១នាក់
- ក្រុមការងារអ្នកផ្តល់សេវាបច្ចេកទេស (TSP) បានរៀបចំកិច្ចពិភាក្សាបង្កើតភាពជាដៃគូ និងបណ្តាញអាជីវកម្មកសិកម្ម រវាងសហគមន៍កសិកម្ម កសិពាណិជ្ជករ និងអ្នកពាក់ព័ន្ធ ចំនួន ៣៨លើក
- On-lending Agreement បានចុះហត្ថលេខារវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ARDB (ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០)។

**ឆ. គម្រោងបែងចែកដីសង្គមកិច្ច ដើម្បីការអភិវឌ្ឍសេដ្ឋកិច្ច (LASET-II)**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានកិច្ចសហការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងធនាគារពិភពលោក បានអនុវត្តសកម្មភាពរបស់ខ្លួន និងទទួលបានលទ្ធផល ដូចខាងក្រោម៖

- បណ្តុះបណ្តាលបច្ចេកទេសកសិកម្ម (បច្ចេកទេសចិញ្ចឹមសត្វ បច្ចេកទេសដាំបន្លែ ការបង្កើនគុណភាពដីកសិកម្មវ៉ែឆ្លាត ទីផ្សារកសិកម្ម ។ល។)ដល់សម្បទានិក នៅក្នុងទីតាំងដីសម្បទានសង្គមកិច្ច ទាំង ១៥ទីតាំង នៃខេត្តក្រចេះ កំពង់ឆ្នាំង កំពង់ធំ កំពង់ស្ពឺ និងខេត្តត្បូងឃ្មុំ សរុបចំនួន ១៩៥វគ្គ ដែល មានអ្នកចូលរួមសរុបចំនួន ៦ ០៦៣នាក់ (ស្រីចំនួន ៤ ១៦១នាក់) និងរៀបចំទីកន្លែងធ្វើបង្ហាញ បច្ចេកទេសចិញ្ចឹមមាន់ចំនួន ៤៩បង្ហាញ ទីកន្លែងបង្ហាញបច្ចេកទេសដាំបន្លែចំនួន ២៣ បង្ហាញ ទីកន្លែង បង្ហាញប្រព័ន្ធកសិកម្មចម្រុះចំនួន១៧បង្ហាញ ទីកន្លែងបង្ហាញបច្ចេកទេសចិញ្ចឹមត្រីចំនួន២២ បង្ហាញ សរុប១១១ បង្ហាញ ដែលមានសិក្ខាកាមចំនួន ៨៤% បានបង្ហាញការពេញចិត្តលើវគ្គបណ្តុះបណ្តាល និងសេវាកម្មកសិកម្មផ្សេងៗ (ការធ្វើបង្ហាញ) របស់គម្រោង និងមានគ្រួសារសម្បទានិកប្រមាណ ៧៥%បានចាប់យកបច្ចេកទេសដែលទទួលបានពីវគ្គបណ្តុះបណ្តាល និងទិវាបង្ហាញទៅអនុវត្ត
- ប្រជុំផ្សព្វផ្សាយ និងបំពាក់បំប៉នបច្ចេកទេសកសិកម្មបាន ៦៧វគ្គ ដែលមានអ្នកចូលរួមសរុបចំនួន ១ ៧២៦ នាក់ ក្នុងនោះមានស្ត្រីចូលរួមចំនួន ៨២១នាក់។ គម្រោងក៏បានចែកទូរភ្ញាស់កូនមាន់ដល់សម្បទានិក បានចំនួន ១០ទូ ដើម្បីភ្ញាស់កូនមាន់លក់ និងចិញ្ចឹម
- បណ្តុះបណ្តាល និងតាមពង្រឹងភ្នាក់ងារសុខភាពសត្វភូមិចំនួន ១៣នាក់ ក្នុងមួយនាក់មួយទីតាំងដីសម្បទានសង្គមកិច្ច និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មចំនួន ២៦នាក់ (ពីរនាក់ក្នុងមួយទីតាំងដីសម្បទានសង្គមកិច្ច)។ ភ្នាក់ងារទាំងនេះ បានចូលរួមបណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងចិញ្ចឹមសត្វដល់សម្បទានិក។ ពិសេសទៅទៀតនោះ ភ្នាក់ងារសុខភាពសត្វភូមិទាំងនេះ បានចូលរួមក្នុងយុទ្ធនាការចាក់

វ៉ាក់សាំងការពារជំងឺគោ ក្របី ដែលរៀបចំដោយការិយាល័យផលិតកម្ម និងបសុព្យាបាលនៃមន្ទីរកសិកម្មរុក្ខាប្រមាញ់និងនេសាទខេត្តគោលដៅរបស់គម្រោង និងបានចូលរួមអនុវត្តកម្មវិធីពង្រីកផលិតកម្មចិញ្ចឹមមាន់នៅក្នុងទីតាំងដីសម្បទាន

- ចុះយុទ្ធនាការផ្សព្វផ្សាយចាក់វ៉ាក់សាំងដល់សត្វចិញ្ចឹម និងការការពារជំងឺឆ្លងដល់សត្វបានចំនួន ២៩ដង ដែលក្នុងនោះមានការចូលរួមពីសម្បទានិកចំនួន ៩៣៥គ្រួសារ និងបានចាក់វ៉ាក់សាំងដល់សត្វមាន់បានចំនួន ៣៩ ១៩៦ក្បាល ដែលធ្វើឱ្យអត្រាមាន់ងាប់ថយចុះរហូតដល់៥០%។ ម្យ៉ាងវិញទៀត ៨០%នៃគ្រួសារសម្បទានិក (ភាគច្រើនជាស្ត្រី) ចេះបច្ចេកទេសចាក់វ៉ាក់សាំងដោយខ្លួនឯង
- គាំទ្រដល់សហគមន៍កសិកម្មចំនួន០៨ នៅក្នុងទីតាំងដីសម្បទានសង្គមកិច្ចគម្រោងដែលមានសមាជិកចំនួន ៥០៦ នាក់ ភាគហ៊ុនចំនួន ៤ ២៧០ហ៊ុន និង មានទុនសរុបចំនួន ២១៥ ៥៧៤ ០០ រៀល និងក្រុមទុនបង្វិលចំនួន ១០១ក្រុម ដែលមានសមាជិកជាស្ត្រីចំនួន២ ០២៥នាក់ ក្នុងនោះ ១ ៣១៥នាក់ ដែលមានដើមទុនសរុបចំនួន២៣៨ ៦៣២ ៧៧០រៀល
- ជារួមគម្រោងសម្រេចលទ្ធផលបានចំនួន៣៣,៣៣% នៃផែនការសរុបប្រចាំឆ្នាំ។ ចំណាយថវិកាអស់ចំនួន ៨ ៥៤០ ៧៥៨ដុល្លារ ស្មើនឹង ២១,៣៨% នៃថវិការឆ្នាំ២០២០ ចំនួន ៤០ ១០០ ០៣៣ដុល្លារ។

### ជ. កម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះគុណភាពដី (NAP)

កម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះគុណភាពដី ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីទប់ស្កាត់ និងដោះស្រាយបញ្ហាធ្លាក់ចុះនៃគុណភាពដី សំដៅថែរក្សា ការពារកេ្សត្របរិស្ថាន បង្កើនផលិតភាពដី និងចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ និងអភិវឌ្ឍប្រទេសជាតិប្រកបដោយនិរន្តរភាព ព្រមទាងចូលរួមអនុវត្តនូវកាតព្វកិច្ចក្នុងអនុសញ្ញាសហប្រជាជាតិប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះគុណភាពដី ជាពិសេសដើម្បីរួមចំណែកធ្វើឱ្យសម្រេចបាននូវភាពគ្មានការធ្លាក់ចុះគុណភាពដីនៅឆ្នាំ២០៣០។

ជាក់ស្តែងក្នុងឆ្នាំ២០២០នេះ ការអនុវត្តកម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះគុណភាពដីរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រេចបាន លទ្ធផលដូចខាងក្រោម៖

- បានរៀបចំទស្សនកិច្ចសិក្សាចុះពិនិត្យស្ថានភាពទីជម្រាលស្ទឹងព្រែកត្នោត និងពិនិត្យមើលសកម្មភាពចម្ការឈើដាំ នៅស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ
- បានសម្របសម្រួល និងរៀបចំសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងទីជម្រាលថ្នាក់ក្រោមជាតិចំនួន៣៩ទីជម្រាល ទូទាំងប្រទេសកម្ពុជា
- បានថតចម្លង និងចែករំលែកសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងទីជម្រាលថ្នាក់ក្រោមជាតិ ទៅកាន់សមាជិកគណៈកម្មាធិការគ្រប់គ្រងទីជម្រាលថ្នាក់ក្រោមជាតិ ប្រមាណ ៥០០០ រូប
- បានរៀបចំសិក្ខាសាលាស្តីពីការលើកកម្ពស់ការយល់ដឹងអំពីគុណភាពដី និងទឹកសំដៅចូលរួមគ្រប់គ្រង និងប្រើប្រាស់ធនធានដីកសិកម្មប្រកបដោយនិរន្តរភាព និងភាតរបរិស្ថាន នៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានរៀបចំកិច្ចប្រជុំពិភាក្សាស្តីពីរបាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្ត NAP & UNCDD នៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានរៀបចំកិច្ចប្រជុំពិភាក្សាអំពីការបែងចែកតួនាទី ភារកិច្ចរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍ NAP នៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ការរាយការណ៍អំពីវឌ្ឍនភាពក្នុងការអនុវត្ត NAP & UNCCD នៅសកលវិទ្យាល័យភូមិន្ទកសិកម្ម

- បានរៀបចំកិច្ចប្រជុំពិភាក្សាស្តីពីការអនុវត្តសកម្មភាពឆ្នាំ២០២០ និងវិធីសាស្ត្រប្រមូលរបាយការណ៍ពីក្រសួងស្ថាប័នផ្សេងៗពាក់ព័ន្ធទៅនឹងការធ្លាក់ចុះគុណភាពដី និងពិភាក្សាការបែងចែកសេចក្តីសម្រេចទៅថ្នាក់ស្រុក និងឃុំ
- បានរៀបចំកិច្ចប្រជុំពិគ្រោះថ្លៃ ស្តីពីការជួលទីប្រឹក្សាសម្រាប់ដំណើរផ្នែកការប្រព្រឹត្តទៅនៃអង្គភាព NAP
- បានរៀបចំឯកសារ និងជ្រើសរើសទីប្រឹក្សាជំនាញបច្ចេកទេសជាតិសម្រាប់ការសិក្សា និងវឌ្ឍនភាពសម្រាប់ការអនុវត្ត
- បានរៀបចំកិច្ចប្រជុំពិនិត្យ និងប្រគល់ទទួលរបាយការណ៍ការងារ ទីប្រឹក្សាជំនាញបច្ចេកទេស សម្រាប់ការសិក្សា និងវឌ្ឍនភាពសម្រាប់អនុវត្ត
- បានបោះពុម្ពឯកសារសម្រាប់ចែកជូនសមាជិក គណៈកម្មាធិការគ្រប់គ្រងទីជម្រាលថ្នាក់ក្រោមជាតិចំនួន២លើក រួមមាន ៖ ទស្សនទាន និងពាក្យគន្លឹះទាក់ទងនឹង UNCCD (៥០០ក្បាល) និងរបោស្ថានកម្ម/ ឱនភាពដីនៅតំបន់ដីស្ងួត ស្ងួតមធ្យម និងសើមតិចតួច (៣០០ក្បាល)។

## ៥.៨. ការងារគ្រប់គ្រងឯកសារ និងប្រព័ន្ធព័ត៌មានកសិកម្ម

### ក. ការគ្រប់គ្រងឯកសារ

- បានទទួលសៀវភៅ ឯកសារបច្ចេកទេសកសិកម្ម ទស្សនាវដ្តី ដែលទទួល បានពីនាយកដ្ឋានកិច្ចការរដ្ឋបាល នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងផ្នែកផ្សេងៗសរុបចំនួន៦៩៥ ក្បាល/ច្បាប់
- បានបោះពុម្ព និងទិញបន្ថែម សម្រាប់ដាក់តម្កល់ សរុបចំនួន៤២៣ក្បាល/ច្បាប់
- បានផ្សព្វផ្សាយអំពីបណ្ណាល័យកសិកម្មអេឡិចត្រូនិកដែលមានអ្នកចូលទស្សនាចំនួន៩៥ ៤០១ដង/នាក់ អ្នកបានបង្កើតគណនីប្រើប្រាស់សរុបចំនួន ៥ ៣៧៦នាក់
- បានស្កេនឯកសារ ដើម្បីបញ្ចូលក្នុងប្រព័ន្ធបណ្ណាល័យអេឡិចត្រូនិកបានចំនួន០៨ក្បាល
- បញ្ចូលសៀវភៅ ឯកសារបច្ចេកទេសកសិកម្ម និងអត្ថបទផ្សេងៗសរុបចំនួន១៩៩ក្បាល/ច្បាប់ និងឯកសារវីដេអូសរុបចំនួន០២វីដេអូ
- ជំរុញការផ្សព្វផ្សាយឯកសារបច្ចេកទេសកសិកម្ម សេចក្តីជូនដំណឹង សារាចរណែនាំ សេចក្តីសម្រេច ប្រកាស និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីជំរុញឲ្យបានទូលំទូលាយលើបណ្តាញផ្សព្វផ្សាយសង្គម (ហ្វេសប៊ុក) និងគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

### ខ. ការគ្រប់គ្រងប្រព័ន្ធព័ត៌មានកសិកម្ម

- ដកស្រង់ព័ត៌មានប្រចាំថ្ងៃសកម្មភាពរបស់ថ្នាក់ដឹកនាំក្រសួង និងតាមបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីផុសក្នុងហ្វេសប៊ុកផេកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សរុបចំនួន ១ ៩៣៤ព័ត៌មាន
- ដកស្រង់ព័ត៌មានកសិកម្មប្រចាំថ្ងៃចេញពីបណ្តាញផ្សព្វផ្សាយសារព័ត៌មានសរុបចំនួន២ ១៩៩ព័ត៌មាន
- តាមដានលើការផ្សព្វផ្សាយសកម្មភាពការងាររបស់អង្គភាពថ្នាក់កណ្តាល លើគេហទំព័រសរុបចំនួនផុស៣៩៤ព័ត៌មាន
- តាមដានលើការផ្សព្វផ្សាយសកម្មភាពការងាររបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត លើគេហទំព័រសរុបចំនួនផុស ៦ ៩២១ព័ត៌មាន
- បញ្ចូលសកម្មភាពរបស់ឯកឧត្តមរដ្ឋមន្ត្រី និងថ្នាក់ដឹកនាំក្រសួង ចូលរួមជួបភ្ញៀវ ប្រជុំ និងចូលរួមកម្មវិធីផ្សេងៗ លើគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានចំនួន២១២ព័ត៌មាន

- ថែទាំលើគេហទំព័រ (Web) និង Mobile App របស់ក្រសួង និងអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ សរុបចំនួន១៧ (១៦ គេហទំព័រ និង១កម្មវិធី) និងគេហទំព័រមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត
- បានបន្ថែមតំណភ្ជាប់លើគេហទំព័រក្រសួង ដើម្បីទាញយកកម្មវិធីទូរស័ព្ទ (Mobile App) របស់ក្រសួងក្នុង Playstore និង Appstore
- បានសម្របសម្រួល និងសហការរៀបចំបង្កើតប្រព័ន្ធដាក់ពាក្យបណ្តឹងក្នុងគេហទំព័រនៃអគ្គាធិការដ្ឋាន https://gi.maff.gov.kh
- បានបញ្ចូលតំណភ្ជាប់គេហទំព័រនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទៅក្នុងគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (https://deaff.maff.gov.kh)
- បានបង្កើត Sub Domain (http://dphrd.maff.gov.kh) សម្រាប់គេហទំព័ររបស់នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស
- បានបង្កើតគេហទំព័រ casdp.maff.gov.kh និងអ៊ីមែល casdp@maff.gov.kh ជូនគម្រោងពិពិធកម្មកសិកម្មកម្ពុជា
- បានបង្កើតគេហទំព័រ gdr.1maff.gov.kh ជូនអគ្គនាយកដ្ឋានកៅស៊ូ
- បានបង្កើតអ៊ីមែល dphrd@maff.gov.kh សម្រាប់នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្សក្នុងការទំនាក់ទំនងផ្លូវការ
- បានបង្កើតអ៊ីមែល (@maff.gov.kh) ផ្លូវការរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីប្រើប្រាស់ក្នុងការទំនាក់ទំនងផ្លូវការ របស់រដ្ឋបាលជលផល
- ចុះបណ្តុះបណ្តាល តាមដានការប្រើប្រាស់ និងបង្ហាញមុខងារប្រើប្រាស់ថ្មីៗលើគេហទំព័ររបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តចំនួន១០ រួមមាន ខេត្តកំពង់ស្ពឺ សៀមរាប កំពង់ធំ កោះកុង តាកែវ ព្រះសីហនុ រតនគិរី មណ្ឌលគិរី ក្រចេះ និងខេត្តស្ទឹងត្រែង
- ចុះប្រមូលទីតាំងដំណាំស្រូវប្រាំងចំនួន០៣ខេត្ត គឺខេត្តស្វាយរៀង តាកែវ និងខេត្តព្រៃវែង ដោយបានប្រមូលយកទីតាំងដំណាំស្រូវប្រាំងចំនួន២០៤ចំណុច សម្រាប់ធ្វើការវិភាគកំណត់សម្គាល់តំបន់ស្រូវប្រាំង និងបរិមាណស្រូវប្រាំង
- ចងក្រង JavaScript code ដែលប្រើប្រាស់សម្រាប់វិស័យកសិកម្ម (ចំណាត់ថ្នាក់ប្រើប្រាស់ដី) ដំណាំ និងបម្រែបម្រួលការប្រើប្រាស់ដី Data Center របស់ក្រុមហ៊ុន Google (Google Earth Engine)
- បានសហការជាមួយរាជបណ្ឌិតសភាវិទ្យាសាស្ត្រនៃសាធារណរដ្ឋប្រជាមានិតចិន ដើម្បីសិក្សា និងប្រមូលទិន្នន័យសម្រាប់ប្រព័ន្ធតាមដានដំណាំ៣ប្រភេទ រួមមាន ដំណាំស្រូវ ពោត និងដំណាំសណ្តែក សម្រាប់ប្រទេសកម្ពុជា
- បន្តការធ្វើបច្ចុប្បន្នភាពលើគេហទំព័របណ្ណាល័យកសិកម្ម និងជំរុញការផ្សព្វផ្សាយ និងបណ្តុះបណ្តាលការប្រើប្រាស់អំពីគេហទំព័របណ្ណាល័យកសិកម្ម និងពិនិត្យអំពីការរៀបចំបណ្ណាល័យរបស់មន្ទីរកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន១០ រួមមាន ខេត្តព្រះវិហារ ក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ កណ្តាល និងខេត្តព្រៃវែង
- សម្អាត Cache នៅលើ Cloud server នៃគេហទំព័រទាំង៤១ (ក្រសួង អគ្គនាយកដ្ឋាន នាយកដ្ឋាន និងមន្ទីរ)
- តាមដានទិន្នន័យដែល ផ្ទុកនៅលើ Cloud server នៃគេហទំព័រទាំង៤១ (ក្រសួង អគ្គនាយកដ្ឋាន នាយកដ្ឋាន និងមន្ទីរ)

- បានរៀបចំសិក្ខាសាលាស្តីពី “សមិទ្ធផលព័ត៌មានវិទ្យាក្នុងវិស័យកសិកម្ម” ។

**គ. ការចុះថតផ្តិតយករូបភាព និងការផលិតវីដេអូ**

- ថតយកសកម្មភាពឯកឧត្តមរដ្ឋមន្ត្រី និងថ្នាក់ដឹកនាំក្រសួងចូលរួមប្រជុំ និងសកម្មភាពការងារផ្សេងៗ មានចំនួន២២៨ដង និងវីដេអូបច្ចេកទេសកសិកម្មសរុបចំនួន១៣០វីដេអូ ដែលមាននៅក្នុង YouTube របស់ក្រសួង ដោយបានបញ្ចូលចំនួន ៧០វីដេអូបន្ថែមទៀត ដើម្បីជំរុញការផ្សព្វផ្សាយតាមរយៈគេហទំព័រក្រសួង និងបណ្តាញផ្សព្វផ្សាយសង្គម របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានផលិតវីដេអូចំនួន០៥ ដែលទាក់ទងទៅនឹងបទយកការណ៍ស្តីពីសក្តានុពលដំណាំបន្លែនៅស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ ពិធីបុណ្យដារលាន ប្រចាំឆ្នាំ២០១៩ នៅខេត្តតាកែវ ទស្សនីយភាពដើមឈើចងចាំនៅភូមិបាទី ស្រុកពាមរក៍ ខេត្តព្រៃវែង បទយកការណ៍ស្តីពីការផលិត និងការកែច្នៃគ្រាប់ស្វាយចន្ទី និងបទយកការណ៍ស្តីពី ភាពជោគជ័យរបស់សហគមន៍ព្រៃតាព្រឹត្តសាមគ្គីមានជ័យ នៅស្រុកបន្ទាយមាស ខេត្តកំពត។

## ៥.៩. ការលើកកម្ពស់ការងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឆ្នាំ២០២០នេះ ក្រសួងបានពង្រឹងសេវាផ្សព្វផ្សាយលើការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងបានទទួលលទ្ធផលដូចខាងក្រោម៖

- បានបណ្តុះបណ្តាលមន្ត្រីកសិកម្ម ឱ្យក្លាយជាទីប្រឹក្សាផ្សព្វផ្សាយកសិកម្មបានចំនួន៥៤នាក់ ស្ត្រី១៣នាក់ រហូតមកដល់ពេលនេះបណ្តុះបណ្តាលបានចំនួន ៤៧៨នាក់ ស្ត្រីចំនួន ១០៥នាក់
- បានធ្វើការវិភាគប្រព័ន្ធក្សេត្របរិស្ថានឃុំបានចំនួន០៣ឃុំ រហូតមកដល់ពេលនេះបានចំនួនសរុប ៧៦ឃុំ
- បានរៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាចំនួន២១វគ្គ ស្តីពីប្រសិទ្ធភាពសេវាផ្សព្វផ្សាយកសិកម្ម ការអង្កេតនៃការទទួលយក និងបច្ចេកវិទ្យាកសិកម្ម ការប្រើប្រាស់ប្រព័ន្ធសេវា ព័ត៌មានវិទ្យា កសិកម្ម (ICT) រៀបចំគោលការណ៍ណែនាំសម្រាប់អ្នកឯកទេសផ្សព្វផ្សាយកសិកម្ម រៀបចំគោលការណ៍ ណែនាំសម្រាប់កសិករផ្សព្វផ្សាយកសិកម្ម ការរៀបចំផែនការប្រមូលទិន្នន័យទី២ ដែលមានមន្ត្រីចូលរួម សរុបចំនួន ៦៤៣ នាក់ ស្ត្រីចំនួន ១៥៥នាក់
- បានចុះប្រមូលទិន្នន័យពីកសិករ ស្តីពីប្រសិទ្ធភាពសេវាផ្សព្វផ្សាយកសិកម្ម ការអង្កេតការទទួលយក និងបច្ចេកវិទ្យាកសិកម្ម សិក្សាអំពីតម្រូវការកសិករ លើការប្រើប្រាស់ប្រព័ន្ធសេវាព័ត៌មានវិទ្យាកសិកម្ម (ICT) បានធ្វើការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំ ចងក្រងបណ្តុះកសិករ ដែលមានកសិករចូលរួមសរុបចំនួន ៤ ០៤០ នាក់ ស្ត្រីចំនួន ២ ៣៩០នាក់
- បានផលិត និងបោះពុម្ពទស្សនាវដ្តី ព្រឹត្តិបត្រ និងកូនសៀវភៅបច្ចេកទេសកសិកម្មចំនួន ២៥ ២០០ច្បាប់
- បានផលិតបទយកការណ៍ និងអត្ថបទបច្ចេកទេសកសិកម្មសរុបចំនួន ១២០ប្រធានបទ និងបានចាក់ផ្សាយតាមប្រព័ន្ធព័ត៌មានសាធារណៈទូរទស្សន៍ និងវិទ្យុចំនួន ៤៣២លើក
- បានផលិតព័ត៌មានទាក់ទងនឹងការងារកសិកម្មចំនួន២៧០ព័ត៌មាន និងចាក់ផ្សាយបាន ៥៤០លើក
- បានរៀបចំពិព័រណ៍សម្ភារ និងផលិតផលកសិកម្មចំនួន ០២លើក
- បានផ្សព្វផ្សាយវីដេអូ ឯកសារ សកម្មភាព និងព័ត៌មានកសិកម្មបានចំនួន ៧៦០ឯកសារ ទៅក្នុងទំព័រហ្វេសប៊ុករបស់នាយកដ្ឋាន ដែលមានអ្នកចូលចិត្ត ៩៣ ២០៤នាក់ និងអ្នកតាមដាន ១២០ ១០០នាក់
- បានដាក់បញ្ចូលឯកសារកសិកម្ម ក្នុងគេហទំព័រផ្សព្វផ្សាយកសិកម្ម (khmeragri.info) សរុបចំនួន៦០៣ ឯកសារ ដែលមានអ្នកចូលទស្សនាចំនួន ១ ១៣៣ ០៥៨ នាក់ និងអ្នកទាញយក ២៣៤ ១១០ដង

- បានផ្តល់សេវាព័ត៌មានបច្ចេកទេសកសិកម្មដល់កសិករ និងអតិថិជន (Call Center) ដែលបានដោះស្រាយបញ្ហា និងផ្តល់ព័ត៌មានដល់កសិករ និងអតិថិជន ហៅទូរស័ព្ទចូលមកពី២៥រាជធានី-ខេត្ត បានចំនួន ២៨៦ដង ពាក់ព័ន្ធនឹងគ្រប់អនុវិស័យកសិកម្ម។

### ៥.១០. ការងារយេនឌ័រ និងកុមារ

ដោយអនុវត្តនូវគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្មឆ្នាំ២០១៦-២០២០ ក្រុមការងារយេនឌ័រនិងកុមារប្រចាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសម្រេចនូវលទ្ធផលសំខាន់ៗ ក្នុងឆ្នាំ២០២០នេះ ដូចខាងក្រោម៖

- បានបើកវគ្គបណ្តុះបណ្តាល ស្តីពីចំណេះដឹងយេនឌ័រ និងអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ហៅកាត់ថា(ស៊ី.ដ) សហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្ត ដែលមានអ្នកចូលរួមសរុប ចំនួន៧៦នាក់ ស្រី ៤៣នាក់ នៅខេត្តបាត់ដំបង និងខេត្តមណ្ឌលគិរី
- បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការយល់ដឹងលើផែនការសកម្មភាពយេនឌ័រ ក្នុងក្របខ័ណ្ឌគម្រោងខ្សែច្រវ៉ាក់ផលិតកម្មដោយភាតរៈបរិស្ថាន
- បានរៀបចំកិច្ចប្រជុំបណ្តុះបណ្តាលដល់មាតាបិតា និងអាណាព្យាបាលកុមារមត្តេយ្យសហគមន៍ ស្តីពីអាហារូបត្ថម្ភ នៅស្រុកជើងព្រៃ ខេត្តកំពង់ចាម ដោយមានការចូលរួមពីអាជ្ញាធរឃុំ នាយកសាលា លោកគ្រូ អ្នកគ្រូ មាតាបិតា អាណាព្យាបាល សិស្សានុសិស្សមត្តេយ្យសរុប ២២០នាក់
- បានបើកវគ្គបណ្តុះបណ្តាលកសិករគំរូស្តីពីយេនឌ័រ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម ចំនួន២៨វគ្គ នៅខេត្តគោលដៅគម្រោង ដែលមានកសិករអ្នកចូលរួម ៧០០នាក់ ក្នុងនោះស្ត្រីមានចំនួន ៣៨៩នាក់
- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការយល់ដឹងរបស់បុរសនិងស្ត្រី អំពីការប្រែប្រួលអាកាសធាតុកសិកម្មចម្រុះ និងការកាត់បន្ថយគ្រោះថ្នាក់ការងារក្នុងវិស័យព្រៃឈើ ដល់សមាជិកសហគមន៍ព្រៃឈើនៅខេត្តកំពង់ធំ សិក្ខាកាមចូលរួម៤០ រូបក្នុងនោះស្ត្រីចំនួន២១ រូប
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយការបញ្ជ្រាបយេនឌ័រក្នុងអនុវិស័យកសិកម្មដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៅអគ្គនាយកដ្ឋានកសិកម្មដែលមានអ្នកចូលរួម ១៥០នាក់ (ស្ត្រី១០៣នាក់)
- បានចុះបណ្តុះបណ្តាលលើការអនុវត្តសកម្មភាពបញ្ជ្រាបយេនឌ័រ និងអំពើហិង្សា ដោយការលើកទឹកចិត្តដល់កសិករស្ត្រី សមាជិកសហគមន៍នេសាទជាស្ត្រីពីសារសំខាន់សិទ្ធិ និងគុណតម្លៃស្ត្រីក្នុងការចូលរួមការងារគ្រប់គ្រង ការអភិវឌ្ឍ និងអភិរក្សវិស័យជលផល នៅខណ្ឌរដ្ឋបាលជលផលស្ទឹងត្រែង និងខណ្ឌរដ្ឋបាលជលផលក្រចេះ បានចំនួន៣វគ្គ មានអ្នកចូលរួមសរុប ២២៣ នាក់ ក្នុងនោះស្ត្រីមានចំនួន ១១៧នាក់
- ចុះធ្វើវេទិកាសាធារណៈស្តីពីសារសំខាន់ សិទ្ធិក្នុងការចូលរួមការងារគ្រប់គ្រង ការការពារ អភិវឌ្ឍ និងអភិរក្សវិស័យជលផល នៅខណ្ឌរដ្ឋបាលជលផលស្ទឹងត្រែង បានចំនួន១លើក មានអ្នកចូលរួមសរុប ៧៨នាក់ ក្នុងនោះស្ត្រីមានចំនួន៣១នាក់
- បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលចំនួន០៤វគ្គ ជូនដល់គណៈកម្មការ និងសមាជិកសហគមន៍នេសាទចំនួន៧៩នាក់ ក្នុងនោះស្ត្រីមានចំនួន ១៩នាក់ នៅក្នុងខេត្តពោធិ៍សាត់ កំពង់ឆ្នាំង និងខេត្តកំពង់ធំ
- ចូលរួមសិក្ខាសាលាឆ្លុះបញ្ចាំងពីលទ្ធផល នៃការរៀបចំវេទិកាជជែកពិភាក្សារយៈពេល៨ឆ្នាំ (២០១២-២០១៩) និងបានរៀបចំផែនការការងារជាមួយក្រសួងកិច្ចការនារីក្នុងគោលបំណងបញ្ជ្រាបយេនឌ័រ

- បានចូលរួមវេទិកាកសិករថ្នាក់ក្រោមជាតិ ស្តីពីការលើកកម្ពស់ការចូលរួមពហុភាគីក្នុងការជំរុញបច្ចេកវិទ្យាកសិកម្មផ្សារភ្ជាប់ទីផ្សារ និងសមភាពយេនឌ័រក្នុងការអភិវឌ្ឍវិស័យកសិកម្ម ដោយមានកសិករចូលរួមសរុប ចំនួន ២០០នាក់ ស្រី ១២១នាក់ នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តពោធិ៍សាត់
- បានបើកវគ្គបណ្តុះបណ្តាលស្តីពី ការបញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម ដោយមានកសិករចូលរួមសរុប ចំនួន ២០០នាក់ ស្រី ១២១នាក់ នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តពោធិ៍សាត់
- បានបណ្តុះបណ្តាល ស្តីពីគោលនយោបាយក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ និងការការពារកុមារក្នុងវិស័យកសិកម្មដល់កសិករនៅឃុំជន្លាសដៃ ស្រុកក្រឡាញ់ សរុប២៨នាក់ ស្រី ២៥នាក់ និងនៅសហគមន៍ល្វាសសរស្តម្ភមានជ័យ ឃុំសសរស្តម្ភ ស្រុកពួក សរុប ៣០នាក់ ស្រី ២៦នាក់ សរុបទាំងពីរស្រុក៥៨នាក់ ស្រី៥១នាក់ ដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប
- បានចូលរួមសិក្ខាសាលាស្តីពីគោលគំនិត និងទស្សនទាននៃការបង្កើតភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី សរុបអ្នកចូលរួម៩០នាក់ ស្រី៦៥នាក់ នៅសណ្ឋាគារតារាអែជត ភ្នំពេញ
- បានបើកវគ្គផ្សព្វផ្សាយយេនឌ័រស្តីពី ការផ្តល់ឬបង្កើនសិទ្ធិអំណាចជូនស្ត្រី ដល់កសិករ ក្រុមប្រឹក្សាឃុំ ចំនួន៣វគ្គ មានអ្នកចូលរួមសរុប ១០៨នាក់ក្នុងនោះស្រី៧០នាក់
- បានបញ្ជ្រាបយេនឌ័រស្តីពី ការផ្តល់ឬបង្កើនសិទ្ធិអំណាចជូនស្ត្រីក្នុងវគ្គបណ្តុះបណ្តាលការចិញ្ចឹមមាន់យកសាច់ និងការចិញ្ចឹមកង្កែបយកសាច់ របស់គម្រោងកាត់បន្ថយភាពក្រីក្រនិងអភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់ទន្លេសាបជំហានទី២ ដល់កសិករក្រុមកែលម្អជីវភាពសរុប៣៦នាក់ក្នុងនោះ ស្រី ២៦នាក់
- បានធ្វើការផ្សព្វផ្សាយស្តីពីគោលនយោបាយការបញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្មចំនួន០១លើក មានអ្នកចូលរួមចំនួន៤៥នាក់ ស្ត្រី២២នាក់
- បានធ្វើការផ្សព្វផ្សាយពីគោលនយោបាយ និងយុទ្ធសាស្ត្រការអភិវឌ្ឍ និងការការពារកុមារនៅក្នុងវិស័យកសិកម្មចំនួន០១លើក ដែលមានអ្នកចូលរួមចំនួន៣៥នាក់ ស្រី១៥នាក់
- បានបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន០១លើក ស្តីពីការពង្រឹងសេដ្ឋកិច្ចស្ត្រីនៅក្នុងវិស័យកសិកម្ម មានអ្នកចូលរួមចំនួន៥១នាក់ ស្រី១០នាក់ នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តរតនគិរី
- បានធ្វើការបញ្ជ្រាបយេនឌ័រ ស្តីពីការអភិវឌ្ឍ និងការការពារកុមារ ការធ្វើអាហារូបត្ថម្ភដល់កុមារនៅតាមសហគមន៍កសិកម្មក្រុង-ស្រុកបានចំនួន ០៩លើកដែលមានអ្នកចូលរួមសរុប ២៧៥នាក់ ស្រី ១៣០នាក់ នៅក្នុងស្រុកកូនមុំ ខេត្តរតនគិរី
- បានបើកវគ្គផ្សព្វផ្សាយស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម បានចំនួន០៩លើក ស្មើ៣៦៩នាក់ ស្រី២៥១នាក់ នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តឧត្តរមានជ័យ
- បើកវគ្គផ្សព្វផ្សាយស្តីពី គោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ និងអភិវឌ្ឍន៍កុមារក្នុងវិស័យកសិកម្ម ចំនួន០២វគ្គ ដែលមានអ្នកចូលរួមសរុបចំនួន៤៨នាក់ ក្នុងនោះស្ត្រីចំនួន៥២នាក់ នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកណ្តាល
- បានចូលរួមវេទិកាកសិករថ្នាក់ក្រោមជាតិ ស្តីពីការលើកកម្ពស់ការចូលរួមពហុភាគីក្នុងការជំរុញបច្ចេកវិទ្យាកសិកម្មផ្សារភ្ជាប់ទីផ្សារ និងសមភាពយេនឌ័រ ក្នុងការអភិវឌ្ឍវិស័យកសិកម្ម ដោយមានកសិករ ចូលរួមសរុបចំនួន២២០នាក់ ក្នុងនោះស្រី១២១នាក់ នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ធំ
- បានចុះបញ្ជ្រាបយេនឌ័រតាមបណ្តុំអាជីវកម្ម (មាន់ បន្លែ) ចំនួន២៤បណ្តុំ ដោយមានអ្នកចូលរួមចំនួន ១៨០នាក់ ស្រី៩៧នាក់ នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តតាកែវ។

## ៥.១១. ការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ក្នុងឆ្នាំ២០២០នេះ ក្រសួងបានពង្រឹងកិច្ចដំណើរការកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងបានទទួលលទ្ធផលដូចខាងក្រោម៖

- បានចុះត្រួតពិនិត្យ តាមដាន វាយតម្លៃ ព្រមទាំងគាំទ្រលើការអភិវឌ្ឍសមត្ថភាព និងគាំទ្រផ្នែកបច្ចេកទេសលើមុខងារដែលបានផ្ទេរទៅឱ្យថ្នាក់ក្រោមជាតិ ស្របតាមផែនការប្រចាំឆ្នាំ នៅរដ្ឋបាលខេត្តចំនួន១០
- បានប្រជុំពិនិត្យ និងពិភាក្សាលើមុខងារដែលបានប្រតិភូកម្មទៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត ជាមួយអង្គភាពជំនាញពាក់ព័ន្ធ
- បានប្រជុំពិនិត្យ និងពិភាក្សារៀបចំទម្រង់ពាក្យស្នើសុំបែបបទ និងលក្ខខណ្ឌភ្ជាប់នានាសម្រាប់ការស្នើសុំសេវារដ្ឋបាលក្នុងវិស័យកសិកម្ម នៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត ជាមួយអង្គភាពជំនាញពាក់ព័ន្ធ
- បានប្រជុំពិនិត្យ និងពិភាក្សារៀបចំសេចក្តីណែនាំអន្តរក្រសួងស្តីពីបច្ចេកទេស បែបបទ នីតិវិធីសម្រាប់ការស្នើសុំសេវារដ្ឋបាលក្នុងវិស័យកសិកម្ម នៅរដ្ឋបាលរាជធានី ខេត្ត ជាមួយអង្គភាពជំនាញពាក់ព័ន្ធ
- បានប្រជុំពិនិត្យ និងពិភាក្សារៀបចំសេចក្តីណែនាំបច្ចេកទេស និងនីតិវិធីសម្រាប់អនុវត្តមុខងារវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ជាមួយអង្គភាពជំនាញពាក់ព័ន្ធ
- បានចូលរួមក្នុងពិធីសម្ពោធនិងប្រកាសដាក់ឱ្យដំណើរការជាផ្លូវការនៃអង្គភាពច្រកចេញចូលតែមួយ២៥ រាជធានី ខេត្តក្រោមអធិបតីភាព **សម្តេចក្រឡាហោម ស ខេង**
- បានចូលរួមប្រជុំពិភាក្សា និងពិនិត្យលើមុខងារដែលបានប្រតិភូកម្មទៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត នៅទីស្តីការក្រសួងមហាផ្ទៃ
- បានចូលរួមប្រជុំពិភាក្សារៀបចំទម្រង់ពាក្យស្នើសុំបែបបទ និងលក្ខខណ្ឌភ្ជាប់នានានៃការស្នើសុំសេវារដ្ឋ-បាលនៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត នៅទីស្តីការក្រសួងមហាផ្ទៃ
- បានចូលរួមកិច្ចប្រជុំពិភាក្សាកំណត់ធនធានរបស់ក្រសួង ស្ថាប័ន (មនុស្ស ថវិកាទ្រព្យសម្បត្តិ) សម្រាប់ផ្ទេរភ្ជាប់មុខងារទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ នៅលេខាធិការដ្ឋាន គ.ជ.អ.ប
- បានចូលរួមសិក្ខាសាលាបូកសរុបការងារច្រកចេញចូលតែមួយឆ្នាំ២០២០ និងសកម្មភាពទិសដៅការងារ ២០២០ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ នៅរដ្ឋបាលខេត្តកំពត
- បានចូលរួមកិច្ចប្រជុំពិភាក្សាក្នុងការរៀបចំសេចក្តីសម្រេចរួមឆ្នាំ២០២០ និងបិទសេចក្តីសម្រេចរួមឆ្នាំ ២០១៩ រវាងលេខាធិការដ្ឋាន គ.ជ.អ.ប ជាមួយក្រសួង ស្ថាប័ន នៅលេខាធិការដ្ឋាន គ.ជ.អ.ប
- បានចូលរួមកិច្ចប្រជុំលើកទី១៨ នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នៅគ.ជ.អ.ប
- បានចូលរួមកិច្ចប្រជុំពិភាក្សាស្តីពីសេចក្តីព្រាងឯកសារទស្សនទានសម្រាប់ការរៀបចំតាក់តែងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ (២០២១-២០៣០) នៅទីស្តីការក្រសួងមហាផ្ទៃ
- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើឯកសារទស្សនទានសម្រាប់រៀបចំកម្មវិធីជាតិ ក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ (២០២១-២០៣០) ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានគ.ជ.អ.ប។

## V- បញ្ហាប្រឈម

បញ្ហាជាសាកលដែលបានកើតមានឡើងនាដើមឆ្នាំ២០២០នេះ គឺការឆ្លងរាលដាលនៃជំងឺកូវីដ-១៩បានក្លាយជាបញ្ហាប្រឈមដ៏ធំមួយទៀត និងបានប៉ះពាល់ធ្ងន់ធ្ងរដល់សេដ្ឋកិច្ច សង្គមនៅក្នុងតំបន់និងពិភពលោក រួមទាំងកម្ពុជាផងដែរ។ កត្តាប្រែប្រួលអាកាសធាតុ ជាពិសេសគ្រោះរាំងស្ងួត និងគ្រោះជំនន់ទឹកភ្លៀង បានវាយលុកមកលើផលិតកម្មដំណាំកសិកម្ម សត្វ និងជលផល។ ផលិតភាពកសិកម្មនៅមានកម្រិតទាប និងការប្រកួតប្រជែងទីផ្សារនៃផលិតផលកសិកម្មនៅពុំទាន់ដោះស្រាយបានប្រសើរនៅឡើយ។ ការផ្ទេរបច្ចេកទេសកសិកម្មទំនើប និងសមស្របដល់កសិករនៅពុំទាន់បានគ្រប់គ្រាន់ស្របតាមសេចក្តីត្រូវការជាក់ស្តែង។ ហេដ្ឋារចនាសម្ព័ន្ធគាំទ្រផលិតកម្មកសិកម្ម ដូចជាប្រព័ន្ធស្រោចស្រពក្នុងកសិដ្ឋានដោយសន្សំសំចៃទឹក ផ្ទះសំណាញ់ ផ្លូវចូលកសិដ្ឋានដើម្បីសម្រួលការដឹកជញ្ជូនផលិតផលរបស់កសិករ ប្រព័ន្ធស្តុកទុក ឃ្លាំងសម្ងួត ឃ្លាំងត្រជាក់ នៅមិនទាន់បង្កើតបានគ្រប់គ្រាន់សម្រាប់ការធ្វើកសិកម្ម និងកសិ-ពាណិជ្ជកម្ម។ កង្វះការវិនិយោគលើការកែច្នៃផលិតផលកសិកម្ម ដែលបណ្តាលមកពីថ្លៃដើមផលិតកម្មមានកម្រិតខ្ពស់ និងកង្វះលទ្ធភាពទទួលបានហិរញ្ញប្បទានក្នុងអត្រាការប្រាក់ទាប។

ផលិតកម្មសត្វមានបម្រែបម្រួលកំណើនយឺត ដោយមានការលំបាកកន្លងមក និងការប្រឈមដូចជាជំងឺឆ្លងរាតត្បាត។ ការប្រកួតប្រជែងនៃទីផ្សារសាច់សត្វក៏ជាបញ្ហាប្រឈមខ្លាំង ដោយសារថ្លៃដើមផលិតកម្មខ្ពស់ ពិសេសថ្លៃចំណីសត្វ និងថ្នាំព្យាបាលសត្វជាដើម។ ជាក់ស្តែង ចំណីសត្វប្រមាណ ៩៩,៨% ត្រូវបាននាំចូលពីបរទេស និងម្យ៉ាងវិញទៀត ថ្លៃដើមផលិតកម្មផលិតចំណីសត្វក្នុងស្រុកក៏មានកម្រិតខ្ពស់នៅឡើយ។

ផលត្រីចាប់ពីដែនធម្មជាតិមាននិន្នាការប្រែប្រួលជារៀងរាល់ឆ្នាំ ពិសេសនៅពេលដែលកម្រិតកម្ពស់ទឹកទន្លេមេគង្គទាបក្នុងឆ្នាំ២០២០នេះ បានធ្វើឱ្យទឹកចូលមិនដល់បឹង ស្ទឹង ព្រៃកប៉ះពាល់ដល់ការរីកលូតលាស់របស់មច្ឆជាតិ។ ព្រៃលិចទឹកមួយចំនួនត្រូវបានប្រឈមនឹងការកាប់បំផ្លាញ ដែលត្រូវតែមានវិធានការជាបន្តទៀតដោយម៉ឺងម៉ាត់។ ការនេសាទខុសច្បាប់នៅតែមានសកម្មភាព ទោះបីមានការបង្ក្រាបយ៉ាងណាក៏ដោយ។ សមត្ថភាពរបស់គណៈកម្មការសហគមន៍នេសាទក៏នៅមានកម្រិតដែរ ដោយសហគមន៍ភាគច្រើនពុំមានការជួយឧបត្ថម្ភគាំទ្រគ្រប់គ្រាន់។

នៅក្នុងផ្នែកព្រៃឈើ ការធ្វើឱ្យសម្រេចបាននូវការពង្រីកគម្របព្រៃឈើ គឺជាភារកិច្ចមួយដ៏ធំធេង និងត្រូវមានការយកចិត្តទុកដាក់ខ្ពស់។ ការធ្លាក់ចុះនូវផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើក្នុងដំណាក់កាលចុងក្រោយនេះគឺបណ្តាលមកពីកំណើននៃការប្រើប្រាស់ដីកសិកម្ម ស្របទៅនឹងកំណើនប្រជាពលរដ្ឋ និងការរីកលូតលាស់ផ្នែកសេដ្ឋកិច្ចកសិកម្ម។ ការទប់ស្កាត់ការកាប់រានទន្ទ្រានយកដីព្រៃឈើតែងជួបប្រទះការលំបាក។ ប្រជាពលរដ្ឋនៅមូលដ្ឋានដែលរស់នៅក្នុងនិងក្បែរតំបន់ព្រៃឈើនៅតែពឹងអាស្រ័យខ្លាំងលើព្រៃឈើ ហើយការគ្រប់គ្រងជនចំណាកស្រុកនៅមានភាពធូររលុងដែលជាសម្ពាធធ្ងន់ធ្ងរចំពោះធនធានព្រៃឈើ។

## VI- ទិសដៅអនុវត្ត

សម្រាប់ឆ្នាំ២០២០-២០២១នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំរិះរកចំណុចគន្លឹះ និងវិធានការជាមូលដ្ឋាន ដើម្បីដាក់ចេញនូវទិសដៅ និងផែនការ សកម្មភាពសម្រាប់អនុវត្តបន្តដូចខាងក្រោម៖

### ១. ផែនការផលិតកម្មដំណាំស្រូវ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្ម

#### ក. សូចនាករទិសដៅ

- បង្កើនផលិតកម្មដំណាំស្រូវទូទាំងប្រទេសក្នុងរង្វង់ ៣,៤៧២លានហ.ត ក្នុងនោះស្រូវវស្សា ២,៨៦២លានហ.ត និងប្រាំង ០,៦០៩ លានហ.ត ជាមួយទិន្នផលជាមធ្យម ៣,៤២១ត/ហ.ត និងទទួលបានបរិមាណ ផលស្រូវ ១១,២៥៧លានតោន

- បង្កើនផលិតកម្មដំណាំសាកវប្បកម្មក្នុងរង្វង់ ០,១០៧លានហិកតា និងបរិមាណផលប្រមាណ ១,០៧១ លានតោន (ពោតស ដំឡូងជ្វា ដំឡូងឈើ បន្លែគ្រប់មុខ ឱឡឹក និងម្ទេស)
- បង្កើនផលិតកម្មដំណាំឧស្សាហកម្ម (ពោតក្រហម ដំឡូងឈើ សណ្ដែកបាយ សណ្ដែកដី សណ្ដែកសៀង អំពៅ ល្ង ឈូក ក្រចៅ ថ្នាំជក់) ក្នុងរង្វង់ ០,៨៩២លានហិកតា និងបរិមាណផល ១៤,៨៨លានតោន។

**ខ. វិធានការអនុវត្តដើម្បីសម្រេចបានទិសដៅកំណត់**

- ជំរុញការអភិវឌ្ឍដំណាំស្រូវ ដោយលើកកម្ពស់ផលិតភាព ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារនិងការនាំចេញតាមរយៈការសិក្សាស្រាវជ្រាវនិងបន្សុទ្ធពូជស្រូវ ការពង្រឹងការត្រួតពិនិត្យនិងបញ្ជាក់គុណភាពគ្រាប់ពូជស្រូវ ការផលិតនិងចែកចាយគ្រាប់ពូជស្រូវមានគុណភាពល្អ ការអនុវត្តបង្កំបច្ចេកទេសទំនើប បច្ចេកទេសក្នុងនិងក្រោយពេលប្រមូលផល និងការបញ្ជាក់គុណភាព និងសុវត្ថិភាពស្រូវអង្ករ។ ជំរុញការធ្វើពិពិធកម្មស្រូវក្រអូប និងស្រូវដែលមានអាយុកាលខ្លី ធន់នឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងលើកកម្ពស់ការអនុវត្តផលិតកម្មដំណាំស្រូវតាមស្តង់ដារ ការអនុវត្តកសិកម្មល្អ ផលិតកម្មស្រូវនិរន្តរភាព និងស្រូវសរីរាង្គ
- ជំរុញការអភិវឌ្ឍដំណាំសាកវប្បកម្មដោយលើកម្ពស់ផលិតភាព គុណភាព សុវត្ថិភាព ដើម្បីផ្គត់ផ្គង់ទីផ្សារក្នុងស្រុក កាត់បន្ថយការនាំចូល និងជំរុញការនាំចេញតាមរយៈការលើកម្ពស់ផលិតកម្មដំណាំសាកវប្បកម្ម និងពិពិធកម្មប្រភេទដំណាំដែលមានតម្លៃបន្ថែមខ្ពស់ ការអនុវត្តបង្កំបច្ចេកទេសទំនើប (ប្រព័ន្ធផ្ទះសំណាញ់ និងស្រោចស្រពទំនើប) ការប្រមូល បន្សុទ្ធ និងពង្រីកពូជដំណាំដែលមានសក្តានុពលទីផ្សារ ជាពិសេសពង្រីកពូជរុក្ខជាតិលម្អ និងគ្រឿងទេសសំខាន់ៗ ការលើកកម្ពស់ការអនុវត្តកសិកម្មល្អ និងស្តង់ដារកសិកម្មសរីរាង្គលើដំណាំបន្លែ និងឈើហូបផ្លែ ការប្រមូលនិងពង្រឹងការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពផលិតផលដំណាំសាកវប្បកម្ម។ ម៉្យាងទៀត ត្រូវជំរុញការរៀបចំគោលនយោបាយអភិវឌ្ឍន៍វិស័យសាកវប្បកម្ម និងរៀបចំយុទ្ធសាស្ត្រតាមដំណាំសំខាន់ៗដូចជាស្វាយ ចេក និងដំណាំបន្លែ និងបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំស្តីពីស្តង់ដារកសិកម្មសរីរាង្គ និងស្តង់ដារដំណាំសំខាន់ៗ
- ជំរុញការអភិវឌ្ឍដំណាំឧស្សាហកម្ម ដោយលើកម្ពស់ផលិតភាពនិងគុណភាពដំណាំឧស្សាហកម្មសំខាន់ៗ ឆ្លើយតបនឹងតម្រូវការទីផ្សារ ហើយគាំទ្រការកែច្នៃក្នុងស្រុកនិងការនាំចេញតាមរយៈការលើកកម្ពស់ផលិតភាព និងពិពិធកម្មប្រភេទដំណាំដែលមានតម្លៃបន្ថែមខ្ពស់ ការអនុវត្តបង្កំបច្ចេកទេសទំនើប ការប្រមូល បន្សុទ្ធ និងពង្រីកពូជដំណាំដែលមានសក្តានុពលទីផ្សារ ជាពិសេសពង្រីកពូជរុក្ខជាតិគ្រឿងទេសសំខាន់ៗ និងកោស័យវប្បកម្ម ពង្រឹងការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពផលិតផលកម្មដំណាំឧស្សាហកម្ម ព្រមទាំងជំរុញរៀបចំយុទ្ធសាស្ត្រតាមមុខដំណាំសំខាន់ៗដូចជា ដំណាំដំឡូងមី ស្វាយចន្ទី ពោត ជាដើម
- ជំរុញការផ្តល់សេវាបច្ចេកទេសកសិកម្មថ្មី និងបច្ចេកវិទ្យាវៃឆ្លាតនឹងអាកាសធាតុដល់កសិករ និងសហគមន៍កសិកម្ម ដើម្បីទទួលបានទិន្នន័ខ្ពស់ និងចំណាយតិច តាមរយៈការជ្រើសរើសនិងការប្រើប្រាស់ពូជធន់ និងមានគុណភាពល្អ បច្ចេកទេសដាំដុះមានផលិតភាពខ្ពស់ ការប្រើប្រាស់ដីនិងទឹកប្រកបដោយប្រសិទ្ធភាព ការកម្ចាត់សមាសភាពចង្រៃប្រកបដោយភាតរបរិស្ថាន ការប្រើប្រាស់គ្រឿងយន្តកសិកម្ម និងបច្ចេកទេសក្រោយពេលប្រមូលផលសមស្រប ដើម្បីលើកកម្ពស់ផលិតភាព គុណភាព និងសុវត្ថិភាព ឆ្លើយតបទៅតាមតម្រូវការស្តង់ដារនិងការប្រកួតជែងទីផ្សារ
- បន្តពង្រឹងវិធានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ ដោយជំរុញការអនុវត្តវិធានការពារដំណាំ ពង្រឹង និងពង្រីកសមត្ថកិច្ចភូតគាមអនាម័យក្នុងការត្រួតពិនិត្យផលិតផលកសិកម្មនាំចេញ-នាំចូល ដើម្បីចូលរួមសម្រួលពាណិជ្ជកម្ម និងកាត់បន្ថយហានិភ័យពាក់ព័ន្ធនឹងការរាតត្បាត សមាសភាពចង្រៃ ភូតគាមអនាម័យហាមឃាត់ ទប់ស្កាត់ការធ្លាក់ចុះគុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម ដែលនាំឱ្យប៉ះពាល់ដល់សុខភាពប្រជាជន ខូចទីផ្សារក្នុងស្រុក និងទីផ្សារសម្រាប់នាំចេញរបស់កម្ពុជា។ ពង្រឹងនិងពង្រីកសមត្ថភាពមន្ទីរ

ពិសោធន៍ជាតិក្នុងការពិនិត្យវិភាគ និងវាយតម្លៃគុណភាពធាតុចូលកសិកម្ម (ពូជ ជី ថ្នាំកសិកម្ម) គុណភាពដី និងកម្រិតសំណល់ធាតុពុលក្នុងផលិតផលកសិកម្ម ដី និងទឹក

- ពង្រឹងរចនាសម្ព័ន្ធនិងធុរកិច្ចរបស់សហគមន៍កសិកម្ម ឱ្យក្លាយជាសហគ្រាសកសិកម្មទំនើបតាមរយៈការបង្កើតយន្តការគ្រប់គ្រងសហគមន៍កសិកម្ម ដែលរួមមានសម្ព័ន្ធសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសហគមន៍កសិកម្ម និងការបន្តធ្វើទំនាក់ទំនងជាមួយធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម និងគ្រឹះស្ថានហិរញ្ញវត្ថុនានាក្នុងការផ្តល់ឥណទានដល់សហគមន៍កសិកម្ម និងសហគ្រាសកសិកម្មធុនតូច និងមធ្យម ដើម្បីប្រមូលទិញកសិផល ការកែច្នៃ និងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តចាំបាច់ ដូចជាឃ្លាំងស្តុកកសិផល ឡសម្ងួត ឃ្លាំងត្រជាក់ជាដើម ដើម្បីផ្សារភ្ជាប់កសិករខ្នាតតូចទៅនឹងទីផ្សារ
- លើកកម្ពស់ផលិតភាពនិងប្រសិទ្ធភាពនៃការប្រើប្រាស់គ្រឿងយន្តកសិកម្ម ព្រមទាំងផលិតភាពនិងប្រសិទ្ធភាពនៃការប្រើប្រាស់ទឹកកសិកម្ម ដោយអនុវត្តបច្ចេកវិទ្យាទំនើប (ស្រោចស្រពដោយបង្ហៀរបញ្ចូលស្រែ ទុយយោ បំពង់បង្កប់ដី ឧបករណ៍ស្រោចស្រពដំណក់ទឹក សាចទឹកជាដើម)
- បន្តស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យាគ្រប់គ្រង និងប្រើប្រាស់ធនធានដីកសិកម្មប្រកបដោយនិរន្តរភាពផ្នែកសេដ្ឋកិច្ច សង្គម និងបរិស្ថាន ដោយផ្តោតអាទិភាពលើបច្ចេកវិទ្យាកែលម្អជីជាតិដីនិងទឹក កសិកម្មវៃឆ្លាតនឹងអាកាសធាតុ យុទ្ធសាស្ត្រគ្រប់គ្រងធនធានដីកសិកម្មដែលមានភាពទន់ភ្លន់ជាមួយការជ្រើសរើសមុខដំណាំដែលមានសក្តានុពលសមស្របនឹងដី ការអភិវឌ្ឍបច្ចេកវិទ្យាកសិកម្មអភិរក្ស និងការពង្រឹងសមត្ថភាពប្រើប្រាស់ព័ត៌មានប្រព័ន្ធផ្កាយរណបនិងបច្ចេកវិទ្យាឌីជីថល
- ពង្រឹងសមត្ថភាពអង្គភាព និងការអនុវត្តក្របខ័ណ្ឌគតិយុត្ត ដើម្បីលើកកម្ពស់ផលិតភាព ប្រសិទ្ធភាពការងារ និងសេវាគាំទ្រ តាមរយៈការបន្តការរៀបចំក្របខ័ណ្ឌគោលនយោបាយ បទដ្ឋានគតិយុត្ត ការកសាងសមត្ថភាព ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងធនធានមនុស្សក្នុងអនុវិស័យដំណាំ។

## ២. ផែនការផលិតកម្មដំណាំកៅស៊ូ

### ក. សូចនាករទិសដៅ

ក្នុងឆ្នាំ២០២១ ទិសដៅសំខាន់ៗដែលបានគ្រោងនិងត្រូវសម្រេចរួមមាន៖

- ជំរុញបង្កើនផ្ទៃដីចៀរឱ្យបាន៣១៨៣ពាន់ហិកតា
- ជំរុញបង្កើនផលិតកម្មកៅស៊ូឱ្យដល់៣៧៨៣ពាន់តោន
- បង្កើនការនាំចេញកៅស៊ូឱ្យបានប្រមាណ៣៦៧ពាន់តោន
- ប្រមូលចំណូលឱ្យសម្រេចតាមចំណុចដៅចំនួន១ ៥២៤លានរៀល
- អនុវត្តចង្កោមសកម្មភាពថវិកាកម្មវិធីឆ្នាំ២០២១ ឱ្យសម្រេចបាននូវចំណុចដៅដែលបានកំណត់
- រៀបចំគម្រោងថវិកាកម្មវិធីឆ្នាំ២០២២។

### ខ. វិធានការអនុវត្តដើម្បីសម្រេចទិសដៅកំណត់

- បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវនិងកសាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា
- ជំរុញការពង្រីកផ្ទៃដីកៅស៊ូយកផលរបស់ក្រុមហ៊ុនកសិឧស្សាហកម្មនិងកៅស៊ូគ្រួសារ និងបន្តពិនិត្យតាមដានការអនុវត្តផែនការកម្មវិធីវិនិយោគកៅស៊ូលើក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច
- ពិនិត្យតាមដានការអនុវត្តចង្កោមសកម្មភាពថវិកាកម្មវិធីឆ្នាំ២០២១ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តថវិកាកម្មវិធី និងខិតខំប្រមូលចំណូលឱ្យសម្រេចតាមគោលដៅ
- ជំរុញការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងផែនការសកម្មភាពនៃថវិកាកម្មវិធីឆ្នាំ២០២២ ដោយពិនិត្យឡើងវិញនូវអនុកម្មវិធី ចង្កោមសកម្មភាព សូចនាករ ចំណុចដៅសូចនាករ និងថវិកាចំណាយ ដើម្បីឱ្យត្រូវនឹងស្ថានភាពនិងលទ្ធភាពជាក់ស្តែង

- អនុវត្តនិងតាមដានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០
- បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រស្តីពីការដាំដុះ ថែទាំកូនកៅស៊ូ ការគ្រប់គ្រងសមាសភាពចង្រៃ ការយកផល និងការកែច្នៃ
- បន្តចុះផ្សព្វផ្សាយនិងបណ្តុះបណ្តាលបច្ចេកវិទ្យាដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារ
- អនុវត្តបែបបទវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ (CSR) សម្រាប់ការនាំចេញកៅស៊ូ អនុវត្តបែបបទវិញ្ញាបនបត្របញ្ជាក់គុណភាពច្បារពូជ ជំរុញការអនុវត្តកម្មវិធីផ្លាស់ប្តូរក្លូនពហុភាគីក្នុងរង្វង់ប្រទេសជាសមាជិកនៃ IRRDB
- បង្កើនកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន (ខេត្ត ស្រុក និងសមត្ថកិច្ចនៅតាមច្រកព្រំដែន) ដើម្បីជួយទប់ស្កាត់សកម្មភាពការបើកស្ពាក់ការប្រមូលទិញកៅស៊ូគ្រួសារដែលគ្មានលិខិតអនុញ្ញាត និងការនាំចេញកៅស៊ូនិងឈើកៅស៊ូមិនទាន់កែច្នៃទៅប្រទេសជិតខាងដោយខុសច្បាប់
- បន្តចូលរួមសន្និសីទ កិច្ចប្រជុំ និង សន្និបាតប្រចាំឆ្នាំរបស់សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ និងអង្គការកៅស៊ូអន្តរជាតិនានា
- ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ ទីភ្នាក់ងារ និងអង្គការកៅស៊ូអន្តរជាតិនានា លើកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌការងារស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិជ្ជាវិទ្យាសាស្ត្រ ព័ត៌មានអំពីការផ្គត់ផ្គង់ និងតម្រូវការប្រើប្រាស់កៅស៊ូ និងអំពីនិន្នាការនៃតម្លៃកៅស៊ូលើទីផ្សារក្នុងនិងក្រៅប្រទេស
- ពង្រីកដៃគូសហប្រតិបត្តិការក្នុងការស្វែងរកថវិកានិងបច្ចេកទេស ដើម្បីគាំទ្រអភិវឌ្ឍន៍កៅស៊ូគ្រួសារ និងបន្តចូលរួមសហការជាមួយគ្រឹះស្ថានសិក្សានានា លើការបណ្តុះបណ្តាលធនធានមនុស្សក្នុងអនុវិស័យកៅស៊ូ។

## ៣. ផែនការលើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ

### ក. សូចនាករទិសដៅ

- បង្កើនផលិតផលសាច់កើន៣%ក្នុងមួយឆ្នាំ គឺពី២៥៤៣ាន់តោននៅឆ្នាំ២០២១ ដល់២៧០តោននៅឆ្នាំ២០២៣
- បង្កើនអត្រានៃការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មឱ្យកើន ពី២៧% នៅឆ្នាំ២០២១ ដល់៣០% នៅឆ្នាំ ២០២៣។
- កាត់បន្ថយអត្រាជំងឺឆ្លងសត្វឱ្យនៅក្រោម៥%។

### ខ. វិធានការអនុវត្តដើម្បីសម្រេចទិសដៅកំណត់

- បន្តផ្តល់សេវាបសុព្យាបាល និងបង្កើនសមត្ថភាព បច្ចេកទេសដល់កសិករចិញ្ចឹមសត្វ តាមរយៈកម្មវិធីចាក់វ៉ាក់សាំងការពារ ពិនិត្យព្យាបាលជំងឺសត្វ អនុវត្តវិធានជីវសុវត្ថិភាព បណ្តុះបណ្តាលបច្ចេកទេស និងអនុវត្តការចិញ្ចឹមសត្វល្អ ជាពិសេសជំរុញផ្លាស់ប្តូរឥរិយាបថពីការចិញ្ចឹមតាមបែបប្រពៃណីទៅជាការចិញ្ចឹមបែបទំនើបសម្រាប់ធ្វើពាណិជ្ជកម្ម ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារនាពេលបច្ចុប្បន្ន តាមរយៈការកែលម្អពូជចំណីមានគុណភាពល្អ និងកាត់បន្ថយជំងឺឆ្លងរាលដាលសត្វ។ ជាមួយគ្នានេះដែរ ផ្តល់ការគាំទ្រធ្វើឱ្យប្រសើរនូវបរិយាកាសវិនិយោគលើការចិញ្ចឹមសត្វ និងផលិតចំណីសត្វ ដើម្បីធ្វើឱ្យថ្លៃដើម ផលិតកម្មសត្វទាបដោយការកែច្នៃវត្ថុធាតុដើមក្នុងស្រុកដែលមានស្រាប់ឱ្យអស់លទ្ធភាព
- បន្តពង្រឹងការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ ពង្រឹងការអនុវត្តច្បាប់ សមត្ថភាពមន្ត្រី និងបណ្តុះបណ្តាលពីបច្ចេកទេសពិឃាតសត្វ ប្រកបដោយមនុស្សធម៌ដល់ម្ចាស់សត្តឃាតដ្ឋាន និងអាជីវករពិឃាតសត្វ

- បន្តជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំនានា ពង្រឹងសមត្ថភាពមន្ត្រី និងផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ បង្កើនការត្រួតពិនិត្យនិងធ្វើអធិការកិច្ចអនាម័យសត្តឃាតដ្ឋាន កសិដ្ឋានចិញ្ចឹមសត្វ រោងចក្រ/កន្លែងផលិតចំណី បសុឱសថ សន្និធិ កែច្នៃចំណីសត្វ ផលិតផលសត្វ សត្វ សាច់ និងចរាចរណ៍នាំចេញ នាំចូល នាំឆ្លងកាត់សត្វនិងផលិតផលសត្វ ដើម្បីបង្ការ ទប់ស្កាត់ការឆ្លងរាលដាលជំងឺសត្វ ការពារសុខភាពសត្វ សុខភាពសាធារណៈ សុខុមាលភាពសត្វ និងបរិស្ថាន
- ការបង្កើនសមត្ថភាពមន្ត្រីគ្រប់កម្រិត ដើម្បីផ្ទេរចំណេះដឹងលើជំនាញសុខភាពសត្វ និងផលិតកម្មសត្វ ដូចជាការចិញ្ចឹម ការបង្កាត់ពូជសត្វ សុវត្ថិភាពចំណីអាហារ បសុឱសថ ជីវៈសុវត្ថិភាព ការបង្ការជំងឺ ខ្សែច្រវ៉ាក់ផលិតកម្មសត្វ ការធ្វើពាណិជ្ជកម្មសត្វដល់វិស័យឯកជន អង្គការដៃគូអភិវឌ្ឍន៍ សហគមន៍ សមាគមកសិករចិញ្ចឹមសត្វ ដើម្បីបង្កើនផលិតភាពសត្វ។ លើសពីនេះទៀត ភ្នាក់ងារសុខភាពសត្វត្រូវបានបណ្តុះបណ្តាលពីជំនាញបច្ចេកទេសសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីសម្របសម្រួល ពិនិត្យ ព្យាបាលសត្វ និងផ្តល់ព័ត៌មានពីស្ថានភាពជំងឺសត្វដល់មន្ត្រីជំនាញបានទាន់ពេល
- ជំរុញលើកទឹកចិត្តសហគមន៍ចិញ្ចឹមសត្វ កសិករចិញ្ចឹមសត្វតាមកិច្ចសន្យា ដើម្បីលើកកម្ពស់ផលិតកម្មសត្វធានាបាននូវបរិមាណផ្គត់ផ្គង់ ការពារផលប្រយោជន៍នូវផលិតផលដែលផលិតបាន ក្នុងការកាត់បន្ថយការនាំចូលសត្វពីបរទេស និងឈានទៅរកការនាំចេញ
- បន្តពង្រឹងការសិក្សាស្រាវជ្រាវ ការអង្កេតតាមដានជំងឺឆ្លងសត្វ សំដៅរកឱ្យឃើញប្រភពជំងឺ និងឆ្លើយតបទាន់ពេលវេលា ព្រមទាំងពង្រឹងការស្រាវជ្រាវចំណីសត្វ បសុឱសថ ពូជសត្វដែលមានលក្ខណៈបន្សាំនឹងការប្រែប្រួលអាកាសធាតុ ធន់នឹងជំងឺ លូតលាស់លឿនស្របនឹងតម្រូវការទីផ្សារ និងការបង្កាត់ពូជសិប្បនិម្មិត រួមជាមួយនឹងការបង្កើនសមត្ថភាពមន្ទីរពិសោធន៍ សមត្ថភាពស្រាវជ្រាវ និងបង្កើនធនធាន (មនុស្ស សម្ភារ និងថវិកា) សម្រាប់ការស្រាវជ្រាវ និងការផ្សព្វផ្សាយឱ្យបានទូលំទូលាយ
- បន្តកិច្ចពិភាក្សាពិគ្រោះយោបល់ ចែករំលែកព័ត៌មាន ជាមួយវិស័យឯកជន អង្គការសង្គមស៊ីវិល សហគមន៍ សមាគម និងកសិករចិញ្ចឹមសត្វពាក់ព័ន្ធនឹងការងារសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីដោះស្រាយបញ្ហាប្រឈមកើតមានឡើងលើការចិញ្ចឹមសត្វ តម្លៃទីផ្សារ ស្ថានភាពជំងឺឆ្លងសត្វ ការចរាចរណ៍សត្វ និងផលិតផលសត្វ។
- លើកទឹកចិត្ត គាំទ្រ និងជួយសម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធ ប្រទេសបញ្ជាទិញ ដើម្បីអន្តរាគមន៍បានចូលទីផ្សារក្នុងការប្រកួតប្រជែងផលិតផលរបស់ខ្លួន។ ជាពិសេសរៀបចំកែសម្រួលលិខិតបទដ្ឋានគតិយុត្ត នីតិវិធីក្នុងការផ្តល់សេវា និងបច្ចេកទេសបានឆាប់ រហ័សដល់អ្នកវិនិយោគ
- បន្តកិច្ចពិភាក្សាពិគ្រោះយោបល់ ចែករំលែកព័ត៌មាន ក្នុងគោលដៅពង្រឹងកិច្ចសហប្រតិបត្តិការទាំងកម្រិតថ្នាក់ជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍន៍ ផ្នែកឯកជន អង្គការជាតិ អង្គការអន្តរជាតិនានាពាក់ព័ន្ធអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ។

## ៤. ផែនការផ្នែកជលផល

### ក. សូចនាករទិសដៅ

- នេសាទទឹកសាបៈ
    - នេសាទដាយត្រីដាយបង្កងនិងសិប្បកម្ម ១១ ០០០តោន
    - នេសាទគ្រួសារក្នុងដែននេសាទ ៣៤០ ០០០តោន
    - នេសាទគ្រួសារក្នុងវាលស្រែ ១៤០ ០០០តោន
- អាជីវកម្មនេសាទសមុទ្រៈ ១១៥ ០០០តោន
- វារីវប្បកម្មៈ
    - ការចិញ្ចឹមត្រី-បង្គា ៤៨១ ០០០តោន

- ការចិញ្ចឹមក្របី ៣៣០ ០០០ក្បាល
- ការផលិតកូនត្រីពូជ ២៨០ ០០០ ០០០កូន

- ការកែច្នៃផលនេសាទ៖
  - ការកែច្នៃផលនេសាទទឹកសាប ៨០ ០០០តោន
  - ការកែច្នៃផលនេសាទសមុទ្រ ១២ ០០០តោន
  - ការផលិតទឹកត្រី ៥៥ ០០០ ០០០លីត្រ
- ការនាំចេញផលនេសាទ៖ ២០ ០០០តោន
- ចំណូលថវិកា៖ ៣ ៥៨ ៦០០ ០០០ ០០០រៀល។

**ខ. វិធានការអនុវត្តដើម្បីសម្រេចទិសដៅកំណត់**

- បន្តការផ្សព្វផ្សាយច្បាប់ស្តីពីជលផល លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងអនុសាសន៍៧ចំណុចរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បន្តរៀបចំកែលម្អច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានក្រោមច្បាប់នានាតាមការចាំបាច់
- បន្តពង្រឹងកិច្ចសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេស ជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្តក្នុងការទប់ស្កាត់និងបង្ក្រាបបទល្មើសជលផលឱ្យបានល្អប្រសើរ
- បន្តអនុវត្តក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលឆ្នាំ២០១៥-២០២៤
- បន្តពង្រឹងសហគមន៍នេសាទ ឱ្យទទួលខុសត្រូវលើភាពជាម្ចាស់នៃការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទសហគមន៍ដើម្បីសំដៅធានាសហគមន៍នេសាទគ្មានបទល្មើសជលផល ក៏ដូចជាការចូលរួមអភិរក្សធនធានធម្មជាតិ ដើម្បីទាក់ទាញពីភ្ញៀវទេសចរណ៍ផងដែរ
- បន្តពង្រឹងការងារបង្ក្រាបបទល្មើសជលផល ជាពិសេសឧបករណ៍ឆក់ ឧបករណ៍ស្បៃមុង និងឧបករណ៍ភ្លើងពណ៌ជាដើម
- បន្តលែងកូនត្រីពូជក្នុងតំបន់ទឹកធម្មជាតិ ដើម្បីបង្កើនផលស្តុកសម្រាប់បម្រើសេចក្តីត្រូវការរបស់ប្រជាកសិករ
- បន្តពង្រីកតំបន់ផ្សព្វផ្សាយការអភិវឌ្ឍវិស័យវារីវប្បកម្ម និងការគ្រប់គ្រងធនធានជលផលនៅតាម មូលដ្ឋាន
- បង្កើនការយល់ដឹងនិងសមត្ថភាពរបស់អ្នកកែច្នៃឱ្យកាន់តែល្អប្រសើរឡើង លើការអនុវត្តការធ្វើអនាម័យល្អ និងការអនុវត្តការផលិតល្អ ក្នុងខ្សែច្រវ៉ាក់ផលិតកម្មកែច្នៃជលផល
- បង្កើនការត្រួតពិនិត្យនិងវិភាគគុណភាព សុវត្ថិភាពលើផល ផលិតផលជលផលតាមបណ្តាទីកន្លែងកែច្នៃនិងការនាំចូល
- បង្កើនសមត្ថភាពផ្តល់សេវាសាធារណៈឲ្យកាន់តែល្អប្រសើរឡើង ដើម្បីជួយសម្រួលសកម្មភាពនាំចេញនាំចូលផលផលិតផលជលផល
- បន្តការងារសិក្សាស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រទាំងទឹកសាប និងសមុទ្រ
- បន្តការងារសហប្រតិបត្តិការជាមួយអង្គការជាតិ និងអន្តរជាតិ ដើម្បីជំរុញការងារអភិវឌ្ឍន៍វារីវប្បកម្ម និងការគ្រប់គ្រងធនធានជលផលប្រកបដោយប្រសិទ្ធផល។

## ៥. ផែនការផ្នែកព្រៃឈើ

**ក. សូចនាករទិសដៅ**

- បរិមាណផលឈើដាំកើនដល់២៥០ពាន់ម៉ែត្រគូប
- អត្រាចំណូលសហគមន៍ព្រៃឈើត្រូវបានកើនឡើង១៤%
- អត្រាបទល្មើសព្រៃឈើត្រូវបានកាត់បន្ថយ១០%
- ទំហំផ្ទៃដីដាំឈើ រដ្ឋ និងឯកជន កើនដល់១០ពាន់ហ.ត
- សហគមន៍ព្រៃឈើចំនួន ៣០ ត្រូវបានបង្កើនប្រាក់ចំណូល។

**ខ. វិធានការអនុវត្តដើម្បីសម្រេចទិសដៅកំណត់**

- បន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងទំនាក់ទំនងទ្វេភាគីនិងពហុភាគីសម្រាប់ការបណ្តុះបណ្តាលសមត្ថភាពដល់មន្ត្រីរដ្ឋបាលព្រៃឈើ និងភាគីពាក់ព័ន្ធក្នុងការចែករំលែកព័ត៌មាន ព្រមទាំងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ សត្វព្រៃ
- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយភាគីពាក់ព័ន្ធនានា ជាពិសេសប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ព្រះរាជអាជ្ញា តុលាការ គណៈបញ្ជាការឯកភាពរាជធានី-ខេត្ត និងបន្តការផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទប្បញ្ញត្តិ បទបញ្ជា និងលិខិតបទដ្ឋានគតិយុត្តនានា ឲ្យបានជ្រួតជ្រាបដល់ប្រជាពលរដ្ឋនៅទូទាំងរាជធានី ខេត្ត ព្រមទាំងមានចំណាត់ការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ និងឲ្យមានប្រសិទ្ធភាពខ្ពស់ពាក់ព័ន្ធនឹងការកាប់រាន ដុតឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីវាតយកដីធ្វើកម្មសិទ្ធិ
- ពង្រឹងការអនុវត្តច្បាប់ ការត្រួតពិនិត្យតាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រសិប្បកម្មកែច្នៃ និងអាជីវកម្មឈើឲ្យបានហ្មត់ចត់ ព្រមទាំងចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាត ដើម្បីលុបបំបាត់សកម្មភាពដឹកជញ្ជូនឈើខុសច្បាប់ឲ្យមានប្រសិទ្ធភាពខ្ពស់
- បន្តពង្រឹង និងពង្រីកសហគមន៍ព្រៃឈើឲ្យចូលរួមគ្រប់គ្រងថែរក្សាធនធានព្រៃឈើ តាមដានត្រួតពិនិត្យការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ឲ្យបានល្អ និងបណ្តុះផ្នត់គំនិតបង្កើតមុខរបរថ្មីៗបន្ថែមទៀតដើម្បីបង្កើនចំណូលតាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម និងការចិញ្ចឹមសត្វ សំដៅកាត់បន្ថយការពឹងអាស្រ័យលើផល និងអនុផលព្រៃឈើ
- បន្តជំរុញការដោះស្រាយទំនាស់ដីធ្លីក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ និងសម្បទានដីសេដ្ឋកិច្ចដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បន្តស្វែងរកទីតាំងដីព្រៃទំនេររបស់រដ្ឋដើម្បីបង្កើតជាស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើ និងជំរុញការដាំដុះស្តារព្រៃឈើឡើងវិញ ដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសម្រាប់ចែកចាយជូនប្រជាពលរដ្ឋ និងត្រៀមរៀបចំពិធីរុក្ខទិវាថ្នាក់ជាតិឆ្នាំ២០២១
- ធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះ និងសិក្សាស្រាវជ្រាវស្ថានភាពសត្វព្រៃ និងហានិភ័យនៃជំងឺឆ្លងពីសត្វព្រៃមកមនុស្ស ព្រមទាំងបន្តចុះផ្សព្វផ្សាយនិងជំរុញការចុះបញ្ជីថែរក្សាសត្វត្រចៀកកាំជាលក្ខណៈគ្រួសារ
- បន្តជំរុញការអនុវត្តផែនការសកម្មភាព និងថវិកាកម្មវិធីទី៤ ពង្រឹងការប្រមូលចំណូលថវិកាជាតិ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដោយធ្វើការត្រួតពិនិត្យ ការធ្វើតារាង ការផ្ទៀងផ្ទាត់ និងការចុះបញ្ជីទិន្នន័យទ្រព្យសម្បត្តិរដ្ឋក្នុងតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើងថយចុះ និងថែរក្សាទ្រព្យសម្បត្តិទាំងនោះឱ្យបានគង់វង្សល្អ។ ទន្ទឹមនឹងនេះ ជំរុញការចុះបញ្ជិកាស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ ថ្នាលបណ្តុះកូនឈើ និងទីតាំងស្រាវជ្រាវព្រៃឈើ សត្វព្រៃ។

## VII- សេចក្តីសន្និដ្ឋាន

ផ្អែកលើសមិទ្ធផលដែលទទួលបានក្នុងរយៈពេលមួយឆ្នាំ នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា ក្រសួងអាចវាយតម្លៃជារួមថា បើទោះបីជាប្រទេសជាតិយើងកំពុងទទួលរងនូវហានិភ័យបណ្តាលមកពីវិបត្តិនៃជំងឺឆ្លងកូវីដ-១៩ ក៏ដូចជាបានជួបប្រទះនូវគ្រោះធម្មជាតិខ្លះៗក៏ដោយ តែក្រោមការខិតខំប្រឹងប្រែងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពិសេសតាមការណែនាំនិងតម្រង់ទិស ក៏ដូចជាវិធានការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយមានការចូលរួមដ៏សកម្មពីគ្រប់ក្រសួងស្ថាប័ន

រដ្ឋបាលថ្នាក់ក្រោមជាតិ កងកម្លាំងប្រដាប់អាវុធ ព្រមទាំងការរួមចំណែកពីដៃគូអភិវឌ្ឍន៍គួបផ្សំនឹងការខិតខំឧស្សាហ៍ព្យាយាម និងការផ្លាស់ប្តូរទម្លាប់របស់ប្រជាកសិករផង បានជំរុញឱ្យដំណើរការផលិតកម្មកសិកម្មទទួលបានជោគជ័យ និងជម្នះដោះស្រាយបាននូវការលំបាកផ្សេងៗដូចបានរៀបរាប់ខាងលើ និងបានធ្វើឱ្យផលិតកម្មកសិកម្មមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងរយៈពេលកន្លងមកនេះ។

ពិតណាស់ថា ការជំរុញកំណើនវិស័យកសិកម្មនៅតែជាគោលដៅចម្បង ដើម្បីធានាសន្តិសុខស្បៀងអាហារូបត្ថម្ភ និងការនាំចេញ។ គោលដៅនេះ អាចសម្រេចបានដោយសារគោលនយោបាយវិត្តារកម្មរបស់រាជរដ្ឋាភិបាលក្នុងការវិនិយោគបន្ថែមលើការកសាងហេដ្ឋារចនាសម្ព័ន្ធគាំទ្រវិស័យកសិកម្ម ការស្រាវជ្រាវ ការប្រើប្រាស់ពូជថ្មីៗ ការផ្សព្វផ្សាយបច្ចេកទេស ដើម្បីដើរតាមឲ្យទាន់ក្នុងបរិបទនៃសាកលភាវូបនីយកម្ម រួមទាំងការចូលរួមកាន់តែសកម្មជាងមុនពីសំណាក់ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ក្នុងការវិនិយោគលើវិស័យកសិកម្ម ពិតមែនតែយើងនៅជួបប្រទះបញ្ហាប្រឈមខ្លះៗនៃការប្រែប្រួលអាកាសធាតុក៏ដោយ។ ម្យ៉ាងវិញទៀត ផលិតកម្មដំណាំកសិ-ឧស្សាហកម្មត្រូវបានវាយតម្លៃថានឹងបន្តកំណើនខ្ពស់ ដោយផ្អែកលើការកើនឡើងនៃតម្រូវការទីផ្សារអន្តរជាតិ ព្រមទាំងការកើនឡើងនៃការវិនិយោគលើផ្នែកកសិ-ឧស្សាហកម្មនេះជាបណ្តើរៗជាដើម។ ជាមួយគ្នានេះ អនុវិស័យកសិកម្មផ្សេងទៀត ពិសេសវារីវប្បកម្ម និងការចិញ្ចឹមសត្វត្រូវបានវាយតម្លៃថាបានបន្តកំណើនល្អប្រសើរគួរជាទីពេញចិត្ត។ ក្នុងបរិការណ៍នេះ ក្រសួងនឹងបន្តផ្តោតការផ្តល់អាទិភាពខ្ពស់ចំពោះការរៀបចំកសាងផែនការមេអភិវឌ្ឍន៍វិស័យកសិកម្ម និងការអនុវត្តផែនការ រយៈពេលមធ្យមនិងវែង ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយដើម្បីអភិវឌ្ឍន៍វិស័យកសិកម្ម ដែលទាមទារឲ្យមានការចូលរួមយ៉ាងសកម្មពីគ្រប់តួអង្គពាក់ព័ន្ធទាំងអស់តាមអភិក្រម "រដ្ឋ-ឯកជន-ដៃគូអភិវឌ្ឍន៍ និងសហគមន៍" ដោយត្រូវធ្វើសមាហរណកម្មឲ្យកៀកទៅនឹងផលិតករ សហគមន៍កសិកម្មនៅមូលដ្ឋាន ក្នុងការដោះស្រាយបញ្ហាប្រឈមទាំងឡាយដែលបាននិងកំពុងជួបប្រទះ ដោយមិនមើលរំលងអំពីការចុះធ្វើវេទិកាសាធារណៈ ក្នុងនាមក្រុមការងាររាជរដ្ឋា-ភិបាលចុះតាមមូលដ្ឋាននានានោះឡើយ។ ដោយឡែក ប្រជាកសិករទទួលបាននូវការយកចិត្តទុកដាក់ខ្ពស់ប្រកបដោយភាពកក់ក្តៅពីសំណាក់រាជរដ្ឋាភិបាល តាមរយៈការវិនិយោគលើគម្រោងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចជនបទ និងការលើកកម្ពស់ផលិតភាពកសិកម្ម ក៏ដូចជាការជួយអន្តរាគមន៍ផ្ទាល់របស់រដ្ឋនៅពេលកសិផលជាពិសេសស្រូវ-អង្ករ ប្រឈមនឹងការធ្លាក់ចុះថ្លៃនៅលើទីផ្សារជាតិ-អន្តរជាតិ។

ជាមួយនេះ ក្រសួងកត់សម្គាល់ឃើញថា មានក្រសួងស្ថាប័នពាក់ព័ន្ធ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ ព្រមទាំងសង្គមស៊ីវិលបាននិងកំពុងផ្តល់សេវាកម្មដើម្បីបង្កើនចំណេះដឹង និងចំណេះធ្វើដល់កសិករនៅមូលដ្ឋាន ហើយក៏មានកសិករជាច្រើនបានក្រេបជញ្ជក់យកបទពិសោធន៍ និងទេពកោសល្យទាំងអស់នេះយកទៅអនុវត្តប្រកបដោយភាពឧស្សាហ៍ព្យាយាមនិងថ្នៃប្រឌិត ដោយទទួលបានលទ្ធផលជាផ្លែផ្កាយ៉ាងត្រចះត្រចង់នៅក្នុងតំបន់ជាច្រើនទៅតាមអនុវិស័យនីមួយៗ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាននិងកំពុងជំរុញការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីជលផលដោយបានសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងមានសមត្ថកិច្ចពាក់ព័ន្ធ និងអាជ្ញាធរថ្នាក់ក្រោមជាតិ ក្នុងការទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ និងជលផលឱ្យមានប្រសិទ្ធភាពខ្ពស់ ពិសេសក្រសួងបានពង្រឹងកិច្ចសហការជាមួយគណៈបញ្ជាការឯកភាពរាជធានី ខេត្តយ៉ាងល្អប្រសើរ។ លើសពីនេះទៀត ការបន្តចូលរួមសហការជាមួយគណៈកម្មការជាតិដែលបានបង្កើតឡើងក៏ជាការងារសំខាន់មួយទៀត ដើម្បីរួមគ្នាទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ និងបទល្មើសនេសាទឱ្យបានជោគជ័យ។ ចំពោះការងារកែទម្រង់ផ្នែកគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានធ្វើការណែនាំអនុវត្តនូវចំណុចគន្លឹះមួយចំនួន ដើម្បីបន្តនិរន្តរភាពលើការគ្រប់គ្រង និងអភិវឌ្ឍដីសម្បទានសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាព។

ដោយឡែក កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា រួមទាំងវិស័យឯកជនផងដែរ កំពុងត្រូវបានពង្រឹងនិងយកចិត្តទុកដាក់ខ្ពស់ រួមទាំងការអភិវឌ្ឍធនធានមនុស្ស ការស្តារហេដ្ឋារចនាសម្ព័ន្ធគាំទ្រចាំបាច់នានា ដែលជាកត្តាគន្លឹះសំខាន់មិនអាចមើលរំលងបានឡើយ។ រីឯដំណើរការប្រព្រឹត្តទៅនៃការកែទម្រង់រដ្ឋបាលសាធារណៈ ហិរញ្ញវត្ថុសាធារណៈ និងវិមជ្ឈការនិងវិសហមជ្ឈការ ព្រមទាំងការបញ្ជ្រាបយេនឌ័រនិងកុមារ ក៏ដូចជាការលើកកម្ពស់ការពង្រឹងរចនាសម្ព័ន្ធចាត់តាំងក្បាលម៉ាស៊ីនដឹកនាំរបស់ក្រសួងទាំងថ្នាក់កណ្តាល រួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តទាំងអស់ក៏ត្រូវបានពង្រឹងក្នុងស្មារតីយកចិត្តទុកដាក់ខ្ពស់ និងប្រព្រឹត្តទៅប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។ លើសពីនេះទៀត សេវាគាំទ្រផ្សេងៗក៏បានសម្រេចលទ្ធផលការងារតាមផ្នែកនីមួយៗល្អប្រសើរ ស្របតាមគោលការណ៍និងទិសដៅរបស់រាជរដ្ឋាភិបាល ពិតមែនតែនៅជួបប្រទះបញ្ហាប្រឈមខ្លះៗក៏ដោយ។ ទន្ទឹមនឹងនេះ អង្គភាពជំនាញនីមួយៗដែលជាសេនាធិការរបស់ក្រសួងនឹងបន្តអនុវត្តតាមទិសដៅគោលនយោបាយ និងផែនការយុទ្ធសាស្ត្រដែលបានដាក់ចុះសម្រាប់ឆ្នាំ២០២០-២០២១ ដោយស្មារតីទទួលខុសត្រូវខ្ពស់។

សរុបសេចក្តីមក ដើម្បីរួមចំណែកក្នុងការសម្រេចបានគោលដៅយុទ្ធសាស្ត្រក្នុងក្របខណ្ឌកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលកម្ពុជា លើការលើកស្ទួយវិស័យកសិកម្ម ក្នុងការបង្កើតការងារ ការធានាសន្តិសុខស្បៀង ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍ជនបទ ពិសេសក្នុងកាលៈទេសៈដែលប្រទេសជាតិយើងកំពុងទទួលរងនូវហានិភ័យពីវិបត្តិនៃជំងឺឆ្លងកូវីដ-១៩នោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងខិតខំបន្តជំរុញការធ្វើទំនើបកម្មកសិកម្មឱ្យអស់លទ្ធភាព ដើម្បីឆ្លើយតបទៅនឹងកំណើនសេដ្ឋកិច្ចជាតិ តាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ក្រោមការដឹកនាំតម្រង់ទិសប្រកបដោយគតិបណ្ឌិត និងម៉ឺងម៉ាត់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

ថ្ងៃ ព្រហស្បតិ៍ ៤ រោច ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

# តារាងឧបសម្ព័ន្ធ

# ស្ថិតិផ្ទៃដីភ្ជួររាស់ និងផ្ទៃដីដាំដុះដំណាំស្រូវរដូវវស្សាឆ្នាំ ២០២០

ឧបសម្ព័ន្ធទី ១

| ល.រ | រាជធានី-ខេត្ត | ផែនការ (ហត) | ផ្ទៃដីភ្ជួររាស់ (ហ.ត) | | | | | ផ្ទៃដីសាប (ហត) | ផ្ទៃដីព្រោះស្ទូង និងបុកដាំ (ហត) | | | | | | | សរុបស្ទូងនិងព្រោះបុកដាំ (ហត) | ភាគរយ (%) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | សរុប | គោ-ក្របី | | គ្រឿងយន្ត | | | ស្រូវស្រាល | | កណ្ដាល | | ធ្ងន់ | ចំការ | ឡើងទឹក | | |
| | | | | ហ.ត | % | ហ.ត | % | | សរុប | បង្កើនរដូវ | សរុប | បង្កើនរដូវ | | | | | |
| 01 | បន្ទាយមានជ័យ | 252,320 | 268,817 | | - | 268,817 | 100.00 | | 102,921 | 95,176 | 132,241 | - | 25,176 | - | 8,183 | 268,521 | 106.42 |
| 02 | បាត់ដំបង | 323,200 | 374,031 | | - | 374,031 | 100.00 | 75 | 203,384 | 60,325 | 119,139 | - | 47,134 | 250 | 4,123 | 374,030 | 115.73 |
| 03 | កំពង់ចាម | 86,460 | 93,204 | 3,180 | 3.41 | 90,024 | 96.59 | 147 | 43,488 | 12,010 | 26,725 | - | 21,941 | - | 1,050 | 93,204 | 107.80 |
| 04 | កំពង់ឆ្នាំង | 122,000 | 127,691 | | - | 127,691 | 100.00 | 320 | 15,513 | 1,460 | 70,503 | - | 41,675 | - | - | 127,691 | 104.66 |
| 05 | កំពង់ស្ពឺ | 113,600 | 120,998 | 16,575 | 13.70 | 104,423 | 86.30 | 4,598 | 10,174 | 1,354 | 67,685 | - | 43,088 | 51 | - | 120,998 | 106.51 |
| 06 | កំពង់ធំ | 213,300 | 232,529 | 1,531 | 0.66 | 230,998 | 99.34 | 402 | 58,383 | 22,776 | 95,422 | - | 58,588 | 518 | 11,982 | 224,893 | 105.44 |
| 07 | កំពត | 133,000 | 141,674 | 1,400 | 0.99 | 140,274 | 99.01 | 954 | 16,369 | - | 86,904 | 16,316 | 38,401 | - | - | 141,674 | 106.52 |
| 08 | កណ្ដាល | 30,100 | 37,031 | 259 | 0.70 | 36,772 | 99.30 | 100 | 17,094 | - | 10,837 | - | 3,928 | - | - | 31,859 | 105.84 |
| 09 | កោះកុង | 9,840 | 9,406 | 897 | 9.54 | 8,509 | 90.46 | 427 | 1,590 | - | 7,425 | - | 379 | 785 | - | 10,179 | 103.45 |
| 10 | ក្រចេះ | 33,000 | 40,435 | 1,508 | 3.73 | 38,927 | 96.27 | 740 | 22,892 | 1,100 | 14,812 | - | 2,575 | 150 | - | 40,429 | 122.51 |
| 11 | មណ្ឌលគិរី | 23,000 | 25,349 | | - | 25,349 | 100.00 | 1,752 | 8,867 | - | 13,405 | - | 1,375 | 1,209 | - | 24,856 | 108.07 |
| 12 | ភ្នំពេញ | 8,120 | 6,711 | 10 | 0.15 | 6,701 | 99.85 | 6 | 3,455 | - | 2,502 | - | 729 | - | - | 6,686 | 82.34 |
| 13 | ព្រះវិហារ | 91,200 | 93,345 | 100 | 0.11 | 93,245 | 99.89 | 2,511 | 9,478 | - | 58,322 | - | 21,310 | 3,110 | - | 92,220 | 101.12 |
| 14 | ព្រៃវែង | 250,000 | 280,399 | | - | 280,399 | 100.00 | | 111,229 | 33,618 | 129,352 | - | 39,818 | - | - | 280,399 | 112.16 |
| 15 | ពោធិសាត់ | 115,000 | 136,167 | 238 | 0.17 | 135,929 | 99.83 | 41 | 73,751 | 1,135 | 53,470 | - | 15,478 | 883 | 1,760 | 145,342 | 126.38 |
| 16 | រតនគិរី | 26,350 | 21,679 | 840 | 3.87 | 20,839 | 96.13 | 725 | 2,617 | - | 13,637 | - | 5,425 | 10,520 | - | 32,199 | 122.20 |
| 17 | សៀមរាប | 186,560 | 190,260 | 700 | 0.37 | 189,560 | 99.63 | 135 | 41,634 | - | 105,460 | - | 35,560 | 1,700 | 6,350 | 190,704 | 102.22 |
| 18 | ព្រះសីហនុ | 13,000 | 10,839 | | - | 10,839 | 100.00 | | - | - | 10,839 | - | - | - | - | 10,839 | 83.38 |
| 19 | ស្ទឹងត្រែង | 27,800 | 27,617 | 167 | 0.60 | 27,450 | 99.40 | 2,827 | 12,759 | - | 12,214 | - | 971 | 1,225 | - | 27,169 | 97.73 |
| 20 | ស្វាយរៀង | 167,500 | 169,973 | | - | 169,973 | 100.00 | | 54,100 | 11,584 | 110,644 | - | 5,229 | - | - | 169,973 | 101.48 |
| 21 | តាកែវ | 180,000 | 565,701 | | - | 565,701 | 100.00 | | 77,134 | 52,645 | 126,789 | - | 5,972 | - | - | 209,895 | 116.61 |
| 22 | ឧត្តរមានជ័យ | 95,780 | 115,095 | | - | 115,095 | 100.00 | 8 | 2,469 | - | 89,090 | - | 3,945 | 282 | - | 95,786 | 100.01 |
| 23 | កែប | 3,520 | 3,543 | | - | 3,543 | 100.00 | | 1,081 | 493 | 1,259 | - | 1,203 | - | - | 3,543 | 100.65 |
| 24 | ប៉ៃលិន | 6,100 | 6,154 | | - | 6,154 | 100.00 | | 405 | - | 5,674 | - | 75 | - | - | 6,154 | 100.89 |
| 25 | ត្បូងឃ្មុំ | 77,380 | 77,380 | | - | 77,380 | 100.00 | 25 | 14,465 | 6,695 | 34,620 | 1,725 | 28,295 | - | - | 77,380 | 100.00 |
| **សរុប** | | **2,588,130** | **3,176,028** | **27,405** | **0.86** | **3,148,623** | **99.14** | **15,793** | **905,252** | **300,371** | **1,398,970** | **18,041** | **448,270** | **20,683** | **33,448** | **2,806,623** | **108.44** |
| **តួលេខឆ្នាំមុន** | | **2,586,152** | **2,815,991** | **32,779** | **1.16** | **2,783,212** | **98.84** | **23,715** | **890,681** | **213,484** | **1,295,673** | **3,541** | **490,190** | **23,833** | **30,961** | **2,731,338** | **105.61** |
| **ប្រៀបធៀប** | | **1,978** | **360,037** | **-5,374** | **-0.30** | **365,411** | **0.30** | **-7,922** | **14,571** | **86,887** | **103,297** | **14,500** | **-41,920** | **-3,150** | **2,487** | **75,285** | **2.76** |

# ផ្ទៃដីប៉ះពាល់ និងខូចខាតលើដំណាំស្រូវរដូវវស្សាឆ្នាំ ២០២០

ឧបសម្ព័ន្ធទី ២

| ល.រ | រាជធានី-ខេត្ត | បញ្ចប់ផ្ទៃដីអនុវត្តបាន | ប៉ះពាល់និងខូចខាតដោយប្រការផ្សេងៗ | | | | | | | | ផ្ទៃដីស្តារឡើងវិញ (ហ.ត) | ខូចខាតទាំងស្រុង (ហ.ត) |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ប៉ះពាល់ (ហ.ត) | | | | ខូចខាត (ហ.ត) | | | | | |
| | | | រាំងស្ងួត | សត្វល្អិត | ទឹកជំនន់ | សរុប | រាំងស្ងួត | សត្វល្អិត | ទឹកជំនន់ | សរុប | | |
| 01 | បន្ទាយមានជ័យ | 268,521 | 80,205 | - | 79,658 | **159,863** | 13,011 | - | 33,404 | **46,415** | 5,977 | 40,438 |
| 02 | បាត់ដំបង | 374,030 | | | 127,189 | **127,189** | | | 42,517 | **42,517** | | 42,517 |
| 03 | កំពង់ចាម | 93,204 | | | 606 | **606** | | | 318 | **318** | 292 | 26 |
| 04 | កំពង់ឆ្នាំង | 127,691 | 286 | | 3,161 | **3,447** | | | 1,792 | **1,792** | 1,792 | - |
| 05 | កំពង់ស្ពឺ | 120,998 | | 1,500 | 2,835 | **4,335** | | | 601 | **601** | | 601 |
| 06 | កំពង់ធំ | 224,893 | 22,429 | - | 18,850 | **41,279** | 1,247 | - | 10,361 | **11,608** | | 11,608 |
| 07 | កំពត | 141,674 | | | 1,220 | **1,220** | | | 466 | **466** | 466 | - |
| 08 | កណ្តាល | 31,859 | 1,326 | - | 3,472 | **4,798** | | | 1,464 | **1,464** | | 1,464 |
| 09 | កោះកុង | 10,179 | | 33 | | **33** | | | | **-** | | - |
| 10 | ក្រចេះ | 40,429 | | | 314 | **314** | | | | **-** | | - |
| 11 | មណ្ឌលគិរី | 24,856 | | | | **-** | | | | **-** | | - |
| 12 | ភ្នំពេញ | 6,686 | 915 | | 1,857 | **2,772** | | | 1,471 | **1,471** | | 1,471 |
| 13 | ព្រះវិហារ | 92,220 | | | 5,110 | **5,110** | | | 2,852 | **2,852** | | 2,852 |
| 14 | ព្រៃវែង | 280,399 | 18,325 | 150 | 12,645 | **31,120** | 221 | - | 3,580 | **3,801** | 3,801 | - |
| 15 | ពោធិសាត់ | 145,342 | 18,475 | | 36,679 | **55,154** | 5,686 | | 25,421 | **31,107** | 5,686 | 25,421 |
| 16 | រតនគិរី | 32,199 | | | | **-** | | | | **-** | | - |
| 17 | សៀមរាប | 190,704 | 5,810 | | 13,509 | **19,319** | | | 995 | **995** | 995 | - |
| 18 | ព្រះសីហនុ | 10,839 | | | | **-** | | | | **-** | | - |
| 19 | ស្ទឹងត្រែង | 27,169 | | | 405 | **405** | | | 260 | **260** | | 260 |
| 20 | ស្វាយរៀង | 169,973 | 50 | | 2,159 | **2,209** | | | 912 | **912** | | 912 |
| 21 | តាកែវ | 209,895 | 172 | - | 6,145 | **6,317** | | | 885 | **885** | 350 | 535 |
| 22 | ឧត្តរមានជ័យ | 95,786 | | | | **-** | | | | **-** | | - |
| 23 | កែប | 3,543 | 301 | - | 20 | **321** | 11 | | | **11** | 11 | - |
| 24 | ប៉ៃលិន | 6,154 | | | 76 | **76** | | | 62 | **62** | | 62 |
| 25 | ត្បូងឃ្មុំ | 77,380 | 990 | 815 | 824 | **2,629** | 701 | 815 | 818 | **2,334** | 718 | 1,616 |
| | សរុប | **2,806,623** | **149,284** | **2,498** | **316,734** | **468,516** | **20,877** | **815** | **128,179** | **149,871** | **20,088** | **129,783** |
| | តួលេខឆ្នាំមុន | **2,731,338** | **325,180** | **46** | **80,410** | **405,636** | **71,474** | **6** | **25,554** | **97,034** | **37,342** | **59,692** |
| | ប្រៀបធៀប | **75,285** | **-175,896** | **2,452** | **236,324** | **62,880** | **-50,597** | **809** | **102,625** | **52,837** | **-17,254** | **70,091** |

# បរិមាណផល និងទិន្នផលដំណាំស្រូវរដូវវស្សាតាមប្រភេទឆ្នាំ ២០២០

ឧបសម្ព័ន្ធទី ៣ក

| ល.រ | រាជធានី-ខេត្ត | ស្រូវស្រាល | | | | ស្រូវកណ្តាល | | | | ស្រូវធ្ងន់ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផ្ទៃ.ដាំដុះ | ផ្ទៃ.ប្រ.ផល | ទិន្នផល | បរិ.ផល | ផ្ទៃ.ដាំដុះ | ផ្ទៃ.ប្រ.ផល | ទិន្នផល | បរិ.ផល | ផ្ទៃ.ដាំដុះ | ផ្ទៃ.ប្រ.ផល | ទិន្នផល | បរិ.ផល |
| | | (ហត) | (ហត) | (ត/ហត) | (តោន) | (ហត) | (ហត) | (ត/ហត) | (តោន) | (ហត) | (ហត) | (ត/ហត) | (តោន) |
| 01 | បន្ទាយមានជ័យ | 102,921 | 78,729 | 3.227 | 254,065 | 132,241 | 119,048 | 2.497 | 297,319 | 25,176 | 22,123 | 2.704 | 59,823 |
| 02 | បាត់ដំបង | 203,384 | 180,554 | 3.708 | 669,416 | 119,139 | 100,616 | 2.821 | 283,827 | 47,134 | 45,970 | 3.178 | 146,077 |
| 03 | កំពង់ចាម | 43,488 | 43,462 | 3.556 | 154,564 | 26,725 | 26,725 | 3.472 | 92,777 | 21,941 | 21,941 | 3.478 | 76,303 |
| 04 | កំពង់ឆ្នាំង | 15,513 | 15,513 | 3.613 | 56,050 | 70,503 | 70,503 | 3.369 | 237,524 | 41,675 | 41,675 | 3.536 | 147,343 |
| 05 | កំពង់ស្ពឺ | 10,174 | 10,174 | 3.114 | 31,684 | 67,685 | 67,609 | 3.167 | 214,100 | 43,088 | 42,563 | 3.232 | 137,578 |
| 06 | កំពង់ធំ | 58,383 | 50,447 | 3.198 | 161,316 | 95,422 | 92,325 | 2.515 | 232,227 | 58,588 | 58,013 | 2.751 | 159,605 |
| 07 | កំពត | 16,369 | 16,369 | 3.177 | 52,007 | 86,904 | 86,904 | 3.231 | 280,806 | 38,401 | 38,401 | 3.201 | 122,935 |
| 08 | កណ្តាល | 17,094 | 17,094 | 4.022 | 68,756 | 10,837 | 9,599 | 2.529 | 24,280 | 3,928 | 3,702 | 2.584 | 9,565 |
| 09 | កោះកុង | 1,590 | 1,590 | 2.694 | 4,283 | 7,425 | 7,425 | 2.755 | 20,453 | 379 | 379 | 2.858 | 1,083 |
| 10 | ក្រចេះ | 22,892 | 22,892 | 2.929 | 67,051 | 14,812 | 14,812 | 2.726 | 40,378 | 2,575 | 2,575 | 2.347 | 6,044 |
| 11 | មណ្ឌលគិរី | 8,867 | 8,867 | 3.334 | 29,565 | 13,405 | 13,405 | 3.060 | 41,018 | 1,375 | 1,375 | 2.836 | 3,900 |
| 12 | ភ្នំពេញ | 3,455 | 3,455 | 2.501 | 8,642 | 2,502 | 1,708 | 2.741 | 4,682 | 729 | 52 | 3.519 | 183 |
| 13 | ព្រះវិហារ | 9,478 | 9,478 | 2.431 | 23,043 | 58,322 | 55,470 | 2.806 | 155,671 | 21,310 | 21,310 | 2.922 | 62,277 |
| 14 | ព្រៃវែង | 111,229 | 111,229 | 4.131 | 459,526 | 129,352 | 129,352 | 2.799 | 362,062 | 39,818 | 39,818 | 2.912 | 115,931 |
| 15 | ពោធិសាត់ | 73,751 | 63,570 | 3.661 | 232,728 | 53,470 | 41,884 | 3.222 | 134,930 | 15,478 | 11,824 | 3.219 | 38,060 |
| 16 | រតនគិរី | 2,617 | 2,617 | 2.585 | 6,766 | 13,637 | 13,637 | 2.696 | 36,760 | 5,425 | 5,425 | 2.702 | 14,656 |
| 17 | សៀមរាប | 41,634 | 41,634 | 2.683 | 111,719 | 105,460 | 105,460 | 2.773 | 292,454 | 35,560 | 35,560 | 2.927 | 104,076 |
| 18 | ព្រះសីហនុ | - | - | #DIV/0! | | 10,839 | 10,839 | 3.304 | 35,812 | - | - | | - |
| 19 | ស្ទឹងត្រែង | 12,759 | 12,499 | 2.627 | 32,832 | 12,214 | 12,214 | 2.915 | 35,607 | 971 | 971 | 2.975 | 2,889 |
| 20 | ស្វាយរៀង | 54,100 | 53,188 | 3.520 | 187,222 | 110,644 | 110,644 | 2.543 | 281,320 | 5,229 | 5,229 | 2.540 | 13,282 |
| 21 | តាកែវ | 77,134 | 77,134 | 3.564 | 274,917 | 126,789 | 126,254 | 3.314 | 418,450 | 5,972 | 5,972 | 3.459 | 20,657 |
| 22 | ឧត្តរមានជ័យ | 2,469 | 2,469 | 2.470 | 6,098 | 89,090 | 89,090 | 2.758 | 245,703 | 3,945 | 3,945 | 3.480 | 13,729 |
| 23 | កែប | 1,081 | 1,081 | 3.304 | 3,572 | 1,259 | 1,259 | 3.031 | 3,816 | 1,203 | 1,203 | 3.213 | 3,865 |
| 24 | ប៉ៃលិន | 405 | 402 | 2.950 | 1,186 | 5,674 | 5,615 | 3.180 | 17,856 | 75 | 75 | 3.307 | 248 |
| 25 | ត្បូងឃ្មុំ | 14,465 | 13,664 | 3.606 | 49,275 | 34,620 | 33,805 | 3.300 | 111,546 | 28,295 | 28,295 | 3.418 | 96,705 |
| សរុប | | **905,252** | **838,111** | **3.515** | **2,946,283** | **1,398,970** | **1,346,202** | **2.898** | **3,901,378** | **448,270** | **438,396** | **3.095** | **1,356,814** |
| តួលេខឆ្នាំមុន | | **890,681** | **857,404** | **3.605** | **3,090,615** | **1,295,673** | **1,276,846** | **2.843** | **3,630,317** | **490,190** | **483,628** | **2.965** | **1,434,152** |
| ប្រៀបធៀប | | **14,571** | **(19,293)** | **-0.089** | **(144,332)** | **103,297** | **69,356** | **0.055** | **271,061** | **-41,920** | **-45,232** | **0.130** | **-77,338** |

# បរិមាណផល និងទិន្នផលដំណាំស្រូវរដូវវស្សាតាមប្រភេទឆ្នាំ ២០២០

ឧបសម្ព័ន្ធទី ៣ខ

| លរ | រាជធានី-ខេត្ត | ស្រូវចំការ | | | | ស្រូវឡើងទឹក | | | | សរុប | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផ្ទៃ.ដាំដុះ (ហត) | ផ្ទៃ.ប្រ.ផល (ហត) | ទិន្នផល (ត/ហត) | បរិ.ផល (តោន) | ផ្ទៃ.ដាំដុះ (ហត) | ផ្ទៃ.ប្រ.ផល (ហត) | ទិន្នផល (ត/ហត) | បរិ.ផល (តោន) | ផ្ទៃ.ដាំដុះ (ហត) | ផ្ទៃ.ប្រ.ផល (ហត) | ទិន្នផល (ត/ហត) | បរិ.ផល (តោន) |
| 01 | បន្ទាយមានជ័យ | - | | - | | 8,183 | 8,183 | 2.486 | 20,341 | 268,521 | 228,083 | 2.769 | 631,548 |
| 02 | បាត់ដំបង | 250 | 250 | 1.908 | 477 | 4,123 | 4,123 | 2.583 | 10,651 | 374,030 | 331,513 | 3.350 | 1,110,448 |
| 03 | កំពង់ចាម | - | | - | | 1,050 | 1,050 | 2.805 | 2,945 | 93,204 | 93,178 | 3.505 | 326,589 |
| 04 | កំពង់ឆ្នាំង | - | | - | | - | | - | | 127,691 | 127,691 | 3.453 | 440,917 |
| 05 | កំពង់ស្ពឺ | 51 | 51 | 2.118 | 108 | - | | - | | 120,998 | 120,397 | 3.185 | 383,470 |
| 06 | កំពង់ធំ | 518 | 518 | 1.606 | 832 | 11,982 | 11,982 | 1.669 | 20,003 | 224,893 | 213,285 | 2.691 | 573,983 |
| 07 | កំពត | - | | - | | - | | - | | 141,674 | 141,674 | 3.217 | 455,748 |
| 08 | កណ្តាល | - | | - | | - | | - | | 31,859 | 30,395 | 3.376 | 102,601 |
| 09 | កោះកុង | 785 | 785 | 2.790 | 2,190 | - | | - | | 10,179 | 10,179 | 2.752 | 28,009 |
| 10 | ក្រចេះ | 150 | 150 | 1.960 | 294 | - | | - | | 40,429 | 40,429 | 2.814 | 113,767 |
| 11 | មណ្ឌលគិរី | 1,209 | 1,209 | 1.007 | 1,218 | - | | - | | 24,856 | 24,856 | 3.046 | 75,701 |
| 12 | ភ្នំពេញ | - | | - | | - | | - | | 6,686 | 5,215 | 2.590 | 13,507 |
| 13 | ព្រះវិហារ | 3,110 | 3,110 | 2.588 | 8,049 | - | | - | | 92,220 | 89,368 | 2.787 | 249,040 |
| 14 | ព្រៃវែង | - | | - | | - | | - | | 280,399 | 280,399 | 3.344 | 937,519 |
| 15 | ពោធិសាត់ | 883 | 883 | 1.618 | 1,429 | 1,760 | 1,760 | 2.400 | 4,224 | 145,342 | 119,921 | 3.430 | 411,371 |
| 16 | រតនគិរី | 10,520 | 10,520 | 1.773 | 18,655 | - | | - | | 32,199 | 32,199 | 2.386 | 76,837 |
| 17 | សៀមរាប | 1,700 | 1,700 | 2.695 | 4,581 | 6,350 | 6,350 | 2.444 | 15,517 | 190,704 | 190,704 | 2.771 | 528,347 |
| 18 | ព្រះសីហនុ | - | | - | | - | | - | | 10,839 | 10,839 | 3.304 | 35,812 |
| 19 | ស្ទឹងត្រែង | 1,225 | 1,225 | 2.181 | 2,672 | - | | - | | 27,169 | 26,909 | 2.750 | 74,000 |
| 20 | ស្វាយរៀង | - | | - | | - | | - | | 169,973 | 169,061 | 2.850 | 481,824 |
| 21 | តាកែវ | - | | - | | - | | - | | 209,895 | 209,360 | 3.411 | 714,024 |
| 22 | ឧត្តរមានជ័យ | 282 | 282 | 2.500 | 705 | - | | - | | 95,786 | 95,786 | 2.779 | 266,235 |
| 23 | កែប | - | | - | | - | | - | | 3,543 | 3,543 | 3.176 | 11,253 |
| 24 | ប៉ៃលិន | - | | - | | - | | - | | 6,154 | 6,092 | 3.166 | 19,290 |
| 25 | ត្បូងឃ្មុំ | - | | - | | - | | - | | 77,380 | 75,764 | 3.399 | 257,526 |
| សរុប | | **20,683** | **20,683** | **1.992** | **41,210** | **33,448** | **33,448** | **2.203** | **73,681** | **2,806,623** | **2,676,840** | **3.108** | **8,319,366** |
| តួលេខឆ្នាំមុន | | **23,833** | **23,833** | **2.047** | **48,786** | **30,961** | **29,935** | **2.192** | **65,610** | **2,731,338** | **2,671,646** | **3.095** | **8,269,480** |
| ប្រៀបធៀប | | **-3,150** | **-3,150** | **-0.055** | **-7,576** | **2,487** | **3,513** | **0.011** | **8,071** | **75,285** | **5,194** | **0.013** | **49,886** |

# ផ្ទៃដីភ្ជួររាស់ និងដាំដុះដំណាំស្រូវរដូវប្រាំងឆ្នាំ ២០២០

ឧបសម្ព័ន្ធទី ៤

| ល.រ | ឈ្មោះស្រុក | ផែនការ (ហ.ត) | ផ្ទៃដីភ្ជួររាស់ | | | | | ផ្ទៃដីសាប (ហ.ត) | ផ្ទៃដីស្ទូង និងព្រោះ (ហត) | | | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | សរុប (ហ.ត) | គោ-ក្របី | | គ្រឿងយន្ត | | | សន្ទូង | ពង្រោះ | សរុប | |
| | | | | ហ.ត | % | ហ.ត | % | | | | | |
| 01 | បន្ទាយមានជ័យ | 22,000 | 55,067 | | - | 55,067 | 100.00 | - | - | 55,067 | 55,067 | 250.30 |
| 02 | បាត់ដំបង | 18,675 | 17,244 | | - | 17,244 | 100.00 | - | - | 17,244 | 17,244 | 92.34 |
| 03 | កំពង់ចាម | 42,000 | 42,697 | 3,768 | 8.82 | 38,929 | 91.18 | 25 | 244 | 42,462 | 42,706 | 101.68 |
| 04 | កំពង់ឆ្នាំង | 32,000 | 41,712 | | - | 41,712 | 100.00 | - | - | 41,712 | 41,712 | 130.35 |
| 05 | កំពង់ស្ពឺ | 750 | 450 | 21 | 4.67 | 429 | 95.33 | 1 | 7 | 443 | 450 | 60.00 |
| 06 | កំពង់ធំ | 40,000 | 65,455 | | - | 65,455 | 100.00 | - | - | 65,455 | 65,455 | 163.64 |
| 07 | កំពត | 8,220 | 8,515 | | - | 8,515 | 100.00 | - | - | 8,515 | 8,515 | 103.59 |
| 08 | កណ្ដាល | 57,600 | 57,600 | 22 | 0.04 | 57,578 | 99.96 | - | - | 57,600 | 57,600 | 100.00 |
| 09 | កោះកុង | - | - | | | | | | | | - | - |
| 10 | ក្រចេះ | 14,000 | 14,155 | 430 | 3.04 | 13,725 | 96.96 | 30 | 50 | 14,093 | 14,143 | 101.02 |
| 11 | មណ្ឌលគិរី | 100 | 137 | | - | 137 | 107.00 | | | 130 | 130 | 130.00 |
| 12 | ភ្នំពេញ | 945 | 450 | 5 | 1.11 | 445 | 98.89 | 3 | 20 | 430 | 450 | 47.62 |
| 13 | ព្រះវិហារ | 130 | 12 | | - | 12 | 100.00 | | | 12 | 12 | 9.23 |
| 14 | ព្រៃវែង | 75,000 | 111,040 | | - | 111,040 | 100.00 | | | 111,040 | 111,040 | 148.05 |
| 15 | ពោធិសាត់ | 9,500 | 28,356 | | - | 28,356 | 100.00 | | | 26,912 | 26,912 | 283.28 |
| 16 | រតនគិរី | - | - | | | | | | | | - | - |
| 17 | សៀមរាប | 26,455 | 22,585 | | - | 22,585 | 100.00 | - | - | 22,585 | 22,585 | 85.37 |
| 18 | ព្រះសីហនុ | - | - | | | | | | | | - | - |
| 19 | ស្ទឹងត្រែង | - | - | | | | | | | | - | - |
| 20 | ស្វាយរៀង | 20,500 | 20,102 | | - | 20,102 | 100.00 | | | 20,102 | 20,102 | 98.06 |
| 21 | តាកែវ | 80,000 | 104,845 | | - | 104,845 | 100.00 | | | 101,511 | 101,511 | 126.89 |
| 22 | ឧត្តរមានជ័យ | 139 | 155 | | - | 155 | 100.00 | | | 139 | 139 | 100.00 |
| 23 | កែប | 20 | 20 | | - | 20 | 100.00 | | | 20 | 20 | 100.00 |
| 24 | ប៉ៃលិន | 665 | 795 | | - | 795 | 100.00 | | | 795 | 795 | 119.55 |
| 25 | ត្បូងឃ្មុំ | 10,900 | 10,920 | | - | 10,920 | 100.00 | 15 | 135 | 10,785 | 10,920 | 100.18 |
| **សរុប** | | **459,599** | **602,312** | **4,246** | **0.70** | **598,066** | **99.30** | **74** | **456** | **597,052** | **597,508** | **130.01** |
| **តួលេខឆ្នាំមុន** | | **459,599** | **602,312** | **4,246** | **0.70** | **598,066** | **99.30** | **74** | **456** | **597,052** | **597,508** | **130.01** |
| **ប្រៀបធៀប** | | **-** | **0** | **0** | **0.00** | **0** | **-** | **0** | **0** | **0** | **0** | **0.00** |

# រិមាណផលិតកម្មដំណាំស្រូវប្រចាំឆ្នាំ ២០២០

ឧបសម្ព័ន្ធទី ៥

| ល.រ | រាជធានី-ខេត្ត | រដូវវស្សា | | | | រដូវប្រាំង | | | | សរុបប្រចាំឆ្នាំ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផ្ទៃដីអនុវត្ត (ហ.ត) | ផ្ទៃដីប្រមូលផល (ហ.ត) | ទិន្នផល (ត/ហ.ត) | បរិមាណផល (តោន) | ផ្ទៃដីអនុវត្ត (ហ.ត) | ផ្ទៃដីប្រមូលផល (ហ.ត) | ទិន្នផល (ត/ហ.ត) | បរិមាណផល (តោន) | ផ្ទៃដីអនុវត្ត (ហ.ត) | ផ្ទៃដីប្រមូលផល (ហ.ត) | ទិន្នផល (ត/ហ.ត) | បរិមាណផល (តោន) |
| 01 | បន្ទាយមានជ័យ | 268,521 | 228,083 | 2.769 | 631,548 | 55,067 | 55,067 | 4.405 | 242,570 | 323,588 | 283,150 | 3.087 | 874,118 |
| 02 | បាត់ដំបង | 374,030 | 331,513 | 3.350 | 1,110,448 | 17,244 | 17,244 | 4.130 | 71,218 | 391,274 | 348,757 | 3.388 | 1,181,666 |
| 03 | កំពង់ចាម | 93,204 | 93,178 | 3.505 | 326,589 | 42,706 | 42,325 | 4.150 | 175,654 | 135,910 | 135,503 | 3.707 | 502,243 |
| 04 | កំពង់ឆ្នាំង | 127,691 | 127,691 | 3.453 | 440,917 | 41,712 | 41,652 | 4.650 | 193,682 | 169,403 | 169,343 | 3.747 | 634,599 |
| 05 | កំពង់ស្ពឺ | 120,998 | 120,397 | 3.185 | 383,470 | 450 | 450 | 3.351 | 1,508 | 121,448 | 120,847 | 3.186 | 384,978 |
| 06 | កំពង់ធំ | 224,893 | 213,285 | 2.691 | 573,983 | 65,455 | 65,235 | 4.296 | 280,255 | 290,348 | 278,520 | 3.067 | 854,238 |
| 07 | កំពត | 141,674 | 141,674 | 3.217 | 455,748 | 8,515 | 8,515 | 4.100 | 34,912 | 150,189 | 150,189 | 3.267 | 490,660 |
| 08 | កណ្តាល | 31,859 | 30,395 | 3.376 | 102,601 | 57,600 | 57,600 | 4.421 | 254,649 | 89,459 | 87,995 | 4.060 | 357,250 |
| 09 | កោះកុង | 10,179 | 10,179 | 2.752 | 28,009 | - | | - | - | 10,179 | 10,179 | 2.752 | 28,009 |
| 10 | ក្រចេះ | 40,429 | 40,429 | 2.814 | 113,767 | 14,143 | 14,143 | 4.393 | 62,130 | 54,572 | 54,572 | 3.223 | 175,897 |
| 11 | មណ្ឌលគិរី | 24,856 | 24,856 | 3.046 | 75,701 | 130 | 130 | 4.246 | 552 | 24,986 | 24,986 | 3.052 | 76,253 |
| 12 | ភ្នំពេញ | 6,686 | 5,215 | 2.590 | 13,507 | 450 | 450 | 3.400 | 1,530 | 7,136 | 5,665 | 2.654 | 15,037 |
| 13 | ព្រះវិហារ | 92,220 | 89,368 | 2.787 | 249,040 | 12 | 12 | 3.000 | 36 | 92,232 | 89,380 | 2.787 | 249,076 |
| 14 | ព្រៃវែង | 280,399 | 280,399 | 3.344 | 937,519 | 111,040 | 111,040 | 4.400 | 488,576 | 391,439 | 391,439 | 3.643 | 1,426,095 |
| 15 | ពោធិសាត់ | 145,342 | 119,921 | 3.430 | 411,371 | 26,912 | 22,376 | 4.446 | 99,484 | 172,254 | 142,297 | 3.590 | 510,855 |
| 16 | រតនគិរី | 32,199 | 32,199 | 2.386 | 76,837 | - | | - | - | 32,199 | 32,199 | 2.386 | 76,837 |
| 17 | សៀមរាប | 190,704 | 190,704 | 2.771 | 528,347 | 22,585 | 22,585 | 3.530 | 79,725 | 213,289 | 213,289 | 2.851 | 608,072 |
| 18 | ព្រះសីហនុ | 10,839 | 10,839 | 3.304 | 35,812 | - | | - | - | 10,839 | 10,839 | 3.304 | 35,812 |
| 19 | ស្ទឹងត្រែង | 27,169 | 26,909 | 2.750 | 74,000 | - | | - | - | 27,169 | 26,909 | 2.750 | 74,000 |
| 20 | ស្វាយរៀង | 169,973 | 169,061 | 2.850 | 481,824 | 20,102 | 20,102 | 4.300 | 86,439 | 190,075 | 189,163 | 3.004 | 568,263 |
| 21 | តាកែវ | 209,895 | 209,360 | 3.411 | 714,024 | 101,511 | 101,511 | 4.898 | 497,201 | 311,406 | 310,871 | 3.896 | 1,211,225 |
| 22 | ឧត្តរមានជ័យ | 95,786 | 95,786 | 2.779 | 266,235 | 139 | 139 | 3.504 | 487 | 95,925 | 95,925 | 2.781 | 266,722 |
| 23 | កែប | 3,543 | 3,543 | 3.176 | 11,253 | 20 | 20 | 3.650 | 73 | 3,563 | 3,563 | 3.179 | 11,326 |
| 24 | ប៉ៃលិន | 6,154 | 6,092 | 3.166 | 19,290 | 795 | 795 | 3.301 | 2,624 | 6,949 | 6,887 | 3.182 | 21,914 |
| 25 | ត្បូងឃ្មុំ | 77,380 | 75,764 | 3.399 | 257,526 | 10,920 | 10,737 | 4.000 | 42,948 | 88,300 | 86,501 | 3.474 | 300,474 |
| **សរុប** | | **2,806,623** | **2,676,840** | **3.108** | **8,319,366** | **597,508** | **592,128** | **4.418** | **2,616,253** | **3,404,131** | **3,268,968** | **3.345** | **10,935,619** |
| **តួលេខឆ្នាំមុន** | | **2,731,338** | **2,671,646** | **3.095** | **8,269,480** | **597,508** | **592,128** | **4.418** | **2,616,253** | **3,328,846** | **3,263,774** | **3.335** | **10,885,733** |
| **ប្រៀបធៀប** | | **75,285** | **5,194** | **0.013** | **49,886** | **0** | **0** | **0.000** | **0** | **75,285** | **5,194** | **0.010** | **49,886** |

ឧបសម្ព័ន្ធទី ៦

# តុល្យភាពស្បៀងតាមបណ្តារាជធានី-ខេត្តឆ្នាំ ២០២១

